កាតាលីករ អាស៊ាន

CIMB

របាយការណ៍ប្រចាំឆ្នាំ ២០១៨

ទំព័រ ១០

ការលើកកម្ពស់ធនធានមនុស្សក្នុងស្រុក

យើងមានមោទនភាពក្រៃលែង ដែលបានក្លាយជាស្ថាប័នហិរញ្ញវត្ថុដ៏ជោគជ័យមួយជាមួយនឹងបុគ្គលិកក្នុងស្រុក ១០០% ជាជនជាតិខ្មែរ ដែលបានរួមចំណែកដល់ភាពរីកចម្រើនប្រកបដោយស្ថិរភាព របស់ធនាគារទាំងមូល។

ទំព័រ ១២

ធនាគារអន្តរជាតិល្អបំផុត នៅកម្ពុជា

ឆ្នាំ២០១៨ គឺជាឆ្នាំដ៏ល្អវិសាល ដែលធនាគារទទួលបានពានរង្វាន់ជា «ធនាគារអន្តរជាតិល្អបំផុតនៅកម្ពុជា» ហើយសម្រេចបានសមិទ្ធផលអាជីវកម្ម និងហិរញ្ញវត្ថុលើសពីការរំពឹងទុក។

ទំព័រ ២៨

ភាពច្នៃប្រឌិត លើផលិតផល

យើងបានណែនាំផលិតផលឥណទាន និងប្រាក់បញ្ញើជាប្រាក់រៀល ដែលផ្តល់ឲ្យអតិថិជននូវជម្រើសរូបិយប័ណ្ណក្នុងស្រុក ក្នុងកម្រិតល្អប្រសើរ សមស្របនឹងតម្រូវការគ្រប់គ្រងទុនបង្វិល និងតម្រូវការវិនិយោគនៃអាជីវកម្មរបស់ពួកគេ។

Exceed

ផ្នែកខាងក្នុងនៃរបាយការណ៍

០១

ទិដ្ឋភាពទូទៅ

០៨ សារតារធនាគារ
០៩ ការប្តេជ្ញាលើគុណភាពសេវាកម្ម និងឧត្តមភាព
០៩ តម្លៃស្នូលរបស់ស្ថាប័ន
១០ សារពីប្រធានក្រុមប្រឹក្សាភិបាលធនាគារ
១១ សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
១២ ការពិនិត្យមើលលទ្ធផលប្រតិបត្តិការ
របស់ប្រធាននាយកប្រតិបត្តិ

០២

ការពិនិត្យមើលធុរកិច្ច

១៦ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
១៧ សេវាកម្មហិរញ្ញវត្ថុបុគ្គល
១៨ សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ
១៩ ធនធានសាជីវកម្ម
២០ ទីផ្សារ និងទំនាក់ទំនង
២១ ហិរញ្ញវត្ថុ
២២ ការគ្រប់គ្រងហានិភ័យ
២៤ បច្ចេកវិទ្យា និងប្រតិបត្តិការ
២៥ រតនាគារ និងទីផ្សារ
២៦ សវនកម្មផ្ទៃក្នុង
២៦ នីតិកម្ម និងលេខាធិការក្រុមហ៊ុន
២៧ បទពិសោធន៍សេវាកម្មអតិថិជន
២៨ គ្រប់គ្រងផលិតផល
២៩ ប្រតិបត្តិតាម

០៣

អភិបាលកិច្ចធនាគារ

៣២ សេចក្តីថ្លែងការណ៍ស្តីពីអភិបាលកិច្ចធនាគារ
៤១ របាយការណ៍គណៈកម្មាធិការសវនកម្ម
៤៣ សេចក្តីថ្លែងការណ៍ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
៤៧ រចនាសម្ព័ន្ធនៃការគ្រប់គ្រងពីក្រុមហ៊ុនមេ
៤៧ រចនាសម្ព័ន្ធគ្រប់គ្រង
៤៨ របាយការណ៍ព័ត៌មានរបស់ធនាគារ

០៤

ព្រឹត្តិការណ៍សំខាន់ៗ និងការចុះផ្សាយក្នុងសារព័ត៌មាននៅឆ្នាំ២០១៨

៥២ ព្រឹត្តិការណ៍សំខាន់ៗ
៥៩ ការចុះផ្សាយក្នុងសារព័ត៌មាន

០៥

ប្រវត្តិសង្ខេបរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រង

៦៤ ក្រុមប្រឹក្សាភិបាល
៧១ លេខាធិការក្រុមហ៊ុនរួម
៧៤ គណៈកម្មាធិការគ្រប់គ្រង

០៦

របាយការណ៍ហិរញ្ញវត្ថុ

៨២ របាយការណ៍ក្រុមប្រឹក្សាភិបាល
៨៣ របាយការណ៍សវនករឯករាជ្យ
៨៤ តារាងតុល្យការ
៨៥ របាយការណ៍លទ្ធផល
៨៦ របាយការណ៍បម្រែបម្រួលមូលធន
៨៧ របាយការណ៍លំហូរសាច់ប្រាក់
៨៨ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
១១៤ ឧបសម្ព័ន្ធ៖ កំណត់សម្គាល់ស្ដីពីតម្រូវការតាមប្រកាសរបស់ធនាគារកណ្ដាល

០៧

បណ្ដាញរបស់ធនាគារ

១២៦ បណ្ដាញធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
១២៨ បណ្ដាញសាខារបស់ក្រុមហ៊ុនមេ

០១ ទិដ្ឋភាពទូទៅ

០៨ សារតារធនាគារ

០៩ ការប្តេជ្ញាលើគុណភាពសេវាកម្ម និងឧត្តមភាព

០៩ តម្លៃស្នូលរបស់ស្ថាប័ន

១០ សារពីប្រធានក្រុមប្រឹក្សាភិបាលធនាគារ

១១ សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ

១២ ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

សារតារធនាគារ

អំពីធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការ នៅក្នុងទីផ្សារប្រទេសកម្ពុជា នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានបើកដំណើរការសាខាធនាគារពាណិជ្ជទី១ នៅចំកណ្តាលរាជធានីភ្នំពេញ។ រហូតមកដល់បច្ចុប្បន្ននេះ ធនាគារមានសាខាចំនួន ១៣ កន្លែង ជាមួយនឹងម៉ាស៊ីនដាក់ប្រាក់ ១០ កន្លែង ម៉ាស៊ីនដាក់មូលប្បទានបត្រ ១០ កន្លែង និងម៉ាស៊ីនអេធីអិម ៣២ កន្លែង នៅក្នុងខេត្ត និងរាជធានីសំខាន់ៗ ចំនួនប្រាំនៃព្រះរាជាណាចក្រកម្ពុជា រួមមានរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

បច្ចុប្បន្ននេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី កំពុងបម្រើសេវាកម្ម និងផ្តល់ផលិតផលធនាគារ ជូនដល់អតិថិជន ប្រមាណ ២៨.០០០ នាក់ ដែលរួមមានទាំងអតិថិជនជាបុគ្គល និងក្រុមហ៊ុន។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងរបស់ចំនួនអតិថិជន នៅក្នុងប្រទេសកម្ពុជា ធនាគារមានផ្តល់ជូនសេវាកម្ម និងផលិតផលធនាគារដ៏ទូលំទូលាយ រួមមានសេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ព្រមទាំងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការផងដែរ។

គិតត្រឹមខែធ្នូ ឆ្នាំ ២០១៨ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មាននិយោជិតជាង ៣៦០ នាក់ ដែលមានបទពិសោធន៍ និងជំនាញផ្សេងៗគ្នា ទាំងក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យផ្សេងៗទៀតផងដែរ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅក្នុងប្រទេសកម្ពុជា បានប្តេជ្ញាចិត្ត ក្នុងការកសាងវិស័យហិរញ្ញវត្ថុឲ្យរឹងមាំ និងយូរអង្វែងមួយ សម្រាប់អតិថិជនរបស់ខ្លួន ហើយនឹងបន្តព្យាយាមបង្កើតឱកាស និងគុណតម្លៃ តាមរយៈផលិតផល និងសេវាកម្មថ្មីៗ ដែលមានអត្ថប្រយោជន៍ខ្ពស់។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានមោទនភាពក្រៃលែង ដោយសារតែយើងមិនត្រឹមតែជាអ្នកបម្រើសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាដៃគូអាជីវកម្មដ៏ល្អមួយរបស់អតិថិជនផងដែរ ក្នុងការគាំទ្រពួកគេឲ្យធ្វើការសម្រេចចិត្តត្រឹមត្រូវលើផ្នែកហិរញ្ញវត្ថុ និងការវិនិយោគ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាសាខារបស់ ស៊ីអាយអិមប៊ី គ្រុប។

អំពី ស៊ីអាយអិមប៊ី គ្រុប

ស៊ីអាយអិមប៊ី គ្រុប គឺជាធនាគារសកលឈានមុខគេមួយ ក្នុងតំបន់អាស៊ាន និងជាដៃគូប្រឹក្សាសាជីវកម្មធំបំផុតមួយក្នុងតំបន់។ ស៊ីអាយអិមប៊ី គ្រុប ក៏នាំមុខគេ ក្នុងពិភពលោកលើផ្នែកហិរញ្ញវត្ថុឥស្លាមផងដែរ។

ស៊ីអាយអិមប៊ី គ្រុប មានទីស្នាក់ការកណ្តាល នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ហើយមានផ្តល់សេវាកម្មធនាគារពាណិជ្ជ ធនាគារវិនិយោគ ធនាគារឥស្លាម និងសេវាកម្មគ្រប់គ្រងទ្រព្យធន។ ស៊ីអាយអិមប៊ី គ្រុប គឺស្ថិតក្នុងលំដាប់លេខ ៥ នៅអាស៊ីអាគ្នេយ៍ បើគិតលើទ្រព្យសកម្ម នៅចុងឆ្នាំ ២០១៨ ដែលមានបុគ្គលិកជាង ៣៦.០០០ នាក់ និងអតិថិជនប្រហែល ១៤ លាននាក់។

ស៊ីអាយអិមប៊ី គ្រុប ហូលឌីង បើហាដ ត្រូវបានចុះបញ្ជីនៅលើទីផ្សារភាគហ៊ុន ប៊ូរសាម៉ាឡេស៊ី (Bursa Malaysia) តាំងពីឆ្នាំ ១៩៨៧ ជាមួយតម្លៃលើទីផ្សារភាគហ៊ុន ៥៤,៦ ពាន់លានរីងហ្គិតម៉ាឡេស៊ី បើគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨។ ទ្រព្យសរុបគិតត្រឹមចុងឆ្នាំ២០១៨ មានចំនួន ៥៣៤,១ ពាន់លានរីងហ្គិតម៉ាឡេស៊ី ជាមួយប្រាក់បម្រុងរបស់ភាគហ៊ុនិកសរុបចំនួន ៥១,៤ ពាន់លានរីងហ្គិតម៉ាឡេស៊ី ហើយទ្រព្យសរុបស្ថិតក្រោមការគ្រប់គ្រងមានចំនួន ១២១,១ ពាន់លានរីងហ្គិតម៉ាឡេស៊ី។ គិតត្រឹមចុងឆ្នាំ ២០១៨ ភាគហ៊ុនិកដែលមានភាគហ៊ុនច្រើនបំផុត គឺ Khazanah Nasional ដែលមាន ២៦,៨០% នៃភាគហ៊ុនសរុប។ ប្រាក់បម្រុងសម្រាប់បុគ្គលិក (EPF) មានចំនួន ១៤,១៦% និងKumpulan Wang Persaraan (Diperbadankan) មានចំនួន ៦,៨៤%។

ការប្តេជ្ញាលើគុណភាពសេវាកម្ម និងឧត្តមភាព

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាក្រុមហ៊ុន ដែលផ្តោតលើការដឹកនាំរបស់មនុស្ស។ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អ្វីដែលយើងផ្តោតជាសំខាន់នោះ គឺការផ្តល់សេវាដល់អតិថិជន ឬក៏គាំទ្រដល់អ្នកដែលផ្តល់សេវាកម្មដល់អតិថិជន។

តាំងពីដើមរៀងមក អតិថិជន គឺជាចំណុចស្នូលនៃគ្រប់ការងារទាំងអស់ ដែលយើងបានធ្វើ។ គុណតម្លៃស្នូលទី១ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺយើងផ្តោតការយកចិត្តទុកដាក់លើអតិថិជន។ វត្តមានរបស់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺដើម្បីអតិថិជន ហើយយើងផ្តល់ផលិតផល និងសេវាកម្ម ដែលអតិថិជនយល់ និងផ្តល់តម្លៃឲ្យ។

យើងក៏ផ្តោតសំខាន់ដូចគ្នាផងដែរ ទៅលើគុណតម្លៃស្នូលចំនួន ៤ផ្សេងទៀត រួមមាន សមិទ្ធផលខ្ពស់ ការផ្តល់លទ្ធភាពដល់បុគ្គលិក កម្លាំងចម្រុះ និងសុចរិតភាព។ យើងជឿជាក់ថា ការរួមបញ្ចូលគ្នានៃគុណតម្លៃស្នូលទាំងអស់នេះ ទៅលើអ្វីគ្រប់យ៉ាង ដែលយើងធ្វើ នឹងបង្កើតនូវគុណតម្លៃយូរអង្វែង មិនត្រឹមតែសម្រាប់អតិថិជនប៉ុណ្ណោះទេ តែថែមទាំងសម្រាប់បុគ្គលិក និងភាគីពាក់ព័ន្ធរបស់យើងផងដែរ។

ដើម្បីសម្រេចបានគោលដៅសេវាកម្មអតិថិជនដ៏ល្អឥតខ្ចោះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានកំណត់គោលការណ៍ នៃសេវាកម្មអតិថិជនរបស់ខ្លួន ដើម្បីផ្តល់សេវាកម្មល្អប្រសើរជូនដល់អតិថិជន។ គ្រប់ពេលវេលាទាំងអស់ យើងនឹង៖

- ធ្វើគារវកិច្ចអតិថិជន ដោយ**ការសំពះ**
- ផ្តល់សេវាកម្មភ្ជាប់ជាមួយនឹង**ស្នាមញញឹម**
- **បម្រើសេវាកម្មអតិថិជន** ដោយកាត់បន្ថយរយៈពេលរង់ចាំ មិនលើសពី ៥ នាទី
- ផ្តោតទៅលើ **ដំណោះស្រាយ** សម្រាប់អតិថិជន

នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
អតិថិជន គឺជាអ្វីដែលយើងផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុត។

តម្លៃស្នូលរបស់ស្ថាប័ន

ការផ្តោតការយកចិត្តទុកដាក់លើអតិថិជន
វត្តមានរបស់យើង គឺដើម្បីបម្រើអតិថិជន ព្រមទាំងផ្តល់ជូនសេវាកម្ម និងផលិតផលទាំងឡាយណាដែលអតិថិជនយល់ និងឲ្យតម្លៃ។

សមិទ្ធផលខ្ពស់
យើងខិតខំបំពេញការងារយ៉ាងសកម្ម ដោយមានយុទ្ធសាស្ត្រជាក់លាក់ សម្រាប់អតិថិជន បុគ្គលិក និងអ្នកពាក់ព័ន្ធទាំងអស់។

ការផ្តល់លទ្ធភាពដល់បុគ្គលិក
យើងផ្តល់អំណាច និងតម្រង់ទិស ដល់បុគ្គលិក ឲ្យមានគំនិតច្នៃប្រឌិត និងផ្តល់គុណតម្លៃ ដល់ស្ថាប័ន ក៏ដូចជាសហគមន៍ ដែលគាត់បម្រើជូនផងដែរ។

កម្លាំងចម្រុះ
យើងគោរពវប្បធម៌ផ្សេងៗគ្នា និងផ្តល់គុណតម្លៃ លើទស្សនវិស័យខុសៗគ្នា ហើយយើងយល់ឃើញថា ភាពចម្រុះគ្នា គឺជាប្រភពនៃកម្លាំង។

សុចរិតភាព
យើងបំពេញការងារទាំងអស់ ដោយភាពស្មោះត្រង់ ប្រកបដោយការគោរព និងមានវិជ្ជាជីវៈច្បាស់លាស់ ពីព្រោះសុចរិតភាព គឺជាគុណតម្លៃស្នូលរបស់ ស៊ីអាយអិមប៊ី គ្រុប។

សារពីប្រធានក្រុមប្រឹក្សាភិបាលធនាគារ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សាកលលោក ដែលមានការផ្សាភ្ជាប់គ្នាយ៉ាងសស្រាក់សស្រាំនេះ បានពើបប្រទះនឹងការប្រឈមមួយចំនួន ដោយការផ្លាស់ប្តូរ និងភាពមិនប្រាកដប្រជា ផ្នែកភូមិសាស្ត្រ និងសេដ្ឋកិច្ចជាសកល រួមមានជម្លោះពាណិជ្ជកម្ម រវាងប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗ។ ទោះបីជាមានឧបសគ្គរាំងស្ទះទាំងអស់នេះក៏ដោយ ប្រទេសកម្ពុជា ដែលមានចំនួនប្រជាជន ប្រមាណ១៦,១លាននាក់ នៅតែបន្តភាពរីកចម្រើនរបស់ខ្លួន។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានក្លាយជាប្រទេសនាំចេញធំជាងគេទី៦៩ នៅក្នុងពិភពលោក។ ភាពរីកចម្រើនរបស់ប្រទេស កើតឡើងដោយផ្អែកតាមកំណើនយ៉ាងឆាប់រហ័ស នៃចំនួនប្រជាជន ដែលគ្រប់អាយុចូលធ្វើការងារ ការកើនឡើងថ្លៃប្រាក់ឈ្នួល ការលូតលាស់លើវិស័យទេសចរណ៍ និងលំហូរទុនវិនិយោគដោយផ្ទាល់ពីបរទេស ស្របតាមគោលនយោបាយវិនិយោគ និងការធ្វើពាណិជ្ជកម្មសេរី ព្រមទាំងអំណោយផលពីទីតាំងយុទ្ធសាស្ត្ររបស់ខ្លួន ដែលស្ថិតចំកណ្តាលនៃតំបន់អាស៊ាន។ ចំនួនជនបរទេស ដែលមកវិនិយោគ ក្នុងប្រទេសកម្ពុជា មានការកើនឡើងពី ៤,៤% ក្នុងឆ្នាំ២០១៣ រហូតដល់ ៩% ក្នុងឆ្នាំ២០១៨ ដែលជាទិន្នន័យជាក់ស្តែង នៃការអភិវឌ្ឍយ៉ាងឆាប់រហ័ស នៃទីផ្សារ ក្នុងតំបន់អាស៊ាន។

បើតាមការព្យាករណ៍ចុងក្រោយ ដោយធនាគារជាតិ នៃកម្ពុជា សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថាមានកំណើន ៧% ក្នុងឆ្នាំ២០១៩។ ក្នុងនោះវិស័យធនាគារ គឺជាវិស័យរីកចម្រើនឆាប់រហ័សមួយក្នុងប្រទេសកម្ពុជា។ ទំនុកចិត្ត ទៅលើប្រព័ន្ធធនាគារ នៅតែរក្សាបាននូវភាពរឹងមាំ ដោយឥណទានធនាគារ ធៀបនឹងទំហំផលិតផលក្នុងស្រុកសរុប បានកើនឡើងពី ៣១,៤% ក្នុងឆ្នាំ២០១០ រហូតដល់ ៧៣% នៅចុងខែមិថុនា ឆ្នាំ២០១៨ ហើយប្រាក់បញ្ញើវិស័យឯកជនបានកើនឡើង ២២,៤% ក្នុងរយៈពេលដូចគ្នានេះ។ ខណៈដែលប្រទេសកម្ពុជាកំពុងខិតខំសម្រេចផែនការ ដើម្បីក្លាយជាប្រទេស ដែលមានប្រាក់ចំណូលលើកម្រិតមធ្យម មុនឆ្នាំ២០៣០ និងក្លាយជាប្រទេស ដែលមានប្រាក់ចំណូលកម្រិតខ្ពស់ មុនឆ្នាំ២០៥០ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រយ៉ាងពេញទំហឹងដល់ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា។

ជាមួយនឹងការប្តេជ្ញាចិត្តនេះ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា តែងតែខិតខំប្រឹងប្រែង ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុដ៏មានសារៈសំខាន់មួយ ក្នុងការជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្នុងវិស័យហិរញ្ញវត្ថុ ក៏ដូចជាវិស័យដទៃទៀតផងដែរ។ នៅធនាគារ ស៊ីអាយអិមប៊ី យើងជឿជាក់ទៅលើការកសាងមូលដ្ឋានគ្រឹះរឹងមាំ ដើម្បីសម្រេចបានការរីកចម្រើនរយៈពេលវែង ក្នុងនាមជាដៃគូហិរញ្ញវត្ថុដ៏គួរឲ្យទុកចិត្តក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ ក្នុងរយៈពេល៧ឆ្នាំកន្លងមកនេះ យើងបានធ្វើការយ៉ាងពេញទំហឹង ដើម្បីធានាថាអតិថិជនរបស់យើងទាំងលក្ខណៈបុគ្គល និងក្រុមហ៊ុន ចាត់ទុកធនាគារ ស៊ីអាយអិមប៊ី គឺទីកន្លែងមួយ ដែលពួកគេអាចមកប្រឹក្សា ទទួលបានអ្វីដែលខ្លួនត្រូវការ និងយកទៅវិនិយោគ ដើម្បីអនាគតល្អប្រសើរដែលពួកគេចង់បាន។ ដើម្បីបំពេញតម្រូវការកើនឡើងរបស់អតិថិជន យើងបានពង្រីកសេវាកម្មធនាគារ សម្រាប់ថ្ងៃសៅរ៍ នៅតាមសាខាធនាគារ ៣ទីតាំង ក្នុងឆ្នាំ២០១៨ ហើយព្រមទាំងបន្តកែលម្អសេវាកម្មធនាគារឌីជីថលទៀតផង។ ធនាគារ ស៊ីអាយអិមប៊ី មានមោទនភាពក្រៃលែង ដែលបានក្លាយស្ថាប័នហិរញ្ញវត្ថុដ៏ជោគជ័យមួយ ជាមួយនឹងបុគ្គលិកក្នុងស្រុក ១០០% ជាជនជាតិខ្មែរ ដែលបានរួមចំណែកដល់ភាពរីកចម្រើន ប្រកបដោយស្ថេរភាព របស់ធនាគារទាំងមូល។

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ប្រាក់ចំណេញមុនកាត់ពន្ធរបស់ធនាគារ បានកើនឡើង ៧ដង ពីចំនួន ២លានដុល្លារអាមេរិក រហូតដល់ ១៤,២១លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ដែលមានកំណើន ៤៥% បើធៀបនឹងឆ្នាំមុន។ ហើយទំហំទ្រព្យសកម្មរបស់ធនាគារ បានកើនឡើងលើសពី២ដង រហូតដល់ ៨៦៥លានដុល្លារអាមេរិក ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ ក្នុងឆ្នាំ២០១៨ ឥណទានរបស់ធនាគារមានចំនួន ៥៤៥លានដុល្លារអាមេរិក ដែលកើនឡើង ៣២% ហើយប្រាក់បញ្ញើមានចំនួន ៧០០លានដុល្លារអាមេរិក ដែលកើនឡើង ៣០%។

ចំពោះការគាំទ្រ ការជឿទុកចិត្ត និងការរួមចំណែកយ៉ាងមុតមាំ ដែលនាំឲ្យធនាគារ ស៊ីអាយអិមប៊ី ក្លាយជា «ធនាគារអន្តរជាតិល្អបំផុត នៅកម្ពុជា» ប្រចាំឆ្នាំ២០១៨ ធនាគារសាកលឈានមុខគេ ក្នុងតំបន់អាស៊ានយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី ព្រមទាំងអតិថិនជនដ៏ស្មោះស្ម័គ្ររបស់យើង។ សូមជ្រើសរើសធនាគារ ស៊ីអាយអិមប៊ី សម្រាប់អតិថិជន និងវិនិយោគិនទាំងអស់ ដែលចង់ទទួលបានសេវាកម្មធនាគារដ៏ល្អ។

ការជួយគ្រទ្បប់ ទៅដល់សហគមន៍ គឺជាគុណតម្លៃស្នូលមួយរបស់ធនាគារ ស៊ីអាយអិមប៊ី។ សម្រាប់ការអប់រំ និងបច្ចេកវិទ្យា ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានចូលរួមក្នុងកម្មវិធីប្រកួតប្រជែង 3D Conquest ជាលើកដំបូង ក្នុងឆ្នាំ២០១៨។ កម្មវិធីថ្នាក់តំបន់ប្រកបដោយភាពច្នៃប្រឌិតនេះ គឺជាការប្រកួតប្រជែងមួយ ដែលយកលំនាំតាមបែប Hackathon ជាមួយនឹងការប្រកួតប្រជែង ៣ ប្រភេទ រួមមានវិទ្យាសាស្ត្រទិន្នន័យ (Data Science) បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងការសរសេរកូដ (Coding) ក្នុងគោលបំណងស្វែងរក និងទាក់ទាញយុវជនឆ្នើម ផ្នែកឌីជីថល និងមានភាពច្នៃប្រឌិតខ្ពស់ ជាមួយនឹងផ្តត់គំនិតជាសហគ្រិនឈ្លាសវៃក្នុងតំបន់អាស៊ាន។ ក្រៅពីរង្វាន់ទឹកប្រាក់សរុបចំនួន ១២០.០០០ ដុល្លារអាមេរិក សម្រាប់កម្មវិធីប្រកួតប្រជែងនេះ ម្ចាស់ជ័យលាភីថ្នាក់តំបន់នឹងទទួលបានបទពិសោធន៍ដ៏កម្រ តាមរយៈទស្សនកិច្ច ទៅកាន់តំបន់ដ៏ល្បីល្បាញ ដែលមានឈ្មោះថា Silicon Valley នៅសហរដ្ឋអាមេរិក រួមទាំងឱកាសការងារ ជាមួយនឹងធនាគារ CIMB បន្ទាប់ពីបញ្ចប់ការសិក្សាផងដែរ។

«ធនាគារ CIMB យកចិត្តទុកដាក់លើសុខភាពមាតា និងកុមារ» គឺជាប្រធានបទ នៃកម្មវិធីទំនួលខុសត្រូវសង្គមចុងក្រោយរបស់យើង ដែលបង្កើតឡើង ក្នុងគោលបំណងលើកកម្ពស់ការថែទាំសុខភាពមាតុភាព ក្នុងចំណោមប្រជាពលរដ្ឋ ដែលខ្វះខាតនៅតាមជនបទ។ យើងបានបរិច្ចាគសម្ភារៈពេទ្យសំខាន់ៗមួយចំនួន ដល់មន្ទីរពេទ្យបង្អែកបាទី ខេត្តតាកែវ រួមមានអេកូស្ទង់ចង្វាក់បេះដូងទារកក្នុងផ្ទៃម្តាយ ដែលជាសម្ភារៈពេទ្យទំនើបដំបូងបំផុត នៅក្នុងមន្ទីរពេទ្យ។ ក្រៅពីនេះ យើងបានរៀបចំព្រឹត្តិការណ៍ជាច្រើន ក្នុងឆ្នាំ២០១៨ រួមមានទិវាសិទ្ធិនារី ទិវាថ្លែងអំណរគុណអតិថិជន កម្មវិធីជួបជុំបុគ្គលិក និងកសាងក្រុមការងាររបស់ធនាគារ រួមទាំងការឧបត្ថម្ភ និងការចូលរួមកម្មវិធីផ្សេងៗ ដូចជាសន្និសីទអាហារូបករណ៍ ពិព័រណ៍ការងារ និងផលិតភាពជាតិ ព្រមទាំងព្រឹត្តិការណ៍រត់ប្រណាំងពាក់កណ្តាលម៉ារាតុង អន្តរជាតិអង្គរវត្តជាដើម។

ជាចុងក្រោយ តាងនាមឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ខ្ញុំសូមសម្តែងការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិ នៃកម្ពុជា និងអតិថិជនទាំងអស់របស់យើង ដែលបានគាំទ្រមកលើធនាគារ ចាប់តាំងពីបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០។ នៅក្នុងដំណាក់កាលដ៏សំខាន់ នៃភាពរីកចម្រើន ផ្នែកវិស័យហិរញ្ញវត្ថុ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងប្រជាជនកម្ពុជា។



Dato' Wira Zainal Abidin Mahamad Zain

សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ

ឆ្នាំ២០១៨ មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់! ស្របពេលដែល ស៊ីអាយអិមប៊ី គ្រុប ឈានដល់ឆ្នាំចុងក្រោយ នៃយុទ្ធសាស្ត្រ T១៨ ការកើនឡើងកម្តៅនៃជម្លោះពាណិជ្ជកម្ម រវាងសហរដ្ឋអាមេរិក និងប្រទេសចិន បានគម្រាមកំហែងដល់គោលដៅរបស់យើងផងដែរ។ នៅតាមវេទិការបស់អាស៊ានគ្រប់កម្រិត កង្វល់ចម្បង ដែលស្ថិតលើឥទ្ធិពលអវិជ្ជមានកាន់តែច្រើនទៅៗ លើពាណិជ្ជកម្ម និងតួនាទីរបស់អាស៊ាន នៅក្នុងសង្វាក់ផ្គត់ផ្គង់ជាសាកល អាចប្រឈមនឹងភាពជាប់គាំងអូសបន្លាយ ដែលបណ្តាលមកពីប្រទេសមហាអំណាចពាណិជ្ជកម្មទាំងពីរនេះ។

ទោះបីជាមានការប្រឈមនៃការអភិវឌ្ឍ ពីមជ្ឈដ្ឋានខាងក្រៅក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅតែទទួលបានអត្រាល្អប្រសើរប្រមាណ ៧,៣% ក្នុងឆ្នាំ២០១៨ ដែលកើនឡើងជាងឆ្នាំមុន (៦,៨%) ដោយរក្សាបានចំណាត់ថ្នាក់ជាប្រទេស ដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតមួយ ក្នុងតំបន់អាស៊ាន។ ក្នុងឆ្នាំ២០១៨ ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ គឺជាគ្រឹះយ៉ាងសំខាន់នៃសេដ្ឋកិច្ច ដោយក្នុងនោះភ្ញៀវទេសចរអន្តរជាតិ មានកំណើន ១១% ខណៈដែលឧស្សាហកម្មកាត់ដេរ ត្រូវបានពង្រីកការដាក់ទីតាំងរោងចក្របន្ថែមទៀត ដោយការដករោងចក្រ ពីប្រទេសចិន និងបង់ក្លាដេស មកកាន់ប្រទេសកម្ពុជា ជាមួយនឹងទីផ្សារផលិតកាន់តែមានភាពប្រកួតប្រជែង។ នៅក្នុងត្រីមាសទី២ នៃឆ្នាំ២០១៨ លំហូរទុនវិនិយោគដោយផ្ទាល់ពីបរទេស មានកំណើន ៨៣២លានដុល្លារអាមេរិក ដែលកើនឡើងជាប់ៗគ្នាប្រាំដង នៅក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ។ កំណើនថេរ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ បានផ្តល់នូវនិរន្តភាពសេដ្ឋកិច្ច ទោះបីជាមានការប្រកួតប្រជែង ពីប្រទេសជិតខាង ដែលមានសេដ្ឋកិច្ចរីកចម្រើនជាង ដូចជាប្រទេសថៃ និងវៀតណាមក៏ដោយ។

ក្នុងឆ្នាំ២០១៨ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា សម្រេចបានឆ្នាំដ៏ជោគជ័យបំផុតរបស់ខ្លួន ជាមួយនឹងប្រាក់ចំណូលមុនកាត់ពន្ធ ចំនួន ១៤,២១លានដុល្លារអាមេរិក ដែលមានកំណើន៤៥%បើធៀបនឹងឆ្នាំមុន។សមិទ្ធផលនេះកើតឡើងមួយផ្នែកធំតាមរយៈឥណទានរបស់ធនាគារ ចំនួន ១៣៧លានដុល្លារអាមរិក ដែលកើនឡើង ៣៤% បើធៀបនឹងឆ្នាំមុន ដែលជាការបន្តកំណើនឆ្នាំទី៨។ ផ្នែកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មានចំនួន ៥៨% នៃកំណើនឥណទានសរុបរបស់ធនាគារ ក្នុងឆ្នាំ២០១៨។ ជាមួយគ្នានេះ ប្រាក់បញ្ញើរបស់អតិថិជនមានកំណើន ២៦% បើធៀបនឹងឆ្នាំមុន ដែលភាគច្រើនមកពីផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គល។ ផ្នែកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម រក្សាបាននូវសន្ទុះរីកចម្រើនរបស់ខ្លួន ដោយចាប់យកចំណែកទីផ្សារ ទាំងនៅក្នុងស្រុក និងថ្នាក់តំបន់ ដែលរួមចំណែកដល់កំណើនប្រាក់ចំណូលមុនកាត់ពន្ធ ១៤% បើធៀបនឹងឆ្នាំមុន។ ជាមួយនឹងលទ្ធផលហិរញ្ញវត្ថុយ៉ាងរឹងមាំ ក៏ដូចជាការប្តេជ្ញាចិត្តរបស់យើង ក្នុងការនាំយកបទពិសោធន៍បម្រើសេវាកម្មដ៏ល្អប្រពៃ វាគឺពិតជាសាកសមបំផុត ដែលធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ទទួលបានពានរង្វាន់ជាធនាគារអន្តរជាតិល្អបំផុតនៅកម្ពុជានៅក្នុងពិធីប្រគល់ពានរង្វាន់ធនាគារល្អបំផុតរបស់ទស្សនាវដ្តី Asiamoney ក្នុងឆ្នាំ២០១៨។

ឆ្នាំ២០១៨ គឺជាឆ្នាំបញ្ចប់នៃយុទ្ធសាស្ត្រ T18 របស់ ស៊ីអាយអិមប៊ី គ្រុប ដែលបានពង្រឹងមូលដ្ឋានគ្រឹះរបស់យើង នៅគ្រប់ផ្នែកនៃអតិថិជន ដើមទុន ការចំណាយ វប្បធម៌ និងការប្រតិបត្តិតាមច្បាប់។ ធនាគារ បានវិនិយោគយ៉ាងខ្លាំងក្លាលើការកសាងមូលដ្ឋានគ្រឹះថ្មីៗ និងពង្រឹងអ្វីដែលមានស្រាប់ ដូចជាតាមរយៈការពង្រីកកម្លាំងពលកម្មការងារ ក៏ដូចជាផ្នែកឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានជាដើម។ ក្នុងឆ្នាំ២០១៩ ស៊ីអាយអិមប៊ី គ្រុប នឹងចាប់ផ្តើមយុទ្ធសាស្ត្រថ្មីបន្ទាប់ទៀត គឺ «Forward23» ដើម្បីជម្រុញដល់កំណើន ស៊ីអាយអិមប៊ី គ្រុប មានកំណើន ប្រកបដោយការផ្លាស់ប្តូរល្អប្រសើរ។ យើងនឹងផ្តោតលើចំណុចយុទ្ធសាស្ត្រស្នូល៥ចំណុច រួមមានការយកចិត្តទុកដាក់លើអតិថិជន និរន្តរភាពការផ្សងព្រេង និងភាពជាដៃគូ បច្ចេកវិទ្យា និងទិន្នន័យ ព្រមទាំងធនធានមនុស្សរបស់យើង។ សម្រាប់ទស្សនវិស័យ ទៅលើភូមិសាស្ត្រ យើងមានផែនការកសាងសន្ទុះរីកចម្រើន ដែលកើតចេញពីការផ្លាស់ប្តូរយុទ្ធសាស្ត្រ T18 និងពន្លឿនដល់ភាពរីកចម្រើនរបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា មួយកម្រិតទៀតផងដែរ។

ក្នុងឆ្នាំ២០១៩ ការសាងសង់អាកាសយានដ្ឋានថ្មី នឹងចាប់ផ្តើមបង្កើតនៅក្នុងប្រទេសកម្ពុជា ដែលនឹងជម្រុញបន្ថែមទៀតដល់វិស័យទេសចរណ៍ឲ្យកាន់តែល្អប្រសើរ។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលទើបតែបានចុះហត្ថលេខាលើច្បាប់ថ្មី ដើម្បីព្យួរការបង់ពន្ធប្រាក់ចំណេញ លើវិស័យកសិកម្ម ដែលអាចបង្កើនប្រាក់ចំណូលកាន់តែច្រើនរបស់អ្នកវិនិយោគ។ ទោះជាយ៉ាងណាក៏ដោយ នៅមានបញ្ហាប្រឈមខ្លះផងដែរសម្រាប់សេដ្ឋកិច្ច។ ក្នុងនោះ កាលពីពាក់កណ្តាលខែកុម្ភៈ សហភាពអឺរ៉ុប បានចាប់ផ្តើមនីតិវិធីសិក្សាដកប្រព័ន្ធអនុគ្រោះពន្ធរបស់ប្រទេសកម្ពុជាជាផ្លូវការរយៈពេល១២ខែ ដោយសារសម្ពាធអន្តរជាតិ។ ការបាត់បងប្រព័ន្ធអនុគ្រោះពន្ធទៅកាន់ទីផ្សារសហភាពអឺរ៉ុប និងក្រោយពេលការចាកចេញពីសហភាពអឺរ៉ុបរបស់ចក្រភពអង់គ្លេស ក៏ដូចជាការកាត់បន្ថយការផលិតរបស់ប្រទេសចិន ដែលប៉ះពាល់ដល់វិស័យកាត់ដេរដ៏មានសារៈសំខាន់ដោយប្រទេសចិន និងចក្រភពអង់គ្លេស នឹងក្លាយជាទីផ្សារនាំចេញសំខាន់។ យ៉ាងណាមិញ យើងរំពឹងថា សេដ្ឋកិច្ចកម្ពុជានឹងមានកំណើន ៧% ក្នុងឆ្នាំ២០១៩ ដែលប្រហាក់ប្រហែលនឹងឆ្នាំមុនៗ។

តាងនាមឲ្យ ស៊ីអាយអិមប៊ី គ្រុប ខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅ ដល់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិ នៃកម្ពុជា សម្រាប់ការបន្តជួយជ្រោមជ្រែងរហូតមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណ ដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលធនាគារ អតិថិជន ភាគទុនិក និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការជឿទុកចិត្ត និងការគាំទ្រ។ ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ ដល់សហសេវិកទាំងអស់ ក្នុងក្រុមការងារ #TeamCIMB ដែលបន្តផ្តល់ការគាំទ្ររួមចំណែក ប្រកបដោយគុណតម្លៃ ទៅក្នុងភាពជោគជ័យរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងប្រទេសកម្ពុជា។ ជាមួយនឹងការជួយគាំទ្ររបស់អ្នកទាំងអស់គ្នា ខ្ញុំមានទំនុកចិត្តថា យើងនឹងអាចធ្វើឲ្យយុទ្ធសាស្ត្រ Forward23 ទទួលបានជោគជ័យដ៏អស្ចារ្យ។

សូមអរគុណ!

Tengku Zafrul Tengku Abdul Aziz
នាយកប្រតិបត្តិក្រុមហ៊ុនមេ
ស៊ីអាយអិមប៊ី គ្រុប

ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

បរិយាកាសប្រតិបត្តិការឆ្នាំ ២០១៨

ជាមួយនឹងកំណើនសេដ្ឋកិច្ចយ៉ាងរឹងមាំ ជាងពីរទស្សវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជា គឺបានស្ថិតក្នុងចំណោមប្រទេស ដែលមានភាពរីកចម្រើនល្អបំផុតមួយ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយមានកំណត់ត្រាកំណើនប្រចាំឆ្នាំពីរខ្ទង់ ក្នុងឆ្នាំ២០១៨។ ប្រទេសដែលជាសមាជិកទីដប់នៃតំបន់អាស៊ាននេះ បានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៧ ផ្អែកលើសេដ្ឋកិច្ច ដែលរក្សាបានអត្រាកំណើនជាមធ្យម ៧,៧% ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៨។ យើងមានក្តីសោមនស្សរីករាយដែលផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា បានកើនឡើងបួនដង ពីចំនួន ៤១៧ដុល្លារអាមេរិក ដល់ ១.៥៦៣ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨។ អត្រានៃភាពក្រីក្រ ក្នុងប្រទេស មានចំនួនថយចុះ ពី៥៣% ក្នុងឆ្នាំ២០០៤ មកប្រហែល ១៣,៤% ក្នុងឆ្នាំ២០១៤។ បើតាមការប៉ាន់ស្មាន យើងរំពឹងថា ទិន្នន័យនេះបានធ្លាក់ចុះបន្ថែមទៀត ក្នុងឆ្នាំ២០១៨ មកត្រឹមប្រមាណ ១០% ប៉ុណ្ណោះ។

គិតត្រឹមចុងឆ្នាំ២០១៨ សេដ្ឋកិច្ចទាំងមូលរបស់ប្រទេសកម្ពុជា នៅតែមានភាពរឹងមាំ ដែលរួមចំណែកមួយភាគធំ ពីការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ រួមមានផលិតផលវាយនភណ្ឌ សម្លៀកបំពាក់ និងស្បែកជើង ដែលមានចំនួនដល់ទៅ ៧៤% នៃទំនិញនាំចេញសរុប ជាមួយនឹងកំណត់ត្រាកំណើនពីរខ្ទង់ ១៦,១% ក្នុងរយៈពេលប្រាំមួយខែដំបូង នៃឆ្នាំ២០១៨។ ចំនួនជនបរទេស ដែលវិនិយោគ ក្នុងប្រទេសបានកើនឡើងជិត ៩% ក្នុងឆ្នាំ២០១៨ ដែលឆ្នាំ២០១៣ មានត្រឹមតែ ៤,៤% ប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ ភ្ញៀវទេសចរបរទេស មានចំនួន ៦,២លាននាក់ក្នុងឆ្នាំ២០១៨ កើនឡើងរហូតដល់ ១១% ។

ឥណទានធនាគារ និងមីក្រូហិរញ្ញវត្ថុ ធៀបនឹងផលិផលក្នុងស្រុកសរុប កើនឡើងពី ៣១,៤% និង ៣,៨% ក្នុងឆ្នាំ២០១០ ដល់ចំនួនខ្ពស់បំផុតមួយ ៧៣% និង ២០% គិតត្រឹមចុងខែមិថុនា ឆ្នាំ២០១៨។ ទំនុកចិត្ត ក្នុងប្រព័ន្ធធនាគារ បានរក្សាភាពរឹងមាំ ជាមួយនឹងប្រាក់បញ្ញើ ផ្នែកវិស័យឯកជន ប្រមាណ ២២,៤% ក្នុងខែមិថុនា ឆ្នាំ២០១៨ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំកន្លងមក។ ទោះជាយ៉ាងណាក៏ដោយ អតិផរណាក៏បានកើនឡើង ពី ២,២% ក្នុងខែធ្នូ ឆ្នាំ២០១៧ ដល់ ២,៩% ក្នុងខែមិថុនា ឆ្នាំ២០១៨ ដែលអាស្រ័យលើការកើនឡើងតម្លៃអាហារ និងទឹកភ្លើង។

លទ្ធផលប្រតិបត្តិការឆ្នាំ ២០១៨

ឆ្នាំ២០១៨ គឺជាឆ្នាំដ៏ល្អវិសាល ដែលធនាគារទទួលបានពានរង្វាន់ជា «ធនាគារអន្តរជាតិល្អបំផុត នៅកម្ពុជា» ហើយសម្រេចបានសមិទ្ធផលអាជីវកម្ម និងហិរញ្ញវត្ថុ លើសពីការរំពឹងទុក។ យើងខ្ញុំមានកិត្តិយស សូមជម្រាបជូនថា ធនាគារទទួលបានកំណើនប្រាក់ចំណេញមុនបង់ពន្ធគួរឲ្យចាប់អារម្មណ៍ ៣៩,៥% ក្នុងឆ្នាំ២០១៨ បើធៀបនឹងឆ្នាំមុន តាមរយៈភាពរីកចម្រើននៃឥណទានសរុប ៣៦,៧% និងប្រាក់បញ្ញើអតិថិជន ២៨%។ ប្រាក់ចំណេញមុនបង់ពន្ធ និងទ្រព្យសកម្ម បានកើនឡើង ១៤,២១លានដុល្លារអាមេរិក និង ៨៦៥លានដុល្លារអាមេរិក។

ឥណទាន និងប្រាក់បញ្ញើរបស់យើង បានឆ្លុះបញ្ចាំងពីកំណើនយ៉ាងល្អប្រសើរ។ ទំហំឥណទានសរុបរបស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មានចំនួន ២៨៧លានដុល្លារអាមេរិក ជាមួយនឹងប្រាក់បញ្ញើសរុប ២០០លានដុល្លារអាមេរិក។ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម រក្សាបានកំណត់ត្រាឥណទានមិនដំណើរការ ក្នុងកម្រិតទាប ត្រឹមតែ ០,២៤%។ សេវាកម្មហិរញ្ញវត្ថុបុគ្គលមានភាពរីកចម្រើនឈានមុខគេ ក្នុងវិស័យធនាគារ ទាំងផ្នែកប្រាក់បញ្ញើ និងឥណទាន ក្នុងឆ្នាំ២០១៨ ដោយទទួលបានកំណើនប្រចាំឆ្នាំ ៤០% កំណើនឥណទានគេហដ្ឋាន ៣៣% និងកំណើនប្រាក់ចំណេញមុនបង់ពន្ធ ២៤% បើធៀបនឹងឆ្នាំមុន។

ក្រៅពីសន្ទុះរីកចម្រើនយ៉ាងល្អប្រសើរ ក្នុងឆ្នាំ២០១៨ យើងមានមោទនភាព ក្នុងការសម្រេចបានគម្រោងថ្នាក់តំបន់សំខាន់ៗ របស់ ស៊ីអាយអិមប៊ី គ្រុប ដូចជាកម្មវិធីប្រកួតប្រជែង 3D Conquest ដែលជាគម្រោងពិសេសមួយ។ នេះជាសកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងៗ ដែលបានឆ្លុះបញ្ចាំងនូវទំនួលខុសត្រូវសង្គមរបស់ធនាគារ និងឆន្ទៈមោះមុត សម្រាប់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា យើងបានប្តេជ្ញាចិត្តខ្ពស់ចំពោះធនាគារជាតិ នៃកម្ពុជា ក្នុងការលើកកម្ពស់ប្រាក់រៀល ក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ។ ជាក់ស្តែង ចាប់តាំងពីដើមឆ្នាំ២០១៨មក យើងបានដាក់ឲ្យប្រើប្រាស់ការកំណត់តម្លៃផ្ទេរប្រាក់មូលធនជាប្រាក់រៀល (KHR-FTP) ក៏ដូចជាលើកកម្ពស់ផលិតផលធនាគារថ្មីៗ ជាប្រាក់រៀល ទាំងផ្នែកឥណទាន និងប្រាក់បញ្ញើ។

នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ការផ្តល់ភាពងាយស្រួល សម្រាប់អតិថិជន ក្នុងការប្រើប្រាស់សេវាកម្មធនាគារ គឺជាអាទិភាពចម្បងរបស់យើង ក្នុងឆ្នាំ២០១៨។ យើងបាននាំយកគម្រោងបច្ចេកវិទ្យាធំៗចំនួន៤ លើកកម្ពស់គោលដៅនេះ រួមមានប្រព័ន្ធផ្ទេរប្រាក់រហ័ស កូដនីយកម្មលើការរក្សាទុកទិន្នន័យ ផលិតផលធនាគារជាប្រាក់រៀល និងការទូរទាត់មូលប្បទានបត្រដោយស្វ័យប្រវត្តិ។ ឆ្នាំ២០១៨ គឺសម្រេចបានការសម្ពោធគេហទំព័រហ្វេសប៊ុករបស់ធនាគារ ស៊ីអាយអិមប៊ី ព្រមទាំងកែលម្អគម្រោងផ្តល់មតិយោបល់របស់អតិថិជន តាមប្រព័ន្ធឌីជីថល ដោយដាក់ឲ្យប្រើឧបករណ៍បង្កប់អេក្រង់ ដើម្បីប្រមូលមិតិយោបល់ជាក់ស្តែង ពីអតិថិជនរបស់យើង។ ដើម្បីផ្តល់ភាពងាយស្រួលបន្ថែមទៀត ដល់អតិថិជន យើងបានដំឡើងម៉ាស៊ីនអេធីអិមបន្ថែមទៀត នៅតាមផ្សារទំនើបធំៗ ក្នុងប្រទេសកម្ពុជាផងដែរ។

ក្នុងឆ្នាំ២០១៨ យើងបានខិតខំធ្វើការ ដើម្បីធានាថា ធនាគារ ស៊ីអាយអិមប៊ី គឺជាគេហដ្ឋានទី២ របស់និយោជិត ដែលជាទីកន្លែងពោរពេញដោយកិច្ចសហការគ្នាល្អ ការសិក្សារៀនសូត្រ និងការអភិវឌ្ឍ។ យើងបានរៀបចំវគ្គបណ្តុះបណ្តាល ជាង ១០.០០០ម៉ោង សម្រាប់បុគ្គលិកធនាគារ។ វគ្គបណ្តុះបណ្តាលទាំងនោះផ្តោតលើទាំងចំណេះដឹង និងជំនាញអនុវត្តន៍ការងារ។ ក្រៅពីនេះ យើងបានរៀបចំសកម្មភាពធនាគារជាច្រើន រួមមានកិច្ចពិភាក្សាថ្ងៃអង្គារ ពិធីសំណេះសំណាល ជាមួយប្រធាននាយកប្រតិបត្តិ ពានរង្វាន់បាល់ទាត់ កម្មវិធីកសាងក្រុមការងារ អ្នកគ្រប់គ្រងឆ្នើមប្រចាំឆ្នាំ និយោជិតឆ្នើមប្រចាំត្រីមាស និងកម្មវិធីជួបជុំបុគ្គលិកប្រចាំឆ្នាំជាដើម។ កម្មវិធីពានរង្វាន់បុគ្គលិកឆ្នើម ផ្នែកបម្រើសេវាកម្មអតិថិជន ត្រូវបានប្រារព្ធឡើង ដល់បុគ្គលិក

របស់យើង ដើម្បីលើកកម្ពស់ភាពឥតខ្ចោះរបស់ពួកគេ លើអាកប្បកិរិយាយកចិត្តទុកដាក់អតិថិជន និងដើម្បីអបអរដល់ការរួមចំណែកលេចធ្លោររបស់ពួកគេ ចំពោះធនាគារ។



ចក្ខុវិស័យសម្រាប់ឆ្នាំ ២០១៩

ចក្ខុវិស័យនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា សម្រាប់ឆ្នាំ២០១៩ នៅតែមានសន្ទុះល្អប្រសើរ។ ទំហំផលិតផលក្នុងស្រុកសរុបរបស់ប្រទេស ត្រូវបានប៉ាន់ស្មានថា នឹងមានកំណើន ៧% ហើយកំណើនផលិតផលក្នុងស្រុក ក្នុងម្នាក់ នឹងមានចំនួនប្រមាណ ៤,៤% ដែលនឹងក្លាយជាប្រទេសមានចំណូលមធ្យម កម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០។ បច្ចុប្បន្ន ប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនេះ គឺជាទីផ្សារគោលដៅមួយ តាមរយៈសក្តានុពល សម្រាប់ការវិនិយោគកំណើនសេដ្ឋកិច្ចខ្ពស់ តម្លៃពលកម្មទាប និងកំណើនទីផ្សារនៃការប្រើប្រាស់។ ដោយប្រកាន់យករបបទីផ្សារសេដ្ឋកិច្ចសេរី ព្រមទាំងគោលនយោបាយវិនិយោគបើកចំហរ ព្រមទាំងជាទីតាំងយុទ្ធសាស្រ្តអនុគ្រោះមួយ ក្នុងតំបន់អាស៊ាន ប្រទេសកម្ពុជាត្រូវបានប៉ាន់ស្មានថា នឹងបន្តទាក់ទាញកំណើនលំហូរនៃទុនវិនិយោគ ពីបរទេស។ បើតាមការប៉ាន់ស្មាន ប្រទេសកម្ពុជាមានឱកាសដ៏ល្អសម្រាប់កំណើនសេដ្ឋកិច្ចឆាប់រហ័ស មិនត្រឹមតែក្នុងឆ្នាំ២០១៩ប៉ុណ្ណោះទេ តែថែមទាំងក្នុងរយៈពេល៣០ឆ្នាំទៅមុខផងដែរ ដោយប្រទេសកម្ពុជាមានចំនួនប្រជាជនគ្រប់អាយុធ្វើការ ដែលបានកើនឡើងឆាប់រហ័ស ជាងចំនួនប្រជាជនសរុបរបស់ខ្លួន ប្រមាណ ២,៣% ខណៈដែលចន្លោះឆ្នាំ ២០០៧ ដល់ ២០១៥ ត្រឹមតែ ១,៥៦% ប៉ុណ្ណោះ។

នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា យើងរំពឹងថា ឆ្នាំ២០១៩ នឹងក្លាយជាឆ្នាំជោគជ័យម្តងទៀត។ ក្រៅពីបញ្ហា ពីផ្នែកខាងក្រៅ ដែលយើងត្រូវប្រឈម យើងមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការខិតខំបំពេញការងារ សម្រាប់ភាគីពាក់ព័ន្ធ និងអតិថិជនរបស់យើង។ ក្រោយពីបញ្ចប់ឆ្នាំ២០១៨ប្រកបដោយលទ្ធផលជាទីមោទន យើងនឹងបន្តអនុវត្តយុទ្ធសាស្រ្តកំណើន រយៈពេលមធ្យមថ្មី របស់ស៊ីអាយអិមប៊ី គ្រុប គឺ «Forward23»។ ផែនការយុទ្ធសាស្រ្តនេះ មានគោលដៅពង្រឹងទិសដៅប្រកួតប្រជែងឲ្យកាន់តែរឹងមាំ ហើយនាំយកគុណតម្លៃ ប្រកបដោយនិរន្តរភាព ទៅដល់ភាគីពាក់ព័ន្ធទាំងអស់របស់យើង។ តួនាទីលេចធ្លោររបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ក្នុងក្របខណ្ឌយុទ្ធសាស្រ្តនេះ ផ្តល់នូវធនធាន ប្រកបដោយស្ថិរភាព នៃការលើកទឹកចិត្តយ៉ាងមុតមាំ។យើងមានការប្តេជ្ញាចិត្តក្នុងការកំណត់ទិសដៅទៅលើគោលដៅរបស់ស៊ីអាយអិមប៊ី គ្រុប ហើយធ្វើឲ្យធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ក្លាយជាក្រុមហ៊ុនរួមចំណែកដ៏ល្អប្រសើរ ដល់ប្រាក់ចំណេញរបស់ស៊ីអាយអិមប៊ី គ្រុប។

ស្របនឹងទិសដៅក្រុមហ៊ុន ក្នុងឆ្នាំ២០១៩ យើងនឹងផ្តោតជាសំខាន់ទៅលើវិស័យដូចខាងក្រោម៖

- **ខិតខំបន្ថែមទៀត លើកំណើន និងប្រាក់ចំណេញ ប្រកបដោយស្ថិតស្ថេរ៖** យើងនឹងដាក់ចិត្ត និងដាក់កាយ ក្នុងការបម្រើជូនសេវាកម្ម និងផលិតផលធនាគារ កាន់តែសម្បូរបែប និងបត់បែនខ្ពស់ ហើយគាំទ្រដល់ធនាគារជាតិ នៃកម្ពុជា ក្នុងការប្រើប្រាស់ប្រាក់រៀល។ យើងនឹងបន្តដំណើរការត្រួតពិនិត្យ ដល់ទីកន្លែង លើការអនុវត្តការអនុលោមតាមច្បាប់ និងការត្រួតពិនិត្យ លើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់សាខាទាំងអស់ ព្រមទាំងបញ្ចប់ការវិភាគ ទៅលើបទប្បញ្ញត្តិ ដែលកំពុងអនុវត្តនានា សម្រាប់នាយកដ្ឋានទាំងអស់។ យើងនឹងធានាថា ជម្រើសសេវាកម្មធនាគាររបស់យើង គឺមានភាពជឿជាក់ និងស្មោះត្រង់ ចំពោះអតិថិជនរបស់យើង ហើយធនាគារ ស៊ីអាយអិមប៊ី គឺជាដៃគូជឿជាក់ និងពិតប្រាកដ ក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។
- **ខិតខំបន្ថែមទៀត លើបទពិសោធន៍បម្រើសេវាកម្មអតិថិជន ប្រកបដោយភាពវិជ្ជមាន៖** នៅធនាគារ ស៊ីអាយអិមប៊ី អតិថិជន គឺជាសន្ទុះ នៃកំណើនអាជីវកម្មរបស់ធនាគារ ហើយយើងមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការផ្តល់ជូនអតិថិជន នូវលក្ខខណ្ឌស្នូល៣ធំៗ គឺការប្រើប្រាស់សេវាកម្មធនាគារ ជាមួយធនាគារ ស៊ីអាយអិមប៊ី មានប្រសិទ្ធភាព និងងាយស្រួល ហើយយើងតែងតែខិតខំបន្ថែមទៀត ដើម្បីបំពេញចិត្តអតិថិជន។ អង្គភាពបទពិសោធន៍បម្រើសេវាកម្មអតិថិជន ធានាថា ធនាគារអាចផ្តល់ជូនសេវាកម្មល្អបំផុត ក្នុងការបំពេញចិត្តអតិថិជន ដោយអនុវត្តវិធីសាស្រ្ត នៃការផ្តោតការយកចិត្តទុកដាក់ ទៅលើអតិថិជន។ ក្នុងឆ្នាំ២០១៩ យើងនឹងកែលម្អដំណើរការនិងប្រព័ន្ធ ឲ្យកាន់តែល្អប្រសើរ ដើម្បីលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន។
- **ខិតខំបន្ថែមទៀត លើការអភិវឌ្ឍនិយោជិត៖** និយោជិត គឺជាកត្តាចម្បង ក្នុងការបំពេញចិត្តអតិថិជនរបស់យើង និងការសម្រេចបានជោគជ័យរបស់ធនាគារ។ យើងរក្សាការផ្តោតសំខាន់ លើភាពរីកចម្រើនរបស់និយោជិត និងគុណតម្លៃរបស់ពួកគេម្នាក់ៗ ស្របតាមគុណតម្លៃ និងវប្បធម៌ស្នូលរបស់យើង គឺ «បំពេញភារៈកិច្ចលើសពីការរំពឹងទុក ដើម្បីបំពេញចិត្តអតិថិជន / ភ្ជាប់ទំនាក់ទំនងដោយបើកចំហរ និងធ្វើការរួមគ្នា/ គោរព និងតែងតែជួយគាំទ្រគ្នាទៅវិញទៅមក»។ ដូច្នេះយើងនឹងបន្តយកចិត្តទុកដាក់ លើភាពច្នៃប្រឌិតថ្មីៗ ដើម្បីធានាថា ធនាគារ ស៊ីអាយអិមប៊ី រួមទាំងបុគ្គលិករបស់ខ្លួន បានត្រៀមខ្លួនរួចរាល់ សម្រាប់បដិវត្តន៍បច្ចេកវិទ្យាថ្មី នៅក្នុងវិស័យធនាគារ ដែលជាពិសេសគឺ «3D Awareness Series» ដែលរួមមាន ឌីជីថល (Digital) ទិន្នន័យ (Data) ការរំខាន (Disruption) ដើម្បីក្លាយជា «ស្ថាប័ន ដែលជាជម្រើសឈានមុខគេ» ក្នុងវិស័យហិរញ្ញវត្ថុ។

សម្រាប់ការបន្តគាំទ្រ ការរួមចំណែក និងជឿទុកចិត្តទាំងអស់ នាពេលកន្លងមក ដែលបានធ្វើឲ្យធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ទទួលបានពានរង្វាន់ជា «ធនាគារអន្តរជាតិល្អបំផុត នៅកម្ពុជា» ក្នុងឆ្នាំ២០១៨ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជន ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងសហការីទាំងអស់។ ខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងនូវការគោរព ព្រមទាំងកោតសរសើរដ៏ខ្ពង់ខ្ពស់ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសធនាគារជាតិនៃកម្ពុជា ចំពោះការបន្តគាំទ្រ និងការណែនាំកន្លងមក។ សមិទ្ធផលដ៏ត្រចះត្រចង់របស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងឆ្នាំ២០១៩ គឺមិនត្រឹមតែជាជោគជ័យរបស់ធនាគារតែមួយនោះទេ តែក៏ជាជោគជ័យរបស់អតិថិជន និងប្រទេសកម្ពុជាទាំងមូលផងដែរ។

ប៊ុន យីន
ប្រធាននាយកប្រតិបត្តិ
ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ការពិនិត្យមើលធុរកិច្ច

១៦ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
១៧ សេវាកម្មហិរញ្ញវត្ថុបុគ្គល
១៨ សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ
១៩ ធនធានសាជីវកម្ម
២០ ទីផ្សារ និងទំនាក់ទំនង
២១ ហិរញ្ញវត្ថុ
២២ ការគ្រប់គ្រងហានិភ័យ
២៤ បច្ចេកវិទ្យា និងប្រតិបត្តិការ
២៥ រតនាគារ និងទីផ្សារ
២៦ សវនកម្មផ្ទៃក្នុង
២៦ នីតិកម្ម និងលេខាធិការក្រុមហ៊ុន
២៧ បទពិសោធន៍សេវាកម្មអតិថិជន
២៨ គ្រប់គ្រងផលិតផល
២៩ ប្រតិបត្តិតាម

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បំពេញតម្រូវការដល់ពាណិជ្ជកររបស់ធនាគារ ដោយផ្តល់ជូននូវផលិតផលឥណទាន និងប្រាក់បញ្ញើ ព្រមទាំងសេវាកម្មប្រតិបត្តិការ ទៅដល់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជាសហគ្រាសធំៗផងដែរ។ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម គឺជាផ្នែកដ៏សំខាន់មួយនៃសកម្មភាពអាជីវកម្មរបស់ធនាគារ ដែលមានចំណែក ៥៣% នៃឥណទានសរុបរបស់ធនាគារ ២៩% នៃប្រាក់បញ្ញើសរុបរបស់ធនាគារ និង៤៣% នៃចំណូលដុលមុនកាត់ពន្ធរបស់ធនាគារ។

លទ្ធផលហិរញ្ញវត្ថុ និងសមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០១៨

ហិរញ្ញវត្ថុពាណិជ្ជកម្ម បានបង្ហាញនូវកំណើនរឹងមាំ ជាមួយនឹងឥណទាន និងប្រាក់បញ្ញើ ដែលកើនឡើង **៣៨%** និងដែលកើនឡើង **១១%** បើធៀបនឹងឆ្នាំចាស់

អនុបាតគណនីចរន្ត/គណនីសន្សំដ៏រឹងមាំចំនួន **៧២%** គឺជាសញ្ញាបញ្ជាក់ពីការគ្រប់គ្រងតារាងតុល្យការដ៏មានប្រសិទ្ធភាពដែលនាំឲ្យមានការចំណាយថវិកាជារួមក្នុងកម្រិតទាប

គុណភាពទ្រព្យសកម្មរបស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មនៅតែមានភាពរឹងមាំ ដោយរក្សាបានឥណទានមិនដំណើរការត្រឹមតែ **០,២៤%** នាចុងឆ្នាំ២០១៨

ក្នុងឆ្នាំ២០១៨ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មានបុគ្គលិកប្រកបដោយសក្តានុពលសរុប ចំនួន **៤៥**នាក់ រួមមានផ្នែកទំនាក់ទំនងអតិថិជន ត្រួតពិនិត្យឥណទាន និងរដ្ឋបាលឥណទាន។ ជាមួយនឹងការផ្តោតសំខាន់លើការលើកកម្ពស់ការផ្ទេរចំណេះដឹង និងបទពិសោធន៍ ព្រមទាំងដំណើរអភិវឌ្ឍន៍អាជីពយ៉ាងច្បាស់លាស់ យើងបានផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលផ្សេងៗគ្នា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនៅគ្រប់កម្រិត ហើយជាមួយគ្នានេះ យើងសង្កេតឃើញថា សមត្ថភាពរបស់បុគ្គលិកមានការរីកចម្រើន គួរឲ្យកត់សម្គាល់ តាមរយៈការកើនឡើងយ៉ាងរឹងមាំ លើប្រសិទ្ធភាព និងផលិតភាព ហើយបុគ្គលិកដែលមានស្នាដៃឆ្នើម ត្រូវបានដំឡើងតំណែង នៅក្នុងចំណោមក្រុមការងារផងដែរ។

យើងបាននាំយកបណ្តាញទំនាក់ទំនងថ្នាក់តំបន់របស់ ស៊ីអាយអិមប៊ី គ្រុប សម្រាប់ផលប្រយោជន៍ទៅវិញទៅមក រវាងធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា និងទីផ្សារសំខាន់ៗផ្សេងទៀតរបស់ ស៊ីអាយអិមប៊ី គ្រុប នៅក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី វៀតណាម និងថៃ។ ជាមួយនឹងក្របខណ្ឌនេះ យើងបានបង្កើតនូវគុណតម្លៃកាន់តែល្អប្រសើរ សម្រាប់អតិថិជនរបស់យើង ដោយសម្រួលដល់ការស្វែងរកធនធានឆ្លងប្រទេស និងការពង្រីកអាជីវកម្ម សម្រាប់ពួកគេ។

ផែនការសម្រាប់ឆ្នាំ២០១៩

យើងរំពឹងជឿជាក់ថា និន្នាការនៃកំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា នឹងនៅបន្តភាពរីកចម្រើន ក្នុងឆ្នាំ២០១៩ ហើយបង្កើតឱកាសអាជីវកម្មកាន់តែច្រើនថែមទៀត សម្រាប់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងសហគ្រាសធំៗ នៅក្នុងប្រទេស។ ជាមួយនឹងមូលដ្ឋានគ្រឹះដ៏រឹងមាំ និងសមត្ថភាពបុគ្គលិកដ៏ខ្លាំងក្លា យើងបានកំណត់ទិសដៅយ៉ាងច្បាស់លាស់ ក្នុងការបំពេញតម្រូវការរបស់អតិថិជន ខណៈដែលពួកគេត្រូវការពង្រឹង និងពង្រីកអាជីវកម្មរបស់ខ្លួន។

ក្នុងឆ្នាំ២០១៩ យើងនឹងបន្តលើកកម្ពស់សមត្ថភាពក្រុមការងាររបស់យើង ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង នូវសេវាកម្មបម្រើអតិថិជន ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ក៏ដូចជាការអភិវឌ្ឍផលិតភាពជារួម។ យើងនឹងបន្តវិនិយោគលើការអភិវឌ្ឍសមត្ថភាពនិយោជិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងទិសដៅលើកកម្ពស់ជំនាញបន្ថែមទៀត។

ផលិតផលសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មទាំងអស់ រួមមាន៖

- ឥណទានមានកាលកំណត់
- ឥណទានវិបារូបន៍
- ឥណទានសម្រាប់ទុនបង្វិល
- លិខិតធានាពីធនាគារ
- លិខិតឥណទាន
- ផលិតផល និងសេវាកម្មហិរញ្ញប្បទានពាណិជ្ជកម្មផ្សេងៗ
- គណនីចរន្ត
- គណនីបញ្ញើមានកាលកំណត់
- គណនីរូបិយប័ណ្ណបរទេស
- គណនីបញ្ញើទុកក្នុងដៃតតិយជន
- សេវាកម្មប្តូរប្រាក់
- សេវាកម្មប្រតិបត្តិការ

សេវាកម្មហិរញ្ញវត្ថុបុគ្គល

នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល គឺជាគ្រឹះយ៉ាងសំខាន់ សម្រាប់ដំណើរការអាជីវកម្ម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងប្រទេសកម្ពុជា ដែលមានបុគ្គលិកប្រមាណ ៥៣% នៃចំនួនបុគ្គលិកសរុបរបស់ធនាគារ។ នាយកដ្ឋាននេះបម្រើសេវាកម្ម ដល់អតិថិជនគ្រប់ប្រភេទ តាមរយៈផលិតផល និងសេវាកម្មដ៏សម្បូរបែប ដោយផ្តោតលើអតិថិជនទូទៅ និងអតិថិជនជាន់ខ្ពស់។ សេវាកម្មហិរញ្ញវត្ថុបុគ្គល មានបណ្តាញប្រតិបត្តិការ ទាំង១៣សាខា ជាមួយសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម រួមទាំងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ។

សមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០១៨

យើងមានក្តីសោមនស្សរីករាយ ដែលនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១៨ បានឈានមុខគេ លើការផ្តល់ប្រាក់បញ្ញើ និងប្រាក់កម្ចី ហើយយើងបន្តរក្សាចំណែកទីផ្សារនៅក្នុងផ្នែកឥណទានគេហដ្ឋាន ទោះបីជាមានការកើនឡើងនៃការប្រកួតប្រជែងខ្លាំងក៏ដោយ។ យើងសម្រេចបានប្រាក់ចំណេញគួរឲ្យកត់សម្គាល់ ហើយស្របពេលជាមួយគ្នានេះ យើងបានរក្សានូវឥណទានមិនដំណើរការ ឲ្យនៅក្នុងកម្រិតទាបផងដែរ។

សមិទ្ធផលសំខាន់ៗ

- ប្រាក់បញ្ញើកើនឡើង ៤០% ធៀបនឹងឆ្នាំ២០១៧
- ឥណទានគេហដ្ឋានកើនឡើង ៣៣% ធៀបនឹងឆ្នាំ២០១៧
- ប្រាក់ចំណេញមុនកាត់ពន្ធ របស់សេវាកម្មហិរញ្ញវត្ថុបុគ្គល កើនឡើង ២៤% ធៀបនឹងឆ្នាំ២០១៧
- ផ្តល់ជូនផលិតផលឥណទានគេហដ្ឋាន ឥណទានរថយន្ត និងសេវាកម្ម Preferred ឲ្យកាន់តែទាក់ទាញ សម្រាប់អតិថិជន
- កែលម្អផលិតផលឥណទាន និងបញ្ញើ ដើម្បីរក្សាភាពឈានមុខគេ ក្នុងការបំពេញតម្រូវការអតិថិជន ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស
- ផ្តល់ជូនផលិតផល និងសេវាកម្ម កាន់តែមានគុណតម្លៃ ដល់អតិថិជនគ្រប់ប្រភេទ
- ផ្តួចផ្តើមការទទួលយកមតិយោបល់របស់អតិថិជន តាមរយៈកម្មវិធីឌីជីថល នៅតាមបណ្តាញសាខា ដើម្បីភ្ជាប់ទំនាក់ទំនងកាន់តែល្អប្រសើរ ជាមួយនឹងអតិថិជន
- ធ្វើមជ្ឈការ លើកិច្ចប្រតិបត្តិការ ពាក់ព័ន្ធនឹងការអនុលោមតាមច្បាប់ នៅតាមសាខា ដើម្បីកសាងសមត្ថភាព ឲ្យកាន់តែល្អប្រសើរ ប្រកបដោយស្ថិរភាព

ដើម្បីពង្រឹងបន្ថែមនូវចំណេះដឹង និងជំនាញរបស់បុគ្គលិកផ្នែកលក់របស់ធនាគារ យើងបានវិនិយោគបន្ថែមលើកម្មវិធីអភិវឌ្ឍន៍និយោជិត ដែលបុគ្គលិករបស់យើងទាំងអស់បានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលសរុបរបស់ធនាគារ ប្រមាណ ៤០០ម៉ោង ក្នុងឆ្នាំ២០១៨។ វគ្គបណ្តុះបណ្តាលទាំងអស់នោះគ្របដណ្តប់លើការអភិវឌ្ឍចំណេះដឹង និងជំនាញអភិវឌ្ឍន៍ការងារ ដែលរួមមានផ្នែកលក់ និងការបម្រើសេវាកម្មអតិថិជន ការវាយតម្លៃឥណទាន ការគ្រប់គ្រងការហានិភ័យ ការប្រតិបត្តិតាមច្បាប់ ព្រមទាំងប្រព័ន្ធ និងដំណើរការជាដើម។

ផែនការ សម្រាប់ឆ្នាំ២០១៩

យើងមានផែនការ ក្នុងការនាំយកផលិតផល និងសេវាកម្មដ៏ល្អបំផុត ដើម្បីបំពេញតម្រូវការអតិថិជនកាន់តែជិតស្និទ្ធ។ យើងនឹងមានផែនការកែលម្អមួយចំនួន ដែលរួមមានការបន្តបង្កើតផលិតផលថ្មីៗ យុទ្ធនាការផ្នែកលក់ និងកម្មវិធីបទពិសោធន៍សេវាកម្មអតិថិជន។ សម្រាប់ឆ្នាំ២០១៩ ផែនការសំខាន់ៗរបស់យើងនឹងផ្តោតលើចំណុច ដូចខាងក្រោម៖

- បន្តនាំយកផលិតផល និងសេវាកម្ម ប្រកបដោយភាពច្នៃប្រឌិតខ្ពស់
- នាំយកឥណទានបុគ្គល ជាផ្នែកមួយនៃផលិតផលឥណទានរបស់សេវាកម្មហិរញ្ញវត្ថុបុគ្គល ដើម្បីបំពេញតម្រូវការកើនឡើងរបស់អតិថិជន
- សហការជាមួយនឹងអ្នកបង្កើតគម្រោងនានា លើគម្រោងឥណទានគេហដ្ឋាន និងកែលម្អផ្នែកបទពិសោធន៍សេវាកម្មអតិថិជន និងការភ្ជាប់ទំនាក់ទំនង ទៅលើរយៈពេលបំពេញការងារ
- បន្តកែលម្អ និងអភិវឌ្ឍជំនាញរបស់បុគ្គលិក
- បង្កើតកម្មវិធីថែរក្សាទុក និងពង្រីកចំនួនអតិថិជន សម្រាប់គ្រប់ផ្នែកនៃសេវាកម្មហិរញ្ញវត្ថុបុគ្គល ដូចជាឥណទានបុគ្គល ប័ណ្ណឥណទាន និងសេវកម្ម Preferred ។ល។

សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ

សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ ទទួលបន្ទុកលើការទំនាក់ទំនងជាមួយនឹងអតិថិជន ជាក្រុមហ៊ុនរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលរួមមានក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនថ្នាក់តំបន់របស់ ស៊ីអាយអិមប៊ី គ្រប់ដែលកំពុងដំណើរការអាជីវកម្មក្នុងប្រទេសកម្ពុជា។ វិសាលភាពនៃសេវាកម្មប្រតិបត្តិការ គឺពាក់ព័ន្ធនឹងភាពច្នៃប្រឌិតផលិតផល និងសេវាប្រតិបត្តិការ។

សេចក្តីសង្ខេប ក្នុងឆ្នាំ២០១៨

ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតសកលដោយជោគជ័យ ក្នុងឆ្នាំ២០១៨ ដែលជាកត្តាបន្តធានានូវស្ថិរភាព និងមូលដ្ឋានគ្រឹះ សម្រាប់កំណើនសេដ្ឋកិច្ចនាពេលអនាគត។ សេវាកម្មហិរញ្ញវត្ថុ ក៏នៅតែបានបន្តភាពរីកចម្រើនដូចឆ្នាំមុន។ ធនាគារជាតិ នៃកម្ពុជា បានដាក់ចេញបន្ថែម នូវបទប្បញ្ញត្តិផ្សេងៗ ក្នុងគោលបំណងពង្រឹងសុវត្ថិភាព និងភាពរឹងមាំនៃប្រព័ន្ធធនាគារ។

នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបន្តសម្រេចជោគជ័យ សម្រាប់ឆ្នាំ២០១៨ ស្តែងចេញតាមរយៈកំណើនចំណូល ពីការប្រាក់ ២៥% និងកម្រៃជើងសារ ៥១% បើធៀបនឹងឆ្នាំចាស់ រីឯអនុបាតផលធៀបចំណាយ និងចំណូល ត្រឹមតែ ៨% ឥណទានមិនដំណើរការមានកម្រិតសូន្យ ហើយអនុបាតគណនីសន្សំ និងគណនីចរន្ត មានចំនួន ៧៧%។ សមិទ្ធផលនេះបានកើតឡើង តាមរយៈការរួមបញ្ចូលគ្នា នៃការបង្កើនភាពច្នៃប្រឌិត លើគុណភាពផលិតផល និងសេវាកម្ម ព្រមទាំងទំហំគ្របដណ្តប់សេវាកម្ម ក៏ដូចជាការចាប់យកនូវក្រុមអតិថិជន ក្នុងវិស័យថ្មីៗ។

ក្រុមការងាររបស់យើងបានប្រឹងប្រែងបំពេញការងារ ឲ្យអស់លទ្ធភាព ដើម្បីស្វែងយល់ពីការវិវឌ្ឍអាជីវកម្ម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់អតិថិជន ឲ្យកាន់តែស៊ីជម្រៅ។ តាមរយៈការខិតខំប្រឹងប្រែងរបស់ក្រុមការងារយើង និងបណ្តាញដ៏រឹងមាំរបស់ ស៊ីអាយអិមប៊ី ថ្នាក់តំបន់ អតិថិជនរបស់យើងនឹងទទួលបានផលិតផល និងសេវាកម្មដ៏ល្អប្រសើរឥតខ្ចោះ នៅគ្រប់ទីកន្លែង ដែលពួកគេប្រកបអាជីវកម្ម ក្នុងតំបន់អាស៊ាន។

ទស្សនវិស័យ ក្នុងឆ្នាំ២០១៩

ទោះបីជាមានការបញ្ហាប្រឈមមួយចំនួន ដែលបណ្តាលមកពីជម្លោះពាណិជ្ជកម្ម ក្នុងតំបន់ និងលើសកលលោកក៏ដោយ ទស្សនវិស័យ សម្រាប់ប្រទេសកម្ពុជា នៅតែរក្សាភាពរឹងមាំល្អ។ សេដ្ឋកិច្ចរបស់ប្រទេសមានការវិវឌ្ឍល្អប្រសើរ ហើយលំហូរនៃការវិនិយោគពីបរទេសនឹងនៅតែបន្តកើនឡើង។ កម្រិតអតិផរណាទាប ស្ថិរភាពរូបិយប័ណ្ណ តម្រូវការប្រើប្រាស់ផលិតផលក្នុងស្រុក និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលស្ថិតក្នុងបរិបទល្អប្រសើរ សបញ្ជាក់ថាកំណើនសេដ្ឋកិច្ចនឹងបន្តទៅមុខយ៉ាងពិតប្រាកដ។

ផ្អែកលើមូលដ្ឋានគ្រឹះ ដែលបានកសាងឡើងជាច្រើនឆ្នាំកន្លងមកនេះ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ ក៏ដូចជាធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជាទាំងមូល នៅតែរក្សាតួនាទីរបស់ខ្លួន ក្នុងការបំពេញតម្រូវការអតិថិជន និងសេដ្ឋកិច្ចជាតិ។ ការប្តេជ្ញាចិត្តចម្បងរបស់យើង គឺបន្តប្រកាន់ខ្ជាប់ នូវការផ្តល់សេវកម្មធនាគារ ដោយប្រុងប្រយ័ត្ន ដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារអន្តរជាតិ។

ធនធានសាជីវកម្ម

នាយកដ្ឋានធនធានសាជីវកម្ម ទទួលបន្ទុកផ្នែកធនធានមនុស្ស រដ្ឋបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការយុទ្ធសាស្ត្រលទ្ធកម្ម។ តួនាទីសំខាន់របស់ផ្នែកធនធានមនុស្ស គឺរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការអភិវឌ្ឍស្ថាប័ន និងការធ្វើផែនការបុគ្គលិករបស់អង្គភាព / ការគិតគូរពីប្រាក់រង្វាន់ និងការគ្រប់គ្រងការអនុវត្តការងារ / ការសិក្សា និងការអភិវឌ្ឍទេពកោសល្យ / ការកសាងកិត្តិនាមស្ថាប័ន និងការចូលរួមក្នុងកិច្ចការសង្គមនានា ក្នុងនោះផងដែរ ក៏ផ្តោតទៅលើផ្នែករដ្ឋបាល និងគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការលទ្ធកម្មយុទ្ធសាស្ត្រ ចាត់ចែងការងាររដ្ឋបាលទូទៅ ការរៀបចំគម្រោង និងការថែរក្សាទ្រព្យសម្បត្តិក្រុមហ៊ុន រួមទាំងដំណើរការលទ្ធកម្ម/ដេញថ្លៃ និងសន្តិសុខ។

ការអភិវឌ្ឍធនធានមនុស្ស និងទេពកោសល្យ

យើងពេញចិត្តជាមួយការអភិវឌ្ឍទេពកោសល្យ យើងផ្តល់តម្លៃដល់បុគ្គលិកគ្រប់រូប ដែលរួមចំណែកជួយគាំទ្រធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី រហូតដល់មានថ្ងៃនេះ

បណ្តុះទេពកោសល្យ

យើងតែងតែខិតខំទាក់ទាញរក្សា និងបណ្តុះសមត្ថភាពបុគ្គលិករបស់យើង ដើម្បីឲ្យពួកគាត់បានត្រៀមខ្លួនរួចជាស្រេច សម្រាប់អនាគតរបស់ពួកគាត់។ ជាការពិតណាស់ យើងក៏ផ្តល់ឲ្យពួកគាត់ នូវឱកាសនៅខាងក្នុង ឬឆ្លងនាយកដ្ឋាន ទាំងនៅក្នុងស្រុក និងថ្នាក់តំបន់ ដើម្បីបង្កើនលទ្ធភាពដល់និយោជិត ក្នុងការបង្ហាញសមត្ថភាព ទៅតាមបែបបទផ្សេងៗគ្នាដូចជា៖ ផ្តល់នូវសារៈសំខាន់ សម្រាប់ការបង្កើនចំណេះដឹង ការបន្ថែមគុណតម្លៃ ភាពច្នៃប្រឌិត និងការចែករំលែកនៃការអនុវត្តការងារល្អៗ ព្រោះយើងជឿជាក់ថា ការអភិវឌ្ឍនិយោជិត គឺជាមធ្យោបាយដែលល្អបំផុតក្នុងការរក្សាភាពរឹងមាំរបស់ធនាគារក្នុងការប្រកួតប្រជែងដ៏យូរអង្វែង នៅក្នុងទីផ្សារអាជីវកម្មនៅប្រទេសកម្ពុជា។

ភ្ជាប់ទំនាក់ទំនងនិយោជិត

យើងផ្តោតលើការវិនិយោគលើធនធានសំខាន់ៗ ដើម្បីធានាថា និយោជិតរបស់យើង ត្រូវបានជម្រុញឲ្យមានការភ្ជាប់ទំនាក់ទំនងគ្នាគ្រប់ពេលវេលា ជាក់ស្តែងយើងក៏បានរៀបចំជាទៀតទាត់នូវកម្មវិធីជួបជុំគ្នាទាំងផ្លូវការ និងមិនផ្លូវការ ដល់បុគ្គលិកគ្រប់កម្រិត ដើម្បីបង្កើតជាឱកាស សម្រាប់ការផ្តល់ជាមតិយោបល់ទៅវិញទៅមក ក្នុងគោលបំណងដាក់ចេញនូវទិសដៅ និងគោលដៅយុទ្ធសាស្ត្ររួមគ្នា។ យ៉ាងណាមិញកម្មវិធីភ្ជាប់ទំនាក់ទំនងនិយោជិតរបស់យើង គឺរួមមានកិច្ចពិភាក្សាថ្ងៃអង្គារជាមួយបុគ្គលិក វេទិកាពិភាក្សាជាមួយសមាជិកគណៈកម្មាធិការគ្រប់គ្រង កិច្ចស្វាគមន៍របស់ប្រធាននាយកប្រតិបត្តិ ព្រឹត្តិការណ៍ក្រៅផ្លូវការជាមួយប្រធាននាយកប្រតិបត្តិ កិច្ចប្រជុំបង្ហាញលទ្ធផលការងារប្រចាំឆ្នាំ (Town Hall) កម្មវិធីជួបជុំបុគ្គលិកទូទាំងធនាគារ និងកម្មវិធីកីឡា ព្រមទាំងកម្មវិធីកសាងភាពជាក្រុមជាដើម ជាពិសេសយើងក៏បានរៀបចំកម្មវិធីប្រគល់រង្វាន់បុគ្គលិកឆ្នើមប្រចាំត្រីមាស និងបុគ្គលិកឆ្នើមប្រចាំឆ្នាំ ទៅដល់បុគ្គលិកឆ្នើមៗបំផុត នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ក្រៅពីនេះ យើងជឿជាក់ថា និយោជិតដែលមានការភ្ជាប់ទំនាក់ទំនងល្អ គឺជាបុគ្គលិកដែលប្រកបដោយផលិតភាពឆ្នើមផងដែរ។

មានសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់

យើងមានប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារដ៏រឹងមាំជម្រុញដោយសូចនាករអនុវត្តន៍ការងារ (KPI)។ យើងធានាថា សូចនាករអនុវត្តន៍ការងារស្របទៅតាមគោលដៅអាជីវកម្ម និងទិសដៅរបស់ ស៊ីអាយអិមប៊ី គ្រុប។ សូចនាករអនុវត្តន៍ការងារ (KPI) តម្រូវឲ្យមានសមាសធាតុការប្រតិបត្តិតាម(Compliance) និងអភិបាលកិច្ច (Governance) ដែលផ្សារភ្ជាប់ភាពសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់។

លើកកម្ពស់វប្បធម៌ របស់ធនាគារ ស៊ីអាយអិមប៊ី

គុណតម្លៃស្នូលរបស់យើងត្រូវបានចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីលើកតម្កើងឥរិយាបទល្អទាំង៣ «បំពេញភារៈកិច្ចលើសពីការរំពឹងទុក ដើម្បីបំពេញចិត្តអតិថិជន / ភ្ជាប់ទំនាក់ទំនងដោយបើកចំហរ និងធ្វើការរួមគ្នា / គោរព និងតែងតែជួយគាំទ្រគ្នាទៅវិញទៅមក»។ គោលការណ៍ណែនាំនេះអាចជួយដល់បុគ្គលិកយើង ប្រកបការងារកាន់តែមានប្រសិទ្ធភាពទាំងជាមួយក្រុមការងារក្នុងស្រុក និងថ្នាក់តំបន់។ ដើម្បីជម្រុញនូវការប្រកាន់ខ្ជាប់វប្បធម៌របស់ក្រុមហ៊ុន យើងតែងតាំងអ្នកគាំទ្រអាជីវកម្ម និងអ្នកដឹកនាំក្រៅផ្លូវការ នៅតាមអង្គភាពអាជីវកម្មផ្សេងៗគ្នា ដើម្បីលើកទឹកចិត្តដល់បុគ្គលិក ក្នុងការអនុវត្តឥរិយាបទល្អទាំង៣ ហើយសាយភាយវប្បធម៌ល្អប្រពៃនេះ ក្នុងនាមជាអ្នកគម្រូល្អ ទៅដល់បុគ្គលិកដទៃទៀត។

ទីផ្សារ និងទំនាក់ទំនង

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រកម្មវិធីទំនាក់ទំនងរបស់ធនាគារ ដើម្បីលើកកម្ពស់សារតា និងស្លាកសញ្ញា របស់ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា។ នាយកដ្ឋាននេះត្រួតពិនិត្យ លើការទំនាក់ទំនងផ្ទៃក្នុង រវាងនាយកដ្ឋានផ្សេងៗ និងសកម្មភាពទំនាក់ទំនងខាងក្រៅ ដើម្បីជម្រុញការលក់ផលិតផល និងសេវាកម្មរបស់ធនាគារ។ នាយកដ្ឋាននេះ អភិវឌ្ឍ និងលើកកម្ពស់ការកំណត់ទិសដៅស្លាកសញ្ញាធនាគារ និងរបៀបវារៈទំនាក់ទំនង តាមរយៈក្របខណ្ឌចម្រុះមួយ ដែលមានមុខងារផ្សេងៗគ្នា ដូចជាការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ / ទំនាក់ទំនងសាធារណៈ និងសារព័ត៌មាន / គ្រប់គ្រងការឧបត្ថម្ភ និងការរៀបចំកម្មវិធីទីផ្សារ ព្រមទាំងការគ្រប់គ្រងទំនាក់ទំនងផ្ទៃក្នុង។

សមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០១៨

យើងបានកំណត់ទិសដៅយ៉ាងជាក់លាក់ របស់ធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសកម្ពុជា ក្នុងនាមជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ និងជាដៃគូពាណិជ្ជកម្ម ដែលមានមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ នៅក្នុងស្រុក និងមានបណ្តាញដ៏ទូលំទូលាយ នៅទូទាំងតំបន់អាស៊ាន។ ក្រៅពីបង្កើតយុទ្ធសាស្ត្រ ក្នុងការចាក់គ្រឹះអត្តសញ្ញាណ នៅក្នុងស្រុករបស់ធនាគារ ស៊ីអាយអិមប៊ី យើងបានពឹងផ្អែកលើធនធាន ក្នុងតំបន់របស់ ស៊ីអាយអិមប៊ី គ្រុប និងភ្ជាប់សេវាកម្មថ្នាក់តំបន់ដែលសមស្របបំផុតសម្រាប់អតិថិជន ក្នុងប្រទេសកម្ពុជា ដែលរួមមានសេវាកម្មបណ្តាញអេធីអិម ក្នុងតំបន់អាស៊ាន សេវាផ្ទេរប្រាក់តែលេក្រោមក្នុងថ្ងៃតែមួយ សម្រាប់៥ប្រទេស ក្នុងតំបន់អាស៊ាន ព្រមទាំងកម្មវិធីនិងបុព្វសិទ្ធិពិសេសថ្នាក់តំបន់ សម្រាប់ការទិញទំនិញក្នុងហាងការទទួលទានអាហារ និងដំណើរកម្សាន្តជាដើម។ មិនតែប៉ុណ្ណោះ យើងបានផ្សព្វផ្សាយលក្ខណៈស្លាកសញ្ញាថ្មីរបស់ ស៊ីអាយអិមប៊ី គ្រុប គឺ «Forward» ដែលត្រូវបានប្រើប្រាស់រួមគ្នា នៅគ្រប់ទីផ្សារ របស់ ស៊ីអាយអិមប៊ី គ្រុប ដើម្បីបង្ហាញការប្តេជ្ញាចិត្តរបស់ស៊ីអាយអិមប៊ីក្នុងការជម្រុញដល់ការសម្រេចបានគោលដៅ និងបំណងប្រាថ្នារបស់អតិថិជន។

ក្នុងឆ្នាំ ២០១៨ យើងបានដឹកនាំរៀបចំសកម្មភាព និងព្រឹត្តិការណ៍សាធារណៈមួយចំនួន សម្រាប់អតិថិជនទូទៅ និងអតិថិជនជាន់ខ្ពស់របស់ធនាគារ។ យើងបានរៀបចំទិវាថ្លែងអំណរគុណអតិថិជន នៅគ្រប់សាខា ទូទាំងប្រទេស ដែលជាផ្នែកមួយ នៃកម្មវិធីបទពិសោធន៍សេវាកម្មអតិថិជន ដើម្បីភ្ជាប់ទំនាក់ទំនងកាន់តែជិតស្និទ្ធ ជាមួយនឹងអតិថិជន និងបង្ហាញនូវការថ្លែងអំណរគុណ ដែលពួកគេតែងតែបន្តគាំទ្រ ដល់ធនាគារនាពេលកន្លងមក។ មិនតែប៉ុណ្ណោះ យើងបានប្រារព្ធពិធីថ្លែងអំណរគុណ ដល់អតិថិជន Preferred នៅចុងឆ្នាំ២០១៨ ដើម្បីពង្រឹងបណ្តាញទំនាក់ទំនងនិងបង្ហាញការយកចិត្តទុកដាក់មួយកម្រិតទៀតរបស់ធនាគារទៅដល់អតិថិជន។

លើសពីសកម្មភាព លើគម្រោងក្នុងស្រុក យើងបានគាំទ្រដល់ការរៀបចំគម្រោងសំខាន់ៗ ថ្នាក់តំបន់មួយចំនួន របស់ ស៊ីអាយអិមប៊ី គ្រុប ដូចជាកម្មវិធីប្រកួត 3D Conquest ដែលជាកម្មវិធីប្រកួតប្រជែងដំបូងបំផុត តាមបែប Hackathon សម្រាប់និស្សិតសាកលវិទ្យាល័យ ក្នុងប្រទេសកម្ពុជា ទាំងនៅវគ្គប្រកួតក្នុងស្រុក និងថ្នាក់តំបន់ ដើម្បីបង្ហាញនូវទេពកោសល្យ ផ្នែកឌីជីថល និងភាពច្នៃប្រឌិតខ្ពស់របស់ពួកគេ ជាមួយនឹងផ្ទត់គំនិតជាសហគ្រិនឈ្លាសវៃ។ ជារៀងរាល់ឆ្នាំ យើងតែងតែគាំទ្រ ដល់ការរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ និងការចុះផ្សាយព័ត៌មាន អំពីកម្មវិធីអាហារូបករណ៍អាស៊ាន របស់ ស៊ីអាយអិមប៊ី ដោយផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងលើកទឹកចិត្តនិស្សិតខ្មែរក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍ ១០០% នេះនៅតាមសាកលវិទ្យាល័យល្បីឈ្មោះ ជុំវិញពិភពលោក។ ជាលទ្ធផល មាននិស្សិតខ្មែរមួយរូប ដែលទទួលបានអាហារូបករណ៍នេះ ហើយកំពុងសិក្សា នៅសាកលវិទ្យាល័យ McGill ក្នុងប្រទេសកាណាដា។

សម្រាប់ផ្នែកទំនាក់ទំនង ទាក់ទងនឹងផលិតផល និងសេវាម្ម នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្ពោធ និងផ្សព្វផ្សាយផលិតផលថ្មីជាប្រាក់រៀល ទាំងផ្នែកឥណទាន និងប្រាក់បញ្ញើ ដែលជាផ្នែកមួយនៃការគាំទ្រ និងប្តេជ្ញាចិត្តយ៉ាងមុតមាំ ជាមួយធនាគារជាតិ នៃកម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលខ្មែរ ក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ និងធនាគារ។ មិនតែប៉ុណ្ណោះ យើងបានខិតខំបង្កើនការផ្សព្វផ្សាយព័ត៌មានរបស់ធនាគារ ជាមួយនឹងស្ថាប័នសារព័ត៌មាននានា ចាប់ពីសារព័ត៌មានប្រពៃណី រហូតដល់សារព័ត៌មានឌីជីថល ដូចជាកាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍ ព្រមទាំងគេហទំព័រជាដើម។ ជាងនេះទៅទៀត យើងសម្រេចបានការសម្ពោធគេហទំព័រហ្វេសប៊ុកដំបូងបង្អស់របស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ចាប់តាំងពីបើកដំណើរការអាជីវកម្មរបស់ខ្លួន ក្នុងឆ្នាំ២០១០ ដែលជាផ្នែកមួយនៃកម្មវិធីភ្ជាប់ទំនាក់ទំនង ក្នុងបណ្តាញសង្គម ហើយបណ្តាញទំនាក់ទំនងទៅវិញទៅមកថ្មីនេះ បានជួយដល់ធនាគារក្នុងការខិតកាន់តែជិតជាមួយនឹងអតិថិជនថ្មីៗ ដែលជួយពង្រីកដល់ទិសដៅអាជីវកម្មរបស់យើង។

ផែនការអាទិភាព សម្រាប់ឆ្នាំ២០១៩

ឆ្នាំ២០១៩ នឹងជាឆ្នាំដ៏រំភើបរីករាយមួយទៀត សម្រាប់នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ទើបតែបានឈ្នះពានរង្វាន់ជា ធនាគារអន្តរជាតិល្អបំផុត ក្នុងប្រទេសកម្ពុជា ដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធដ៏រឹងមាំ ក្នុងតំបន់អាស៊ាន និងសមិទ្ធផលអាជីវកម្មជាទីគាប់ប្រសើរ ក្នុងឆ្នាំ២០១៨។ តួនាទីដ៏មានវិសាលភាពរបស់យើង គឺណែនាំស្លាកសញ្ញាឡើងវិញ របស់ធនាគារ ស៊ីអាយអិមប៊ី ទៅកាន់ទីផ្សារ ក្នុងនាមជាធនាគារអន្តរជាតិ ដែលអាចជម្រុញឲ្យការតាំងចិត្ត និងគោលដៅ ទាំងផ្ទាល់ខ្លួន និងអាជីវកម្មរបស់អតិថិជនឈានទៅរកភាពជោគជ័យ។ យើងមានបំណងកសាងវត្តមាន នៅលើបណ្តាញអនឡាញ និងកែលម្អគេហទំព័ររបស់ក្រុមហ៊ុន ដើម្បីធ្វើឲ្យរចនាបទ កាន់តែផ្តល់នូវភាពជិតស្និទ្ធ និងភាពងាយស្រួល ដល់អ្នកប្រើប្រាស់ ក្នុងគោលបំណងទាក់ទាញអតិថិជនថ្មីៗ។ ហើយយើងនឹងបន្តពង្រីកកម្មវិធីទំនាក់ទំនងសាធារណៈរបស់ធនាគារ ដោយភ្ជាប់ទំនាក់ទំនងកាន់តែទូលំទូលាយ ជាមួយនឹងស្ថាប័នសារព័ត៌មាននានា។ ស្របតាមគម្រោងថ្នាក់តំបន់ របស់ ស៊ីអាយអិមប៊ី គ្រុប នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នឹងដឹកនាំកែលម្អក្របខណ្ឌទំនាក់ទំនងផ្ទៃក្នុងថ្មីមួយ ដើម្បីធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធទំនាក់ទំនងនៅក្នុងស្រុក និងថ្នាក់តំបន់។

ហិរញ្ញវត្ថុ

នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីរៀបចំ និងអនុវត្តគោលការណ៍ និងនីតិវិធីគណនេយ្យ ដើម្បីឲ្យស្របតាមគម្រូស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ ដែលបានរៀបចំដោយធនាគារជាតិ នៃកម្ពុជា។ នាយកដ្ឋាននេះក៏ដើរតួនាទីគ្រប់គ្រងហិរញ្ញវត្ថុ វិភាគ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុផងដែរ។

នៅក្នុងការរៀបចំគណនេយ្យហិរញ្ញវត្ថុ យើងធានារាល់ដំណើរការគណនេយ្យមានភាពច្បាស់លាស់ តម្លាភាព និងមានការរៀបចំយ៉ាងត្រឹមត្រូវ។ យើងក៏ធានាការប្រតិបត្តិតាមបទប្បញ្ញត្តិគ្រប់ពេលផងដែរ នូវរាល់របាយការណ៍ ដែលតម្រូវដោយបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃកម្ពុជា ក៏ដូចជាការប្រកាសពន្ធជូននាយកដ្ឋានពន្ធដារ និងរៀបចំរបាយការណ៍យ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា សម្រាប់ក្រុមហ៊ុនមេ និងគណៈគ្រប់គ្រងផងដែរ។

សមិទ្ធផលសំខាន់ៗ សម្រាប់ឆ្នាំ ២០១៨

ការធ្វើសវនកម្មពន្ធទូទៅ សម្រាប់ឆ្នាំសារពើពន្ធ ២០១៣ ២០១៤ និង ២០១៥ ត្រូវបានបញ្ចប់ជាស្ថាពរ ដោយមានការរកឃើញតែមួយចំណុចប៉ុណ្ណោះ ទាក់ទងនឹងការចាត់ថ្នាក់អចលនទ្រព្យ។ ក្រុមការងាររបស់យើងបានធ្វើកិច្ចសហការយ៉ាងល្អ ជាមួយមន្ត្រីអគ្គនាយកដ្ឋានពន្ធដារ សម្រាប់កិច្ចការដែលពាក់ព័ន្ធនឹងការផ្តល់ឯកសារគាំទ្រ ការវាយតម្លៃឡើងវិញ លើការប្រកាសពន្ធឆ្នាំមុន ព្រមទាំងការបញ្ជាក់ និងហេតុផលនានា ដែលតម្រូវឲ្យមាន។

យើងបានពឹងផ្អែកលើធនធានរបស់ ស៊ីអាយអិមប៊ី គ្រុប រួមមានគោលការណ៍ និងនីតិវិធី ក៏ដូចជាតម្រូវការគម្រូទិន្នន័យ សម្រាប់ការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (CIFRS) មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ ក្រុមការងារនៃគម្រោងនេះបានសហការគ្នារវាងក្រុមការងារ ផ្នែកហិរញ្ញវត្ថុ (រួមទាំងបុគ្គលិកចូលថ្មី សម្រាប់កាន់ការងារគម្រោងនេះ) និងអ្នកជំនាញ សម្រាប់ការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ មកពីក្រុមការងារ ផ្នែកហិរញ្ញវត្ថុ របស់ ស៊ីអាយអិមប៊ី គ្រុប ក្នុងខែមិថុនា ឆ្នាំ២០១៨ ដើម្បីរៀបចំវិសាលភាព និងគម្រូការងារសម្រាប់ដំណើរការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៨ ការបន្តសាកល្បងត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃពីផលប៉ះពាល់ ទៅលើសមិទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ និងចំណុចខ្វះខាតនានា មុនពេលដាក់ឲ្យអនុវត្ត។

បន្ថែមពីលើការអនុវត្តយន្តការកំណត់តម្លៃសេវាផ្ទេរមូលធនជាប្រាក់ដុល្លារអាមេរិក (USD-FTP) នាពេលបច្ចុប្បន្ន យើងបានប្រើប្រាស់ការកំណត់តម្លៃសេវាផ្ទេរមូលធនជាប្រាក់រៀល (KHR-FTP) ក្នុងដើមឆ្នាំ២០១៨ ដើម្បីគាំទ្រអាជីវកម្មប្រាក់រៀលរបស់ធនាគារ។ វានឹងអនុលោមបានយ៉ាងល្អ តាមក្របខណ្ឌកំណត់តម្លៃសេវាផ្ទេរមូលធនជាប្រាក់ដុល្លារអាមេរិក សម្រាប់វិធីសាស្ត្រ ទាក់ទងនឹងយន្តការកំណត់តម្លៃ និងការទូទាត់។

ដើម្បីអនុលោមតាមការតម្រូវ លើយន្តការកំណត់តម្លៃសេវាផ្ទេរ (Transfer Pricing) កិច្ចព្រមព្រៀងសេវាកម្មមេ (Master Service Agreement) ត្រូវបានបង្កើតឡើង និងព្រមព្រៀងគ្នា លើការគិតកម្រៃអន្តរក្រុមហ៊ុននានា ជាមួយនឹងកិច្ចសម្របសម្រួល ពីក្រុមការងារផ្នែកនីតិកម្ម។

ផែនការ សម្រាប់ឆ្នាំ ២០១៩

ការអនុវត្តលើកដំបូង លើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (CIFRS) មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ នឹងតម្រូវឲ្យមានការបន្តតាមដាន និងពិនិត្យដិតដល់ចំពោះគោលការណ៍ និងនីតិវិធីរបស់ធនាគារ ដើម្បីប្រាកដថាបានអនុលោមតាមបទប្បញ្ញត្តិ ក៏ដូចជាការអនុវត្តល្អបំផុត។ ក្រុមការងារ ផ្នែកហិរញ្ញវត្ថុ នឹងបន្តសហការជាមួយនឹងក្រុមការងារ ផ្នែកបច្ចេកវិទ្យាព័ត៌មាន ដើម្បីអនុវត្តតាមការផ្លាស់ប្តូរនៃតារាងគណនី ក្នុងប្រព័ន្ធគណនេយ្យ និងដើម្បីប្រាកដថា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារ អាចគាំទ្រដល់របាយការណ៍បទប្បញ្ញត្តិបន្ថែមផ្សេងៗទៀត បន្ទាប់ពីការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា។

ការគ្រប់គ្រងដើមទុនបទប្បញ្ញត្តិ សម្រាប់ឆ្នាំ២០១៩ នឹងកាន់តែមានភាពស៊ីជម្រៅជាមួយនឹងការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា និងការអនុវត្តទ្រនាប់ដើមទុនខនសើវេសិន (Regulatory Conservation Capital Buffer) ហើយនឹងទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល (Countercyclical Capital Buffer)។ យើងមានគម្រោងបន្ថែមដើមទុន ថ្នាក់ទី១ និងថ្នាក់ទី២ ដើម្បីបំពេញតម្រូវការបទប្បញ្ញត្តិដើមទុនអប្បបរមា ក៏ដូចជាគាំទ្រការកំណើនអាជីវកម្មស្នូលរបស់ធនាគារ ក្នុងឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់។

ទាក់ទងនឹងតម្រូវការបទប្បញ្ញត្តិ ដើម្បីបង្កើនការប្រើប្រាស់រូបបិយប័ណ្ណប្រាក់រៀល នាយកដ្ឋានហិរញ្ញវត្ថុ នឹងផ្តោតចម្បងលើគម្រោងការងារ ដើម្បីគាំទ្រដល់ការដាក់ឲ្យប្រើប្រាស់នូវសេវាកម្ម និងផលិតផលធនាគារជាប្រាក់រៀល ដែលធនាគារបានគ្រោងទុក សម្រាប់ឆ្នាំ២០១៩ ដែលជាចំណុចចម្បងបំផុត។

ស្របតាមចក្ខុវិស័យរបស់ស៊ីអាយអិមប៊ីគ្រុបផែនការអាជីវកម្មរយៈពេល៥ឆ្នាំ«Forward23» នឹងត្រូវរៀបចំឡើង ដោយមានកិច្ចសហការ ជាមួយនឹងអ្នកជំនាញរបស់ ស៊ីអាយអិមប៊ី គ្រុប សម្រាប់ការអនុវត្តគម្រោងនានារបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ផែនការគម្រោងទាំងអស់នឹងត្រូវបានអនុវត្តគ្រប់នាយកដ្ឋាននានាទាំងផ្នែកអាជីវកម្មនិងផ្នែកគាំទ្រអាជីវកម្មទាំងអស់ ក្នុងអំឡុងកំណើនរយៈពេល៥ឆ្នាំខាងមុខ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ជាមួយនឹងគោលដៅអភិវឌ្ឍន៍របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ឲ្យមានទំហំទីផ្សារកាន់តែធំ គុណភាពសេវាកម្មល្អបំផុត និងជានិយោជកល្អប្រសើរ។

ការអនុវត្តពន្ធអាករលើតម្លៃបន្ថែម (VAT) នឹងនៅតែស្ថិតក្នុងផែនការការងាររបស់យើង ក្នុងឆ្នាំ២០១៩ផងដែរ។ ការអនុវត្តពន្ធអាករលើតម្លៃបន្ថែម នឹងតម្រូវឲ្យមានស្វ័យប្រតិកម្មប្រព័ន្ធ និងការកែលម្អបន្ថែមទៀត នៃដំណើរការរក្សាទុកដាក់ឯកសាររបស់ធនាគារ ដែលនឹងតម្រូវឲ្យមានកិច្ចសហការ ពីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងផ្នែកបម្រើសេវាកម្មអតិថិជន របស់ធនាគារផងដែរ។

ការគ្រប់គ្រងហានិភ័យ

ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័ស នៅក្នុងវិស័យធនាគារ ក្នុងប្រទេសកម្ពុជា ការផ្លាស់ប្តូរ លើតម្រូវការបទប្បញ្ញត្តិនៅកម្រិតសាកល និងហានិភ័យថ្មីៗ ដែលបានកើតឡើងពីទស្សនវិស័យនៃការអនុលោមតាមច្បាប់ និងបច្ចេកវិទ្យា ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតនូវក្របខណ្ឌគ្រប់គ្រងហានិភ័យដ៏រឹងមាំ ដើម្បីគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធឲ្យបានល្អប្រសើរ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាត់ទុកថា ការគ្រប់គ្រងហានិភ័យ គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់អាជីវកម្មរបស់ធនាគារ ហើយធនាគារក៏បានបញ្ចូល វប្បធម៌ហានិភ័យដ៏រឹងមាំ ទៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យបានចូលរួមតាំងពីដំណាក់កាលដំបូងនៃដំណើរការនៃការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ សម្រាប់ការវាយតម្លៃផលិតផលថ្មី ការកំណត់យុទ្ធសាស្ត្រ ការវាយតម្លៃឥណទាន និងផ្នែកដទៃទៀត។

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលជាផ្នែកមួយ នៃ ស៊ីអាយអិមប៊ី គ្រុប បានប្រើប្រាស់ក្របខណ្ឌ គ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់សហគ្រាសទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន។ ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅ សម្រាប់សហគ្រាសទាំងមូល ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ខ្លួននូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រងហានិភ័យដែលមានស្រាប់ និងហានិភ័យដែលអាចនឹងកើតមាន ដោយធ្វើការពិចារណាទៅលើការកែប្រែនូវទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរយុទ្ធសាស្ត្រអាជីវកម្ម បញ្ញត្តិច្បាប់ និងសកម្មភាពការងារ ។

គណៈកម្មាធិការហានិភ័យ គឺជាគណៈកម្មាធិការមួយ ដែលទទួលសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាល និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ។ កិច្ចប្រជុំគណៈកម្មាធិការហានិភ័យបានធ្វើឡើងជារៀងរាល់ខែ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្ត លើរាល់សកម្មភាពក្នុងការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

គណៈកម្មាធិការឥណទានកម្ពុជា ធ្វើរបាយការណ៍ជូនគណៈកម្មាធិការហានិភ័យ នូវរាល់បញ្ហាទាក់ទងនឹងឥណទានរបស់ធនាគារ។ គណៈកម្មាធិការឥណទានកម្ពុជា រៀបចំកិច្ចប្រជុំពិភាក្សាជារៀងរាល់សប្តាហ៍ ដោយទទួលបានសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាល ក្នុងការពិចារណា និងការសម្រេចលើសំណើរឥណទាន។

ហានិភ័យឥណទាន

ហានិភ័យឥណទាន និងសមភាគី សំដៅដល់លទ្ធភាពនៃការខាតបង់ ដោយសារអតិថិជនដែលមានបំណុលជាមួយធនាគារ ឬដៃគូទីផ្សារ ឬអ្នកចេញមូលបត្រ បរាជ័យក្នុងការបំពេញកាតព្វកិច្ចក្នុងការទូទាត់សងមកធនាគារវិញតាមការសន្យា។ហានិភ័យឥណទានដែលបានផ្តល់ដោយធនាគារ ត្រូវបានគ្រប់គ្រងដោយគោលនយោបាយហានិភ័យឥណទាន គោលការណ៍គោលនយោបាយឥណទាន (CPG) / នីតិវិធីឥណទាន (CPM) និងច្បាប់ជំនួញឥណទាននីមួយៗ។

ធនាគារបានប្រើប្រាស់ សូចនាករផ្តល់សញ្ញាជាមុន (Early Warning Indicator) រួមទាំងក្របខណ្ឌបញ្ជីតាមដាន (Watchlist frameworks) ជាវិធានការត្រៀមទុកជាមុនសម្រាប់គ្រប់គ្រងហានិភ័យឥណទាន ដែលអាចចង្អុលបង្ហាញនូវភាពចុះខ្សោយនៃឥណទានពីដំណាក់កាលដំបូង ដើម្បីកាត់បន្ថយការខាតបង់ឥណទានដែលអាចកើតមានឡើង។

ដើម្បីប្រាកដថា សំណើសុំឥណទានទាំងអស់ពិតជាទទួលបានការវាយតម្លៃឯករាជ្យ ការអនុម័តឥណទានទាំងអស់ទាមទារការបោះឆ្នោតសម្រេចចិត្ត ពីបុគ្គលវាយតម្លៃហានិភ័យ។ ធនាគារក៏បានអនុវត្តក្របខណ្ឌអ្នកជំនាញវាយតម្លៃរួមគ្នា ដោយផ្តល់សិទ្ធិអំណាច ដល់គណៈគ្រប់គ្រងបុគ្គល ក្នុងការអនុម័តពាក្យស្នើសុំឥណទាន ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ពួកគេ។ ផ្នែកគ្រប់គ្រងឥណទាន ត្រូវបានបង្កើតឡើងក្រោមនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីបំពេញតួនាទីឯករាជ្យ ក្នុងការវាយតម្លៃសំណើសុំឥណទាន។

ទំហំឥណទាន ត្រូវបានតាមដានយ៉ាងសកម្ម ត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ និងរាយការណ៍ជូនគណៈកម្មាធិការហានិភ័យជារៀងរាល់ខែ។ ភាពអន់ថយនៃឥណទាន ត្រូវបានកំណត់សម្គាល់ វិភាគ និងពិភាក្សា ជាមួយនឹងអង្គភាពអាជីវកម្មដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការកែលម្អឲ្យបានសមស្រប។

ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព កើតឡើងនៅពេលដែលធនាគារពុំមានលទ្ធភាព ក្នុងការបំពេញតម្រូវការថវិកា នាពេលបច្ចុប្បន្ន និងពេលអនាគត ឬ មិនអាចបំពេញកាតព្វកិច្ចនិយ័តកម្ម នៅពេលដល់ការកំណត់។ វាអាចធ្វើឲ្យប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃយ៉ាងធ្ងន់ធ្ងរ នឹងអាចបង្កឲ្យមានការខាតបង់។ តួនាទីចម្បងរបស់ធនាគារ គឺការប្រើប្រាស់ប្រាក់បញ្ញើរយៈពេលខ្លីដើម្បីផ្តល់ជាឥណទានរយៈពេលវែង ដូច្នេះធ្វើឲ្យធនាគារងាយនឹងរងគ្រោះដោយសារហានិភ័យសន្ទនីយភាព។ ជាងនេះទៅទៀត ធនាគារ ត្រូវតែប្រតិបត្តិអាជីវកម្មរបស់ខ្លួនស្របទៅតាមតម្រូវការបទប្បញ្ញត្តិគ្រប់ពេលវេលា។

ហានិភ័យសន្ទនីយភាពជាបឋមត្រូវបានធ្វើការតាមដាន និងគ្រប់គ្រងដោយផ្អែកលើមូលដ្ឋាននៃការព្យាករណ៍លំហូរសាច់ប្រាក់របស់ធនាគារ គឺតាមរយៈការព្យាករណ៍ឲ្យបានទៀងទាត់ទៅលើលំហូរសាច់ប្រាក់របស់ធនាគារ ដែលកើតឡើងពី ទម្រង់កាលកំណត់នៃទ្រព្យសកម្ម បំណុល កាតព្វកិច្ចក្រៅតារាងតុល្យការ និងនិស្សន្ទវត្ថុទៅតាមរយៈពេលផ្សេងៗគ្នា ស្ថិតក្រោមស្ថានភាពអាជីវកម្មធម្មតា និងស្ថានភាពមានវិបត្តិ។

ធនាគារក៏បានធ្វើស្ត្រេសតេស្ត (Stress Test) ជារៀងរាល់ឆមាស រួមមានស្ត្រេសតេស្តទៅលើសន្ទនីយភាព ដើម្បីកំណត់ផ្នែកដែលងាយរងគ្រោះទៅលើទំហំសន្ទនីយភាព និងដើម្បីប៉ាន់ស្មានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងបង្កភាពងាយស្រួលដល់គណៈគ្រប់គ្រងរបស់ធនាគារចាត់វិធានការទុកជាមុន។

នាយកដ្ឋានគ្រប់គ្រងហានិភ័យទទួលខុសត្រូវ ចំពោះការត្រួតពិនិត្យតាមដានដោយឯករាជ្យលើទម្រង់ហានិភ័យសន្ទនីយភាពរបស់ធនាគារ និងរៀបចំរបាយការណ៍ប្រចាំខែ ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលទ្រព្យសកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ វាមានសារៈសំខាន់ សម្រាប់ធនាគារក្នុងការគ្រប់គ្រងស្ថានភាពសន្ទនីយភាពរបស់ខ្លួន ដើម្បីអាចបំពេញតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការផ្នែកច្បាប់ដែលមានចំពោះហានិភ័យឥណទាន ដែលបានកំណត់ផងដែរ។

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺរួមមានហានិភ័យ លើការខាតបង់ដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីកង្វះខាត ឬភាពបរាជ័យនៃដំណើរការផ្ទៃក្នុង បុគ្គលិក ប្រព័ន្ធកុំព្យូទ័រ និងកត្តាពីខាងក្រៅ។

ហានិភ័យប្រតិបត្តិការ ត្រូវបានបញ្ចូលជាផ្នែកមួយដ៏សំខាន់ ដល់ការវាយតម្លៃហានិភ័យ ទាក់ទងនឹងផលិតផល សេវាកម្ម ដំណើរការផ្ទៃក្នុង និងប្រព័ន្ធនៅក្នុងធនាគារ។

គំនិតផ្តួចផ្តើមជាច្រើនត្រូវបានធ្វើឡើង ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ លើសមត្ថភាពនៃប្រព័ន្ធ ការគ្រប់គ្រងទិន្នន័យ និងការគ្រប់គ្រងផ្ទៃក្នុង។

យុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺផ្តោតលើក្របខណ្ឌគ្រង់គ្រងហានិភ័យដ៏រឹងមាំ ដែលផ្តល់នូវគោលការណ៍ណែនាំរួម ជាមួយនឹងរចនាសម្ព័ន្ធអភិបាលកិច្ចដ៏ល្អប្រសើរមួយ ដើម្បីបណ្តុះនូវវប្បធម៌គ្រប់គ្រងហានិភ័យមួយ តាមបែបបុរេសកម្មគ្រប់ពេលជានិច្ច។

ផ្នែកគ្រប់គ្រងហានិភ័យប្រតិបត្តិការ តែងធ្វើការណែនាំផ្តល់យោបល់ និងតាមដានលើគ្រប់នាយកដ្ឋានទាំងអស់ ដើម្បីធានាឲ្យបានថា គោលការណ៍ និងនីតិវិធី ដែលបានកំណត់ ត្រូវបានអង្កេតលើគ្រប់គម្រោងទាំងអស់ និងស្ថិតនៅក្នុងដំណើរកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ។ ផ្នែកគ្រប់គ្រងហានិភ័យប្រតិបត្តិការក៏ធានាឲ្យបាននូវការអនុលោមតាមច្បាប់បទបញ្ជា ដែលមានស្រាប់ត្រូវបានអង្កេតយ៉ាងតឹងរឹង។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារសំដៅទៅលើហានិភ័យ ដែលធ្វើឲ្យខាតបង់ដោយសារការប្រែប្រួលលើតម្លៃមូលធន អត្រាការប្រាក់លើទីផ្សារ ភាគរយនៃប្រាក់ចំណេញ ឥណទាន អត្រាប្តូរប្រាក់បរទេស តម្លៃទំនិញ ព្រមទាំងសូចនាករផ្សេងៗ ដែលតម្លៃត្រូវបានកំណត់នៅក្នុងទីផ្សារសាធារណៈ។

សកម្មភាពទូទៅរបស់ធនាគារ ដែលរួមមានការផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើ ជាមួយនឹងកាលបរិច្ឆេទកំណត់ និងអត្រាការប្រាក់ខុសៗគ្នា បានបណ្តាលឲ្យធនាគារពុំអាចចៀសផុត ពីហានិភ័យអត្រាការប្រាក់បានឡើយ។

ហានិភ័យអត្រាការប្រាក់ ជាចម្បងបណ្តាលមកពីកាលបរិច្ឆេទ និងការកំណត់តម្លៃខុសៗគ្នា នៃលំហូរសាច់ប្រាក់។ ហានិភ័យអត្រាការប្រាក់ នាពេលបច្ចុប្បន្នត្រូវបានវាស់វែងដោយរបាយការណ៍គម្លាត វេទយិតភាព នៃអត្រាការប្រាក់។ នាយកដ្ឋានគ្រប់គ្រងហានិភ័យទទួលខុសត្រូវ លើការត្រួតពិនិត្យឡើងវិញ ដោយឯករាជ្យ និងតាមដានទម្រង់ហានិភ័យអត្រាការប្រាក់របស់ធនាគារ ដោយផ្អែកលើរបាយការណ៍គម្លាតវេទយិតភាពនៃអត្រាការប្រាក់។

បច្ចេកវិទ្យា និងប្រតិបត្តិការ

នាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការមានតួនាទីផ្តល់សេវាកម្ម ច្ចេកវិទ្យាព័ត៌មាន និងគាំទ្រដល់ប្រតិបត្តិការរបស់ធនាគារទាំងមូល។ នាយកដ្ឋានមានរចនាសម្ព័ន្ធប្រតិបត្តិការ ស្របទៅតាម CIMB Group Technology & Operations (GTO)។ នាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការ ធ្វើការរាយការណ៍ ដោយផ្ទាល់ទៅថ្នាក់ដឹកនាំរបស់ធនាគារ និងបន្តទៅ Group Technology & Operations (GTO)។

បច្ចេកវិទ្យា

ក្នុងឆ្នាំ ២០១៨ នេះ ផ្នែកបច្ចេកវិទ្យា បានផ្តោតសំខាន់ លើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធព័ត៌មានវិទ្យារបស់ខ្លួន និងកម្មវិធីប្រព័ន្ធព័ត៌មានវិទ្យាជាច្រើន ឲ្យកាន់តែប្រសើរឡើង។ ស្របពេលដែលអាជីវកម្មរបស់ធនាគារមានភាពរីកចម្រើនគួរឲ្យកត់សម្គាល់ ក្នុងរយៈពេលជាង៨ឆ្នាំកន្លងទៅនេះ ពួកយើងក៏បានធ្វើឲ្យប្រសើរឡើង លើសន្តិសុខប្រព័ន្ធព័ត៌មានវិទ្យា ដូចជា ប្រព័ន្ធប្រតិបត្តិការ ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងកម្មវិធីប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីរក្សាភាពឈានមុខមួយជំហានលើការកើនឡើងនូវតម្រូវការរបស់អតិថិជននិយ័តករនិងភាគីដែលពាក់ព័ន្ធទាំងអស់។ ក្នុងឆ្នាំ ២០១៨ នេះផងដែរ ពួកយើងក៏បានធ្វើគម្រោងសំខាន់ៗ ចំនួន ៤ ដោយជោគជ័យ ដូចជា ទីមួយប្រព័ន្ធទូទាត់រហ័ស ទីពីរកូដនីយកម្មលើការរក្សាទុកនិន្នន័យ ទីបីផលិតផលជារូបិយប័ណ្ណខ្មែរ និងទីបួនការទូទាត់មូលប្បទានបត្រដោយស្វ័យប្រវត្តិ។ ទន្ទឹមគ្នានេះដែរ គម្រោងប្រព័ន្ធផ្ទេរប្រាក់អន្តរជាតិដោយស្វ័យប្រវត្តិ (SWIFT) និង Cambodian Shared Switch (CSS) ក៏កំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ និងត្រូវដាក់ឲ្យដំណើរការក្នុងពេលឆាប់ៗនេះដើម្បីជួយសម្រួលការងារដល់ផ្នែកប្រតិបត្តិការឲ្យមានប្រសិទ្ធភាពខ្ពស់ និងបំពេញតាមតម្រូវការរបស់និយ័តករ។

លើសពីនេះទៅទៀត ផ្នែកបច្ចេកវិទ្យា ក៏បានផ្តោតសំខាន់ជាចម្បង លើការធ្វើបច្ចុប្បន្នភាពទៅលើប្រព័ន្ធស្នូលរបស់ធនាគារ (Core Banking System) ទាំងមូល (Hardware and Software) ដែលជាផែនការយុទ្ធសាស្ត្ររបស់ថ្នាក់ដឹកនាំ ដើម្បីបំពេញ និងធ្វើឲ្យសមស្របតាមផែនការចម្បងរបស់ Group Technology។

ប្រតិបត្តិការ

ផ្នែកប្រតិបត្តិការទទួលបន្ទុកលើការធានាឲ្យបានថាប្រតិបត្តិការប្រចាំថ្ងៃ ដែលធ្វើនៅផ្នែកបម្រើសេវាកម្មអតិថិជន ត្រូវបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ និងរហ័ស។ តួនាទីរបស់ផ្នែកប្រតិបត្តិការគ្របដណ្តប់លើសេវាកម្មផ្ទេរប្រាក់ក្នុងប្រទេស និងក្រៅប្រទេស ការទូទាត់មូលប្បទានបត្រ ការគ្រប់គ្រងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ ការគ្រប់គ្រងសាច់ប្រាក់ដោយប្រព័ន្ធមជ្ឈការ សេវាបើកប្រាក់បៀវត្ស និងសេវាធនាគារតាមប្រព័ន្ធអ៊ីនធើណេត សេវាទូទាត់ប្រាក់ ប្រតិបត្តិការហិរញ្ញប្បទានពាណិជ្ជកម្ម ប្រតិបត្តិការរតនាគារជាតិ និងសេវារៀបចំឯកសារឥណទាន ព្រមទាំងសេវាបញ្ចេញឥណទាន។

ការផ្តោតសំខាន់របស់ផ្នែកប្រតិបត្តិការ នៅឆ្នាំ ២០១៨ គឺការពង្រឹងប្រសិទ្ធភាពការងារផ្ទៃក្នុង និងការផ្តល់សេវាកម្ម ដោយលុបបំបាត់ចន្លោះប្រហោងក្នុងការធ្វើប្រតិបត្តការ ការធ្វើដោយដៃ និងគោលការណ៍ផ្សេងៗ។ ការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃក្រុមបញ្ចេញឥណទាន ពីពីរក្រុមទៅជាមួយក្រុម បានជួយកាត់បន្ថយពេលវេលានៃការបញ្ចេញឥណទាន និងបង្កើនផលិតភាពការងារជាច្រើន។ ដំណើរការផ្ទៀងផ្ទាត់មួយចំនួនត្រូវបានប្រែក្លាយទៅជាស្វ័យប្រវត្តិ ដែលធ្លាប់តែអនុវត្តដោយដៃពីមុនមក។ លើសពីនេះទៀត ការអភិវឌ្ឍការត្រួតពិនិត្យ Watch-list ជាបណ្តុំនៃប្រតិបត្តិការ បានជួយសម្រួល និងបង្កើនផលិតភាព ដល់ផ្នែកប្រតិបត្តិការ និងសាខាជាច្រើន។ ជាចុងក្រោយ ការធ្វើឥណពន្ធជាបណ្តុំលើមូលប្បទានបត្រ ដោយស្វ័យប្រវត្តិ ត្រូវបានអនុវត្តដើម្បីឆ្លើយតបទៅនឹងកំណើនចំនួនប្រតិបត្តិការ ការលូតលាស់នៃអាជីវកម្ម និងរយៈពេលកំណត់របស់និយ័តករក្នុងការទូទាត់។

អភិបាលកិច្ចហានិភ័យ

មុខងារអភិបាលកិច្ចហានិភ័យ គឺជាមុខងារឯករាជ្យមួយត្រូវបានបង្កើតឡើង នៅក្នុងនាយកដ្ឋាន បច្ចេកវិទ្យា និងប្រតិបត្តិការ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ ឬរកចំណុចដែលខ្វះខាតដែលអាចបង្កឲ្យមានហានិភ័យជាយថាហេតុ និងធានាឲ្យបាននូវប្រតិបត្តិការគោរព ទៅតាមគោលការណ៍ដែលបានចែងប្រកបដោយនិរន្តរភាព។ លើសពីនេះទៅទៀត មុខងារអភិបាលកិច្ចហានិភ័យ ផ្តល់សេវាកម្មប្រឹក្សាយោបល់ទៅលើគម្រោងគ្រប់គ្រងការបន្តដំណើរអាជីវកម្ម (Business Continuity Management) និងការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

ក្នុងឆ្នាំ ២០១៨ នេះ គម្រោងព្រាងទុកចម្បងចំនួន ៤ និងគម្រោងមិនបានព្រាងទុកចំនួន ៥ ត្រូវបានធ្វើឡើងដោយឯករាជ្យដោយក្រុមអភិបាលកិច្ចហានិភ័យ ហើយក្រុមអភិបាលកិច្ចហានិភ័យ ក៏បានដាក់ស្នើគម្រោងកាត់បន្ថយហានិភ័យរយៈពេលវែង និងគម្រោងយុទ្ធសាស្ត្រ ដើម្បីពង្រឹង និងគាំទ្រដល់ការអនុវត្តការប្រតិបត្តិតាម (Compliance) របស់នាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការ និងការត្រៀមខ្លួនរួចជាស្រេចសម្រាប់តម្រូវការសវនកម្មទៅលើលើហានិភ័យ និងអភិបាលកិច្ច នៅក្នុងនាយកដ្ឋានរបស់ខ្លួន។

ក្រុមអភិបាលកិច្ចហានិភ័យ បានដឹកនាំ និងដើរតួនាទីជាអ្នកទាក់ទងចំណុចកណ្តាលដើម្បីជួយសម្របសម្រួលនិងរៀបចំលើអភិបាលកិច្ចទិន្នន័យជារួមរបស់ធនាគារ CIMB ទាំងមូល និងសកម្មភាពនានាទាក់ទងនឹងការគ្រប់គ្រងទិន្នន័យ ដែលគ្រប់នាយកដ្ឋានទាំងអស់ក្នុងធនាគារត្រូវទទួលយកការវាស់វែងបន្ថែម និងមានម្ចាស់ការលើខ្លួនឯង ដើម្បីធ្វើឲ្យប្រសើរឡើងនូវភាពត្រឹមត្រូវរបស់ទិន្នន័យ និងសន្តិសុខទិន្នន័យស្របតាមកំណើននៃតម្រូវការរបស់និយ័តករ។ ការងារចម្បងធំៗចំនួនពីរក៏ត្រូវបានធ្វើឡើង ក្នុងធនាគារទាំងមូលផងដែរ ដូចជា ទីមួយការចាត់ថ្នាក់ និងការបិទស្លាកលើទិន្នន័យ ទីពីរសន្ធានុក្រមអាជីវកម្មដើម្បីបំពេញតាមតម្រូវការរបស់ Group Data Governance (GDG) និងក្របខណ្ឌប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS)។

រតនាគារ និងទីផ្សារ

នាយកដ្ឋានរតនាគារ និងទីផ្សារ នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដោយមានកិច្ចសហការពីអង្គភាពអាជីវកម្មផ្សេងទៀត បានផ្តល់ជូននូវដំណោះស្រាយឆ្លងតំបន់ ទៅឲ្យអតិថិជនទាំងក្នុង និងក្រៅស្រុក សម្រាប់តម្រូវការពាណិជ្ជកម្ម វិនិយោគ និងហិរញ្ញវត្ថុ ដែលរួមមានប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស សម្រាប់ការទូទាត់ភ្លាមៗ និងការព្រមព្រៀងទុកមុន / ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស និងសេវាផ្ទេរប្រាក់ក្រៅប្រទេសជាដើម។ នាយកដ្ឋានរតនាគារ និងទីផ្សារ ទទួលបន្ទុកលើការគ្រប់គ្រងមូលនិធិក្រៅប្រទេស សម្រាប់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដើម្បីធានានូវប្រសិទ្ធភាពសន្ទនីយភាព សម្រាប់ធនាគារ និងដើម្បីបែងចែកប្រភពមូលនិធិ ដោយរក្សាទំនាក់ទំនង ជាមួយធនាគារដទៃទៀត នៅលើទីផ្សារ។

ការពិនិត្យមើលសមិទ្ធផល ក្នុងឆ្នាំ២០១៨

ស្របតាមសន្ទុះកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងទំនោរកំណើននៃលំហូរចូលទុនវិនិយោគបរទេស ដូចការបានរំពឹងទុក នាយកដ្ឋានរតនាគារ និងទីផ្សារ សម្រេចបានផែនការប្រចាំឆ្នាំរបស់ខ្លួនដ៏ជោគជ័យមួយ ទាំងផ្នែកទីផ្សារអន្តរធនាគារ និងអាជីវកម្មលក់ដូររូបិយប័ណ្ណបរទេស ដែលបានកើនឡើង តាមរយៈអាជីវកម្មផ្សេងៗទៀតរបស់ធនាគារ។ ដំណើរការអាជីវកម្មរបស់យើងបានធ្វើឡើងក្នុងបរិយាកាសប្រកួតប្រជែងខ្ពស់ ប៉ុន្តែយើងអាចផ្តល់នូវសេវាកម្មរតនាគារពិសេសពីគេ ដោយផ្អែកលើការគាំទ្រ និងបណ្តាញថ្នាក់តំបន់របស់ ស៊ីអាយអិមប៊ី គ្រប់នូវសេវាកម្មដ៏ធំទូលំទូលាយ និងប្រកួតប្រជែង ទៅដល់អតិថិជនរបស់យើង។

ក្នុងមុខងារជាគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល នាយកដ្ឋានរតនាគារ និងទីផ្សារ បានភ្ជាប់ទំនាក់ទំនងយ៉ាងសកម្ម ជាមួយដៃគូទាំងក្នុង និងក្រៅស្រុក ដើម្បីកសាងបណ្តាញទំនាក់ទំនងឲ្យកាន់តែរឹងមាំ និងដើម្បីពង្រីកទំហំពាណិជ្ជកម្ម។ ទាំងអស់នេះបានផ្តល់ឲ្យធនាគារ នូវភាពបត់បែនអាជីវកម្មជាងមុន ដើម្បីស្វែងរកលទ្ធផលកាន់តែល្អប្រសើរ សម្រាប់មូលនិធិដែលលើស ហើយស្របជាមួយគ្នានេះ យើងនៅតែបន្តស្វែងរកឱកាសបង្កើនមូលនិធិបន្ថែមទៀត។ ជាលទ្ធផល ធនាគារបានបន្តចូលរួមចំណែកធ្វើឲ្យប្រសើរឡើង នូវថ្លៃដើមមូលនិធិទាបជាងមុន ដែលបន្ថែមនូវគម្លាតអត្រាការប្រាក់បានខ្ពស់ជាងមុនផងដែរ។ នាយកដ្ឋាននេះបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើផែនការមូលនិធិបម្រុងទុក (CFP) ជាមួយនឹងនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីធ្វើការព្យាករណ៍ និងកំណត់នូវបញ្ហាផ្សេងៗ អំពីមូលនិធិ ដែលអាចកើតមាន ។

ទស្សនវិស័យ និងយុទ្ធសាស្ត្រ ក្នុងឆ្នាំ២០១៩

ស្របគ្នានិងឆ្នាំ២០១៨ យើងជឿជាក់ថា ឱកាសសំខាន់ៗរបស់នាយកដ្ឋានរតនាគារ និងទីផ្សារ នឹងបន្តកើតមានឡើង ពីលំហូរចូលនៃការវិនិយោគបរទេស និងតម្រូវការយ៉ាងច្រើន សម្រាប់ការនាំចេញផលិតផលចម្បងៗរបស់ប្រទេសកម្ពុជា ដែលរួមមានសម្លៀកបំពាក់ ស្បែកជើង កៅស៊ូ អង្ករ និងទំនិញដទៃៗទៀត។ សំខាន់ជាងនេះ ឆ្នាំ២០១៩ ជាឆ្នាំមួយ ដែលធនាគារពាណិជ្ជទាំងអស់ត្រូវប្រតិបត្តិតាមកម្រិតឥណទានជាប្រាក់រៀល ស្មើដប់ភាគរយនៃឥណទានសរុប ដែលតម្រូវតាមធនាគារជាតិ នៃកម្ពុជា ហើយបទបញ្ជានេះ នឹងជម្រុញយ៉ាងខ្លាំងក្លាក្នុងការប្រើប្រាស់ប្រាក់រៀល ក៏ដូចជាទំហំ នៃការប្តូររូបិយប័ណ្ណ នៅក្នុងលំហទីផ្សារអន្តរធនាគារ។

ក្រុមការងារទទួលខុសត្រូវខាងមូលនិធិរបស់យើងនឹងបន្តពង្រឹងសមត្ថភាពឲ្យកាន់តែប្រសើរឡើង និងពង្រីកបណ្តាញដៃគូសហការ ជាមួយស្ថាប័នហិរញ្ញវត្ថុ។ យើងក៏នឹងបន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការមូលនិធិបម្រុងទុកក្នុងការឆ្លើយតបយថាហេតុ ពីតម្រូវការចាំបាច់ ដែលកើតឡើងបន្ទាន់ ហើយត្រូវតែបំពេញឲ្យសមស្របតាមក្របខណ្ឌ នៃការគ្រប់គ្រងហានិភ័យសន្ទនីយភាពរបស់ធនាគារ។ មិនតែប៉ុណ្ណោះ យើងនឹងធ្វើការពង្រីកប្រភពប្រាក់រៀលរបស់ធនាគារ ដើម្បីត្រៀមបម្រុងឲ្យបានគ្រប់គ្រាន់ សម្រាប់ការកើនឡើង លើអាជីវកម្មប្រាក់កម្ចីជាប្រាក់រៀល ដែលបានគ្រោងទុក និងស្របតាមបទបញ្ជារបស់ធនាគារជាតិ នៃកម្ពុជា។

សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវការវាយតម្លៃឯករាជ្យ ទៅលើភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលអនុវត្តដោយគណៈគ្រប់គ្រង។ ការវាយតម្លៃរបស់នាយកដ្ឋាននេះ គឺធ្វើទៅលើស្ថានភាពនៃការត្រួតពិនិត្យរបស់ធនាគារ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យប្រភពព័ត៌មាន ប្រសិទ្ធភាពនៃការទំនាក់ទំនង និងសកម្មភាពគ្រប់គ្រងតាមដាន។ សវនកម្មផ្ទៃក្នុង មានភារកិច្ចរាយការណ៍ដោយផ្ទាល់ ជូនគណៈកម្មាធិការសវនកម្ម និងមានឯករាជ្យភាព ពីផ្នែកប្រតិបត្តិការអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងៗ។

ជាលទ្ធផល នៅក្នុងឆ្នាំ២០១៨ ដោយមានការគាំទ្រពីសវនកម្មផ្ទៃក្នុង នៃ ស៊ីអាយអិមប៊ី គ្រុប នាយកដ្ឋានសវនកម្មផ្ទៃក្នុង សម្រេចបានការងារចំនួន ១៧ គម្រោង ដែលបានគ្របដណ្តប់ផ្នែកសំខាន់ៗ រួមមានសវនកម្មសាខា សវនកម្មនាយកដ្ឋាន ។

ផែនការរបស់យើង ក្នុងឆ្នាំ ២០១៩ គឺបន្តការងារសវនកម្ម តាមរយៈការវាយតម្លៃហានិភ័យរបស់សវនកម្មផ្ទៃក្នុង ព្រមទាំងការស៊ើបអង្កេតចាំបាច់ផ្សេងៗទៀត។

នីតិកម្ម និងលេខាធិការក្រុមហ៊ុន

នាយកដ្ឋាននីតិកម្ម និងលេខាធិការក្រុមហ៊ុន រួមមានផ្នែក នីតិកម្ម និងលេខាធិការក្រុមហ៊ុន។ នាយកដ្ឋាននីតិកម្មត្រួតពិនិត្យលើទិដ្ឋភាពផ្នែកច្បាប់នៃសកម្មភាព ដែលអនុវត្តដោយធនាគារ និងទទួលខុសត្រូវលើការសម្របសម្រួលផ្តល់ដំបូន្មាន និងពិនិត្យមើលលើផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ។

នាយកដ្ឋាននីតិកម្ម ដើរតួនាទីចម្បងក្នុងការផ្តល់ដំបូន្មានផ្នែកច្បាប់ ទៅបុគ្គលិកទាំងអស់នៅក្នុងធនាគារ ក្នុងការអនុវត្តការងាររបស់ពួកគេ ដើម្បីធានាបានថា អត្ថប្រយោជន៍របស់ធនាគារត្រូវបានការពារ ក្នុងការធ្វើអាជីវកម្មលើគ្រប់វិស័យ។ ក្នុងនោះផងដែរ នាយកដ្ឋាននីតិកម្ម បានចាត់ចែងរឿងក្តីតុលាការ ដែលទទួលបានពីនាយកដ្ឋានផ្សេងៗរបស់ធនាគារ រួចហើយសហការជាមួយក្រុមមេធាវីខាងក្រៅ ដើម្បីគ្រប់គ្រងរឿងក្តីឡើងតុលាការ។

ដើម្បីឲ្យស្របជាមួយនឹងអភិបាលកិច្ចល្អ លេខាធិការក្រុមហ៊ុនពួកយើង បន្តផ្តល់ការគាំទ្រ ទៅដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង លើកាតព្វកិច្ច និងទំនួលខុសត្រូវ។ លេខាធិការក្រុមហ៊ុន មានតួនាទីផ្តល់ដំបូន្មានលើការងារអភិបាលកិច្ច រួមមានតម្រូវការផ្នែកច្បាប់ និងបទប្បញ្ញត្តិ ទៅគ្រប់ផ្នែកក្នុងធនាគារ។ លេខាធិការក្រុមហ៊ុនក៏ចូលរួមចាត់ចែងការងារប្រចាំថ្ងៃរបស់ លេខាធិការក្រុមហ៊ុន និងមុខងាររបស់ធនាគារ រួមទាំងនីតិវិធីដែលពាក់ព័ន្ធក្នុងការអនុម័តរបស់អាជ្ញាធរ និងបញ្ញត្តិករ។

នាយកដ្ឋានក៏ចូលរួមធ្វើការងារផ្សេងៗ និងគម្រោងរបស់ធនាគារ ដើម្បីធានាដល់ទំនួលខុសត្រូវរបស់ធនាគារចំពោះបទប្បញ្ញត្តិនានា។

បទពិសោធន៍សេវាកម្មអតិថិជន

នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ត្រូវបានបង្កើតឡើងក្នុង ខែមករា ឆ្នាំ២០១៧ ដើម្បីជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងរួមរបស់ធនាគារ តាមរយៈការផ្តល់ជូននូវសេវាកម្មល្អបំផុត ក្នុងការបំពេញចិត្តអតិថិជន។ នាយកដ្ឋាននេះអនុវត្តវិធីសាស្ត្រនៃការផ្តោតការយកចិត្តទុកដាក់ ទៅលើអតិថិជន ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជន នៅគ្រប់កម្រិត តាមរយៈគ្រប់ភាគីពាក់ព័ន្ធ រួមមានសាខាធនាគារ ការិយាល័យបម្រើសេវាកម្មអតិថិជន ព្រមទាំងអង្គភាពប្រឈមនឹងអតិថិជននានា ដែលមានប្រព័ន្ធឌីជីថល ដូចជាសេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធឺណេត និងគេហទំព័ររបស់ធនាគារ ក៏ដូចជាដំណើរការក្រុមការងារគាំទ្រផ្សេងៗផងដែរ។ ក្រៅពីនេះ នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ធានាថា ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ពង្រឹងការប្តេជ្ញាចិត្តទាំងបីរបស់ខ្លួន ទៅកាន់អតិថិជន រួមមានប្រសិទ្ធភាព និងភាពងាយស្រួល ក្នុងការសហការជាមួយធនាគារ ស៊ីអាយអិមប៊ី ហើយយើងនឹងតែងតែជម្រុញការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន។

នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ក៏ទទួលបន្ទុកផ្នែកគ្រប់គ្រងការគាំទ្រអាជីវកម្មផងដែរ ដោយពិនិត្យមើលភាពស្របគ្នា និងការអភិវឌ្ឍនៃប្រព័ន្ធ ព្រមទាំងដំណើរការបំពេញមុខងារ។ នាយកដ្ឋាននេះជួយគាំទ្រការគ្រប់គ្រងគម្រោង ដល់អង្គភាពអាជីវកម្មទាំងអស់ នៅក្នុងធនាគារ ដោយធានានូវការអនុវត្តគម្រោង តាមកាលកំណត់។

នៅក្នុងឆ្នាំ ២០១៨ នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន សម្រេចបានការអនុវត្តគម្រោងផ្តល់មតិយោបល់របស់អតិថិជន និងគុណភាពបម្រើសេវាកម្មអតិថិជន តាមរយៈការពង្រឹងយន្តការប្រសិទ្ធភាពនៃប្រតិបត្តិការ និងការបង្កើតថ្មី។ យើងបានបញ្ចប់គម្រោងកែលម្អគម្រោងផ្តល់មតិយោបល់របស់អតិថិជន តាមប្រព័ន្ធឌីជីថល ដោយដាក់ឲ្យប្រើឧបករណ៍បង្កប់អេក្រង់ ដើម្បីប្រមូលមិតិយោបល់ជាក់ស្តែង ពីអតិថិជនរបស់យើង នៅតាមសាខាធនាគារ។ មិនតែប៉ុណ្ណោះ នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន នាំយកកម្មវិធីពានរង្វាន់បុគ្គលិកឆ្នើម ផ្នែកសេវាកម្មអតិថិជន ដើម្បីផ្តល់ជូនដល់បុគ្គលិក ដែលបានបង្ហាញអកប្បកិរិយាយកចិត្តទុកដាក់ខ្ពស់ ដល់អតិថិជន ក្នុងបណ្តាធនាគារ ស៊ីអាយអិមប៊ី ក្នុងតំបន់អាស៊ាន រួមមានប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ និងកម្ពុជា។

ផែនការ ក្នុងឆ្នាំ២០១៩ សម្រាប់នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន គឺបន្តកែលម្អដំណើរការនិងប្រព័ន្ធឲ្យកាន់តែល្អប្រសើរ ដើម្បីលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន។

គ្រប់គ្រងផលិតផល

នាយកដ្ឋានគ្រប់គ្រងផលិតផល គឺជាផ្នែកដ៏សំខាន់នៃសកម្មភាពអាជីវកម្មរបស់ធនាគារ។ មុខងាររបស់នាយកដ្ឋាននេះ គឺជួយជំរុញធនាគារឲ្យរក្សាបាននូវភាពប្រកួតប្រជែង និងបន្តបង្កើនចំណែកទីផ្សារ ដោយធ្វើការណែនាំផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន។

ធនាគារ ស៊ីអាយអិមប៊ី ចូលរួមគាំទ្រដល់ការផ្តល់សេវាឥណទានជារូបិយប័ណ្ណជាតិ។ អំឡុងឆ្នាំ២០១៨ យើងបានណែនាំផលិតផលឥណទាន និងប្រាក់បញ្ញើជាប្រាក់រៀល ដែលផ្តល់ឲ្យអតិថិជននូវជម្រើសរូបិយប័ណ្ណក្នុងស្រុកក្នុងកម្រិតល្អប្រសើរ សមស្របនឹងតម្រូវការគ្រប់គ្រងទុនបង្វិល និងតម្រូវការវិនិយោគនៃអាជីវកម្មរបស់ពួកគេ។

នាយកដ្ឋានគ្រប់គ្រងផលិតផល ក៏ទទួលបន្ទុកលើផ្នែកសេវាកម្មធនាគារឌីជីថលផងដែរ ដែលរួមចំណែករក្សានូវភាពប្រកួតប្រជែង នៅក្នុងទីផ្សាររបស់ធនាគារ តាមរយៈការណែនាំ និងលើកកម្ពស់ផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន ស្របតាមការវិវឌ្ឍ ផ្នែកបច្ចេកវិទ្យាទំនើប។ សេវាកម្មធនាគារឌីជីថលគឺរួមមានម៉ាស៊ីនប្រតិបត្តិការដោយខ្លួនឯង ក្នុងប្រទេសកម្ពុជា និងសេវាកម្មបណ្តាញអេធីអិម ថ្នាក់តំបន់ ដែលអនុញ្ញាតឲ្យអតិថិជនរបស់ធនាគារ ស៊ីអាយអិមប៊ី អាចដកប្រាក់ជារូបិយប័ណ្ណក្នុងស្រុក នៅប្រទេសក្នុងតំបន់អាស៊ាន រួមមានប្រទេសម៉ាឡេស៊ី សិង្ហបុរី ថៃ និងឥណ្ឌូនេស៊ី។ នាយកដ្ឋាននេះក៏បានដាក់ឲ្យដំណើរការម៉ាស៊ីនអេធីអិមបន្ថែមទៀតដើម្បីផ្តល់នូវភាពងាយស្រួល ដល់អតិថិជន។ ក្នុងឆ្នាំ២០១៨ នាយកដ្ឋាននេះបានតំឡើងម៉ាស៊ីនអេធីអិម នៅអគារ Exchange Square ផ្សារទំនើបអ៊ីអន សែនសុខ ផ្សារទំនើប Eden Garden និងផ្សារទំនើប The Park Community Mall ផងដែរ។

សម្រាប់ឆ្នាំ២០១៩ នាយកដ្ឋានគ្រប់គ្រងផលិតផលមានគម្រោងបន្ថែមចំនួនម៉ាស៊ីនអេធីអិម ក្នុងរាជធានីភ្នំពេញ និងនៅផ្សារទំនើបម៉ាក្រូ នៅខេត្តសៀមរាបទៀតផង។ ក្នុងឆ្នាំ២០១៩ យើងមានគោលបំណងអភិវឌ្ឍផលិតផលឲ្យកាន់តែប្រកួតប្រជែង និងថ្លៃប្រឹតខ្ពស់ ទាំងលើប្រាក់បញ្ញើ និងឥណទាន ស្របតាមបទពិសោធន៍ល្អបំផុត នៅក្នុងស៊ីអាយអិមប៊ី គ្រុប។ មិនតែប៉ុណ្ណោះ យើងមានគម្រោងពង្រឹងអភិវឌ្ឍន៍នៃសេវាកម្មធនាគារឌីជីថល តាមរយៈបណ្តាញផ្សេងៗគ្នា ដើម្បីអាចទៅដល់អ្នកប្រើប្រាស់កាន់តែច្រើន ស្របតាមការតាំងចិត្តរបស់យើង ក្នុងការជម្រុញកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញចិត្ត និងតម្រូវការរបស់អតិថិជន។

ប្រតិបត្តិតាម

នាយកដ្ឋានប្រតិបត្តិតាម ទទួលបន្ទុក ក្នុងការធានាថា គ្រប់នាយកដ្ឋាន ក៏ដូចជាបុគ្គលិកទាំងអស់នៅក្នុងធនាគារ ដឹងអំពីកាតព្វកិច្ច និងផលប៉ះពាល់នានានៃបទប្បញ្ញត្តិពាក់ព័ន្ធ។ តួនាទីចម្បងរបស់នាយកដ្ឋាននេះ គឺរួមមានការត្រួតពិនិត្យ និងផ្តល់យោបល់ ដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗរបស់ធនាគារ។ សម្រាប់ការត្រួតពិនិត្យលើការប្រតិបត្តិតាម នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យដល់ទីកន្លែង និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការធ្វើតេស្តខ្លួនឯងលើបទប្បញ្ញត្តិនានា ដើម្បីធានាថា រាល់ដំណើរការ និងនីតិវិធីពាក់ព័ន្ធទាំងឡាយ ត្រូវបានអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗដែលពាក់ព័ន្ធ។ មិនតែប៉ុណ្ណោះ នាយកដ្ឋានេះចូលរួមយ៉ាងសកម្ម ជាមួយក្រុមការងារតាមគម្រោងផ្សេងៗ ដើម្បីធានាថាធនាគារបានអនុវត្តគ្រប់គ្រាន់នូវតួនាទីរបស់ធនាគារ ចំពោះបទប្បញ្ញត្តិផ្សេងៗ ដូចជាច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម បទប្បញ្ញត្តិស្តីពីការប្រតិបត្តិតាមពន្ធគណនីបរទេសរបស់សហរដ្ឋអាមេរិក (US Foreign Account Tax Compliance Act (FATCA)) និងបទប្បញ្ញត្តិដទៃទៀត។

នាយកដ្ឋានប្រតិបត្តិតាម បានបំពេញការងារដោយឯករាជ្យ និងរាយការណ៍ដោយផ្ទាល់ ទៅកាន់ក្រុមប្រឹក្សាភិបាលដែលជាអ្នកពិនិត្យមើល និងអនុម័តលើផែនការការងារប្រតិបត្តិតាមប្រចាំឆ្នាំ ដែលស្នើសុំដោយនាយកដ្ឋានប្រតិបត្តិតាម។ ផ្អែកលើគោលនយោបាយនៃការអនុវត្តការប្រតិបត្តិតាម នាយកដ្ឋាននេះ ត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីសម្រាប់ការប្រតិបត្តិតាម និងគោលការណ៍និងនីតិវិធី ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ជាមួយគ្នានេះ នាយកដ្ឋានេះក៏បានសហការជាមួយនឹងនាយកដ្ឋានដទៃទៀត ដើម្បីបង្កើតគោលការណ៍ណែនាំ និងក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗរួមមាន គោលការណ៍ណែនាំអំពីការបើកគណនីធនាគារ គោលការណ៍ណែនាំអំពីការត្រួតពិនិត្យប្រតិបត្តិការដែលមានសញ្ញាប្រុងប្រយ័ត្ន ក្រមសីលធម៌នៃការលក់ផលិតផល និងសេវាកម្ម ។ល។

សមិទ្ធផល ក្នុងឆ្នាំ២០១៨

ក្នុងឆ្នាំ២០១៨ នាយកដ្ឋានប្រតិបត្តិតាម សម្រេចបានការត្រួតពិនិត្យដល់ទីកន្លែង ចំនួន៩ការិយាល័យ។ មិនតែប៉ុណ្ណោះ នាយកដ្ឋាននេះបានបំពេញការត្រួតពិនិត្យឡើងវិញ ចំពោះបទប្បញ្ញត្តិដែលកំពុងអនុវត្តនានា ចំនួន៨ការិយាល័យ ហើយបានបញ្ចប់ការត្រួតពិនិត្យ លើការអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម សម្រាប់សាខាទាំងអស់ យ៉ាងតិចចំនួន២ដង ក្នុងមួយឆ្នាំ។

កម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញ គឺជាផ្នែកផ្តោតសំខាន់គន្លឹះមួយ សម្រាប់នាយកដ្ឋានប្រតិបត្តិតាម។ គ្រប់និយោជិត ដែលទើបចូលបម្រើការងារថ្មីទាំងអស់ តម្រូវឲ្យចូលរួមវគ្គបណ្តុះបណ្តាល ក្នុងអំឡុងពេលបីខែ គិតចាប់ពីថ្ងៃចូលបម្រើការងារនៅធនាគារ ហើយនិយោជិតដែលបានបម្រើការងារស្រាប់ តម្រូវឲ្យចូលរៀនវគ្គសិក្សាតាមប្រព័ន្ធអេឡិកត្រូនិកអំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។ ក្នុងឆ្នាំ២០១៨ នាយកដ្ឋានប្រតិបត្តិតាម បានរៀបចំវគ្គបណ្តុះបណ្តាលដំបូងចំនួន៧លើក ដែលមានការចូលរួមពីនិយោជិតចំនួន ៦៥នាក់ និងវគ្គបណ្តុះបណ្តាលផ្សេងទៀត ចំនួន៧លើក ដែលមាននិយោជិតចំនួន១៥៣នាក់បានចូលរួម។

ផែនការ សម្រាប់ឆ្នាំ២០១៩

គំនិតផ្តួចផ្តើម លើការវាយតម្លៃហានិភ័យ លើការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ស្ថាប័នព្រមទាំងប្រព័ន្ធស្វ័យប្រវត្តិ សម្រាប់ការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ គឺជាផែនការអាទិភាពថ្មី សម្រាប់នាយកដ្ឋានប្រតិបត្តិតាម ក្នុងឆ្នាំ២០១៩។ នាយកដ្ឋាននេះនឹងបន្តដំណើរការត្រួតពិនិត្យដល់ទីកន្លែង លើការអនុវត្តការអនុលោមតាមច្បាប់ និងការត្រួតពិនិត្យ លើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់សាខាទាំងអស់។ នាយកដ្ឋាននេះនឹងបញ្ចប់ការវិភាគ ទៅលើបទប្បញ្ញត្តិ ដែលកំពុងអនុវត្តនានាសម្រាប់នាយកដ្ឋានផ្សេងទៀត ដែលមិនទាន់បានទទួលការវិភាគ។

០៣ អភិបាលកិច្ចធនាគារ

៣២ សេចក្តីថ្លែងការណ៍ស្តីពីអភិបាលកិច្ចធនាគារ

៤១ របាយការណ៍គណៈកម្មាធិការសវនកម្ម

៤៣ សេចក្តីថ្លែងការណ៍ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

៤៧ រចនាសម្ព័ន្ធនៃការគ្រប់គ្រងពីក្រុមហ៊ុនមេ

៤៧ រចនាសម្ព័ន្ធគ្រប់គ្រង

៤៨ របាយការណ៍ព័ត៌មានរបស់ធនាគារ

សេចក្តីថ្លែងការណ៍ស្តីពីអភិបាលកិច្ចធនាគារ

ក្រុមប្រឹក្សាភិបាល មានជំនឿថា អភិបាលកិច្ចធនាគារដ៏រឹងមាំមួយមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការផ្តល់នូវតម្លៃជានិរន្តរ ការលើកកម្ពស់សុចរិតភាពក្នុងការធ្វើធុរកិច្ច និងការរក្សានូវទំនុកចិត្តរបស់វិនិយោគិន ចំពោះធនាគារឆ្ពោះទៅរកការសម្រេចបាននូវគោលដៅ និងទស្សនវិស័យរបស់ធនាគារ។

វប្បធម៌ និងរចនាសម្ព័ន្ធអភិបាលកិច្ច ប្រកបដោយប្រសិទ្ធភាព គឺជាធាតុសំខាន់បំផុត ក្នុងការកំណត់អំពីរបៀបរបប ដែលធនាគារដំណើរការ ហើយថ្នាក់ដឹកនាំធនាគារតែងតែសង្កត់ធ្ងន់លើចំណុចនេះ ក្នុងការណែនាំដល់គ្រប់បុគ្គលិករបស់ខ្លួនទាំងអស់ជាបន្តបន្ទាប់។ ក្របខណ្ឌអភិបាលកិច្ចដែលធនាគារសម្រេចយកត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍នានា និងការអនុវត្តល្អបំផុត ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងការអនុវត្តល្អបំផុតជាលក្ខណៈអន្តរជាតិ ក្នុងអភិបាលកិច្ចធនាគារដែលពាក់ព័ន្ធ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល និងតុល្យភាពនៃក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន ០៧ រូប ដែលរួមមានអភិបាលប្រតិបត្តិចំនួន ០១ រូប និងអភិបាលមិនប្រតិបត្តិចំនួន ០៦ រូប ហើយក្នុងចំណោមអភិបាលទាំងអស់មានអភិបាលចំនួន ០៣ រូប ជាអភិបាលឯករាជ្យ។ ក្រុមប្រឹក្សាភិបាលបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលមានចំនួនអភិបាលឯករាជ្យគ្រប់គ្រាន់ ដែលអាចធ្វើការវិនិច្ឆ័យដោយឯករាជ្យបំផុត នៅក្នុងកិច្ចពិភាក្សានានារបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលក៏គោរពដំណើរការនៃការធ្វើសេចក្តីសម្រេចរួមផងដែរ។

ក្រុមប្រឹក្សាភិបាលទទួលបានអត្ថប្រយោជន៍ ពីការចូលរួមចំណែកនានារបស់អភិបាលមិនប្រតិបត្តិម្នាក់ៗ នៅក្នុងគ្រប់វិស័យទាំងអស់នៃអាជីវកម្មរបស់ធនាគារ។ បន្ថែមពីលើជំនាញ និងបទពិសោធន៍ផ្នែកអាជីវកម្មជាច្រើនឆ្នាំរបស់អភិបាលម្នាក់ៗ អភិបាលមិនប្រតិបត្តិក៏ធ្វើការវិនិច្ឆ័យដោយឯករាជ្យក្នុងកិច្ចពិភាក្សាស្តីពីបញ្ហាយុទ្ធសាស្ត្រ សវនកម្ម ប្រតិបត្តិការ និងហានិភ័យផងដែរ។

រចនាសម្ព័ន្ធ និងសមាភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងប្រកាសរបស់ ធនាគារជាតិ នៃកម្ពុជា។

សមាសភាពក្រុមប្រឹក្សាភិបាល



ដើម្បីធានាឲ្យបាននូវតុល្យភាពនៃអំណាច ការបង្កើននូវគណនេយ្យភាព និងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេច ប្រកបដោយឯករាជ្យភាព នោះតួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាល និងតួនាទីរបស់អភិបាលប្រតិបត្តិ (Executive Director) ត្រូវបានបែងចែក និងដាក់ឲ្យនៅដាច់ពីគ្នា ដោយមានការបែងចែកយ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវរវាងប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិ ដើម្បីចៀសវាងកុំឲ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយអាចត្រួតត្រាលើដំណើរការនៃការធ្វើសេចក្តីសម្រេចបាន។

ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវបានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល គឺ Dato’ Wira Zainal Abidin Mahamad Zain ដែលបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលបន្តពី Dato’ Shaarani Ibrahim នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨។ Dato’ Wira Zainal Abidin Mahamad Zain ទទួលខុសត្រូវលើការដឹកនាំ និងការគ្រប់គ្រងក្រុមប្រឹក្សាភិបាល និងធានាប្រសិទ្ធភាពនៃការបំពេញមុខងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាលបំពេញតួនាទីផ្លូវការជាថ្នាក់ដឹកនាំ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំងអស់ ដឹកនាំការពិភាក្សារវាងអភិបាល ព្រមទាំងតម្រង់ទិសក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងធនាគារផងដែរ។ ប្រធានក្រុមប្រឹក្សាភិបាលធ្វើការសម្របសម្រួលលំហូរព័ត៌មានរវាងគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ព្រមទាំងប្រឹក្សាយោបល់ជាមួយគណៈគ្រប់គ្រង ដើម្បីដាក់ចេញនូវរបៀបវារៈ សម្រាប់កិច្ចប្រជុំក្រុមប្រឹក្សានីមួយៗ។

អភិបាលប្រតិបត្តិ

លោក ប៊ុន យីន ដែលមានសញ្ជាតិខ្មែរ គឺជាប្រធាននាយកប្រតិបត្តិរបស់ធនាគារ ហើយក៏ជាអភិបាលប្រតិបត្តិផងដែរ។ លោកត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងតែងតាំងជាអភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោក ប៊ុន យីន ក៏ជាបុគ្គលដំបូង ដែលដឹកនាំធនាគារបរទេសលំដាប់អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ក្នុងនាមជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យីន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានពិនិត្យឡើងវិញ ជាទៀងទាត់ ដោយពិនិត្យមើលទៅលើវិសាលភាព លក្ខណៈ ភាពខុសប្លែកគ្នា និងការពង្រីកអាជីវកម្មធនាគារ។

ក្រុមប្រឹក្សាភិបាលយល់ឃើញ និងអះអាងថា សមាសភាពក្រុមប្រឹក្សាភិបាលនាពេលបច្ចុប្បន្នមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងអាជីវកម្មទាំងមូលរបស់ធនាគារ។ សមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន បាននាំយកនូវចំណេះដឹង បទពិសោធន៍ និងជំនាញដ៏មានតម្លៃមកកាន់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំធនាគារឆ្ពោះទៅសម្រេចទស្សនវិស័យរបស់ក្រុមហ៊ុនមេ ស៊ីអាយអិមប៊ី គ្រុប (CIMB Group)។

អភិបាលទាំងអស់របស់ធនាគារ សុទ្ធតែបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់ ដើម្បីទទួលបានមុខតំណែងជាអភិបាល ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។ គ្រប់អភិបាលឯករាជ្យទាំងអស់របស់ធនាគារបង្ហាញពីការវិនិច្ឆ័យដោយឯករាជ្យ និងអាចទទួលយកបាន និងមិនចូលរួមក្នុងប្រតិបត្តិការអាជីវកម្មណា ដែលអាចមានផលប៉ះពាល់ ដល់ការវិនិច្ឆ័យ និងការធ្វើសេចក្តីសម្រេចដោយឯករាជ្យរបស់ខ្លួន។

ប្រវត្តិសង្ខេបរបស់អភិបាលម្នាក់ៗ មានបង្ហាញនៅលើទំព័រ ៦២ ដល់ ៧០ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

ក្រមសីលធម៌របស់អភិបាល

ក្រុមប្រឹក្សាភិបាលគោរពតាមវិធាននៃក្រមសីលធម៌ដែលមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា។

អភិបាលធនាគារប្រកាន់ខ្ជាប់នូវក្រមសីលធម៌ដែលជាគោលការណ៍ណែនាំ សម្រាប់ការអនុវត្តនូវបទដ្ឋានក្រមសីលធម៌មួយដ៏ត្រឹមត្រូវ និងការអនុវត្តអាជីកម្ម ប្រកបដោយភាពប្រុងប្រយ័ត្ន ក៏ដូចជាបទដ្ឋានអាកប្បកិរិយា ប្រកបដោយក្រមសីលធម៌ សម្រាប់អភិបាលម្នាក់ៗ ដោយផ្អែកទៅលើគោលការណ៍សុចរិតភាព ការទទួលខុសត្រូវ ភាពស្មោះត្រង់ និងការទទួលខុសត្រូវចំពោះសង្គម។

កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពមួយរបស់ធនាគារ ដែលធ្វើសេចក្តីសម្រេចចុងក្រោយបង្អស់ លើកលែងតែបញ្ហាណា ដែលទាមទារឲ្យមានការអនុម័តយល់ព្រមពីភាគទុនិក។ ក្រុមប្រឹក្សាភិបាល ដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវទាំងស្រុងលើការដឹកនាំ គ្រប់គ្រង ណែនាំ និងត្រួតពិនិត្យ លើគ្រប់ប្រតិបត្តិការទាំងមូលរបស់ធនាគារ និងពង្រឹងបទដ្ឋាននៃគណនេយ្យភាពក្នុងគោលគំនិតជួយដល់គណៈគ្រប់គ្រង ដើម្បីអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវរួម លើការបង្កើតក្របខណ្ឌការងារនៃអភិបាលកិច្ចល្អ នៅក្នុងធនាគារ រាប់បញ្ចូលទាំង ដំណើរការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមច្បាប់។ សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបនាំយកនូវការវិនិច្ឆ័យឯករាជ្យ ចំណេះដឹងផ្សេងៗគ្នា និងបទពិសោធន៍នានា ដើម្បីធ្វើការពិភាក្សាអំពីបញ្ហានានា ទាក់ទងនឹងយុទ្ធសាស្ត្រ ប្រតិបត្តិការ ធនធាន និងការធ្វើអាជីវកម្ម។

ក្រុមប្រឹក្សាភិបាលបានអនុម័ត លើរបៀបវារៈនៃបញ្ហាមួយចំនួនដែលត្រូវបានរៀបចំសម្រាប់សុំការអនុម័តពីក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំង (ក្នុងចំណោមចំណុចផ្សេងៗទៀតជាច្រើន) ការត្រួតពិនិត្យឡើងវិញ និងការយល់ព្រមលើចំណុចដូចខាងក្រោម ៖

- ផែនការយុទ្ធសាស្ត្រ/អាជីវកម្ម និងគម្រោងថវិកាប្រចាំឆ្នាំ។
- ការវិនិយោគថ្មីៗ ការផ្តាច់ខ្លួន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញក្រុមហ៊ុន ការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ រាប់បញ្ចូលទាំងការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ការចូលហ៊ុន ឬសម្ព័ន្ធយុទ្ធសាស្ត្រ ទាំងនៅក្នុងស្រុក និងក្រៅស្រុក។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងភាគលាភបណ្តោះអាសន្ន និងការផ្តល់យោបល់លើភាគលាភចុងក្រោយ ដែលត្រូវចែកជូនភាគហ៊ុនិក នៅមុនពេលផ្សព្វផ្សាយ និងប្រកាសផ្សាយជាសាធារណៈអំពី ការបែងចែកភាគលាភ។
- ការតែងតាំងអភិបាល និងប្រធាននាយកប្រតិបត្តិថ្មី និងការកំណត់ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ ផ្សេងៗរបស់ពួកគាត់។

ការទទួលខុសត្រូវរួមសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល មានដូចខាងក្រោម ៖

- ផ្តល់នូវគោលដៅ និងគោលនយោបាយច្បាស់លាស់ សម្រាប់ឲ្យមន្ត្រីប្រតិបត្តិជាន់ខ្ពស់អនុវត្ត។
- ធានាឲ្យមាននូវការត្រួតពិនិត្យគ្រប់គ្រាន់ ព្រមទាំងមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រាន់ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយរបស់ធនាគារផងដែរ។
- តាមដានអំពីភាពជោគជ័យរបស់គណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ ផែនការ និងគម្រោងថវិកាដែលបានអនុម័តរួច។
- ស្វែងយល់ពីហានិភ័យចម្បងៗ ដែលទាក់ទងនឹងអាជីវកម្មរបស់ធនាគារ និងធានាថាមានប្រព័ន្ធបច្ចេកវិទ្យា ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើហានិភ័យ ប្រកបដោយប្រសិទ្ធភាព ក្នុងទស្សនវិស័យទទួលបានលទ្ធផល និងភាពជោគជ័យរយៈពេលវែង សម្រាប់ធនាគារ។
- តាមដានត្រួតពិនិត្យ និងសិក្សាវាយតម្លៃលើការអភិវឌ្ឍដែលអាចជះឥទ្ធិពល ដល់ផែនការយុទ្ធសាស្ត្រនានារបស់ធនាគារ។
- ពិនិត្យឡើងវិញ លើភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង រាប់បញ្ចូលទាំងប្រព័ន្ធនៃការប្រតិបត្តិតាមវិធានច្បាប់ បទបញ្ញាសារាចរ និងគោលការណ៍ណែនាំនានាជាធរមាន។
- បញ្ចៀសវិវាទផលប្រយោជន៍ និងធានាការផ្សព្វផ្សាយព័ត៌មាន អំពីវិវាទផលប្រយោជន៍ដែលអាចកើតមាន។
- ប្រកាន់ខ្ជាប់ និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីធនាគារ ព្រមទាំងច្បាប់ វិធាន និងបទប្បញ្ញត្តិ ផ្សេងទៀតផងដែរ។

ក្រៅពីការទទួលខុសត្រូវសំខាន់ៗ ដែលបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាភិបាលក៏ប្រគល់ការទទួលខុសត្រូវជាក់លាក់មួយចំនួនឲ្យគណៈកម្មាធិការនានាផងដែរ។ ក្នុងខណៈដែលគណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចពិភាក្សា និងសម្រេចលើបញ្ហាជាក់លាក់ណាមួយ គណៈកម្មាធិការនោះក៏ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសេចក្តីសម្រេច និង/ឬអនុសាសន៍របស់ខ្លួន ហើយការទទួលខុសត្រូវចុងក្រោយ ចំពោះបញ្ហាទាំងអស់នោះនៅតែជារបស់ក្រុមប្រឹក្សាភិបាលទាំងមូល។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការនានាមានបង្ហាញ នៅទំព័រ ៣៥ ដល់ ៤០។

ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល

ធនាគារអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ ដែលជាគណៈកម្មាធិការមួយរបស់ ស៊ីអាយអិមប៊ី គ្រុប ហូលឌីង បើហាដ (CIMB Group Holdings Berhad)។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការនៃក្រុមហ៊ុនមេ ទទួលបន្ទុកកំណត់ និងបញ្ជូនបេក្ខភាពដែលសក្តិសមសម្រាប់តំណែងអភិបាល ទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័តយល់ព្រមលើការតែងតាំង មិនថាសម្រាប់បំពេញតំណែង ដែលទំនេរ ឬបន្ថែមលើតំណែងដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការប្រែប្រួលរបស់ធនាគារ។ មុនពេលផ្តល់អនុសាសន៍ លើការតែងតាំងអភិបាល ទៅក្រុមប្រឹក្សាភិបាល គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេនឹងអនុវត្តការវាយតម្លៃហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយលើបេក្ខភាពជាអភិបាល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនានា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ធនាគារក៏ពិចារណាទៅលើប្រភេទអាជីវកម្មរបស់ធនាគារ និងផ្គូរផ្គងជាមួយសមត្ថភាព និងការរួមចំណែក ដែលរំពឹងទុកពីបេក្ខភាព ដែលទទួលតំណែងនេះផងដែរ។

នីតិវិធីនៃការតែងតាំង ត្រូវធ្វើឡើងស្របតាមប្រកាស និងគោលការណ៍ និងនីតិវិធីរបស់ក្រុមហ៊ុនមេស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលកាន់មុខងារ ដែលមានការទទួលខុសត្រូវសំខាន់របស់ក្រុមហ៊ុន (គោលការណ៍ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប)។ គោលការណ៍នេះ ចែងនូវនីតិវិធីផ្លូវការមួយ សម្រាប់ការតែងតាំងអភិបាល ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ។ បេក្ខភាពនីមួយៗ ត្រូវឆ្លងកាត់ការវាយតម្លៃដែលត្រឹមត្រូវ ហើយគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេត្រូវធ្វើការបញ្ជាក់ថា បេក្ខភាពនោះមានលក្ខខណ្ឌសក្តិសម និងត្រឹមត្រូវសម្រាប់មុខតំណែង ដែលត្រូវតែងតាំង។

គោលការណ៍ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ក៏ចែងអំពីលក្ខណៈវិនិច្ឆ័យមួយចំនួន សម្រាប់ធ្វើការវាយតម្លៃពីភាពសក្តិសមរបស់បេក្ខភាពដែលត្រូវតែងតាំង ដូចខាងក្រោម៖

i. សុចរិតភាព ភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះបុគ្គល ដែលបេក្ខភាពម្នាក់ៗត្រូវមាន ដូចជា មានភាពស្មោះត្រង់ សុចរិតភាព ភាពឧស្សាហ៍ព្យាយាម គំនិតឯករាជ្យ និងមិនលម្អៀង។

ii. សមត្ថភាពដែលបេក្ខជនត្រូវមាន ដូចជា ជំនាញ បទពិសោធន៍ការងារ សមត្ថភាព និងការប្តេជ្ញាចិត្ត ដែលចាំបាច់ ដើម្បីអនុវត្តតួនាទីរបស់ខ្លួន។

iii. សុចរិតភាពផ្នែកហិរញ្ញវត្ថុ ដែលបេក្ខជនត្រូវគ្រប់គ្រងឥណទាន ឬកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនដោយប្រុងប្រយ័ត្នបំផុត។

នីតិវិធីសម្រាប់កំណត់អត្តសញ្ញាណ និងស្នើឈ្មោះបេក្ខជនដោយគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ សម្រាប់ការតែងតាំងតំណែងនេះមាន ០៥ ដំណាក់កាល ដូចខាងក្រោម៖

ក្របខណ្ឌនៃការស្នើឈ្មោះបេក្ខជន

សំណើសុំតែងតាំងអភិបាលថ្មី គឺអាស្រ័យលើការពិនិត្យ និងអនុម័តយល់ព្រមជាមុនរបស់ធនាគារជាតិ នៃកម្ពុជា។

ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងអភិបាលជាថ្មីម្តងទៀត

ជារៀងរាល់ឆ្នាំ នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ១/៣ នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់តំណែងរបស់ខ្លួន ប៉ុន្តែពួកគាត់នៅតែមានសិទ្ធិអាចឈរឈ្មោះ ឲ្យគេបោះឆ្នោតសាជាថ្មីបាន នៅក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ។ បន្ថែមពីលើនេះទៀត លក្ខន្តិកៈធនាគារតម្រូវថា នៅក្នុងរយៈពេល ០៣ ឆ្នាំម្តង អភិបាលទាំងអស់ត្រូវបញ្ចប់ពីមុខតំណែងយ៉ាងហោចណាស់ឲ្យបានម្តង ប៉ុន្តែពួកគាត់នៅមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសរើសសាជាថ្មីបាន នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ត្រូវផ្តល់អនុសាសន៍លើសំណើសុំតែងតាំង និងបោះឆ្នោតជ្រើសរើសអភិបាលសាជាថ្មី ជូនក្រុមប្រឹក្សាភិបាល មុននឹងដាក់ជូនភាគទុនិកអនុម័ត នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។

កិច្ចប្រជុំ និងការផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំជាប្រចាំ ដើម្បីពិភាក្សាលើយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការហិរញ្ញវត្ថុ បញ្ហាដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងអភិបាលកិច្ច ក៏ដូចជារបាយការណ៍ស្តីពីបញ្ហាដែលគណៈកម្មាធិការនីមួយៗបានពិភាក្សាគ្នា។ ក្រុមប្រឹក្សាភិបាលជួបប្រជុំ នៅរៀងរាល់ ០២ ខែម្តង ហើយក្នុងចំណោមរបៀបវារៈទាំងអស់ដែលដាក់ចូលក្នុងកិច្ចប្រជុំដើម្បីទទួលការពិភាក្សា ឬការអនុម័តពីក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាភិបាលពិនិត្យឡើងវិញ លើប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ការគ្រប់គ្រងហានិភ័យ និងរបាយការណ៍ស្តីពីការអនុវត្តបទប្បញ្ញត្តិ និងធ្វើការអនុម័ត លើលទ្ធផលប្រចាំត្រីមាសរបស់ធនាគារ។ ជារៀងរាល់ឆ្នាំ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានកំណត់កាលបរិច្ឆេទទុកមុនរួចជាស្រេច ដើម្បីអាចឲ្យអភិបាលទាំងអស់មានភាពងាយស្រួល ក្នុងការរៀបចំធ្វើកាលវិភាគប្រជុំផ្ទាល់ខ្លួនរបស់អភិបាល។ ឯកសារសម្រាប់កិច្ចប្រជុំដែលមានសំណើ និងរបាយការណ៍ផ្សេងៗទៀតត្រូវបានចែកជូនក្រុមប្រឹក្សាភិបាល ឲ្យបានមុនពេលដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីអាចឲ្យអភិបាលទាំងអស់មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើការវាយតម្លៃ លើសំណើទាំងនោះ ហើយប្រសិនបើចាំបាច់ ស្នើសុំព័ត៌មានបន្ថែម ដើម្បីជួយសម្រួលអភិបាល ក្នុងការបំពេញកាតព្វកិច្ច ប្រកបដោយប្រសិទ្ធភាព។ នីតិវិធីនានាត្រូវបានបង្កើតឡើងទាក់ទងនឹងទម្រង់ ខ្លឹមសារ បទបង្ហាញ និងការចែកជូនឯកសារ សម្រាប់កិច្ចប្រជុំ។ ឯកសារសម្រាប់កិច្ចប្រជុំបញ្ជាក់យ៉ាងច្បាស់ អំពីប្រវត្តិ គោលបំណង បញ្ហាសំខាន់ៗ សនិទានភាព ផលប៉ះពាល់ និងព័ត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងសំណើនីមួយៗ ដើម្បីជួយឲ្យក្រុមប្រឹក្សាភិបាល អាចធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

អភិបាលមានលទ្ធភាពទទួលបានគ្រប់ព័ត៌មានទាំងអស់របស់ធនាគារ។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដែលធ្វើឡើងជាទៀងទាត់ ក្រុមប្រឹក្សាភិបាលទទួលនូវព័ត៌មាន ដែលបានធ្វើបច្ចុប្បន្នភាព អំពីការអភិវឌ្ឍ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក៏ដូចជាទទួលបានផងដែរនូវឯកសារមួយឈុត រាប់បញ្ចូលទាំងរបាយការណ៍ជាទៀងទាត់ស្តីពីការវិវឌ្ឍនៃអាជីវកម្ម និងឯកសារផ្សេងៗសម្រាប់ពិភាក្សា ទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ។

អភិបាលក៏ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមរយៈប្រព័ន្ធទូរស័ព្ទផងដែរ។ រាល់ការពិភាក្សាដេញដោលនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំងការខ្វែងគំនិតគ្នា ត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុនៃដំណើរការពិភាក្សារបស់អភិបាល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបានផ្ញើទៅគណៈគ្រប់គ្រង ក្នុងរយៈពេលមួយថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកិច្ចប្រជុំត្រូវបានបញ្ចប់ ដើម្បីធានាថា សេចក្តីសម្រេច និងការណែនាំផ្សេងៗត្រូវបានអនុវត្តទាន់ពេលវេលា។ សេចក្តីព្រាងកំណត់ហេតុ ត្រូវបានបញ្ជូនទៅអភិបាលទាំងអស់ ដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាសន៍ មុនពេលដាក់បញ្ជូនកំណត់ហេតុចុងក្រោយ ទៅក្នុងរបៀបវារៈ សម្រាប់អនុម័តយល់ព្រម នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលប្រតិបត្តិ ត្រូវធ្វើការពន្យល់ឲ្យបានក្បោះក្បាយ អំពីបញ្ហាសំខាន់ៗ ទាក់ទងនឹងអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។ ប្រធានគណៈកម្មាធិការសវនកម្មផ្តល់សេចក្តីសង្ខេប អំពីរបាយការណ៍សវនកម្មដែលបានពិភាក្សានៅកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ដើម្បីជាកំណត់ត្រា សម្រាប់ក្រុមប្រឹក្សាភិបាល។ លទ្ធផលសវនកម្មសំខាន់ៗដែលធ្វើឡើងដោយសវនករផ្ទៃក្នុងនៃក្រុមហ៊ុនមេ ក៏ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាលផងដែរ ដើម្បីធ្វើការពិភាក្សា និងណែនាំ។ បន្ថែមពីលើនេះទៀត នាយកនៃនាយកដ្ឋានប្រតិបត្តិតាមត្រូវធ្វើសេចក្តីរាយការណ៍ អំពីស្ថានភាពនៃការគោរពច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ និងនីតិវិធីផ្ទៃក្នុង ដែលបានអនុម័តដោយធនាគារ។ គណៈគ្រប់គ្រងក៏ត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញអំពីសំណើ និងឆ្លើយតបសំណួរផ្សេងៗ ដែលក្រុមប្រឹក្សាភិបាលចោទសួរ តាមការចាំបាច់ផងដែរ។ គណៈគ្រប់គ្រងត្រូវចាត់វិធានការជាបន្ទាន់ លើរាល់បញ្ហាដែលលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងត្រូវធ្វើបច្ចុប្បន្នភាពទៅក្រុមប្រឹក្សាភិបាល អំពីស្ថានភាពនៃបញ្ហាទាំងនោះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ឬប្រសិនបើយល់ថា បន្ទាន់ ត្រូវបញ្ជូនតាមការជូនដំណឹង ជាលាយលក្ខណ៍អក្សរ។

អភិបាលណាម្នាក់ ដែលមានជាប់ពាក់ព័ន្ធទទួលបានផលប្រយោជន៍ ពីសំណើណាមួយ ឬប្រតិបត្តិការណាមួយ ត្រូវប្រកាសប្រាប់អំពីផលប្រយោជន៍ ដែលពាក់ព័ន្ធនឹងខ្លួន ហើយត្រូវដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតគាំទ្រសំណើ ឬកិច្ចការដែលបានស្នើនោះ។ នីតិវិធីនេះត្រូវបានកត់ត្រាទុកទាំងស្រុង នៅក្នុងកំណត់ហេតុនៃដំណើរការកិច្ចប្រជុំ។

នៅដើមឆ្នាំហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលពិចារណា លើថវិកាប្រចាំឆ្នាំរបស់ធនាគារ ស្របជាមួយនឹងយុទ្ធសាស្ត្រ និងផែនការរបស់ធនាគារ ដែលបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបចំនួន ០៧ លើក ត្រូវបានរៀបចំឡើង នៅឆ្នាំ២០១៨ ដោយមានវត្តមានរបស់អភិបាល ដូចមានរៀបរាប់ខាងក្រោម៖

អភិបាល	បានចូលរួម	ចំនួនកិច្ចប្រជុំ
Dato' Shaarani Ibrahim*១ ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ	៤	៤
Dato' Wira Zainal Abidin Mahamad Zain*២ ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
បណ្ឌិត ម៉ី កល្យាណ អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
Aisyal Lam Binti Adbullah*៣ អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៣
ប៊ុន យីន អភិបាលមិនឯករាជ្យប្រតិបត្តិ និងជាប្រធាននាយកប្រតិបត្តិ	៧	៧
Dato' Shahrul Nazri Bin Abdul Rahim អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៦	៧
Yong Jiunn Run អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៦	៧
Renzo Christopher Viegas អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៦	៧

*១ *លាលែងពីតំណែងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

*២ *តែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

*៣ *តែងតាំង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

ការបណ្តុះបណ្តាល និងការអភិវឌ្ឍរបស់អភិបាល

កម្មវិធីបណ្តុះបណ្តាលអភិបាល គឺជាដំណើរការដ៏សំខាន់មួយ ក្នុងការតែងតាំងអភិបាលថ្មី ហើយក្រុមប្រឹក្សាភិបាលក៏ត្រូវយកចិត្តទុកដាក់ លើតម្រូវការក្នុងការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ បទដ្ឋានគណនេយ្យ ការប្រែប្រួលហានិភ័យអាជីវកម្ម និន្នាការទីផ្សារ និងការវិវឌ្ឍចុងក្រោយ បញ្ហាប្រឈមសំខាន់ៗ នៅក្នុងទីផ្សារក្នុងស្រុក និងក្នុងតំបន់ និងក្នុងវិស័យធនាគារ។ ក្នុងគោលបំណងនេះ ក្រុមប្រឹក្សាភិបាលធ្វើការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋាន វាយតម្លៃតាមដំណាក់កាល ហើយកំណត់អំពីចំណុច ដែលអាចពង្រីកចំណេះដឹងរបស់អភិបាល អំពីបញ្ហាដែលទាក់ទងនឹងធនាគារ។

វគ្គបណ្ដុះបណ្ដាលដែលអភិបាលបានចូលរួម ដើម្បីអភិវឌ្ឍចំណេះដឹងថ្មីៗ៖

ប្រធានបទ	ប្រភេទវគ្គបណ្ដុះបណ្ដាល	ចំនួនម៉ោង/ថ្ងៃ	ចូលរួមដោយ
Preparation for Corporate Liability on Corruption	សិក្ខាសាលា	១ ថ្ងៃ	Dato' Wira Zainal Abidin Mahamad Zain
Malaysian Code On Corporate Governance 2017, Regulatory Updates; & Financial Statement Fraud and Misstatement 2017	សិក្ខាសាលា	១ ថ្ងៃ	
Audit, Internal Control and Fraud Detection Seminar 2018	សិក្ខាសាលា	១ ថ្ងៃ	
Governance for the Audit Committee Member	កម្មវិធី	១ ថ្ងៃ	
Sustainable Engagement Series for Directors / Chief Executive Officers	កិច្ចពិភាក្សា	១ ថ្ងៃ	
Regulatory Updates Seminar for Director 2018	សិក្ខាសាលា	១ ថ្ងៃ	
Mandatory Accreditation Programme	កម្មវិធី	១ថ្ងៃ កន្លះ	Renzo Christopher Viegas
BNM Governor's Address on the Malaysian Economy & Panel Discussion	កិច្ចពិភាក្សា	២ ម៉ោង	
Digital Leadership Series - The Hybrid Reality: How Emerging Technologies and Their Interaction With Humans Will Impact Us	ស៊េរី	២ ម៉ោង កន្លះ	
Digital Leadership Series 2018 (Session 2) Cultivating A Culture Of Innovations: Winning The New Talent War	ស៊េរី	២ ម៉ោង កន្លះ	
ASEAN Disruptive Leadership Summit 2018	កិច្ចប្រជុំកំពូល	១ ថ្ងៃ	
Government of Malaysia's Investors' Conference	សន្និសីទ	១ ថ្ងៃ	

ក្នុងអំឡុងឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យ ការធ្វើបច្ចុប្បន្នភាពជាទៀងទាត់ លើការវិវឌ្ឍផ្នែកច្បាប់ ការផ្សព្វផ្សាយ ព័ត៌មាន និងបទដ្ឋានគណនេយ្យ អភិបាលកិច្ចក្រុមហ៊ុន និងការអនុវត្តល្អបំផុត ក៏ត្រូវបានផ្ដល់ជូន សម្រាប់អភិបាលផងដែរ។

លេខាធិការក្រុមហ៊ុន

លេខាធិការក្រុមហ៊ុន បង្ហាញពីការគាំទ្រជាបន្តបន្ទាប់ ក្នុងការផ្ដល់យោបល់ និងជួយក្រុមប្រឹក្សាភិបាល លើបញ្ហាដែលទាក់ទងនឹងកិច្ចការរបស់ធនាគារ រាប់បញ្ចូលទាំងបញ្ហា ដែលទាក់ទងនឹងការអនុវត្តស្របតាមបទប្បញ្ញត្តិរបស់ក្រុមហ៊ុន អភិបាលកិច្ចក្រុមហ៊ុន និងការអនុវត្តល្អបំផុតប្រសិទ្ធភាពនៃសាលប្រជុំ និងកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អភិបាល។ ក្នុងអំឡុងឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យ ដំណើរការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ជាមួយនឹងទស្សនៈលើកកម្ពស់ដំណើរការនៃការធ្វើសេចក្ដីសម្រេច និងប្រសិទ្ធភាពនៃមុខងារក្រុមប្រឹក្សាភិបាល។

លេខាធិការក្រុមហ៊ុនធានាថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិកត្រូវបានរៀបចំឡើង ស្របតាមវិធានច្បាប់ និងការអនុវត្តល្អបំផុតរបស់ធនាគារ ហើយធានាថា ការកត់ត្រាដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិកត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុ និងរក្សាទុកបានយ៉ាងល្អ។

លេខាធិការក្រុមហ៊ុន ក្រៅពីចូលរួមជួយការងារប្រធានក្រុមប្រឹក្សាភិបាល ក្នុងការរៀបចំរបៀបវារៈ និងរៀបចំដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិកក៏ត្រូវសម្របសម្រួលការទំនាក់ទំនង និងផ្សព្វផ្សាយសេចក្ដីសម្រេចសំខាន់ៗ និងគោលការណ៍នានា រវាងក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងថ្នាក់គ្រប់គ្រងប្រតិបត្តិជាន់ខ្ពស់ផងដែរ។

អភិបាលទាំងអស់មានលទ្ធភាពពេញលេញ ក្នុងការស្នើយោបល់ពីលេខាធិការក្រុមហ៊ុន និងអាចស្វែងរកការពិគ្រោះ យោបល់បែបវិជ្ជាជីវៈដោយឯករាជ្យ ពីប្រភពខាងក្រៅ ក្រោមបន្ទុកចំណាយរបស់ធនាគារ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នីតិវិធីមួយត្រូវបានអនុម័តឡើង ដើម្បីជួយសម្រួលអភិបាល ក្នុងការស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈ ដោយឯករាជ្យ។

គណៈកម្មាធិការនានា

ក្រុមប្រឹក្សាភិបាល ផ្ទេរការទទួលខុសត្រូវជាក់លាក់ ដល់គណៈកម្មាធិការនានា ដែលរួមមានគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការទាំងនេះធ្វើប្រតិបត្តិការតាមតួនាទី និងកាតព្វកិច្ច ដែលបានកំណត់យ៉ាងច្បាស់លាស់ ដូចមានចែងនៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនីមួយៗ ដែលបានអនុម័តយ៉ាងត្រឹមត្រូវ។

គណៈកម្មាធិការត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីកិច្ចពិភាក្សា សេចក្ដីសម្រេច និងអនុសាសន៍របស់ខ្លួន។ ប្រធានគណៈកម្មាធិការសវនកម្ម និងប្រធានគណៈកម្មាធិការហានិភ័យត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីបញ្ហាដែលបានលើកយកមកពិភាក្សា និងដោះស្រាយនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលបានទទួលស្គាល់ថា ខណៈដែលគណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចធ្វើការពិភាក្សាលើបញ្ហានានា ដែលបានប្រគល់ជូនរាល់សេចក្ដីសម្រេច និង/ឬអនុសាសន៍របស់គណៈកម្មាធិការទាំងនេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ ហើយគណៈកម្មាធិការទាំងនេះ និងក្រុមប្រឹក្សាភិបាល ជារួម ទទួលខុសត្រូវលើភាពជោគជ័យ អាជីវកម្ម យុទ្ធសាស្ត្រ ការគ្រប់គ្រងហានិភ័យ សកម្មភាពប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។

ព័ត៌មានលម្អិតអំពីគណៈកម្មាធិការនានា មានបង្ហាញនៅក្នុងផ្នែកខាងក្រោមជាបន្តបន្ទាប់។

គណៈកម្មាធិការសវនកម្ម

សមាជិកគណៈកម្មាធិការសវនកម្ម សុទ្ធតែជាអភិបាលឯករាជ្យមិនប្រតិបត្តិ ដែលមានចំណេះដឹង និងបទពិសោធន៍ ផ្នែកហិរញ្ញវត្ថុ។

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការសវនកម្ម គឺធានាឲ្យមានការអនុវត្តអភិបាលកិច្ចរបស់ធនាគារបានល្អប្រសើរ ស្របពេលដែលធ្វើការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការផ្សព្វផ្សាយព័ត៌មាន ការគោរពបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ គណៈកម្មាធិការសវនកម្ម ជួបប្រជុំជាប្រចាំ ដើម្បីពិនិត្យលើលទ្ធផលការងារប្រចាំត្រីមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍សវនកម្ម ដែលរាប់បញ្ចូលទាំងការអនុវត្ត ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក៏ដូចជាប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ។

គណៈកម្មាធិការសវនកម្មបានជួបប្រជុំចំនួន ០៦ ដង ក្នុងឆ្នាំ២០១៨ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម៖

សមាជិក	បានចូលរួម	ចំនួនកិច្ចប្រជុំ
បណ្ឌិត **ម៉ី កល្យាណ** ប្រធានគណៈកម្មាធិការសវនកម្ម/អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
Dato' Shaarani Ibrahim*១ អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៣
Dato' Wira Zainal Abidin Mahamad Zain អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
លោកស្រី Aisyah Lam Binti Abdullah*២ អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៣

**១ លាលែងពីតំណែងជាសមាជិក នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

**២ តែងតាំងជាសមាជិក នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម ៖

ចំណុចគន្លឹះ នៃការទទួលខុសត្រូវ	ការទទួលខុសត្រូវ
ការត្រួតពិនិត្យផ្ទៃក្នុង/ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច	ពិនិត្យឡើងវិញ លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងប្រកាសស្តីពី អភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដងនៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។ គ. មើលការខុសត្រូវ លើប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះបានទទួលអំណាចចាំបាច់ ដើម្បីបំពេញការងារឬនៅ។ ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយ ក្នុងការគ្រប់គ្រងការមិនបានអនុវត្តពេញលេញ តាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀត ដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែកដែលទទួលខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។ ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗ រវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផលប៉ះពាល់ដែលការមិនឯកភាពទាំងនោះអាចមានចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្ម ដែលលើកឡើងដោយសវនករ។ ច. ធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្ត ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថារបាយការណ៍របស់សវនករផ្ទៃក្នុង នឹងមិនតម្រូវឲ្យត្រួតពិនិត្យដោយគណៈគ្រប់គ្រងឡើយ។ ឆ. បង្កើតយន្តការដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។ ជ. វាយតម្លៃសកម្មភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេច អំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។ ឈ. អនុម័តលើការតែងតាំង ផ្លាស់ប្តូរ និងបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹង អំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឲ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះបញ្ជាក់ប្រាប់ពីមូលហេតុនៃការលាឈប់។
សវនកម្មខាងក្រៅ	ក. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល លើការតែងតាំង ឬការបញ្ឈប់សវនករខាងក្រៅ។ ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញ ជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានាលើការសម្របសម្រួល ក្នុងករណីមាន ក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃពីទំនាក់ទំនងផ្សេងៗ រវាងសវនករខាងក្រៅ និងធនាគារ)។ ឃ. អនុម័តលើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះអាចនឹងប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។ ង. ធានាថា មានការពិនិត្យច្បាស់លាស់ លើលក្ខខណ្ឌនៃការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីចៀសវាងការប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។ ច. ធានាថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញជាប្រចាំ លើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធនដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។ ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ ជាមួយសវនករខាងក្រៅ និងតម្រូវឲ្យសវនករខាងក្រៅរាយការណ៍មកកាន់គណៈកម្មាធិការសវនកម្ម អំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។ ជ. ពិនិត្យឡើងវិញ លើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្មខាងក្រៅ និងអនុសាសន៍ដែលលើកឡើង ដោយសវនករខាងក្រៅទាន់ពេលវេលា។ ឈ. តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ រួមទាំងជួបប្រជុំជាមួយសវនករខាងក្រៅយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។
លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហានៃការប្រតិបត្តិតាមច្បាប់	ពិនិត្យឡើងវិញ លើលទ្ធផលនៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ ដែលរាយការណ៍ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនកររបស់និយ័តករ។
របាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់លើ៖ • ការផ្លាស់ប្តូរណាមួយ នៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ • បញ្ហាសំខាន់ៗដែលបានលើកឡើង រួមទាំងបញ្ហាទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀបដែលបញ្ហាទាំងអស់ត្រូវបានបង្ហាញ • ការធ្វើសេចក្តីសន្និដ្ឋានពីបញ្ហា ដែលកំពុងកើតឡើង និង • ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត
ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ	ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើងជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹងដល់ក្រុមប្រឹក្សាភិបាល ពីប្រតិបត្តិការទាំងនោះ។
ការពិនិត្យរបាយការណ៍ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគារ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។
ការតាមដានការអនុវត្តតាមគោលនយោបាយទំនាស់ផលប្រយោជន៍	តាមដានការអនុវត្តតាមគោលនយោបាយស្តីទីទំនាស់ផលប្រយោជន៍របស់ធនាគារ
ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង	ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះការរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ
ផ្សេងៗ	ក. ជូនដំណឹងដល់គណៈគ្រប់គ្រងជាន់ខ្ពស់ជាទៀងទាត់ អំពីបញ្ហាដែលប៉ះពាល់ដល់ធនាគារ។ ខ. កោះប្រជុំជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរក្នុងពេលតែមួយ បើយល់ថា ចាំបាច់។ គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានរហ័ស។

គណៈកម្មាធិការហានិភ័យ

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការហានិភ័យ គឺត្រូវធានាថា មុខងារគ្រប់គ្រងហានិភ័យដែលត្រូវបានដាក់បញ្ចូល នៅក្នុងធនាគារ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការហានិភ័យ ត្រូវរាយការណ៍ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យនៅក្នុងធនាគារ។

គណៈកម្មាធិការហានិភ័យបានជួបប្រជុំចំនួន ១២ ដង ក្នុងឆ្នាំ ២០១៨ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម ៖

សមាជិក	បានចូលរួម	ចំនួនកិច្ចប្រជុំ
Dato' Wira Zainal Abidin Mahamad Zain*១ ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
Aisyah Lam Binti Abdullah*១ ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
ប៊ុន យីន ប្រធាននាយកប្រតិបត្តិ	១១	១២
Neoh Sze Ming*២ អនុប្រធាននាយកប្រតិបត្តិ	១០	១១
គៀន វឌ្ឍនា *៣ នាយកគ្រប់គ្រងហានិភ័យ	១០	១១
ហុង ជៀប នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	១០	១២
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	៩	១២
ហេង វិបុត្រ *៤ នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ	១	១
ហេង វុទ្ធី នាយកហិរញ្ញវត្ថុ	១២	១២
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ	១១	១២

**១ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ លោកស្រី Aisyah Lam Binti Abdullah ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការ បន្តពី Dato' Wira Zainal Abidin Mahamad Zain*

**២ លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨*

**៣ តែងតាំងជានាយកគ្រប់គ្រងហានិភ័យ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩*

**៤ តែងតាំងជាសមាជិក នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការហានិភ័យមានដូចខាងក្រោម៖

- បែងចែកដើមទុន ដែលមានហានិភ័យ (Capital-at-Risk) ទៅតាមប្រភេទជំនួញ និងហានិភ័យផ្សេងៗពីគ្នា ដើម្បីធានាថា ការបែងចែកហានិភ័យបានធ្វើគ្រប់គ្រាន់ អនុលោមតាមលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិច្បាប់ និងធានាថាធនាគារមាន ដើមទុនបម្រុងគ្រប់គ្រាន់ ដើម្បីប្រឈមមុខនឹងស្ថានភាពវិបត្តិផ្សេងៗ។
- បង្កើនតម្លៃភាគទុនិក តាមរយៈការវាយតម្លៃលើប្រាក់ចំណេញ និងហានិភ័យ (risk-return profiles) ពីដំណើរការប្រតិបត្តិការ ហើយធានាថាកម្រិតហានិភ័យដែលទទួលយកស្ថិតនៅក្នុងដែនកម្រិតដែលបានកំណត់ដោយ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ។
- ពិនិត្យ និងជូនយោបល់ ដល់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័ត លើគោលការណ៍ និងកម្រិតហានិភ័យ ដែលសមស្រប ដើម្បីរក្សាក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យ ឲ្យស្របតាមផែនការអាជីវកម្មរបស់ធនាគារ ក្របខណ្ឌនៃ EWRM របស់ ក្រុមហ៊ុនមេ និងស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់ ។
- វាយតម្លៃ និងពិនិត្យលើសំណើសុំអនុម័ត សម្រាប់ផលិតផលថ្មី ការវិនិយោគ អាជីវកម្មយុទ្ធសាស្ត្រ និងផលិតផលដែលត្រូវបានកែច្នៃ ដែលត្រូវអនុម័តជាគោលការណ៍ ឬផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័ត។
- ពិនិត្យ និងអនុម័ត លើសំណើកែប្រែនីតិវិធី និងដំណើរការប្រតិបត្តិការ។
- ជំរុញលើការគោរពតាមគោលការណ៍ និងកម្រិតហានិភ័យ ។
- ដាក់ឲ្យប្រើប្រាស់នូវវិធីសាស្ត្រដ៏សមស្រប ដើម្បីកំណត់ និងវាស់វែងហានិភ័យគ្រប់ស្ថានភាព ។
- បង្កើតយុទ្ធសាស្ត្រសម្រាប់វាយតម្លៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ ឲ្យស្ថិតក្នុងកម្រិតមួយដ៏សមស្រប ។
- ពិភាក្សាសម្រេចលើវិធីសាស្ត្រ និងឧបករណ៍ សម្រាប់ធ្វើការវាស់វែង ទៅលើបរិមាណហានិភ័យផ្សេងៗ ដើម្បីសុំការអនុម័ត ពីក្រុមប្រឹក្សាភិបាល ។
- ត្រួតពិនិត្យសមាសធាតុតារាងតុល្យការរបស់ធនាគារ រួមមានឥណទាន និងប្រាក់បញ្ញើ ។
- ធានានូវការប្រកាន់ខ្ជាប់នូវទ្រឹស្តីសន្តនិយម (holistic approach) ក្នុងការគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ តាមរយៈការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ ប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ការគ្រប់គ្រងគម្លាតកម្រិតការប្រាក់ និងមូលធន ។
- ធានាថា ធនាគាររក្សាបាននូវគុណភាពទ្រព្យសកម្ម តាមរយៈការពិនិត្យតាមដានយ៉ាងហ្មត់ចត់លើដំណើរការ និងការអនុម័ត លើឥណទានថ្មីៗ ព្រមទាំងការប្រមូលឥណទានដែលមិនដំណើរការ ។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ អំពីវិធានការសម្រាប់ ការតាមដាន វិធានការទារសំណង ការរៀបចំឡើងវិញនៃ គណនីក្នុងការឃ្លាំមើល (Early Alert Watchlist Account) គណនីយឺតយ៉ាវ (Delinquent Account) ឬគណនីមិនដំណើរការ (Impaired Account) របស់ធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងសម្រេចឲ្យដាក់បញ្ចូលគណនីដំណើរការ ឬគណនីយឺតយ៉ាវ ទៅក្នុងការឃ្លាំមើល សម្រាប់ធ្វើការ តាមដាន និងផ្ទុយមកវិញ។
- សម្របសម្រួលនូវបញ្ហា ដែលពាក់ព័ន្ធទៅនឹងការផ្ទេរគណនី រវាងផ្នែកអាជីវកម្ម និងក្រុមទារសំណង នៅពេលគណនីនោះបានក្លាយជាមិនដំណើរការ និងផ្ទុយមកវិញ។
- ត្រួតពិនិត្យឡើងវិញ លើទ្រព្យសកម្មដំណើរការ ដែលរួមមាន៖
  - គណនីឃ្លាំមើល យឺតយ៉ាវ ឬមិនដំណើរការ
  - សំវិធានធននៃគណនី ដោយអាស្រ័យតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀត និង
  - បញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងគុណភាពទ្រព្យសកម្ម។
- ពិនិត្យឡើងវិញ នូវផែនការបង្ការ (Contingency Plan) និងការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្ម (Business Continuity Management) សម្រាប់អនុវត្ត នៅពេលចាំបាច់ និងស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល ។
- គណៈកម្មាធិការនេះអាចអនុម័ត រាល់ការផ្លាស់ប្តូរសមាជិក នៅក្នុងមុខងារនៃសាជីវកម្ម (corporate function) ដដែល ដោយធ្វើការជូនដំណឹង ទៅកាន់ក្រុមប្រឹក្សាភិបាល។ រីឯរាល់ការការផ្លាស់ប្តូរសមាជិក នៅក្រៅមុខងារនៃសាជីវកម្ម ឬសំណើសុំកែប្រែលើលក្ខន្តិកៈ (Terms of Reference) ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល មុននឹងអនុវត្ត។
- ពិនិត្យឡើងវិញ និងអនុម័ត លើលក្ខន្តិកៈ និងសមាសភាពនៃគណៈកម្មាធិការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គណៈកម្មាធិការហានិភ័យ រួមបញ្ចូលទាំងការតែងតាំង និងការដកចេញនូវសមាជិក និងអ្នកចូលរួមក្នុងគណៈកម្មាធិការទាំងនេះ ។

គណៈកម្មាធិការគ្រប់គ្រងនានា

គណៈកម្មាធិការគ្រប់គ្រង ដូចមានរៀបរាប់ខាងក្រោម ត្រូវបានបង្កើតឡើងដើម្បីជួយការងាររបស់ប្រធាននាយកប្រតិបត្តិ និងគណៈគ្រប់គ្រង លើប្រតិបត្តិការអាជីវកម្មផ្សេងៗ និងជួយគាំទ្រដល់សកម្មភាពនានារបស់ធនាគារ៖

- គណៈកម្មាធិការគ្រប់គ្រង
- គណៈកម្មាធិការឥណទានកម្ពុជា
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងរាយការណ៍ជូនក្រុមប្រឹក្សាភិបាល នូវបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ធនាគារ។

សមាជិក

ប៊ុន យីន ប្រធាននាយកប្រតិបត្តិ	ប្រធាន
Neoh Sze Ming*[១] អនុប្រធាននាយកប្រតិបត្តិ	ប្រធានជំនួស
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ហេង គួរ៉េង នាយករតនាគារ និងទីផ្សារ	សមាជិក
ហុង ជៀប *[២] នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
គៀន វឌ្ឍនា *[៣] នាយកគ្រប់គ្រងហានិភ័យ	សមាជិក
ហេង វុទ្ធី នាយកហិរញ្ញវត្ថុ	សមាជិក
អ៊ុំ ចិន្តាភក្តី នាយកធនធានសាជីវកម្ម	សមាជិក
ហេង វិបុត្រ *[៤] នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ	សមាជិក
អ៊ុក ថានិន *[៥] នាយកគ្រប់គ្រងផលិតផល	សមាជិក

*[១] *លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨*
*[២] *តែងតាំងជានាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម នាថ្ងៃទី ១ ខែមករា ឆ្នាំ២០១៨ និងជាសមាជិក នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨*
*[៣] *តែងតាំងជានាយកគ្រប់គ្រងហានិភ័យ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩*
*[៤] *តែងតាំងជាសមាជិក នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨*
*[៥] *តែងតាំងជាសមាជិក នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងមានដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាជូនប្រធាននាយកប្រតិបត្តិ។
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពប្រតិបត្តិការរបស់នាយកដ្ឋានអាជីវកម្មនីមួយៗ។
- ពិនិត្យរបាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍គ្រប់គ្រងផ្សេងៗទៀតរបស់ធនាគារ។
- បង្កើតយុទ្ធសាស្ត្រ ផែនការអាជីវកម្ម និងផែនការថវិកា សម្រាប់ធនាគារ (រាប់បញ្ចូលទាំងចំណុច ដែលទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន)
- កំណត់ការងារ ដែលទាមទារឲ្យមានការសហការពីនាយកដ្ឋានច្រើន។
- ពិភាក្សាលើច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗ។
- ការងារផ្សេងៗទៀត តាមការណែនាំរបស់ប្រធាននាយកប្រតិបត្តិ។
- ការងារផ្សេងៗទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល/ប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុនមេ។

គណៈកម្មាធិការឥណទានកម្ពុជា

គណៈកម្មាធិការឥណទានកម្ពុជា ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យ នូវរាល់បញ្ហាទាក់ទងនឹងការងារ ឥណទានរបស់ធនាគារ។

សមាជិក

គៀន វឌ្ឍនា *[១] នាយកគ្រប់គ្រងហានិភ័យ	ប្រធាន
ប៊ុន យីន ប្រធាននាយកប្រតិបត្តិ	ប្រធានជំនួស
ហុង ជៀប *[២] នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ចំណាន វនិតា *[២] គ្រប់គ្រងឥណទាន	សមាជិក
John Chuah Keat Kong ទីប្រឹក្សាឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ	សមាជិក
ហុង ប៊ុនរឿត ឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
Chong Kok Ping*[៣] នាយកគ្រប់គ្រងឥណទានថ្នាក់តំបន់	សមាជិក
Hiroshi Kawachi*[៣] នាយកគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ	សមាជិក
Michael Ng Mun Seng*[៣] នាយកវិភាគហានិភ័យឥណទានថ្នាក់តំបន់ស្ដីទី	សមាជិក
Leong Wai Chyi*[៣] ប្រធានក្រុម NBFI Regional GBIL/GCL	សមាជិក

*[១] *តែងតាំងជានាយកគ្រប់គ្រងហានិភ័យ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩*
*[២] *តែងតាំងជាសមាជិក នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨*
*[៣] *តែងតាំងជាសមាជិក នាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩៖ Chong Kok Ping ជាសមាជិកថ្មីមួយរូប និងជាសមាជិក ដែលមានសំឡេងបោះឆ្នោតចាំបាច់ សម្រាប់សំណើឥណទានពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ដែលសំណើឥណទាននោះហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។ Hiroshi Kawachi ជាសមាជិកថ្មីមួយរូប និងជាសមាជិក ដែលមានសំឡេងបោះឆ្នោត សម្រាប់សំណើឥណទានពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងឥណទានពាណិជ្ជកម្មតែប៉ុណ្ណោះ។ Michael Ng Mun Seng ឬ Leong Wai Chyi (សមាជិកជំនួស ក្នុងពេលអវត្តមានរបស់ Michael Ng Mun Seng) មកពីនាយកដ្ឋានយុទ្ធសាស្ត្រ និងវិភាគរបស់ក្រុមហ៊ុនមេ ជាសមាជិកដែលមានសំឡេងបោះឆ្នោត សម្រាប់សំណើឥណទានពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្មតែប៉ុណ្ណោះ។*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការឥណទានមានដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើឥណទនារបស់ធនាគារ ក្នុងកម្រិតកំណត់ឥណទាន ដែលក្រុមប្រឹក្សាភិបាលផ្តល់សិទ្ធិឲ្យ។
- ផ្តល់អនុសាសន៍ សម្រាប់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល លើរាល់សំណើឥណទាន ដែលហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។
- ធានាថាសមតុល្យឥណទានទាំងមូលរបស់ធនាគារ ស្របតាមគោលការណ៍ណែនាំរបស់អាជ្ញាធរបញ្ញត្តិច្បាប់ និងស្របតាម គោលការណ៍ និងនីតិវិធីឥណទាន ដែលបានអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើហ្វាស៊ីលីធីរៀបចំឡើងវិញ និងវិធានការទារសំណង ដែលរួមមានការទូទាត់ សងដោយសម្រុះសម្រួល និងឥណទាន ដែលត្រូវលុបចេញពីបញ្ជី ដែលនឹងត្រូវអនុវត្ត ស្របតាមលក្ខខណ្ឌពិន័យ។
- វាយតម្លៃសមតុល្យហានិភ័យ នៅពេលអនុម័តឥណទាន ដើម្បីធានាថាឥណទាន ដែលផ្តល់ គឺស្ថិតនៅក្នុងហានិភ័យ ដែលអាចទទួលយកបានដោយធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងវាយតម្លៃផលិតផលឥណទានផ្សេងៗរបស់ធនាគារ ដើម្បីធានាថា ផលិតផលទាំងនោះ ត្រូវបានអនុវត្តតាមបទដ្ឋាន និងគោលការណ៍ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តចំណាត់ថ្នាក់ឥណទានផ្ទៃក្នុងរបស់អ្នកខ្ចីម្នាក់ៗ តាមដែលអាចអនុវត្តបាន។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ អំពីការកែប្រែ ឬវិសោធនកម្មក្នុងគោលការណ៍ឥណទាន និងគោលការណ៍ណែនាំ សម្រាប់ការអនុម័តរបស់គណៈកម្មាធិការនានា ដែលពាក់ព័ន្ធ។
- អនុម័តការតែងតាំងដៃគូវិជ្ជាជីវៈ ដូចជាមេធាវី ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ។
- បំពេញមុខងារដទៃទៀត តាមការណែនាំរបស់គណៈកម្មាធិការហានិភ័យ។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍ទៅគណៈកម្មាធិការហានិភ័យ អំពីហានិភ័យសន្ទនីយភាព និងបញ្ហានានា ដែលទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មជួបប្រជុំចំនួន ១៤ ដង ក្នុងឆ្នាំ២០១៨។

សមាជិក

ប៊ុន យីន ប្រធាននាយកប្រតិបត្តិ	ប្រធាន
Neoh Sze Ming*១ អនុប្រធាននាយកប្រតិបត្តិ	សមាជិក
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ហុង ជៀប *២ នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
ហេង វុទ្ធី នាយកហិរញ្ញវត្ថុ	សមាជិក
ហេង តូរ៉ង់ នាយករតនាគារ និងទីផ្សារ	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ	សមាជិក
គៀន វឌ្ឍនា *៣ នាយកគ្រប់គ្រងហានិភ័យ	សមាជិក

**១ លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨*

**២ តែងតាំងជាសមាជិក នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨*

**៣ តែងតាំងជានាយកគ្រប់គ្រងហានិភ័យ នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩*

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មមានដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញ និងវិភាគផែនការតារាងតុល្យការ តាមផ្នែកអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអកម្មចម្រុះ រូបិយប័ណ្ណ ភាពរីកចម្រើន និងប្រាក់ចំណេញ។
- ត្រួតពិនិត្យឡើងវិញ អំពីភាពខុសគ្នារវាងតារាងតុល្យការជាក់ស្តែង ធៀបនឹងផែនការ ដែលអាចប៉ះពាល់ទៅលើឥណទាន និងបញ្ញើ អនុបាតផ្សេងៗរបស់តារាងតុល្យការ ផែនការហិរញ្ញប្បទាន និងថាតើធនាគារនៅតែបន្តអនុវត្តក្នុងកម្រិតហានិភ័យ ដែលបានកំណត់ឬទេ។
- ត្រួតពិនិត្យឡើងវិញ អំពីចំណូលការប្រាក់សុទ្ធ និងនិន្នាការ ដោយរួមបញ្ចូលការព្យាករណ៍ស្ថានភាព និងភាពខុសគ្នាពីផែនការចំណូលការប្រាក់សុទ្ធ និងធ្វើការលម្អិត អំពីសកម្មភាពដែលបានតម្រូវ ឲ្យបានត្រឹមត្រូវ។
- ត្រួតពិនិត្យឡើងវិញ អំពីផលប៉ះពាល់លើប្រាក់ចំណេញ ទាំងក្នុងករណីសេដ្ឋកិច្ចធម្មតា និងក្នុងករណីមានវិបត្តិសេដ្ឋកិច្ចផ្សេងៗ។
- ត្រួតពិនិត្យឡើងវិញ និងធានាថា ថ្លៃចំណាយលើហិរញ្ញប្បទាន ឬការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន (បើមាន) គឺត្រឹមត្រូវ និងធ្វើជាអាជ្ញាកណ្តាល រវាងផ្នែកអាជីវកម្មទាំងអស់ក្នុងការរៀបចំ និងការអនុវត្តការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន និងលើកកម្ពស់តម្លាភាព ក្នុងធនាគារ។
- ត្រួតពិនិត្យឡើងវិញ អំពីផែនការយថាភាពនៃហិរញ្ញប្បទាន ដែលត្រូវបានចាត់ទុកថាផែនការប្រតិបត្តិការនៃអាជីវកម្ម និងសិក្សាលទ្ធភាព ដើម្បីធានាថា សកម្មភាពដែលតម្រូវដោយអ្នកគ្រប់គ្រងអាចអនុវត្តទៅបាន។
- ធានាថាសូចនាករគ្រើនរំលឹកមុន ត្រូវបានធ្វើបច្ចុប្បន្នភាព និងសមស្រប យោងតាមទិន្នន័យដែលមានជាក់ស្តែង។
- ត្រួតពិនិត្យលើក្របខណ្ឌគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ដើម្បីធានាថាវាសមស្របតាមទំហំ និងភាពស្មុគស្មាញនៃប្រតិបត្តិការរបស់ធនាគារ នាពេលបច្ចុប្បន្ន និងអនាគត។
- លើកកម្ពស់ភាពស្របគ្នា រវាងគោលការណ៍ និងការអនុវត្ត នៅក្នុងធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ លើចំណាត់ការគ្រប់គ្រង (Management Action Triggers «MAT») ឬដែនកំណត់ សម្រាប់ហានិភ័យសន្ទនីយភាព និងហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- កំណត់ ពិនិត្យតាមដាន និងត្រួតពិនិត្យឡើងវិញ លើយុទ្ធសាស្ត្រជម្លៀស របស់ធនាគារ (បើមាន)។
- ត្រួតពិនិត្យឡើងវិញ និងធានាថាទម្រង់ហានិភ័យរបស់ធនាគារ គឺស្ថិតនៅក្រោមចំណាត់ការគ្រប់គ្រង (Management Action Triggers «MAT») ឬដែនកំណត់នៃហានិភ័យសន្ទនីយភាព និងហានិភ័យអត្រាការប្រាក់ នៅក្នុងបញ្ជីធនាគារ (IRRBB) រួមទាំងលទ្ធផលពិសោធន៍ផ្ទៃក្នុង ពេលមានវិបត្តិដោយរូបិយប័ណ្ណគោល។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍គម្រូប៉ារ៉ាម៉ែត្រហានិភ័យគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងលទ្ធផលនៃការបញ្ជាក់ជាគម្រូ ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- កំណត់ និងត្រួតពិនិត្យឡើងវិញ លើសន្ទនីយភាពរបស់ធនាគារ តម្រូវការហិរញ្ញប្បទាន និងការអនុវត្តសមស្របតាមតម្រូវការទាំងនេះ។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ក្របខណ្ឌគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើវិធីសាស្ត្រ និងបទដ្ឋានគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម (បើមាន) ដើម្បីគោរពតាមគោលការណ៍ ដែលបានអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័ត លើវិធីសាស្ត្រ គោលការណ៍ ក្របខណ្ឌនៃថ្លៃចំណាយ លើហិរញ្ញប្បទាន ឬការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន។
- អនុម័តលើសំណើតម្លៃផ្អែកលើសិទ្ធិអំណាច ដែលបានផ្តល់ជូន។
- លើកឡើងទៅគណៈកម្មាធិការហានិភ័យរាល់ការបំពានចំណាត់ការគ្រប់គ្រង ឬដែនកំណត់ (ដែលមិនពាក់ព័ន្ធនឹងច្បាប់) ដែលមិនខុសឆ្ងាយពីដែនកំណត់ ដែលបានកំណត់ និងដើមទុន ឬសន្ទនីយភាព ឬកេរ្តិ៍ឈ្មោះធនាគារ។

គណនេយ្យភាព និងសវនកម្ម

ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ

ដោយយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ត្រូវបានរៀបចំឡើងដោយយោងតាមសេចក្តីណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យរបស់កម្ពុជា។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយផ្អែកលើមូលដ្ឋានកង្វល់ជាប្រចាំ និងត្រូវផ្តល់នូវការពិនិត្យដ៏ជាក់លាក់ និងត្រឹមត្រូវ លើស្ថានភាពអាជីវកម្មរបស់ធនាគារ ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

គោលការណ៍គណនេយ្យដ៏ត្រឹមត្រូវ ត្រូវបានអនុវត្តដើម្បីឲ្យមានភាពស្របគ្នា ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយមានការគាំទ្រនូវការវិនិច្ឆ័យ និងការប៉ាន់ប្រមាណប្រកបដោយភាពប្រុងប្រយ័ត្ន និងសមហេតុផល។ អភិបាលទាំងអស់ត្រូវទទួលខុសត្រូវទាំងស្រុង នៅក្នុងដំណាក់កាលនេះ ដើម្បីការពារនូវទ្រព្យសកម្មរបស់ធនាគារ និងត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ បង្ហាញពីសមតុល្យភាព និងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងការព្យាករណ៍នាថ្ងៃអនាគត ប្រកបដោយភាពត្រឹមត្រូវ និងក្បោះក្បាយ ។

ក្រុមប្រឹក្សាភិបាលមានសេចក្តីពេញចិត្តនឹងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង្ហាញនូវសមតុល្យភាព និងការវាយតម្លៃ អំពីស្ថានភាពហិរញ្ញវត្ថុ និងការព្យាករណ៍នាថ្ងៃអនាគត ប្រកបដោយភាពត្រឹមត្រូវ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដូចមានបង្ហាញនៅក្នុងរបាយការណ៍របស់អភិបាល នៅក្នុងទំព័រ ៨២ ដល់ ៨៩ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍ប្រចាំឆ្នាំនេះ។

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មជួយក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆមាសរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មាធិការសវនកម្ម និងអនុម័តដោយក្រុមប្រឹក្សាភិបាល មុនពេលផ្តល់ជូនធនាគារជាតិ នៃកម្ពុជា។

ការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវរួម លើការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឲ្យមានភាពល្អប្រសើរ ដែលរួមមានដូចជា ការត្រួតពិនិត្យលើហិរញ្ញវត្ថុ ការធ្វើប្រតិបត្តិការ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ការគោរពច្បាប់ និងបទប្បញ្ញត្តិនានា ក៏ដូចជាការគ្រប់គ្រងហានិភ័យ។ ទំហំ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់ធនាគារទាមទារឲ្យមានជាចាំបាច់ នូវការគ្រប់គ្រង និងការបែងចែកហានិភ័យត្រឹមត្រូវ។ លក្ខណៈនៃហានិភ័យទាំងនេះ មានន័យថាព្រឹត្តិការណ៍ទាំងឡាយអាចនឹងកើតមានឡើង ហើយបណ្តាលឲ្យមានការខាតបង់ ដោយមិនអាចដឹងមុន និងចៀសវាងបាន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធ ត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវការធានាដ៏សមហេតុផលមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ចំពោះហានិភ័យដែលកើតចេញពីកំហុសធ្ងន់ធ្ងរ ការកេងបន្លំ ឬការខាតបង់ដែលកើតមានក្តី។

ក្រុមប្រឹក្សាភិបាលបានចាត់ទុកថា ក្របខណ្ឌ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីត្រូវបានអនុវត្តដោយគណៈគ្រប់គ្រងរបស់ធនាគារ ក្នុងឆ្នាំហិរញ្ញវត្ថុ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ និងមានគ្រប់គ្រាន់ ស្របតាមតម្រូវការរបស់ធនាគារ ក្នុងបរិយាកាសអាជីវកម្មនាពេលបច្ចុប្បន្ន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបចំឡើង សម្រាប់ផ្តល់នូវការធានាដ៏សមស្របមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ដើម្បីបង្កើតឲ្យបាននូវបទដ្ឋានជាក់លាក់មួយសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងជួយធនាគារ ក្នុងការគ្រប់គ្រងហានិភ័យ លើការបរាជ័យក្នុងការសម្រេចគោលដៅអាជីវកម្មក្តី ប៉ុន្តែវាប្រសើរជាងការលុបចោលនូវប្រព័ន្ធត្រួតពិនិត្យនេះដែរ។

សេចក្តីថ្លែងការណ៍ អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបង្ហាញពីស្ថានភាពត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារមានបង្ហាញ នៅក្នុងទំព័រ ៤៣ ដល់ ៤៦ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

របាយការណ៍គណៈកម្មាធិការសវនកម្ម

សេចក្តីសង្ខេប

គណៈកម្មាធិការសវនកម្ម នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ប្តេជ្ញាបំពេញតួនាទីរបស់ខ្លួនក្នុងការធានានូវការអនុវត្តអភិបាលកិច្ចយ៉ាងល្អប្រសើរ ព្រមទាំងធានានូវការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

១. សមាជិកចូលរួមកិច្ចប្រជុំ

ព័ត៌មានលម្អិត នៃសមាសភាពគណៈកម្មាធិការសវនកម្ម និងកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ដែលបានរៀបចំឡើង ក្នុងឆ្នាំ ២០១៨ មានរៀបរាប់ដូចខាងក្រោម៖

សមាជិក	មុខងារ	បានចូលរួម	ចំនួនកិច្ចប្រជុំ
បណ្ឌិត ម៉ី កល្យាណ	អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
Dato’ Shaarani Ibrahim*១	អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៣
Dato’ Wira Zainal Abidin Mahamad Zain	អភិបាលឯករាជ្យមិនប្រតិបត្តិ	៦	៦
លោកស្រី Aisyah Lam Binti Abdullah*២	អភិបាលឯករាជ្យមិនប្រតិបត្តិ	៣	៣

*១ *លាលែងពីតំណែងជាសមាជិក នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

*២ *តែងតាំងជាសមាជិក នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨*

ប្រធានគណៈកម្មាធិការសវនកម្ម ធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីបញ្ហាទាំងឡាយណា ដែលត្រូវបានលើកឡើង ក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មរបស់ខ្លួន។

២. សមាសភាព

សមាភាពរបស់គណៈកម្មាធិការសវនកម្ម ត្រូវមានតែអភិបាលមិនប្រតិបត្តិប៉ុណ្ណោះ និងត្រូវមានអភិបាលយ៉ាងតិចបី (៣) រូប ដែលក្នុងចំណោមនោះ អភិបាលភាគច្រើនត្រូវជាអភិបាលឯករាជ្យ។ គណៈកម្មាធិការសវនកម្ម ដឹកនាំដោយអភិបាលឯករាជ្យចំនួនមួយ (១) រូប ដែលមានជំនាញផ្នែកច្បាប់ និងគណនេយ្យ និងមិនមែនជាប្រធានក្រុមប្រឹក្សាភិបាល។ នេះគឺដើម្បីជម្រុញការពិភាក្សាបើកចំហ និងស្វាហាប់នូវរាល់បញ្ហា ដែលលើកឡើងដោយគណៈកម្មាធិការសវនកម្ម។ គ្រប់សមាជិករបស់គណៈកម្មាធិការសវនកម្មទាំងអស់ ត្រូវមានចំណេះដឹងទាក់ទងនឹងហិរញ្ញវត្ថុ ហើយជារួមគណៈកម្មាធិការត្រូវមានអភិបាល ដែលមានជំនាញ ចំណេះដឹង និងបទពិសោធន៍ ពាក់ព័ន្ធនឹងទំនួលខុសត្រូវរបស់គណៈកម្មាធិការសវនកម្ម។

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តដំណើរការមួយ សម្រាប់វាយតម្លៃប្រចាំឆ្នាំ ពីប្រសិទ្ធភាពរបស់គណៈកម្មាធិការសវនកម្ម ក៏ដូចជាការរួមចំណែករបស់សមាជិកម្នាក់ៗ ថាតើគណៈកម្មាធិការសវនកម្ម និងសមាជិកគណៈកម្មាធិការសវនកម្មបានបំពេញភារកិច្ច ស្របទៅតាមតួនាទី និងភារកិច្ច។

តំណែងទំនេរ នៅក្នុងគណៈកម្មាធិការសវនកម្ម ត្រូវបំពេញក្នុងរយៈពេល បី (៣) ខែ។

៣. សិទ្ធិអំណាច

គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយ ដែលទទួលបានការផ្ទេរសិទ្ធិ ពីក្រុមប្រឹក្សាភិបាល។ នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន គណៈកម្មាធិការសវនកម្ម មានសិទ្ធិអំណាចពេញលេញក្នុងការធ្វើការស៊ើបអង្កេត លើបញ្ហានានា ដូចមានចែង នៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការនេះ មានសិទ្ធិពេញលេញ ក្នុងការចូលរួម និងទាមទារឲ្យមានការសហការពីគណៈគ្រប់គ្រង ព្រមទាំងមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការអញ្ជើញអភិបាល ឬមន្ត្រីប្រតិបត្តិណាម្នាក់ចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ព្រមទាំងមានសិទ្ធិទាមទារឲ្យធនាគារផ្តល់ធនធានចាំបាច់នានា ដើម្បីបំពេញការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការសវនកម្មមានសិទ្ធិពេញលេញ និងគ្មានដែនកំណត់ ក្នុងការទទួលបាននូវព័ត៌មានផ្សេងៗ ព្រមទាំងការទទួលយកការប្រឹក្សាយោបល់ពីអ្នកជំនាញឯករាជ្យ ក្នុងករណីចាំបាច់ ដោយរាល់ចំណាយដែលពាក់ព័ន្ធទាំងអស់ជាបន្ទុករបស់ធនាគារ។

៤. តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម៖

តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

ចំណុចគន្លឹះនៃការទទួលខុសត្រូវ	ការទទួលខុសត្រូវ
ការត្រួតពិនិត្យផ្ទៃក្នុង/ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច	ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាសស្តីពី អភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុង បានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដងនៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។ គ. មើលការខុសត្រូវ លើប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះបានទទួលអំណាចចាំបាច់ដើម្បីបំពេញការងារឬនៅ។ ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយ ក្នុងការគ្រប់គ្រង ការមិនបានអនុវត្តពេញលេញតាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀត ដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែកដែលទទួលខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។ ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗ រវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផលប៉ះពាល់ ដែលការមិនឯកភាពទាំងនោះអាចមានចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្មដែលលើកឡើងដោយសវនករ។ ច. ធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថារបាយការណ៍របស់សវនករផ្ទៃក្នុងនឹងមិនតម្រូវឲ្យត្រួតពិនិត្យដោយគណៈគ្រប់គ្រងឡើយ។ ឆ. បង្កើតយន្តការដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។ ជ. វាយតម្លៃសកម្មភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេចអំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។ ឈ.អនុម័តលើការតែងតាំង ផ្លាស់ប្តូរ និងបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹងអំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឲ្យសមាជិកដែល បានដាក់ពាក្យលាឈប់នោះបញ្ជាក់ប្រាប់ពីមូលហេតុនៃការលាឈប់។

សវនកម្មខាងក្រៅ	ក. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល លើការតែងតាំង ឬការបញ្ឈប់សវនករខាងក្រៅ។ ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញ ជាមួយសវនករខាងក្រៅ មុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានាលើការសម្របសម្រួលក្នុងករណីមាន ក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃពីទំនាក់ទំនងផ្សេងៗ រវាងសវនករខាងក្រៅ និងធនាគារ)។ ឃ. អនុម័តលើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះអាចនឹងប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។ ង. ធានាថា មានការពិនិត្យច្បាស់លាស់ លើលក្ខខណ្ឌនៃការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្មដើម្បីចៀសវាងការប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។ ច. ធានាថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញ ជាប្រចាំ លើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធនដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។ ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ជាមួយសវនករខាងក្រៅ និងតម្រូវឲ្យសវនករខាងក្រៅរាយការណ៍មកកាន់គណៈកម្មាធិការសវនកម្ម អំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រងប្រសិនបើចាំបាច់)។ ជ. ពិនិត្យឡើងវិញ លើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្មខាងក្រៅ និងអនុសាសន៍ ដែលលើកឡើងដោយសវនករខាងក្រៅ ទាន់ពេលវេលា។ ឈ. តាមដាននិងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅរួមទាំងជួបប្រជុំជាមួយសវនករខាងក្រៅយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។
លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហានៃការប្រតិបត្តិតាមច្បាប់	ពិនិត្យឡើងវិញ លើលទ្ធផលនៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ ដែលរាយការណ៍ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនកររបស់និយ័តករ។
របាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់លើ៖ • ការផ្លាស់ប្តូរណាមួយ នៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ • បញ្ហាសំខាន់ៗ ដែលបានលើកឡើង រួមទាំងបញ្ហាទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀបដែលបញ្ហាទាំងអស់ត្រូវបានបង្ហាញ • ការធ្វើសេចក្តីសន្និដ្ឋានពីបញ្ហា ដែលកំពុងកើតឡើង និង • ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត
ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ	ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើង ជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលពីប្រតិបត្តិការទាំងនោះ។
ការពិនិត្យរបាយការណ៍ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគារ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។
ការតាមដានការអនុវត្តតាមគោលនយោបាយទំនាស់ផលប្រយោជន៍	តាមដានការអនុវត្តតាមគោលនយោបាយ ស្តីទីទំនាស់ផលប្រយោជន៍របស់ធនាគារ
ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង	ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះការរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ
ផ្សេងៗ	ក. ជូនដំណឹងដល់គណៈគ្រប់គ្រងជាន់ខ្ពស់ជាទៀងទាត់ អំពីបញ្ហាដែលប៉ះពាល់ដល់ធនាគារ។ ខ. កោះប្រជុំជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរក្នុងពេលតែមួយ បើយល់ថា ចាំបាច់។ គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានរហ័ស។

៥. សេចក្តីសង្ខេបសកម្មភាពផ្សេងៗក្នុងឆ្នាំ ២០១៨

៥.១. គណៈកម្មាធិការសវនកម្ម

ក. បានត្រួតពិនិត្យឡើងវិញ និងអនុម័តយល់ព្រម លើផែនការសវនកម្មប្រចាំឆ្នាំ វិសាលភាពការងារ និងតម្រូវការផ្នែកធនធានរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ. បានត្រួតពិនិត្យវិធីសាស្រ្តរបស់សវនកម្មផ្ទៃក្នុង ក្នុងការវាយតម្លៃកម្រិតហានិភ័យ ក្នុងវិស័យផ្សេងៗ ដែលអាចធ្វើសវនកម្មបាន និងធានាថា មុខងារសវនកម្មផ្តោតសំខាន់ទៅលើវិស័យដែលមានកម្រិតហានិភ័យខ្ពស់។

គ. បានត្រួតពិនិត្យឡើងវិញ នូវភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនានា ការធ្វើរបាយការណ៍ និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាថា មានវិធីសាស្រ្តជាប្រព័ន្ធមួយក្នុងការកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យលើវិស័យនានា។

ឃ. បានត្រួតពិនិត្យឡើងវិញ នូវប្រសិទ្ធភាពនៃប្រតិបត្តិការ និងការប្រើប្រាស់ធនធានទាំងអស់នៅក្នុងធនាគារ ដោយសន្សំសំចៃ។

ង. បានត្រួតពិនិត្យឡើងវិញ អំពីការតែងតាំងសវនករខាងក្រៅ ព្រមទាំងឯករាជ្យភាព និងប្រសិទ្ធភាពការងាររបស់ សវនករខាងក្រៅផងដែរ។

ច. បានត្រួតពិនិត្យឡើងវិញ នូវផែនការសវនកម្មរបស់សវនករខាងក្រៅ វិសាលភាពការងារ និងលទ្ធផលនៃសវនកម្មប្រចាំឆ្នាំរបស់ធនាគារ។

ឆ. បានជួបជាមួយសវនករខាងក្រៅ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដោយពុំមានវត្តមានរបស់គណៈគ្រប់គ្រង និងអភិបាលប្រតិបត្តិ ដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនានា និងស្នើសុំយោបល់កែតម្រូវពីសវនករខាងក្រៅ។

ជ. បានត្រួតពិនិត្យឡើងវិញ នូវបញ្ហាពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ដែលរកឃើញដោយសវនករផ្ទៃក្នុង និងសវនករខាងក្រៅ ព្រមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះអនុសាសន៍របស់សវនករ និងការឯកភាព លើផែនការសកម្មភាពដែលត្រូវអនុវត្ត។

ឈ. បានត្រួតពិនិត្យឡើងវិញ នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសរបស់ធនាគារ។

ញ. បានត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ និងភាពគ្រប់គ្រាន់នៃនីតិវិធីរបស់ធនាគារ ក្នុងការកំណត់ តាមដាន រាយការណ៍ និងត្រួតពិនិត្យឡើងវិញនូវប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិនោះ។

ដ. បានធានានូវការប្រតិបត្តិតាមវិធានច្បាប់ និងគោលការណ៍ផ្ទៃក្នុង ព្រមទាំងការវិវឌ្ឍនៃសកម្មភាពការងារនានា របស់គណៈគ្រប់គ្រង ក្នុងការអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ។

៥.២. មុខងារសវនកម្មផ្ទៃក្នុង

ក. ការធ្វើសវនកម្មផ្ទៃក្នុង សម្រាប់ធនាគារ មានការជួយគាំទ្រពីនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនមេ។

ខ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តការងារប្រកបដោយឯករាជ្យភាព និងធានាលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបានអនុវត្តដោយគណៈគ្រប់គ្រង។

គ. នាយកដ្ឋានសវនកម្មផ្ទៃក្នុងជួយគណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ក្នុងការអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាពចំពោះការត្រួតពិនិត្យ លើប្រសិទ្ធភាពចំណាយ ការវាយតម្លៃលើការគ្រប់គ្រងហានិភ័យ និងការផ្តល់យោបល់លើវិធានការកាត់បន្ថយហានិភ័យដែលបានរកឃើញ និងធានានូវដំណើរការអភិបាលកិច្ចត្រឹមត្រូវ។

ឃ. នាយកដ្ឋានសវនកម្មផ្ទៃក្នុងផ្តល់របាយការណ៍ជាប្រចាំ ជូនដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រងដោយរាយការណ៍ អំពីលទ្ធផលនៃការធ្វើសវនកម្ម ដែលបញ្ជាក់អំពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងហានិភ័យសំខាន់ៗ។

ង. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការស៊ើបអង្កេតលើសកម្មភាព ដែលសង្ស័យថាជាការកេងបន្លំ និងសកម្មភាពមិនប្រក្រតីផ្សេងទៀត។

៥.៣. របាយការណ៍សវនកម្មផ្ទៃក្នុង

ក. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានបញ្ចប់ការធ្វើសវនកម្មក្នុងអំឡុងឆ្នាំចំនួន ១៧លើក ដោយបានធ្វើសវនកម្មលើប្រតិបត្តិការសំខាន់ៗទាំងអស់។

ខ. របាយការណ៍សវនកម្ម ដែលត្រូវបានចាត់ថ្នាក់ថាមាន «ហានិភ័យលើសពីកម្រិតមធ្យម» និង«ហានិភ័យកម្រិតខ្ពស់» តម្រូវឲ្យគណៈគ្រប់គ្រងត្រូវមានវត្តមាននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មជាដាច់ខាត ដើម្បីបកស្រាយ និងផ្តល់នូវសេចក្តីពន្យល់ លើបញ្ហាទាំងឡាយ ដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុងបានរកឃើញ។

គ. រាល់បញ្ហាដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុង រកឃើញត្រូវបានកត់ត្រាទុក និងតាមដានបន្តរហូតដល់បញ្ហាទាំងនោះត្រូវបានដោះស្រាយចប់ ហើយនឹងត្រូវរាយការណ៍រៀងរាល់ ០២ ខែម្តង ជូនគណៈកម្មាធិការសវនកម្ម ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង

ឃ. ការវិវឌ្ឍនៃសកម្មភាពការងារ ក្នុងការអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្ម ក៏ត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការសវនកម្មរៀងរាល់ ០២ ខែម្តងផងដែរ។

សេចក្តីថ្លែងការណ៍ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលផ្តល់សារៈសំខាន់ ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្តេជ្ញារក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនោះឲ្យមានលក្ខណៈល្អប្រសើរ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបង្ហាញពីតម្រូវការចាំបាច់ ចំពោះការប្រតិបត្តិការអាជីវកម្ម ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងដំណើរការនៃការរៀបចំ និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងសមស្រប ព្រមទាំងការអនុវត្ត ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមានផងដែរ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវជារួម លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងការគ្រប់គ្រងលើប្រព័ន្ធព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាលក៏ទទួលស្គាល់ផងដែរថា ការត្រួតពិនិត្យឡើងវិញ លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរួមគ្នា និងត្រូវអនុវត្តជាបន្តបន្ទាប់ នៅក្នុងធនាគារ ហើយវាត្រូវធ្វើការផ្លាស់ប្តូរស្របទៅនឹងបច្ចេកវិទ្យា បរិយាកាសអាជីវកម្ម និងបទប្បញ្ញត្តិច្បាប់ ក្នុងន័យធ្វើឲ្យប្រសើរឡើងនូវដំណើរការនៃការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានបង្កើតឡើងដើម្បីកំណត់ គ្រប់គ្រង និងត្រួតពិនិត្យហានិភ័យ រួមបញ្ចូលទាំងហានិភ័យប្រតិបត្តិការ ពោលគឺមិនមែនដើម្បីលុបបំបាត់ចោលនូវហានិភ័យ ដែលកើតចេញពីការបរាជ័យក្នុងការសម្រេចទិសដៅអាជីវកម្មនោះទេ។

ការគ្រប់គ្រងហានិភ័យ និងក្របខណ្ឌនៃការត្រួតពិនិត្យ

ធនាគារចាត់ទុកថាការគ្រប់គ្រងហានិភ័យ គឺជាធាតុមួយយ៉ាងសំខាន់នៃអាជីវកម្មរបស់ធនាគារ ហើយបញ្ចូលវប្បធម៌ហានិភ័យដ៏តឹងរឹង ទៅក្នុងប្រតិបត្តិការ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ ជាមួយនឹងការយល់ដឹង អំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យ សម្រាប់ធនាគារ ដើម្បីសម្រេចបាននូវការរីកចម្រើន ប្រកបដោយនិរន្តរភាពបាន ក្រុមការងារគ្រប់គ្រងហានិភ័យចូលរួមតាំងពីដំណាក់កាលដំបូងនៃដំណើរការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ និងមតិយោបល់ រួមមាន ការវាយតម្លៃផលិតផលថ្មី ការកំណត់យុទ្ធសាស្ត្រ ការវាយតម្លៃឥណទាន ។ល។

ធនាគារ ដែលជាផ្នែកមួយនៃ ស៊ីអាយអិមប៊ី គ្រុប (CIMB Group) បានបញ្ចូលនូវក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់សហគ្រាសទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន។ ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅ សម្រាប់សហគ្រាសទាំងមូល ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ខ្លួននូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រងលើហានិភ័យ ដែលមានស្រាប់ និងហានិភ័យដែលអាចនឹងកើតមានដោយធ្វើការពិចារណា ទៅលើការកែប្រែនូវទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរនៃយុទ្ធសាស្ត្រអាជីវកម្ម បញ្ញត្តិច្បាប់ និងសកម្មភាពការងារ។

សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា

សុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា គឺជាយុទ្ធសាស្ត្រនៃការគ្រប់គ្រង ទៅលើអ្នកប្រើប្រាស់ ដំណើរការរបស់ប្រព័ន្ធ និងប្រព័ន្ធបច្ចេកវិទ្យា។ ដើម្បីពង្រឹងបន្ថែមលើកម្រិតការគ្រប់គ្រងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានវិទ្យា ធនាគារបានជ្រើសយកប្រព័ន្ធ និងបែបបទនៃការគ្រប់គ្រងពីក្រុមហ៊ុនមេ។ អនុវត្តតាមគោលការណ៍នេះ ធនាគារអាចធានាបាននូវសុវត្ថិភាព លើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាដោយមានប្រសិទ្ធភាព ដើម្បីគាំទ្រដំណើរការអាជីវកម្មរបស់ធនាគារ។

ដើម្បីឲ្យស្របទៅតាមការរីកលូតលាស់នៃអាជីវកម្មធនាគារ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ស្ថាបត្យកម្មផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់យើងតែងតែត្រូវបានពិនិត្យឡើងវិញជារឿយៗ និងធ្វើការកែសម្រួលបន្ថែម ដើម្បីឲ្យអាចកាន់តែមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងហានិភ័យទាំងខាងក្នុង និងក្រៅ។ លើសពីនេះទៅទៀត ធនាគារមានការពឹងផ្អែកទៅលើមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខរបស់ក្រុមហ៊ុនមេ (Group's Security Operation Center) ដែលបង្កើតឡើងដើម្បីតាមដាន និងឆ្លើយតបទៅនឹងសកម្មភាពវាយប្រហារ តាមប្រព័ន្ធអ៊ីនធើណេត (cyber-attack) ដែលអាចនឹងកើតឡើងដោយយថាហេតុ។

រីឯនៅកម្រិតសុវត្ថិភាពតាមបណ្តាញកុំព្យូទ័រវិញ ធនាគារបានតំឡើងបន្ថែម នូវជញ្ជាំងសុវត្ថិភាព (Firewall) និងការកំណត់លើការចូលប្រើប្រាស់ ដើម្បីគ្រប់គ្រងសុវត្ថិភាព និងធនធានផ្សេងៗក្នុងបណ្តាញ ហើយអនុញ្ញាតទៅលើសំណើ ដែលបានអនុម័តតែប៉ុណ្ណោះ។ ធនាគារក៏បានតំឡើងបន្ថែមនូវប្រព័ន្ធទប់ស្កាត់នៅចំណុចចុងក្រោយ (End-point Protection) ផងដែរ ដែលមានដូចជាកម្មវិធីកម្ចាត់មេរោគ (Anti-malware) កម្មវិធីរក្សាសុវត្ថិភាពទិន្នន័យ (Hard Disk Encryption) ប្រព័ន្ធទប់ស្កាត់ការបាត់បង់ទិន្នន័យ (Data Loss Prevention) ប្រព័ន្ធទប់ស្កាត់ការជ្រៀតជ្រែក (Intrusion Prevention System) និងប្រព័ន្ធសម្អាតមាតិកាអ៊ីមែល និងអ៊ីនធើណេតជាដើម (Web and Email Content Filtering System) ដែលអាចជួយកាត់បន្ថយហានិភ័យផ្នែកសន្តិសុខ ដែលគួរឲ្យកត់សម្គាល់ នៅពេលទិន្នន័យឆ្លងកាត់ប្រព័ន្ធបណ្តាញរបស់ធនាគារ។ វចនានុក្រមមេរោគថ្មីៗនៃកម្មវិធីបរិក្ខារខាងលើ តែងតែទទួលបានការធ្វើបច្ចុប្បន្នភាពដើម្បីឲ្យពួកវាអាចស្គាល់ រារាំង និងកាត់បន្ថយនូវភាពងាយរងគ្រោះផ្សេងៗ។

ធនាគារក៏បានធ្វើបទបង្ហាញ និងមានការបណ្តុះបណ្តាលចំណេះដឹងទៅដល់បុគ្គលិក ដើម្បីបង្កើនការយល់ដឹងអំពីភាពជាឯកជន ការលេចធ្លាយនៃព័ត៌មាន សុវត្ថិភាពព័ត៌មាន និងទំនួលខុសត្រូវផ្សេងៗ។ ការបណ្តុះបណ្តាលទាំងនេះមានលក្ខណៈ ដូចជាឯកសារសិក្សាអេឡិចត្រូនិច និងការចែកចាយជាព្រឹត្តិបត្រព័ត៌មានផ្សេងៗ។

ដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ

ដំណើរការសំខាន់ៗដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ នូវភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង រួមបញ្ចូលទាំងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ វិធាន សេចក្តីណែនាំ និងគោលការណ៍ណែនាំ ដែលមានជាធរមាន មានដូចខាងក្រោម៖

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម មានសមាជិកជាអភិបាលឯករាជ្យមិនប្រតិបត្តិ។ គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយ ដែលទទួលបានការផ្ទេរសិទ្ធិអំណាច ពីក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ លើការត្រួតពិនិត្យការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការផ្សព្វផ្សាយព័ត៌មាន ការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ ការអនុវត្តអភិបាលកិច្ច និងការតាមដានដំណើរការនៃការគ្រប់គ្រង លើការត្រួតពិនិត្យផ្ទៃក្នុង នៅក្នុងធនាគារ។ គណៈគ្រប់គ្រងជាន់ខ្ពស់ សវនករផ្ទៃក្នុង និងសវនករខាងក្រៅ ផ្តល់របាយការណ៍ជូនគណៈកម្មាធិការសវនកម្ម អំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង។

រាល់បញ្ហាសំខាន់ៗ និងគួរឲ្យកត់សម្គាល់ដែលបានរកឃើញដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងនិយ័តករត្រូវរាយការណ៍ទៅគណៈកម្មាធិការសវនកម្ម ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ និងពិភាក្សា។ គណៈកម្មាធិការសវនកម្មត្រួតពិនិត្យឡើងវិញ និងធានាអំពីការអនុវត្តផែនការកាត់បន្ថយបញ្ហា ឬហានិភ័យរបស់គណៈគ្រប់គ្រង ដើម្បីការពារផលប្រយោជន៍របស់ធនាគារ និងរក្សាបានល្អនូវអភិបាលកិច្ចដ៏សមស្រប។ ការគ្រប់គ្រងផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដែលត្រូវបានចាត់ថ្នាក់ថា មាន «ហានិភ័យលើសពីកម្រិតមធ្យម» ឬ«ហានិភ័យកម្រិតខ្ពស់» ដោយសវនករផ្ទៃក្នុងត្រូវទទួលការពិគ្រោះយោបល់ពីគណៈកម្មាធិការសវនកម្ម។

គណៈកម្មាធិការសវនកម្ម ក៏ធ្វើការត្រួតពិនិត្យឡើងវិញផងដែរ នូវរាល់ប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ ថ្លៃចំណាយលើសវនកម្ម និងថ្លៃចំណាយមិនពាក់ព័ន្ធនឹងកិច្ចការសវនកម្ម ដែលស្នើដោយសវនករខាងក្រៅរបស់ធនាគារ។

ការធ្វើបទបង្ហាញនានា អំពីផែនការអាជីវកម្ម ការវិវឌ្ឍថ្មីៗ ប្រតិបត្តិការនានា ហានិភ័យនៃអាជីវកម្ម និងការត្រួតពិនិត្យនានា ដើម្បីកាត់បន្ថយហានិភ័យត្រូវបានធ្វើឡើងដោយផ្នែកអាជីវកម្មពាក់ព័ន្ធ និងផ្នែកគាំទ្រអាជីវកម្ម ប្រសិនបើគណៈកម្មាធិការសវនកម្មគិតថាចាំបាច់។

សមាជិកគណៈកម្មាធិការសវនកម្ម ក៏ចូលរួមកិច្ចប្រជុំកំពូលរបស់គណៈគ្រប់គ្រងប្រចាំឆ្នាំរបស់ធនាគារ (Bank's Annual Management Summit) ផងដែរ ដែលនៅក្នុងកិច្ចប្រជុំនោះ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មនីមួយៗធ្វើការ ត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការនានារបស់ខ្លួន ដែលបានធ្វើឡើងសម្រាប់ឆ្នាំនេះ ព្រមទាំងធ្វើការបង្ហាញអំពីយុទ្ធសាស្រ្ត និងផែនការនានា សម្រាប់ឆ្នាំបន្ទាប់ផងដែរ។

គណៈកម្មាធិការហានិភ័យ

គណៈកម្មាធិការហានិភ័យកំណត់អំពីកម្មវត្ថុនៃគោលការណ៍ហានិភ័យរបស់ធនាគារ និងបំពេញតួនាទី និងកាតព្វកិច្ចជំនួសឲ្យក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ។ ការទទួលខុសត្រូវ ចំពោះការត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ត្រូវបានប្រគល់សិទ្ធិ ជូនទៅគណៈកម្មាធិការហានិភ័យ ដែលទទួលបន្ទុករាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការហានិភ័យ ធ្វើការជួបប្រជុំជារៀងរាល់ខែ ឬតាមការចាំបាច់។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍ អំពីហានិភ័យសាច់ប្រាក់ងាយស្រួល និងបញ្ហាទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារ ទៅគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ធ្វើការប្រជុំជារៀងរាល់ខែ ដោយមានតួនាទីចម្បង ក្នុងការពិនិត្យតាមដាន និងដោយប្រើយុទ្ធសាស្រ្តគ្រប់គ្រង លើហានិភ័យហិរញ្ញវត្ថុនៃតារាងតុល្យការ។ គណៈកម្មាធិការនេះ មានការទទួលខុសត្រូវជាក់លាក់ ចំពោះការគ្រប់គ្រងលើថ្លៃដើមឥណទាន ការរៀបចំអភិវឌ្ឍបន្ថែម លើការផ្តល់ប្រឹក្សា ដែលសមស្របជូនគណៈកម្មាធិការហានិភ័យ ក្នុងការធ្វើសេចក្តីសម្រេច ទាក់ទងនឹងហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យអត្រាការប្រាក់ ការបែងចែកប្រភពហិរញ្ញប្បទាន និងការត្រួតពិនិត្យឡើងវិញ នូវសមាសភាពក្នុងតារាងតុល្យការពាក់ព័ន្ធនឹងឥណទាន និងប្រាក់បញ្ញើរបស់ធនាគារ។ ជារួមមក គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រួតពិនិត្យមើលការអនុវត្តនៃដំណើរការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រង លើអត្រាការប្រាក់ សាច់ប្រាក់ងាយស្រួល និងហានិភ័យស្រដៀងគ្នាផ្សេងៗទៀត ដែលទាក់ទងនឹងតារាងតុល្យការរបស់ធនាគារ និងកម្រិតពាក់ព័ន្ធផ្សេងទៀត។

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី ត្រូវបានដាក់ឲ្យអនុវត្ត សម្រាប់គ្រប់ផលិតផល និងសេវាកម្មថ្មីៗ ទាំងអស់របស់ធនាគារ។ ផលិតផលថ្មី គឺសំដៅទៅលើផលិតផល និង/ឬសេវាកម្មទាំងឡាយណា ដែលផ្តល់ជូនដំបូងដោយធនាគារ ឬជាការបញ្ចូលផលិតផលច្រើនជាផលិតផលតែមួយ ឬបម្រែបម្រួលទម្រង់របស់ផលិតផល ដែលមានស្រាប់ និង/ឬសេវាកម្មដែលមានការប្រែប្រួលខ្លាំងនូវទម្រង់ហានិភ័យ ដូចដែលបានកំណត់ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។

គ្រប់សំណើសុំការអនុម័តលើផលិតផលថ្មី ត្រូវឆ្លងកាត់ដំណើរការនៃការត្រួតពិនិត្យហានិភ័យឲ្យបានស៊ីជម្រៅ ដោយអ្នកពាក់ព័ន្ធនានា ទាំងនៅក្នុងធនាគារ និងនៅក្នុងក្រុមហ៊ុនមេ ដើម្បីធានាថាគ្រប់ផ្នែកសំខាន់ៗ និងផ្នែកដែលពាក់ព័ន្ធនឹងហានិភ័យ ត្រូវបានកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ មុនពេលដំណើរការផលិតផល និង/ឬ សេវាកម្មថ្មីៗនោះ។ បន្ទាប់មកសំណើសុំការអនុម័តលើផលិតផលថ្មីមួយរបស់ធនាគារ ត្រូវឆ្លងកាត់ការពិភាក្សាយ៉ាងហ្មត់ចត់ដោយគណៈកម្មាធិការនានារបស់ធនាគារ និងក្រុមហ៊ុនមេ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីធ្វើការអនុម័តចុងក្រោយ។

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង គឺជាគណៈកម្មាធិការដែលបង្កើតឡើង ដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងបញ្ហាដែលកើតពីការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។ កិច្ចប្រជុំគណៈកម្មាធិការនេះធ្វើឡើង រៀងរាល់មួយខែម្តង គឺនៅសប្តាហ៍ទី៣ នៃខែនីមួយៗ ឬតាមការចាំបាច់។ សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រង រួមមានសមាជិកមកពីនាយកដ្ឋាននានា រួមបញ្ចូលទាំងតំណាងមកពីសវនករផ្ទៃក្នុងមួយរូប និងមន្រ្តីប្រតិបត្តិតាមមួយរូប ដែលត្រូវបានអញ្ជើញចូលរួមប្រជុំជាអចិន្ត្រៃយ៍។

គោលការណ៍ និងនីតិវិធីផ្ទៃក្នុង

រាល់គោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ផ្នែកអាជីវកម្មទាំងអស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងនីតិវិធីទាំងអស់នេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍នាំផ្លូវមួយ សម្រាប់ការធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានាអំពីការប្រតិបត្តិតាមការត្រួតពិនិត្យផ្ទៃក្នុង នឹងបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន។ គោលការណ៍នេះរៀបចំឡើង ក្នុងគោលបំណងធានាប្រសិទ្ធភាពនៃប្រតិបត្តិការឲ្យកាន់តែមានភាពប្រសើរឡើង ដោយធ្វើការពិចារណាផងដែរ ទៅលើបម្រែបម្រួលនៃវិស័យធនាគារ ដូចជា លក្ខខណ្ឌតម្រូវរបស់ច្បាប់ ហានិភ័យ និងវិធានការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយហានិភ័យ ព្រមទាំងផលិតផល និងសេវាកម្មថ្មីៗផងដែរ។

សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការរាយការណ៍ដោយឯករាជ្យ ជូនគណៈកម្មាធិការសវនកម្ម ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានឯករាជ្យភាពគ្រប់គ្រាន់ ពីផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងទៀត លើគ្រប់សកម្មភាព និងប្រតិបត្តិការទាំងអស់។ ការទទួលខុសត្រូវចម្បងរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺផ្តល់ការវាយតម្លៃឯករាជ្យ លើភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងហានិភ័យ ដំណើរការគ្រប់គ្រង និងការត្រួតពិនិត្យដែលអនុវត្តដោយគណៈគ្រប់គ្រង។ ក្នុងការវាយតម្លៃ ទៅលើការត្រួតពិនិត្យផ្ទៃក្នុង នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តតាមសមាសភាគទាំងប្រាំ (៥) ដែលចែងនៅក្នុងក្របខណ្ឌរួមនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលដាក់ចេញដោយគណៈកម្មាធិការ Committee of Sponsoring Organisations of the Treadway Commission (COSO) ដែលសមាសភាគទាំងនោះ រួមមានស្ថានភាពនៃការត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យ ការទំនាក់ទំនង និងព័ត៌មាន ហើយនឹងការពិនិត្យតាមដានសកម្មភាព។ COSO គឺជាអង្គភាពមួយ ដែលទទួលស្គាល់ជាអន្តរជាតិ ដែលផ្តល់សេចក្តីណែនាំ និងភាពជាអ្នកដឹកនាំផ្នែកទស្សនៈ លើការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យរបស់សហគ្រាស និងការទប់ស្កាត់ការកេងបន្លំ។

វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្របដណ្តប់លើគ្រប់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់។ ការជ្រើសយកផ្នែកណាមួយមកធ្វើសវនកម្ម ត្រូវធ្វើឡើងដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម។ ផែនការសវនកម្មប្រចាំឆ្នាំត្រូវបានបង្កើតឡើង ផ្អែកតាមការវាយតម្លៃកម្រិតហានិភ័យ គោលដៅ និងយុទ្ធសាស្រ្តរបស់ធនាគារ។ ផ្នែកទាំងឡាយណាដែលត្រូវបានវាយតម្លៃថាមានហានិភ័យកម្រិតខ្ពស់ គឺជាកម្មវត្ថុនៃការធ្វើ សវនកម្មប្រចាំឆ្នាំ រីឯផ្នែកដែលទទួលការវាយតម្លៃថាមានហានិភ័យកម្រិតមធ្យម ឬទាប គឺជាកម្មវត្ថុនៃការធ្វើសវនកម្មនៅវដ្តបន្តបន្ទាប់។ ក្រៅពីការវាយតម្លៃលើហានិភ័យផែនការសវនកម្មប្រចាំឆ្នាំ បានដាក់បញ្ចូលផងដែរ នូវនាយកដ្ឋាននានាដែលត្រូវទទួលការធ្វើសវនកម្ម ដែលតម្រូវដោយបទប្បញ្ញត្តិច្បាប់ ឬការកើតមាននូវការលួចបន្លំនាពេលថ្មីៗ ឬក៏ការទទួលការវាយតម្លៃថាមានហានិភ័យកម្រិតខ្ពស់ កាលពីឆ្នាំចាស់ ឬចំណាត់ការថ្មីៗដាក់ចេញដោយនិយ័តករ ដោយផ្អែកតាមប្រតិបត្តិការទីផ្សារ ឬចំណាត់ការផ្សេងពីនេះ ព្រឹត្តិការណ៍ខាតបង់ទាំងឡាយណា ដែលត្រូវបានរាយការណ៍ ហើយដែលមានចំនួនទឹកប្រាក់រហូតដល់ ២៥.០០០ ដុល្លារអាមេរិក ឬលើសពីនេះ ឬការផ្លាស់ប្តូរសំខាន់ៗ ទៅលើប្រព័ន្ធកុំព្យូទ័រ ឬប្រតិបត្តិការ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក៏ធ្វើការស៊ើបអង្កេតផងដែរ លើការសង្ស័យចំពោះការលួចបន្លំ ដែលប្រព្រឹត្តដោយបុគ្គលិក អតិថិជន និងតតិយជន ហើយផ្តល់អនុសាសន៍កែលម្អឲ្យកាន់តែប្រសើរឡើង ដើម្បីបង្ការកុំឲ្យបញ្ហាដែលកើតមានឡើងសាជាថ្មីម្តងទៀត និងចាត់វិធានការចំពោះបុគ្គលពាក់ព័ន្ធ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលចាំបាច់ដោយគ្មានការដាក់កំហិត ក្នុងក្របខណ្ឌនៃការងាររបស់ខ្លួន។ វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើង ដោយយោងតាមស្តង់ដារអន្តរជាតិនៃការប្រកបវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង របស់វិទ្យាស្ថានសវនករអន្តរជាតិ (IIA) និងគោលការណ៍ណែនាំផ្នែកបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ។

របាយការណ៍សវនកម្ម គឺជាលទ្ធផលចុងក្រោយនៃការងារសវនកម្ម ដែលបង្ហាញពីវិសាលភាពការងារសវនកម្ម ដែលបានបំពេញការវាយតម្លៃទូទៅនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ជាមួយនឹងព័ត៌មានលម្អិតនៃការរកឃើញដោយសវនកម្ម ការឆ្លើយតបពីគណៈគ្រប់គ្រងមតិយោបល់ និងអនុសាសន៍នានារបស់នាយកដ្ឋានសវនក្មផ្ទៃក្នុង ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង។ គណៈកម្មាធិការសវនកម្ម ធ្វើការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃរាល់អញ្ញត្តិកម្ម ឬការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ដែលបានលើកឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងតាមដានសកម្មភាពនានា ដើម្បីធានាថាគណៈគ្រប់គ្រងបានចាត់វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដាក់ជូននូវរបាយការណ៍ ទៅកាន់គណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនមេ ជារៀងរាល់មួយត្រីមាសម្តង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង រៀបចំផែនការសវនកម្ម និងការចាត់ថ្នាក់សវនកម្ម ដោយអនុវត្តតាមវិធីសាស្ត្រដូចគ្នាទៅនឹងវិធីសាស្ត្ររបស់សវនកម្មនៃក្រុមហ៊ុនមេ ដោយធ្វើការកែសម្រួល ប្រសិនបើចាំបាច់ ដើម្បីឲ្យសមស្របទៅនឹងបទប្បញ្ញត្តិ និងបរិយាកាសក្នុងស្រុក។

ក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់

ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថាមុខងារការប្រតិបត្តិតាម បង្កើតបានជាផ្នែកមួយនៃការគ្រប់គ្រងរបស់ធនាគារ និងការត្រួតពិនិត្យផ្ទៃក្នុង ពីព្រោះវប្បធម៌នៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ដ៏រឹងមាំឆ្លុះបញ្ចាំងពីវប្បធម៌សាជីវកម្ម ដែលប្រកបដោយសុចរិតភាព និងក្រមសីលធម៌ខ្ពស់។

មុខងារការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ធនាគារ ត្រូវបានដឹកនាំដោយនាយកដ្ឋានប្រតិបត្តិតាម រួមជាមួយនឹងការប្រឹក្សាយោបល់ ក៏ដូចជាការណែនាំពីផ្នែកប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ក្រុមហ៊ុនមេ ដែលមានការិយាល័យនៅប្រទេសម៉ាឡេស៊ី។ មុខងារចម្បងរបស់នាយកដ្ឋានប្រតិបត្តិតាម គឺជួយសម្រួលផ្តល់ដំបូន្មាន តាមដាន អប់រំដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ឲ្យអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានា។ ស្របតាមអភិបាលកិច្ចល្អ នាយកដ្ឋានប្រតិបត្តិតាមធ្វើការរាយការណ៍ទៅក្រុមប្រឹក្សាភិបាលដោយឯករាជ្យ។

ក្រោមក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់ត្រូវបង្កើតទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ (ComplianceMatrix)។ ទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ គឺជាឯកសារដែលដាក់បញ្ចូលនូវច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ ដែលអនុវត្តចំពោះផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម។ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មក៏ត្រូវបង្កើតការធ្វើតេស្តដោយខ្លួនឯង (Self-Testing) លើទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ផងដែរ ហើយនាយកដ្ឋានប្រតិបត្តិតាម ធ្វើការផ្ទៀងផ្ទាត់លើការធ្វើតេស្តដោយខ្លួនឯងនោះដោយឯករាជ្យ។ បន្ថែមពីនេះទៀត នាយកដ្ឋានប្រតិបត្តិតាម ប្រតិបត្តិការពិនិត្យឡើងវិញ (ដោយការចុះត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារផ្សេងៗ) ទៅលើផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ផ្អែកតាមផែនការនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ (Compliance Work Plan) ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ លើសពីនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ទុកត្រូវបានធ្វើឡើងយ៉ាងទៀងទាត់ ដើម្បីបង្កើតការយល់ដឹងអំពីក្របខណ្ឌនៃការប្រតិបត្តិតាម និងដើម្បីសម្រួលដល់ការអនុវត្តបានទូទាំងធនាគារទាំងមូល។

ស្របតាមអភិបាលកិច្ចល្អ នាយកដ្ឋានប្រតិបត្តិតាម ធ្វើការរាយការណ៍ទៅក្រុមប្រឹក្សាភិបាលដោយឯករាជ្យ ហើយផែនការការងារប្រតិបត្តិតាមត្រូវដាក់បញ្ចូល និងទទួលការអនុម័តពីក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ អភិបាលកិច្ចសមស្របមួយក៏ត្រូវបានបង្កើតឡើង ដោយនៅក្នុងនោះមន្ត្រីប្រតិបត្តិតាមប្រចាំធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវរាយការណ៍ទៅនាយកនៃនាយកដ្ឋានប្រតិបត្តិតាមរបស់ក្រុមហ៊ុនមេ ក្នុងកម្រិតមួយដែលអនុញ្ញាតដោយវិធានយុត្តាធិការកម្ពុជា។

ក្រុមប្រឹក្សាភិបាលក៏ត្រូវបានផ្តល់ជូននូវរបាយការណ៍ប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់យ៉ាងទៀងទាត់ ដើម្បីឲ្យក្រុមប្រឹក្សាភិបាលយល់ច្បាស់ អំពីបញ្ហាប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ធនាគារ។

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី ត្រូវបានដាក់ឲ្យអនុវត្តសម្រាប់គ្រប់ផលិតផល និងសេវាកម្មថ្មីៗទាំងអស់របស់ធនាគារ។ ផលិតផលថ្មី គឺសំដៅទៅលើផលិតផល និង/ឬសេវាកម្មទាំងឡាយណា ដែលផ្តល់ជូនដំបូងដោយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ឬជាការបញ្ចូលផលិតផលច្រើនជាផលិតផលតែមួយ ឬបម្រែបម្រួលទម្រង់របស់ ផលិតផលដែលមានស្រាប់ និង/ឬសេវាកម្ម ដែលមានការប្រែប្រួលខ្លាំង នូវទម្រង់ហានិភ័យ ដូចដែលបានកំណត់ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។ គ្រប់សំណើសុំការអនុម័តលើផលិតផលថ្មី ត្រូវឆ្លងកាត់ដំណើរការនៃការត្រួតពិនិត្យហានិភ័យឲ្យបានស៊ីជម្រៅដោយអ្នកពាក់ព័ន្ធនានា ទាំងនៅក្នុងធនាគារ និងនៅក្នុងក្រុមហ៊ុនមេ ដើម្បីធានាថា គ្រប់ផ្នែកសំខាន់ៗ និងផ្នែកដែលពាក់ព័ន្ធនឹងហានិភ័យត្រូវបានកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ មុនពេលដំណើរការផលិតផល និង/ឬសេវាកម្មថ្មីៗនោះ។ បន្ទាប់មកសំណើសុំការអនុម័តលើផលិតផលថ្មីមួយរបស់ធនាគារ ត្រូវឆ្លងកាត់ការពិភាក្សាយ៉ាងហ្មត់ចត់ ដោយគណៈកម្មាធិការនានារបស់ធនាគារ និងក្រុមហ៊ុនមេ មុននឹងដាក់ជូនគណៈកម្មាធិការហានិភ័យ ដើម្បីធ្វើការអនុម័តចុងក្រោយ និងជូនដំណឹងអំពីការអនុម័តនេះទៅក្រុមប្រឹក្សាភិបាល។

ការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ

ធនាគារបន្តសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រកាន់ខ្ជាប់ នូវការគោរពតាមបទប្បញ្ញត្តិច្បាប់ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីផ្សេងទៀត ដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់ធនាគារ។ អញ្ញត្តិកម្មត្រូវបានលើកឡើង និងចាត់ចែងឲ្យបានទាន់ពេលវេលា ប្រកបដោយតម្លាភាព។ ដើម្បីឈានទៅសម្រេចគោលដៅនេះ ធនាគារបានបង្កើតនូវនីតិវិធីគ្រប់គ្រង លើករណីអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយករណីអញ្ញត្តិកម្មណាមួយកើតមានឡើង រួមមានការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការមិន គោរពកាតព្វកិច្ច ការលួចបន្លំ និងការមិនគោរពតាមដំណើរការផ្ទៃក្នុង។ នីតិវិធីនេះជួយឲ្យមាននូវវិធានការកែលម្អទាន់ពេលវេលា និងពង្រឹងតម្លាភាព និងការត្រួតពិនិត្យរបស់គណៈគ្រប់គ្រង។

ស្ថិតក្រោមនីតិវិធីនៃការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ របាយការណ៍ស្តីពីបញ្ហាដែលកើតមានត្រូវផ្ញើជូន ក្នុងកំឡុងពេល ២៤ ម៉ោងនៃការរកឃើញ ឬនៃការជូនដំណឹងដំបូងបំផុតអំពីបញ្ហាដែលបានកើតឡើង។ករណីអញ្ញត្តិកម្មទាំងនេះនឹងត្រូវបានចាត់ចែងដោះស្រាយដោយផ្អែកលើភាពធ្ងន់ធ្ងរ និងផលប៉ះពាល់របស់វាទៅលើធុរកិច្ច ប្រតិបត្តិការ និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។ ករណីអញ្ញត្តិកម្មនេះត្រូវសង្ខេប និងរាយការណ៍ទៅគណៈកម្មាធិការហានិភ័យប្រចាំខែ។

ក្រមសីលធម៌

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានស្តង់ដារក្រមសីលធម៌អប្បបរមាមួយសម្រាប់គ្រប់និយោជិតទាំងអស់របស់ខ្លួន អនុវត្តដែលរួមបញ្ចូលគ្រប់ទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃ។ គោលការណ៍ណែនាំអំពីក្រមសីលធម៌ត្រូវបាន អនុម័តយកតាមក្រមសីលធម៌របស់ក្រុមហ៊ុនមេ និងបានដាក់បញ្ចូលនៅក្នុងនៃកិច្ចសន្យាការងារដែលយល់ព្រម និងចុះហត្ថលេខាដោយគ្រប់និយោជិតទាំងអស់។

គោលការណ៍ និងនីតិវិធីស្តីពីធនធានមនុស្ស

គោលការណ៍ និងនីតិវិធី ស្តីពីធនធានមនុស្សត្រូវបានបង្កើតឡើង និងប្រើប្រាស់នៅក្នុងក្រុមហ៊ុនមេទាំងមូល ដោយមានវិសាលភាពលើគ្រប់ទិដ្ឋភាពទាំងអស់ នៃការគ្រប់គ្រងធនធានមនុស្សក្នុងធនាគារ។ គោលការណ៍នេះបានកំណត់យ៉ាងច្បាស់លាស់ អំពីការជ្រើសរើសនិយោជិត ការតំឡើងឋានៈ ការផ្ទេរកន្លែងការងារ និងការបញ្ឈប់និយោជិត នៅក្នុងក្រុមហ៊ុនមេទាំងមូល។ គោលការណ៍ និងនីតិវិធីទាំងនេះត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិក្នុងស្រុកដែលពាក់ព័ន្ធ ដើម្បីធានាការប្រតិបត្តិតាមបទប្បញ្ញត្តិត្រូវបានអនុវត្ត។ និយោជិតទទួលការវាយតម្លៃការងាររបស់ខ្លួនជារៀងរាល់ឆ្នាំ ហើយការតម្លៃការងារនេះធ្វើឡើងដោយផ្អែកលើសូចនាករនៃការវាយតម្លៃលទ្ធផលការងារ (Key Performance Indicator) និងការវាស់វែងសមត្ថភាពគន្លឹះ។ កម្មវិធីសិក្សា និងអភិវឌ្ឍន៍សមត្ថភាព ដែលរួមបញ្ចូលទាំងជំនាញវគ្គបណ្តុះបណ្តាលបច្ចេកទេសត្រូវបានរៀបចំឡើង និងដាក់ឲ្យអនុវត្តក្នុងគោលដៅគាំទ្រ និងបង្កើនសមត្ថភាពនិយោជិត ដើម្បីធានាថានិយោជិតទាំងអស់អាចបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ធនាគារបានក្រើនរំលឹកដល់និយោជិតរបស់ខ្លួនជារឿយៗ អំពីគោលការណ៍ពាក់ព័ន្ធនានា តាមរយៈសារអេឡិកត្រូនិក ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធនានា។ វគ្គបណ្តុះបណ្តាលមួយ ក្នុងចំណោមវគ្គបណ្តុះបណ្តាលផ្សេងទៀត ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានធ្វើឡើងជារឿយៗ ដើម្បីការបញ្ជាក់ឲ្យឃើញ អំពីទស្សនាទានរបស់ក្រុមហ៊ុនមេ ដែលមិនអធ្យាស្រ័យចំពោះអំពើកេងបន្លំ។ ចំណុចនេះក៏បានធ្វើការសង្កត់ធ្ងន់ដែរ នៅក្នុងកម្មវិធីបណ្តុះបណ្តាលតម្រង់ទិសរបស់ក្រុមហ៊ុនមេ។

ការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្ម

ស៊ីអាយអិមប៊ី គ្រុប បានប្តេជ្ញាចិត្ត ក្នុងការការពារផលប្រយោជន៍ របស់ម្ចាស់ភាគហ៊ុន កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន និងការបង្កើតគុណតម្លៃ ដោយធានាឲ្យបាននូវនិរន្តរភាពអាជីវកម្ម និងមុខងារបម្រើការផ្សេងៗ នៅក្នុង ស៊ីអាយអិមប៊ី គ្រុប ទាំងមូល។ ទំនួលខុសត្រូវនៃការអនុវត្ត និងដាក់ឲ្យដំណើរការ នូវគោលការណ៍គ្រប់គ្រងនិរន្តរភាពអាជីវកម្ម គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

ក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម (Business Continuity Management) ត្រូវបានជ្រើសយកពីក្រុមហ៊ុនមេ (ស៊ីអាយអិមប៊ី គ្រុប) មកអនុម័ត ដើម្បីកំណត់ឲ្យបានជាអប្បរមា នូវកម្រិតនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ការបែងចែងនូវគោលការណ៍អនុវត្តសម្រាប់គាំទ្រនាយកដ្ឋានផ្សេងៗ ហើយធ្វើឲ្យបាននូវនិរន្តរភាពអាជីវកម្ម និងសេវាកម្មសំខាន់ៗទាំងឡាយ នៅក្នុងពេលវេលាកំណត់ណាមួយ នៅពេលមានគ្រោះរំខានកើតឡើង។ ក្របខណ្ឌខាងលើមានចែងជាគោលដូចខាងក្រោម៖

(១) រក្សានូវគុណភាពសេវាកម្ម ដើម្បីបង្កើនទំនុកចិត្ត ដូចការរំពឹងទុករបស់អតិថតិជន

(២) កាត់បន្ថយផលប៉ះពាល់ទៅលើអាជីវកម្មនៅពេលមានគ្រោះរំខានកើតឡើង

(៣) មិនធ្វើឲ្យមានផលអវិជ្ជមានប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ

(៤) រក្សាឲ្យនូវការអនុលោមតាមច្បាប់ គោលការណ៍និរន្តរភាពអាជីវកម្ម និងបទប្បញ្ញត្តិផ្សេងៗ

ក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម តែងតែមានការពិនិត្យឡើងវិញជានិច្ចជាកាល ដើម្បីធ្វើឲ្យស្របទៅតាមបទដ្ឋានរបស់ ក្រុមហ៊ុនមេ ស្របទៅតាមនីតិវិធីនៃការគ្រប់គ្រង និងការអនុវត្តនិរន្តរភាពអាជីវកម្ម រួមបញ្ចូលទាំងការវិភាគទៅលើមុខងារអាជីវកម្ម និងការបង្កើតនូវយុទ្ធសាស្ត្រនិរន្តរភាពអាជីវកម្ម ការឆ្លើយតបពេលមានគ្រោះរំខាន ការបង្កើតវប្បធម៌យល់ដឹងអំពីនិរន្តរភាពអាជីវកម្ម ការរៀបចំលំហាត់និរន្តរភាពអាជីវកម្ម និងការកែសម្រួលទៅលើផែនការនិរន្តរភាពអាជីវកម្មរបស់នាយកដ្ឋាននីមួយៗ។

ដោយអនុលោមតាមក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ផែនការនិរន្តរភាពអាជីវកម្ម ត្រូវបានធ្វើឡើងសម្រាប់មុខងារអាជីវកម្មសំខាន់ៗ ហើយផែនការនិរន្តរភាពពីគ្រោះមហន្តរាយ ត្រូវបានធ្វើឡើងសម្រាប់ប្រព័ន្ធកម្មវិធីផ្សេងៗ។ លំហាត់សាកល្បងលើផែនការទាំងពីរនេះតែងតែត្រូវបានធ្វើឡើងជាប្រចាំ។

លើសពីនេះទៀត ជារៀងរាល់ឆ្នាំធនាគាររៀបចំជាសិក្ខាសាលា អំពីការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម សម្រាប់នាយកដ្ឋានទាំងអស់ឲ្យបានចូលរួម ដើម្បីបង្កើនការយល់ដឹងបន្ថែមទៀត អំពីតួនាទី មុខងារ និងទំនួលខុសត្រូវរបស់ពួកគាត់។

ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ធនាគារ សង្កត់ធ្ងន់លើសារៈសំខាន់ និងប្តេជ្ញាបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងលើ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ដែលមានការប្រកាន់ខ្ជាប់នូវការគោរពតាមបទប្បញ្ញត្តិច្បាប់ គោលការណ៍ណែនាំ និងការអនុវត្តដែលល្អបំផុត សម្រាប់វិស័យធនាគារដែលមានប្រសិទ្ធភាពមួយ។

ធនាគាររក្សាការអនុវត្តតាមគោលនយោបាយ និងនីតិវិធី ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានអនុម័តដោយកុម្រប្រឹក្សាភិបាលរបស់ធនាគារ។

ប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្រព័ន្ធគាំទ្រដទៃទៀតរបស់ធនាគារ បានសម្រួលដល់ការពិនិត្យតាមដានលើប្រតិបត្តិការ អតិថិជន និងហានិភ័យប្រឆាំងការសម្អាតប្រាក់ រួមទាំងសម្រួលដល់ការគ្រប់គ្រង Watchlist (Watchlist Management) ការយកចិត្តទុកដាក់ស្គាល់អតិថិជន (Customer Due Diligence / «Know Your Customer») និងការតាមដានសញ្ញាការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT Alert Monitoring)។

កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងត្រូវបានធ្វើឡើងជាទៀតទាត់។ កម្មវិធីនេះត្រូវបានបំពេញបន្ថែមដោយច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ករណីសិក្សាលើប្រតិបត្តិការជាក់ស្តែង អំពីហានិភ័យនៃការសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម ដោយធ្វើការសង្កត់ធ្ងន់លើតួនាទី និងការទទួលខុសត្រូវរបស់និយោជិត។ ធនាគារបាន និងបន្តចាត់វិធានការ ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមានចំពោះធនាគារ ពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងស្របពេលជាមួយគ្នានេះ ដើម្បីធានានូវការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ និងគោលការណ៍ណែនាំរបស់អាជ្ញាធរពាក់ព័ន្ធ។

សេចក្តីសន្និដ្ឋាន

ក្រុមប្រឹក្សាភិបាលមានជំនឿថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលកំពុងអនុវត្តមានលក្ខណៈគ្រប់គ្រាន់ ក្នុងការការពារផលប្រយោជន៍របស់ភាគហ៊ុនិក និងទ្រព្យសកម្មរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថា ធនាគារមានដំណើរការ ប្រកបដោយប្រសិទ្ធភាពឥតឈប់ឈរ ចំពោះការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យធំៗ នៅក្នុងធនាគារ និងបានប្តេជ្ញាបន្តធ្វើការត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ រួមបញ្ចូលទាំងការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ ប្រតិបត្តិការ និងការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ព្រមទាំងការគ្រប់គ្រងហានិភ័យផងដែរ។

រចនាសម្ព័ន្ធនៃការគ្រប់គ្រងពីក្រុមហ៊ុនមេ

រចនាសម្ព័ន្ធគ្រប់គ្រង



របាយការណ៍ព័ត៌មានរបស់ធនាគារ

(គិតត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩)

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល

Dato' Shaarani Ibrahim
ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ
(លាលែងពីតំណែងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

Dato' Wira Zainal Abidin Mahamad Zain
ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ
(តែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

បណ្ឌិត ម៉ី កល្យាណ
អភិបាលឯករាជ្យមិនប្រតិបត្តិ

Aisyah Lam Binti Abdullah
អភិបាលឯករាជ្យមិនប្រតិបត្តិ
(តែងតាំង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

ប៊ុន យីន
អភិបាលមិនឯករាជ្យប្រតិបត្តិ

Dato' Shahrul Nazri Abdul Rahim
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

Yong Jiunn Run
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

Renzo Christopher Viegas
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

គណៈកម្មាធិការសវនកម្ម

បណ្ឌិត ម៉ី កល្យាណ
ប្រធាន/អភិបាលឯករាជ្យមិនប្រតិបត្តិ

Dato' Shaarani Ibrahim
អភិបាលឯករាជ្យមិនប្រតិបត្តិ
(លាលែងពីតំណែងជាសមាជិក នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

Dato' Wira Zainal Abidin Mahamad Zain
អភិបាលឯករាជ្យមិនប្រតិបត្តិ

Aisyah Lam Binti Abdullah
អភិបាលឯករាជ្យមិនប្រតិបត្តិ
(តែងតាំង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

គណៈកម្មាធិការហានិភ័យ

Dato' Wira Zainal Abidin Mahamad Zain
អភិបាលឯករាជ្យមិនប្រតិបត្តិ
(លាលែងពីតំណែងជាប្រធាននាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

Aisyah Lam Binti Abdullah
អភិបាលឯករាជ្យមិនប្រតិបត្តិ
(តែងតាំងជាប្រធាន នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)

ប៊ុន យីន
ប្រធាននាយកប្រតិបត្តិ

Neoh Sze Ming
អនុប្រធាននាយកប្រតិបត្តិ
(លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨)

គៀន វឌ្ឍនា
នាយកគ្រប់គ្រងហានិភ័យ

ហុង ជៀប
នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

ហេង ធីតា
នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

ហេង វិបុត្រ
នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ
(តែងតាំងជាសមាជិកនាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨)

ហេង វុទ្ធី
នាយកហិរញ្ញវត្ថុ

គី សាណា
នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ

គណៈកម្មាធិការឥណទានកម្ពុជា

គៀន វឌ្ឍនា
ប្រធាន/នាយកគ្រប់គ្រងហានិភ័យ

ប៊ុន យីន
ប្រធានជំនួស/ប្រធាននាយកប្រតិបត្តិ

ហុង ជៀប
នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
(តែងតាំងជាសមាជិកនាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨)

ហេង ធីតា
នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

ចំណាន វនិតា
គ្រប់គ្រងឥណទាន
(តែងតាំងជាសមាជិកនាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨)

John Chuah Keat Kong
ទីប្រឹក្សាឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

គី សាណា
នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ

ហុង ប៊ុនឿត
ឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

Chong Kok Ping
នាយកគ្រប់គ្រងឥណទានថ្នាក់តំបន់
(តែងតាំងជាសមាជិកនាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩)

Hiroshi Kawachi
នាយកគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ
(តែងតាំងជាសមាជិកនាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩)

Michael Ng Mun Seng
នាយកវិភាគហានិភ័យឥណទានថ្នាក់តំបន់ស្តីទី
(តែងតាំងជាសមាជិកនាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩)

Leong Wai Chyi
ប្រធានក្រុម NBFI Regional GBIL/GCL
(តែងតាំងជាសមាជិកនាថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩)

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

ប៊ុន យីន
ប្រធាន/ប្រធាននាយកប្រតិបត្តិ

Neoh Sze Ming
អនុប្រធាននាយកប្រតិបត្តិ
(លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨)

ហេង ធីតា
នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

ហុង ជៀប
នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
(តែងតាំងជាសមាជិក នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨)

ហេង វុទ្ធី
នាយកហិរញ្ញវត្ថុ

ហេង គូរ៉េង
នាយករតនាគារ និងទីផ្សារ

គី សាណា
នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ

គៀន វឌ្ឍនា
នាយកគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រង

ប៊ុន យីន
ប្រធាននាយកប្រតិបត្តិ

Neoh Sze Ming
ប្រធានជំនួស/អនុប្រធាននាយកប្រតិបត្តិ
(លាលែងពីតំណែងជាសមាជិក នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨)

ហេង ធីតា
នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

ហេង គូរ៉េង
នាយករតនាគារ និងទីផ្សារ

ហុង ជៀប
នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
(តែងតាំងជាសមាជិក នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨)

គៀន វឌ្ឍនា
នាយកគ្រប់គ្រងហានិភ័យ

ហេង វុទ្ធី
នាយកហិរញ្ញវត្ថុ

អ៊ុំ ចិន្តាភក្តី
នាយកធនធានសាជីវកម្ម

ហេង វិបុត្រ
នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ
(តែងតាំងជាសមាជិក នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨)

គី សាណា
នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ

អ៊ុក ថានិន
នាយកគ្រប់គ្រងផលិតផល
(តែងតាំងជាសមាជិក នាថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩)

លេខាធិការក្រុមហ៊ុន៖

លី សោភា
Datin Rossaya Mohd Nashir

លេខចុះបញ្ជី៖
០០០១០៥២៤

ការិយាល័យចុះបញ្ជី៖
២០អាបេ មហាវិថីព្រះនរោត្តម កែងផ្លូវ១១៨
សង្កាត់ផ្សារចាស់ រាជធានីភ្នំពេញ ១២២០៣
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៨៨ ៣៨៨
ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៨៨ ០៩៩
គេហទំព័រ៖ www.cimbbank.com.kh

សវនករ៖
PricewaterhouseCoopers (Cambodia) Ltd.
៥៨C មហាវិថីព្រះសីហនុ ខណ្ឌចំការមន
រាជធានីភ្នំពេញ ១២២១០
ប្រអប់សំបុត្រ៖ ១១៤៧
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៦០ ៦០៦
ទូរសារ៖ +៨៥៥ ២៣ ២១១ ៥៩៤

CIMB
BANK
CAMBODIA

ព្រឹត្តិការណ៍សំខាន់ៗ និង ការចុះផ្សាយក្នុងសារព័ត៌មាន នៅឆ្នាំ២០១៨

៥២ ព្រឹត្តិការណ៍សំខាន់ៗ

៥៩ ការចុះផ្សាយក្នុងសារព័ត៌មាន

ព្រឹត្តិការណ៍សំខាន់ៗ

ពិធីសម្ពោធផលិតផល និងបណ្តាញសាខា

ទិវាសិទ្ធិនារីអន្តរជាតិ ឆ្នាំ២០១៨
ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ នៅការិយាល័យកណ្តាល អគារវីក្រាស់ រាជធានីភ្នំពេញ

តាមរយៈការគាំទ្រ ពីក្រសួងកិច្ចការនារី ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិ ក្រោមអធិបតីភាពលោកជំទាវ ញ៉ែម មរកត រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងប្រធាននាយកប្រតិបត្តិរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ដោយមានការចូលរួមពីបុគ្គលិកជាង ៦០នាក់ កម្មវិធីនេះ ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់របស់ស្ត្រី ក្នុងការអភិវឌ្ឍសង្គម និងជាផ្នែកមួយ នៃការអបអរដល់ស្ត្រី ក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក ហើយជាពិសេសសម្តែងសេចក្តីថ្លែងអំណរគុណ ដល់បុគ្គលិកស្ត្រីទាំងអស់របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ីផងដែរ។

ទិវាថ្លែងអំណរគុណអតិថិជន ឆ្នាំ២០១៨
ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ នៅសាខាបាក់ទូក រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធទិវាថ្លែងអំណរគុណអតិថិជន ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែរ។ កម្មវិធីនេះបានបង្កើតភាពភ្ញាក់ផ្អើលរីករាយ ដល់អតិថិជនទាំងអស់ ដែលបានអញ្ជើញមកសាខាធនាគារទូទាំងប្រទេស ដោយមានការផ្តល់ជូនភេសជ្ជៈ និងអាហារសម្រន់ ព្រមទាំងកាដូអនុស្សាវរីយ៍ផងដែរ។ ដើម្បីបង្ហាញពីការថ្លែងអំណរគុណចំពោះការបន្តគាំទ្ររបស់អតិថិជន គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ រួមទាំងប្រធាននាយកប្រតិបត្តិ អនុប្រធាននាយកប្រតិបត្តិ និងនាយកសេវាកម្មហិរញ្ញបុគ្គល បានបង្ហាញវត្តមាន និងបម្រើអតិថិជនដោយផ្ទាល់ នៅសាខាផងដែរ។

សិក្ខាសាលាអតិថិជន ឆ្នាំ២០១៨
ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នៅសណ្ឋាគារ HIMAWARI រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងក្រុមហ៊ុន មេនូឡាយហ្វ៍ ខេមបូឌា បានសហការប្រារព្ធធ្វើកម្មវិធីជប់លៀង សម្រាប់អតិថិជន Preferred របស់ធនាគារ ដើម្បីអបអរសាទរ និងថ្លែងអំណរគុណ ចំពោះការបន្តគាំទ្ររបស់ពួកគេ ដល់ធនាគារ ស៊ីអាយអិមប៊ី និងក្រុមហ៊ុន មេនូឡាយហ្វ៍។ កម្មវិធីនេះក៏ផ្តល់ឱកាសឲ្យអ្នកចូលរួម ដើម្បីទំនាក់ទំនងអាជីវកម្មរួមគ្នាផងដែរ។

កម្មវិធីជួបជុំបុគ្គលិក និងកសាងក្រុមការងាររបស់ធនាគារ ស៊ីអាយអិមប៊ី ថ្ងៃទី២៨-៣០ ខែមេសា ឆ្នាំ២០១៨ នៅខេត្តមណ្ឌលគិរី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំកម្មវិធីជួបជុំបុគ្គលិក និងកសាងក្រុមការងារ ដើម្បីបង្កើតនូវអនុស្សាវរីយ៍រីករាយ និងគួរឲ្យចងចាំ ព្រមទាំងពង្រឹងស្មារតីក្រុមការងារ ក្នុងចំណោមគ្រួសារធនាគារ ស៊ីអាយអិមប៊ី ។ ដើម្បីឆ្លុះបញ្ចាំង និងរៀនសូត្រជំនាញភាពជាអ្នកដឹកនាំ តាមរយៈវិញ្ញាសារប្រកួតប្រជែង ធនាគារបានរៀបចំដំណើរកម្សាន្ត ជាលក្ខណៈបោះជំរុំ ជាមួយនឹងសកម្មភាពការងារជាក្រុមមួយចំនួន រួមមានដំណើរស្វែងរកទីក្រុង ការប្រកួតថតរូប ដុតភ្លើងគប់ និងការសម្តែងជាក្រុមជាដើម។ កម្មវិធីជួបជុំរីករាយនេះ គឺជាការលើកទឹកចិត្តដល់បុគ្គលិកទាំងអស់ ដែលជួយឲ្យធនាគារសម្រេចបានគោលដៅប្រចាំឆ្នាំរបស់ធនាគារ។

កម្មវិធីកសាងក្រុមការងារ នៃគណៈកម្មាធិការគ្រប់គ្រង
ថ្ងៃទី០៩-១១ ខែសីហា ឆ្នាំ២០១៨ នៅសណ្ឋាគារ សូហ្វីតែល រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំកម្មវិធីហ្វឹកហាត់ និងកសាងក្រុមការងារ នៃគណៈកម្មាធិការគ្រប់គ្រង ដែលមានបុគ្គលិកជាន់ខ្ពស់ចូលរួម ប្រមាណ ៦០នាក់ រួមមាន ប្រធាននាយកប្រតិបត្តិ និងអនុប្រធាននាយកប្រតិបត្តិរបស់ធនាគារ។ កម្មវិធីនេះបានបង្កើត នូវក្របខណ្ឌមួយ ក្នុងការកសាង និងពង្រឹងស្មារតីភាពជាក្រុមការងារ ក៏ដូចជាចែករំលែក និងឆ្លុះបញ្ចាំងពីលទ្ធផលអាជីវកម្មព្រមទាំងកំណត់ផែនការយុទ្ធសាស្ត្រថ្មីៗដើម្បីសម្រេចបាន គោលដៅរបស់ធនាគារ។

កម្មវិធីសម្ពោធការយល់ដឹងអំពី 3D
ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ នៅសណ្ឋាគារ សូហ្វីតែល រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធពិធីសម្ពោធជាផ្លូវការ ការយល់ដឹងអំពី 3D ក្នុងចំណោមបុគ្គលិករបស់ធនាគារ ក្នុងប្រទេសកម្ពុជា។ ស្របតាមយុទ្ធសាស្ត្រ និងគោលដៅ របស់ ស៊ីអាយអិមប៊ី គ្រុប អ្នកចូលរួមត្រូវបានបណ្តុះបណ្តាលជាមួយនឹងលំហាត់អនុវត្តន៍ ពីអ្នក ជំនាញថ្នាក់តំបន់ លើការយល់ដឹងអំពី 3D រួមមានឌីជីថល (Digital) ទិន្នន័យ (Data) និងការរំខាន (Disruption)។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងជួយឲ្យបុគ្គលិករបស់ ធនាគារ ស៊ីអាយអិមប៊ី ដើម្បីត្រៀមខ្លួនរួចរាល ចំពោះអនាគត ទៅលើបដិវត្តថ្មី នៃបច្ចេកវិទ្យា ក្នុងវិស័យធនាគារ។

កម្មវិធីជួបជុំបុគ្គលិកប្រចាំឆ្នាំ របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ នៅអគារ City Hall កោះពេជ្រ រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធពិធីជួបជុំបុគ្គលិកប្រចាំឆ្នាំ ដើម្បីអបអរ ខួបទី៨ឆ្នាំ នៃការបើកដំណើរការធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាព ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមេ និងប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេរបស់ ស៊ីអាយអិមប៊ី គ្រុប។ នៅក្នុងកម្មវិធីដ៏វិសេសវិសាលនេះ គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានប្រារព្ធពិធីខួបកំណើត និងជប់លៀងលាគ្នា ដល់ប្រធាន ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមេ។ ជាការថ្លែងអំណរគុណ ដល់បុគ្គលិក សម្រាប់ការបន្តគាំទ្រ និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ធនាគារបានប្រគល់ពានរង្វាន់ខុសៗគ្នាផងដែរ ដល់បុគ្គលិក រួមមានពានរង្វាន់បម្រើការងាររយៈពេល៥ឆ្នាំ បុគ្គលិកផ្នែកលក់ឆ្នើមប្រចាំឆ្នាំ សាខាឆ្នើមប្រចាំឆ្នាំ និងបុគ្គលិកផ្នែកគាំទ្រអាជីវកម្មឆ្នើមប្រចាំឆ្នាំ។

រាត្រីថ្លែងអំណរគុណអតិថិជន របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ នៅភោជនីយដ្ឋាន Topaz រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធធ្វើរាត្រីថ្លែងអំណរគុណអតិថិជន ដោយមាន ការចូលរួមពីអតិថិជន Preferred ប្រមាណ ១០០នាក់ ក្រោមអធិបតីភាពប្រធាននាយក ប្រតិបត្តិ និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារផងដែរ។ ធនាគាររៀបចំកម្មវិធីរីករាយនេះ ដើម្បីថ្លែងអំណរគុណ ដល់អតិថិជន សម្រាប់ការបន្តជឿទុកចិត្ត និងគាំទ្ររបស់ពួកគេ នាពេល កន្លងមក។ ព្រឹត្តិការណ៍នេះបានបង្កើតនូវឱកាស និងអនុស្សាវរីយ៍ល្អៗ រវាងគណៈគ្រប់គ្រង របស់ធនាគារ និងអតិថិជន ក្នុងការរៀនសូត្រ និងស្វែងយល់ពីគ្នា ទៅវិញទៅមក។ ជាមួយ នឹងអាហារបែបអឺរ៉ុបដ៏ឈ្ងុយឆ្ងាញ់ អមដោយវង់តន្ត្រីពិរោះរណ្តំ ភ្ញៀវកិត្តិយសទាំងអស់ទទួល បានភាពរីករាយ ក្នុងការបង្កើតបណ្តាញទំនាក់ទំនង ទាំងក្នុងកិច្ចការជំនួញ និងលក្ខណៈបុគ្គល ជាមួយគ្នា។

ព្រឹត្តិការណ៍ និងការឧបត្ថម្ភកម្មវិធី

សន្និសីទអាហារូបករណ៍
ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ នៅវិទ្យាស្ថាន បច្ចេកវិទ្យា នៃកម្ពុជា រាជធានីភ្នំពេញ

សន្និសីទអាហារូបករណ៍
ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាកូរ៉េ

ស្របតាមគម្រោងថ្នាក់តំបន់របស់ ស៊ីអាយអិមប៊ី គ្រុប ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានឧបត្ថម្ភកម្មវិធីនេះ ដើម្បីលើកកម្ពស់ និងផ្សព្វផ្សាយអាហារូបករណ៍តំបន់អាស៊ានរបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងឆ្នាំ២០១៨ នៅប្រទេសកម្ពុជា។ សន្និសីទនេះត្រូវបានរៀបចំឡើង ដើម្បីកសាងសមត្ថភាពសិស្សនិស្សិតកម្ពុជា ដើម្បីសម្រេចបានជោគជ័យ ក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍នៅបរទេស តាមរយៈការយល់ដឹង ដោយមានការចែករំលែកពីស្ថាប័នគន្លឹះសំខាន់ៗ ផ្នែកអាហារូបករណ៍ រួមមានបណ្ណាស្ថានទូត គណៈកម្មាធិការជ្រើសតាំង និងសមាគមនិស្សិតអាហារូបករណ៍ជាដើម។

ពិព័រណ៍កុមារ និងគ្រួសារ លើកទី៥
ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ

ពិព័រណ៍កុមារ និងគ្រួសារ លើកទី៥ គឺជាពិព័រណ៍ធំបំផុតមួយ ក្នុងប្រទេសកម្ពុជា។ ដោយមានការរៀបចំជារៀងរាល់ឆ្នាំ ព្រឹត្តិការណ៍ គឺជាទិវាគ្រួសារមួយ សម្រាប់ឪពុកម្តាយ និងកុមាររីករាយនឹងសកម្មភាពកម្សាន្តដ៏សម្បូរបែប និងទទួលយកអ្វីថ្មីៗ។ មានក្រុមហ៊ុន ចំនួនជាង ១៧០ បានចូលរួមក្នុងពិព័រណ៍នេះ ជាមួយនឹងអ្នកចូលរួមទស្សនាប្រមាណ ៣០.០០០នាក់។ ធនាគារ ស៊ីអាយអិមប៊ី ក៏បានរួមចំណែកផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្មសម្រាប់ឪពុកម្តាយ ដែលបានចូលរួមផងដែរ។

ពិព័រណ៍រថយន្ត ឆ្នាំ២០១៨
ថ្ងៃទី០៦-០៨ ខែមេសា ឆ្នាំ២០១៨ នៅអគារ Exchange Square រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមក្នុងពិព័រណ៍នេះ ជាមួយនឹងក្រុមហ៊ុនរថយន្តថ្មីទំនើបៗឈានមុខ ក្នុងប្រទេសកម្ពុជា ក្នុងនាមជាអ្នកឧបត្ថម្ភតែមួយគត់ ពីវិស័យធនាគារ។ ដោយមានអ្នកចូលរួមទស្សនាប្រមាណ ១០.០០០នាក់ យើងបានរៀបចំស្តង់ពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយឥណទានរថយន្ត ក៏ដូចជាផលិតផល និងសេវាកម្មដទៃទៀតផងដែរ។។

ទិវាសិទ្ធិកុមារ អន្តរជាតិ
ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ នៅសាលាអន្តរជាតិ CIA FIRST រាជធានីភ្នំពេញ

វិស័យអប់រំ គឺជាសសរគ្រឹះមួយ នៃទំនួលខុសត្រូវសង្គមរបស់ធនាគារ ស៊ីអាយអិមប៊ី ហើយយើងបានចូលរួមយ៉ាងទៀងទាត់ ជាមួយបណ្តាសាលារៀន នៅទូទាំងប្រទេស ដើម្បីរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង ពីវិស័យអប់រំ។ ធនាគារមានក្តីសោមនស្សរីករាយ ដែលបានចូលរួមជាមួយសាលាអន្តរជាតិ CIA FIRST ដើម្បីប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិ និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ក្នុងប្រទេសកម្ពុជា។ យើងក៏បានរៀបចំសកម្មភាពកម្សាន្តមួយចំនួន សម្រាប់កុមារ និងអ្នកចូលរួមកម្មវិធីផងដែរ។

ពិព័រណ៍អាពាហ៍ពិពាហ៍ ឆ្នាំ២០១៨
ថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ

ពិព័រណ៍អាពាហ៍ពិពាហ៍ ឆ្នាំ២០១៧ គឺជាពិព័រណ៍ធំបំផុតមួយ ក្នុងប្រទេសកម្ពុជា ហើយមានការគាំទ្រពីក្រសួងពាណិជ្ជកម្ម និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ចំណុចចម្បងនៃពិព័រណ៍នេះ គឺជាការផ្សព្វផ្សាយកញ្ចប់ និងសេវាកម្មរៀបចំអាពាហ៍ពិពាហ៍ ដោយមានអ្នកចូលរួមទស្សនា ប្រមាណ ៣០.០០០នាក់។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ ធនាគារ ស៊ីអាយអិមប៊ី ក៏បានរួមចំណែកផ្សព្វផ្សាយអំពីផលិតផល និងសេវាកម្មសម្រាប់ដៃគូជិតរៀបការ និងគូស្រករថ្មីថ្មោងផងដែរ។

វេទិកាការងារ
ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំវេទិកាការងារ ដើម្បីបង្កើតឱកាសការងារ រវាងនិយោជិត និងនិយោជក តាមរយៈការសម្ភាសការងារផ្ទាល់មុខ។ ក្រុមហ៊ុន និងគ្រឹះស្ថានឯកជនពីវិស័យផ្សេងគ្នា រួមមានវិស័យធនាគារ និងហិរញ្ញវត្ថុចូលរួមក្នុងវេទិកានេះ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមកម្មវិធីនេះ ដើម្បីចែករំលែកព័ត៌មានអាជីពការងារ និងជ្រើសរើសបុគ្គលិកបន្ថែម។

កម្មវិធីប្រឡងថ្នាក់ជាតិ ឆ្នាំ២០១៨ របស់
ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ

ស្របតាមការផ្តោតសំខាន់ លើការលើកកម្ពស់វិស័យអប់រំ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមឧបត្ថម្ភដល់កម្មវិធីប្រឡងនេះ ដើម្បីគាំទ្រ UCMAS កម្ពុជា ដែលជាសាលាដៃគូមួយរបស់ធនាគារ។ សិស្សប្រមាណ ២.៥០០នាក់ បានចូលរួមប្រកួត ដើម្បីដណ្តើមជើងឯកនៃកម្មវិធីប្រឡងថ្នាក់ជាតិនេះ។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ ធនាគារបានរៀបចំស្តង់តាំងបង្ហាញ និងបង្កើតកម្មវិធីកម្សាន្តសប្បាយ រួមមាន «ការប្រកួតស្វែងរកចំណុចខុសគ្នា» និងការប្រកួតគំនូរ និងផាត់ពណ៌ ដើម្បីបង្កើតភាពរីករាយ ដល់កុមារ និងអាណាព្យាបាលផងដែរ។

សន្និសីទស្តីពីអាជីពការងារ ក្នុងវិស័យធនាគារ និងធានារ៉ាប់រង
ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ នៅសណ្ឋាគារ សូហ្វីតែល រាជធានីភ្នំពេញ

សន្និសីទ ស្តីពីអាជីពការងារ ក្នុងវិស័យធនាគារ និងធានារ៉ាប់រង ត្រូវបានរៀបចំឡើងដោយសាលាពាណិជ្ជកម្ម CamEd ដែលមាននិស្សិត និងអ្នកតំណាងមកពីធនាគារ និងក្រុមហ៊ុនធានារ៉ាប់រងនានា ក្នុងប្រទេសកម្ពុជា ប្រមាណ៥០០នាក់។ យើងបានចូលរួមឧបត្ថម្ភកម្មវិធីនេះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីស្លាកសញ្ញាធនាគារ ក្នុងចំណោមនិស្សិត និងផ្សព្វផ្សាយឱកាសការងារ ជាមួយធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីនៃឯកឧត្តមទេសាភិបាលធនាគារជាតិ នៃកម្ពុជា។

ពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០១៨
ថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍ កោះពេជ្រ រាជធានីភ្នំពេញ

ពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០១៨ គឺជាពិព័រណ៍ផ្សព្វផ្សាយការងារធំជាងគេប្រចាំឆ្នាំ ដែលត្រូវបានជ្រោមជ្រែង និងរៀបចំដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមក្នុងពិព័រណ៍នេះ ដើម្បីជួយគាំទ្រនៃការបង្កើតឱកាសការងារ និងការអភិវឌ្ឍយុវជនឲ្យកាន់តែល្អប្រសើរ។ ក្នុងអំឡុងពេលព្រឹត្តិការណ៍នេះ យើងបានរៀបចំស្តង់ផ្សព្វផ្សាយ និងផ្តល់ជូនឱកាសការងារ ជាមួយនឹងធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសកម្ពុជា ក្នុងចំណោមអ្នកចូលរួមប្រមាណ ៣០.០០០នាក់។

សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបច្ចុប្បន្នភាព
នៃច្បាប់សារពើពន្ធ សម្រាប់សហគ្រាសអ្នកជាប់ពន្ធធំ
ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារ ភ្នំពេញ រាជធានីភ្នំពេញ

សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបច្ចុប្បន្នភាព
នៃច្បាប់សារពើពន្ធ សម្រាប់សហគ្រាសអ្នកជាប់ពន្ធធំ
ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ

ដោយមានការគាំទ្រ ពីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះ ក្នុងគោលបំណងបណ្តុះបណ្តាលក្រុមហ៊ុនធំៗ ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែច្បាស់ អំពីច្បាប់ ស្តីពីគណនេយ្យ និងសេវនកម្ម ក៏ដូចជាច្បាប់សារពើពន្ធចុងក្រោយ។ ក្នុងនាមជាក្រុមហ៊ុនល្អ ដែលគោរពច្បាប់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមឧបត្ថម្ភសិក្ខាសាលានេះ ដើម្បីបង្ហាញការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការរួមចំណែក ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រ និងចូលរួមអភិវឌ្ឍវិជ្ជាជីវៈសនវកម្ម និងគណនេយ្យ ក្នុងប្រទេស។

សន្និបាតជួបជុំគ្រួសារ Century 21 កម្ពុជា ប្រចាំឆ្នាំ
ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៨ នៅសណ្ឋាគារ សុខា រាជធានីភ្នំពេញ

ក្រុមហ៊ុន Century 21 កម្ពុជា បានប្រារព្ធពិធីជួបជុំ និងសន្និបាតបុគ្គលិកប្រចាំឆ្នាំ ដើម្បីអបអរដល់ការសម្រេចបានសមិទ្ធផលការងារ និងលទ្ធផលហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងចំណោមគណៈគ្រប់គ្រង និងបុគ្គលិក ដោយមានការចូលរួមពីម្ចាស់អាជីវកម្ម សហគ្រិន និងក្រុមហ៊ុនទាំងនៅក្នុងស្រុក និងអន្តរជាតិ។ មានការប្រារព្ធពិធីចែកពានរង្វាន់ ដែលប្រកាសជាផ្លូវការដល់ភ្នាក់ងារអចលនទ្រព្យដែលជោគជ័យបំផុត ភ្នាក់ងារប្រតិបត្តិការឆ្នើមបំផុត និងបុគ្គលិកភ្នាក់ងារប្រតិបត្តិការឆ្នើមបំផុត។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមឧបត្ថម្ភព្រឹត្តិការណ៍នេះ ដើម្បីកសាង និងពង្រឹងទំនាក់ទំនងអាជីវកម្ម ជាមួយនឹងក្រុមហ៊ុន Century 21 និងដំឡើងស្តង់ពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយផលិតផល និងសេវាកម្មធនាគារ ដល់ភ្ញៀវចូលរួម ប្រមាណ ៣០០នាក់។

ទិវាគ្រួសារ ប្រចាំឆ្នាំ
ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ នៅសាលាអន្តរជាតិ CIA FIRST រាជធានីភ្នំពេញ

ទិវាគ្រួសារប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងដោយសាលាអន្តរជាតិ CIA First ដោយមានអ្នកចូលរួម ប្រមាណ ១.០០០នាក់ ដើម្បីបង្កើនភាពស្និទ្ធស្នាល នៅក្នុងសង្គមគ្រួសារ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានក្តីសោមនស្សរីករាយ ក្នុងការចូលរួមឧបត្ថម្ភកម្មវិធីនេះ ហើយបានរៀបចំកម្មវិធីប្រឡងប្រាជ្ញា ជាមួយកុមារ ដោយផ្តល់នូវមឹកសន្សំប្រាក់ CIMB ជារង្វាន់សម្រាប់អ្នកទទួលបានជ័យលាភីផងដែរ។

កម្មវិធីប្រកួត 3D CONQUEST

កម្មវិធីប្រកួត 3D Conquest គឺជាការប្រកួតប្រជែងមួយ ដែលយកលំនាំតាមបែប Hackathon ជាមួយនឹងការប្រកួតប្រជែង ៣ ប្រភេទ រួមមានវិទ្យាសាស្រ្តទិន្នន័យ (Data Science) បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងការសរសេរកូដ (Coding) ក្នុងគោលបំណងស្វែងរក និងទាក់ទាញយុវជនឆ្នើម ផ្នែកឌីជីថល និងមានភាពច្នៃប្រឌិតខ្ពស់ ជាមួយនឹងផ្នត់គំនិតជាសហគ្រិនឈ្លាសវៃក្នុងតំបន់អាស៊ាន ដោយបើកឲ្យមានការចូលរួមពីនិស្សិតទាំងអស់។ «3D» គឺមកពីពាក្យ ទិន្នន័យ (Data) ឌីជីថល (Digital) និងការរំខាន (Disruption)។ ក្រៅពីរង្វាន់ទឹកប្រាក់សរុបចំនួន ១២០.០០០ ដុល្លារអាមេរិក សម្រាប់កម្មវិធីប្រកួតប្រជែងនេះ ម្ចាស់ជ័យលាភីថ្នាក់តំបន់ នឹងទទួលបានបទពិសោធន៍ដ៏កម្រ តាមរយៈទស្សនកិច្ច ទៅកាន់តំបន់ដ៏ល្បីល្បាញ ដែលមានឈ្មោះថា Silicon Valley នៅសហរដ្ឋអាមេរិក រួមទាំងឱកាសការងារជាមួយនឹងធនាគារ ស៊ីអាយអិមប៊ី បន្ទាប់ពីបញ្ចប់ការសិក្សាផងដែរ។

ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានចូលរួមក្នុងកម្មវិធីប្រកួតថ្នាក់តំបន់នេះជាលើកដំបូង ហើយយើងបានផ្សព្វផ្សាយយ៉ាងខ្លាំងក្លា ទៅដល់និស្សិតសាកលវិទ្យាល័យ ក្នុងប្រទេសកម្ពុជា។ ដោយមានកិច្ចសហការ ជាមួយបណ្តាសាកលវិទ្យាល័យមួយចំនួន ក្នុងរាជធានីភ្នំពេញ យើងរៀបចំកម្មវិធីតម្រង់ទិសជាច្រើន ដើម្បីលើកកម្ពស់ការយល់ដឹង អំពីកម្មវិធីប្រកួតនេះ និងលើកទឹកចិត្ត ដល់និស្សិតសាកលវិទ្យាល័យ ឲ្យមានចូលរួមប្រកួតកាន់តែច្រើន។ ជាលទ្ធផល យើងទទួលបានពាក្យស្នើសុំចូលរួមប្រកួត គួរឲ្យកត់សម្គាល់ ដែលក្នុងនោះមានក្រុមចុះឈ្មោះប្រកួតសរុប ចំនួន៤៩ មកពី១០សាកលវិទ្យាល័យ។ យើងបានរៀបចំកម្មវិធីតម្រង់ទិសមួយចំនួន នៅតាមទីកន្លែងខុសៗគ្នា ក្នុងរាជធានីភ្នំពេញដូចខាងក្រោម៖

កម្មវិធីតម្រង់ទិស សម្រាប់កម្មវិធីប្រកួត 3D CONQUEST របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ នៅសាកលវិទ្យាល័យ កម្ពុជា

កម្មវិធីតម្រង់ទិស សម្រាប់កម្មវិធីប្រកួត 3D CONQUEST របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ នៅអង្គការ PASSERELLES NUMERIQUES កម្ពុជា

កម្មវិធីតម្រង់ទិស សម្រាប់កម្មវិធីប្រកួត 3D CONQUEST របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ និងព័ត៌មាន

កម្មវិធីតម្រង់ទិស សម្រាប់កម្មវិធីប្រកួត 3D CONQUEST របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ នៅសាកលវិទ្យាល័យ ភ្នំពេញ អាមេរិកាំង

កម្មវិធីតម្រង់ទិស សម្រាប់កម្មវិធីប្រកួត 3D CONQUEST របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ នៅសាលាពាណិជ្ជកម្ម CamEd

កម្មវិធីប្រកួត 3D CONQUEST ថ្នាក់ជាតិ របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី

កម្មវិធីប្រកួត 3D CONQUEST ថ្នាក់ជាតិ របស់ធនាគារ ស៊ីអាយអិមប៊ី
ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅប្រទេសឥណ្ឌូនេស៊ី

ផ្អែកតាមលទ្ធផលនៃការប្រកួត មានក្រុមចំនួន ៧ មកពីប្រទេសកម្ពុជា ត្រូវបានជ្រើសរើសឲ្យចូលរួមប្រកួតថ្នាក់ជាតិ រយៈពេល២ថ្ងៃ ក្នុងប្រទេសឥណ្ឌូនេស៊ី និងសិង្ហបុរី។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានសម្របសម្រួល និងដឹកនាំក្រុមទាំង៧ ចូលរួមប្រកួតជាមួយក្រុមតំណាងប្រទេស នៅក្នុងតំបន់ រួមមានប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ ប្រ៊ុយណេ វៀតណាម ឡាវ និងហ្វីលីពីន។ ជាលទ្ធផល ក្រុមតំណាងប្រទេសកម្ពុជា មិនបានជាប់ទៅប្រកួតវគ្គផ្តាច់ព្រ័ត្រឡើយ។

កម្មវិធីទំនួលខុសត្រូវសង្គម

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំកម្មវិធីសប្បុរសធម៌មួយ សម្រាប់មន្ទីរពេទ្យបង្អែកបាទី ក្នុងខេត្តសៀមរាប។ ជាផ្នែកមួយនៃសកម្មភាពទំនួលខុសត្រូវសង្គម ដើម្បីជួយត្រឡប់ទៅដល់សង្គម ដែលយើងកំពុងប្រកបអាជីវកម្ម យើងបានរៀបចំព្រឹត្តិការណ៍នេះ ក្រោមប្រធានបទ «ធនាគារ CIMB យកចិត្តទុកដាក់លើសុខភាពមាតា និងកុមារ» ដើម្បីលើកកម្ពស់ការថែទាំសុខភាពមាតុភាព ក្នុងចំណោមប្រជាពលរដ្ឋ ដែលខ្វះខាត នៅតាមជនបទ។

យើងបានបរិច្ចាគសម្ភារៈពេទ្យសំខាន់ៗមួយចំនួន រួមមានកៅអីរុញ គ្រែសម្រាប់អ្នកជំងឺសង្គ្រោះបន្ទាន់ គ្រែសម្រាប់សម្រាលកូន គ្រែសម្រាកសម្រាប់អ្នកជំងឺ ឧបករណ៍វាស់ចង្វាក់បេះដូងទារក និងអ្នកជំងឺ និងជាពិសេស អេកូស្វង់ចង្វាក់បេះដូងទារកក្នុងផ្ទៃម្តាយ ដែលជាសម្ភារៈពេទ្យទំនើបដំបូងបំផុត នៅក្នុងមន្ទីរពេទ្យ។ ធនាគារជឿជាក់ថា សកម្មភាពសប្បុរសធម៌នេះបានជួយលើកកម្ពស់សុវត្ថិភាព និងសុខមាលភាព ចំពោះម្តាយ និងទារក ក្នុងប្រទេសកម្ពុជា ដែលជាក់ស្តែង នៅក្នុងមន្ទីរពេទ្យបង្អែកបាទីនេះតែម្តង។

គម្រោង «ធនាគារ CIMB យកចិត្តទុកដាក់លើសុខភាពមាតា និងកុមារ»
ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ នៅមន្ទីរពេទ្យបង្អែក បាទី ខេត្តតាកែវ

កីឡា

ពានរង្វាន់បាល់ទាត់ CEO របស់ធនាគារ ស៊ីអាយអិមប៊ី ឆ្នាំ២០១៨ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំកម្មវិធីប្រកួតពានរង្វាន់បាល់ទាត់ CEO របស់ធនាគារ ស៊ីអាយអិមប៊ី ដើម្បីលើកកម្ពស់សុខភាពរាងកាយ និងពង្រឹងស្មារតីសាមគ្គីភាពជាក្រុមក្នុងចំណោមបុគ្គលិកធនាគារ។ មានក្រុមបាល់ទាត់ចំនួន៤ ដែលមានកីឡាករប្រមាណ ៨០នាក់ បានចូលរួមប្រកួតចំនួន៨លើក ដើម្បីប្រជែងយកតំណែងជើងឯក។

ព្រឹត្តិការណ៍រត់ប្រណាំងពាក់កណ្តាលម៉ារាតុង អន្តរជាតិ អង្គរវត្ត ឆ្នាំ២០១៨ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ នៅអង្គរវត្ត ខេត្តសៀមរាប

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមក្នុងព្រឹត្តិការណ៍រត់ប្រណាំងពាក់កណ្តាលម៉ារាតុង អន្តរជាតិ អង្គរវត្ត ឆ្នាំ២០១៨ ដែលជាការរត់ប្រណាំងសប្បុរសធម៌ លើកទី២៣។ ព្រឹត្តិការណ៍នេះត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការហាមប្រាមនៃការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សជាតិ និងបង្កើនភាពជិតស្និទ្ធ និងអំពើល្អ ក្នុងសង្គមជាតិ។ មិនតែប៉ុណ្ណោះ វាក៏បានជួយលើកទឹកចិត្តដល់និយោជិត ក្នុងការរួមចំណែកក្នុងសកម្មភាពកីឡា និងលើកកម្ពស់ការថែរក្សាសុខភាពផងដែរ។

ការចុះផ្សាយក្នុងសារព័ត៌មាន

KHMER TIMES

CIMB Bank Celebrates Khmer New Year themed 'Customer's Day' @ Bak Touk Branch

CIMB Bank PLC (CIMB Bank) organised a Khmer New Year party themed 'Customer's Day' at all of its branches nationwide on April 11. Customers were pleasantly surprised to see that the bank had decorated its branches in Khmer traditional style, and they enjoyed a Trot Dance performance and Khmer cakes and refreshments served by the bank staff in Khmer traditional attire. In addition, customers also received Khmer scarves as a souvenir for the event.

The 'Customer's Day' event is not only an opportunity for senior management to be involved in frontline service, it is also a platform which facilitates direct feedback from customers.

By engaging with customers more closely, the bank's senior management are able to better understand issues and challenges faced by its customers.

KAMPUCHEA THMEY DAILY

KAMPUCHEA THMEY DAILY

LifeStyle
3D CONQUEST
WIN OVER USD120,000 CASH PRIZES AND A TRIP TO SILICON VALLEY
REGISTER NOW

CIMB preferred
Introducing Regional CIMB Preferred

CIMB BANK

CEN

The Phnom Penh Post
CIMB offers cash prizes of $120,000

ភ្នំពេញ ប៉ុស្តិ៍
CIMB preferred
CUSTOMER APPRECIATION NIGHT

KAMPUCHEA THMEY DAILY

The Khmer Daily Newspaper

sabay NEWS
WIN
CASH PRIZES OF OVER USD120,000
A TRIP TO SILICON VALLEY
REGISTRATION 18 SEPTEMBER - 7 OCTOBER 2018
3Dconquest.cimb.com
CIMB

SPECIAL REPORT
CEO POLL
PRODUCTS

Roving eye
Car Financing Options @ CIMB Bank
Swiss National Day Raclette @ Open Wine Restaurant

Looking TODAY
All Entertainment News & More
www.lookingtoday.com

KQUBE

CIMB BANK
© ThmeyThmey.com

០៤

ប្រវត្តិសង្ខេបរបស់ ក្រុមប្រឹក្សាភិបាល

៦៤ ក្រុមប្រឹក្សាភិបាល
៧១ លេខាធិការក្រុមហ៊ុនរួម
៧៤ គណៈកម្មាធិការគ្រប់គ្រង

DATO’ WIRA ZAINAL ABIDIN MAHAMAD ZAIN
ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ (តែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨)
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ២០១៨
- ជាសមាជិកគណៈកម្មាធិការសវនកម្ម

Dato’ Wira Zainal បានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ជំនាញទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យម៉ាឡាយ៉ា (University of Malaya)។

ចាប់តាំងពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ Dato’ Wira Zainal ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ បច្ចុប្បន្ន Dato’ Wira Zainal ក៏គឺជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ ស៊ីអាយអិមប៊ី វៀតណាម និងជាអភិបាលឯករាជ្យមិនប្រតិបត្តិ នៃក្រុមហ៊ុនម៉ាឡាយានផ្លាវអ័រមៀលប៊ើហាដ (Malayan Flour Mills Berhad) ផងដែរ។

ក្នុងអំឡុងពេលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ Dato’ Wira Zainal គឺជាប្រធានគណៈកម្មាធិការហានិភ័យរបស់ធនាគារ។

Dato’ Wira Zainal បានបម្រើការងារនៅក្រសួងការបរទេស តាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ហើយលោកបានទទួលបន្ទុកការងារផ្សេងៗគ្នាជាច្រើន ក្នុងអំឡុងពេលជាង ៤៤ ឆ្នាំ នៅក្នុងផ្នែកសេវាសាធារណៈនេះ។ លោកក៏ធ្លាប់បម្រើការជាបេសកជនពិសេសរបស់នាយករដ្ឋមន្ត្រីម៉ាឡេស៊ីប្រចាំប្រទេសអាហ្វហ្គានីស្ថានផងដែរ ក្នុងអំឡុងពីខែមិថុនា ឆ្នាំ២០១០ ដល់ខែធ្នូ ឆ្នាំ២០១៤។

ក្នុងអំឡុងពេលបំពេញមុខងាររយៈពេល ៤៤ ឆ្នាំ មកដល់បច្ចុប្បន្ន ដែល Dato’ Wira Zainal បានបម្រើការងារឲ្យរដ្ឋាភិបាលម៉ាឡេស៊ី លោកធ្លាប់បានតែងតាំងជាឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំប្រទេសប្រេស៊ីល វៀតណាម និងឥណ្ឌូនេស៊ី។ លោកក៏ធ្លាប់បំពេញមុខងារជាអគ្គនាយកទីមួយរបស់ប្រទេសម៉ាឡេស៊ីនៃមជ្ឈមណ្ឌលប្រឆាំងភេរវកម្មតំបន់អាស៊ីអាគ្នេយ៍ ដែលមានមូលដ្ឋាននៅកូឡាឡាំពួរ។ លោកក៏ធ្លាប់ជាតំណាងស្តីទីអចិន្ត្រៃយ៍អាស៊ានទីមួយរបស់ប្រទេសម៉ាឡេស៊ី ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី ក្នុងអំឡុងពេលពីខែមីនា ឆ្នាំ២០០៩ ដល់ខែកក្កដា ឆ្នាំ២០០៩។ លោកក៏ត្រូវបានតែងតាំងជាភារធារីម៉ាឡេស៊ីប្រចាំទីក្រុងតេអេរ៉ង់ ប្រទេសអ៊ីរ៉ង់ ជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំទីក្រុងអាប៊ុយដែប៊ី ប្រទេសអារ៉ាប់អេមីរ៉េត ជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំទីក្រុងជេដា ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត និងជាអគ្គកុងស៊ុលម៉ាឡេស៊ីប្រចាំ ទីក្រុងវ៉ាន់ខូវ័រ ប្រទេសកាណាដាផងដែរ។

បណ្ឌិត ម៉ី កល្យាណ
អភិបាលឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិខ្មែរ

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ២០១៨
- ជាប្រធានគណៈកម្មាធិការសវនកម្ម

បណ្ឌិត ម៉ី កល្យាណ បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ពីសាកលវិទ្យាល័យកូបេ (Kobe University) ប្រទេសជប៉ុន នៅឆ្នាំ១៩៨៤។ បន្ទាប់មក លោកបានទទួលការបណ្តុះបណ្តាល វគ្គជំនាញរយៈពេលខ្លីស្តីពី ការអភិវឌ្ឍពីទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងសាកលវិទ្យាល័យហាវឺដ (Harvard University)។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ លើផ្នែកអភិវឌ្ឍសេដ្ឋកិច្ចក្នុងពិភពលោក។

បច្ចុប្បន្ន លោកមានតួនាទីផ្លូវការចំនួន ៣ នៅក្នុងក្របខណ្ឌរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រួមមានដូចជា៖ (១)ទីប្រឹក្សាជាន់ខ្ពស់ (ឋានៈរដ្ឋមន្ត្រី) នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (Supreme National Economic Council) ដែលជាទីប្រឹក្សាសេដ្ឋកិច្ចរបស់នាយករដ្ឋមន្ត្រី (២)ប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង(៣)ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ មុនពេលចូលបម្រើតួនាទីទាំងនោះ លោកធ្លាប់បានបំពេញការងារជាអ្នកសេដ្ឋកិច្ចជាន់ខ្ពស់ សម្រាប់កម្មវិធីសហប្រតិបត្តិការរបស់ UN/FAO-World Bank ប្រចាំនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី អស់រយៈពេល ២០ ឆ្នាំ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ លោកក៏ជាមន្ត្រីហិរញ្ញវត្ថុរបស់សាជីវកម្ម Kanematsu Gosho ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នៅទីក្រុងអូសាកា និងទីក្រុងតូក្យូផងដែរ។ ក្រៅពីតួនាទីក្នុងក្របខណ្ឌរាជរដ្ឋាភិបាល លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលមួយរូបនៃក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹសួរ៉ិនស៍ ភីអិលស៊ី គិតចាប់តាំងពីខែធ្នូ ឆ្នាំ២០១៣ មក។ ក្នុងអំឡុងពេលនៃវិជ្ជាជីវៈរបស់លោក លោកក៏បានធ្វើទស្សនកិច្ច និងបំពេញការងារនៅតាមបណ្តាប្រទេសចំនួនប្រហែលជា ១០០ លើពិភពលោក។

ជាមួយនឹងបទពិសោធន៍ និងចំណេះដឹងដ៏ទូលំទូលាយ ដែលទទួលបានពីគ្រប់ទិសទី នៅជុំវិញពិភពលោក លោកមានកិត្តិយសយ៉ាងខ្លាំង ដើម្បីចូលរួមចំណែកជួយអភិវឌ្ឍប្រទេសកម្ពុជាទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ។ លោកមានជំនឿថា ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុគឺជាគន្លឹះសំខាន់មួយដែលនាំប្រទេសកម្ពុជាទៅរកការអភិវឌ្ឍ និងភាពជោគជ័យ។

AISYAH LAM BINTI ABDULLAH
អភិបាលឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៣ លើកក្នុងឆ្នាំ ២០១៨
- ជាប្រធានគណៈកម្មាធិការហានិភ័យ
- ជាសមាជិកគណៈកម្មាធិការ សវនកម្ម

លោកស្រី Aisyah Lam ត្រូវបានតែងតាំងជាអភិបាលឯករាជ្យ និងជាប្រធាននៃគណៈកម្មាធិការ ហានិភ័យរបស់ធនាគារចាប់តាំងពីថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៨។ លោកស្រីក៏ជាអភិបាលឯករាជ្យនៃធនាគារ ស៊ីអាយអិមប៊ី វៀតណាម និងជាប្រធាននាយកប្រតិបត្តិការនៃក្រុមគ្លីនិកចាប់សសៃអាមេរិក (The American Chiropractic Clinic group) នៅប្រទេសវៀតណាមផងដែរ។

ចាប់ផ្តើមដំបូងនៃអាជីពការងារក្នុងវិស័យធនាគារ លោកស្រីបានធ្វើការនៅឲ្យធនាគារ Standard Chartered Bank។ បន្ទាប់ពីនោះ លោកស្រីបានប្តូរទៅបម្រើការនៅធនាគារ Deutsche (ប្រទេសម៉ាឡេស៊ី) ក្នុង ឆ្នាំ១៩៩៤ នៅកន្លែងនោះលោកស្រីបានកាន់តួនាទីជាប្រធានគ្រប់គ្រងសាច់ប្រាក់សាជីវកម្ម ដោយបានបង្កើតពាណិជ្ជកម្មសាជីវកម្ម និងអាជីវកម្មអន្តរការណ៍តាមប្រព័ន្ធអ៊ីនធើណេតដំបូងគេ សម្រាប់ធនាគារ Deutsche នៅក្នុងប្រទេសម៉ាឡេស៊ី ហើយបន្ទាប់មកទៀតចូលរួមក្នុងក្រុមផ្នែកលក់ថ្នាក់តំបន់ នៅប្រទេសសិង្ហបុរី។ នៅក្នុងឆ្នាំ ២០០១ លោកស្រីបានផ្លាស់ប្តូរការងារទៅក្រុមហ៊ុន IslamicQ.com Asia (ទីក្រុងឌូបៃ) ដែលនៅទីនោះ លោកស្រីជាអ្នកគ្រប់គ្រងប្រចាំប្រទេស ទទួលខុសត្រូវលើការគ្រប់គ្រង អភិវឌ្ឍ និងអនុវត្តយុត្តិសាស្ត្រអាជីវកម្មនៅក្នុងតំបន់អាស៊ីនៃក្រុមហ៊ុននោះ។

នៅឆ្នាំ ២០០៣ លោកស្រី Aisyah បានវិលត្រលប់មកប្រទេសម៉ាឡេស៊ី មកកាន់តួនាទីជាអគ្គនាយក គ្រប់គ្រងទ្រព្យសម្បត្តិ នៃធនាគារ Hong Leong Bank Berhad។ ជាមួយតំណែងនេះ លោកស្រីទទួលខុសត្រូវលើការពង្រីកអាជីវកម្ម ការបង្កើនផលហ្វូលីយ៉ូនៃទ្រព្យសកម្ម ក្រោមការគ្រប់គ្រង ការអភិវឌ្ឍ និងការគ្រប់គ្រង អាទិភាពរបស់ធនាគារ ក៏ដូចជាចាត់ចែងបណ្តាញផ្នែកលក់នៃធនាគារជាន់ខ្ពស់ បន្ថែមទៅលើផ្នែកទំនាក់ទំនងសាខា។ លោកស្រី Aisyah ក៏បានផ្លាស់ទៅបម្រើការងារនៅធនាគារ Citibank ក្នុងឆ្នាំ២០០៦ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍផលហ្វូលីយ៉ូរបស់ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ធនាគារនេះ នៅប្រទេសក្នុងម៉ាឡេស៊ី។

លោកស្រី Aisyah បានសម្រេចចិត្តចាកចេញពីទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងឆ្នាំ២០១០ ដើម្បីចាប់យកបទពិសោធន៍ថ្មី ក្នុងការបង្កើតផ្នែកអាជីវកម្មលក់រាយ ឲ្យធនាគារ Ngan Hang TMCP Bac A។ បេសកម្មនាពេលនោះ គឺដើម្បីដាក់ចេញនូវហេដ្ឋារចនាសម្ព័ន្ធក្នុងធនាគារ ដើម្បីគាំទ្រដល់សេវាកម្ម និងផលិតផលអាជីវកម្មលក់រាយសំខាន់ៗ ស្របតាមគម្រោងយុទ្ធសាស្ត្រ ក្នុងការកសាង និងបណ្តុះផ្នែកនេះឲ្យក្លាយជាអាជីវកម្មចម្បងរបស់ធនាគារ។ បន្ទាប់ពីគម្រោងចប់សព្វគ្រប់អស់ លោកស្រីបានវិលត្រលប់ទៅធនាគារ Hong Leong Bank Vietnam ដែលនៅទីនោះ ពីឆ្នាំ២០១២ ដល់ ២០១៥ លោកស្រីបានអភិវឌ្ឍ និងកសាងអាជីវកម្មសេវាកម្មហិរញ្ញវត្ថុបុគ្គល សម្រាប់ធនាគារនេះ នៅក្នុងប្រទេសវៀតណាម។

ចាប់ផ្តើមពីការងារក្នុងវិស័យធនាគារ លោកស្រី Aisyah បានប្តូរការងារទៅវិស័យថែរក្សាសុខភាពវិញនៅក្នុងឆ្នាំ២០១៦ ហើយបច្ចុប្បន្ននេះលោកស្រីគ្រប់គ្រងក្រុមគ្លីនិកចាប់សសៃ ក្នុងប្រទេសវៀតណាម ទាំងលើគ្រប់ផ្នែកនៃប្រតិបត្តិការ ក៏ដូចជាការអភិវឌ្ឍអាជីវកម្ម។

លោកស្រី Aisyah Lam បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែក Chartered Marketing ពី Chartered Institute of Banking ចក្រភពអង់គ្លេស។

DATO' SHAHRUL NAZRI ABDUL RAHIM
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន ០៦ លើក ក្នុងចំណោម កិច្ចប្រជុំទាំង ០៧លើក ក្នុងឆ្នាំ២០១៨

Dato' Nazri អាយុ ៤៤ឆ្នាំ បច្ចុប្បន្នជានាយកអភិវឌ្ឍសាជីវកម្មរបស់ ស៊ីអាយអិមប៊ី គ្រុប។ លោកចូលរួមធ្វើការជាមួយ ស៊ីអាយអិមប៊ី គ្រុប នៅក្នុងខែមករា ឆ្នាំ២០១៤។

Dato' Nazri បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យអង់គ្លីយ៉ា (Anglia University) ចក្រភពអង់គ្លេស។ លោកក៏ទទួលបានវិញ្ញាបនបត្រ ផ្នែកអនុវត្តវិជ្ជាជីវៈច្បាប់ ពីសាកលវិទ្យាល័យម៉ាឡាយ៉ា (University of Malaya) ប្រទេសម៉ាឡេស៊ី វិញ្ញាបនបត្រ លើវគ្គបណ្ដុះបណ្ដាលផ្នែកអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ពីសាលាពាណិជ្ជកម្មកូឡុំប៊ី (Columbia Business School) និងវិញ្ញាបនបត្របណ្ដុះបណ្ដាលពីសាលាហាវើដ។

លោកចាប់ផ្ដើមអាជីពការងារជាមួយមុខតំណែងជាដៃគូសហការរបស់ការិយាល័យមេធាវី ភេធឺរ ខ្លេតុន និងសហការី (Peter Clayton & Partners) នៅចក្រភពអង់គ្លេស ដែលជាមួយតំណែងនោះ តួនាទីសំខាន់មួយដែលលោកទទួលបន្ទុកគឺជួយការងារដៃគូគ្រប់គ្រង (សាស្ត្រាចារ្យ Peter Clayton) នៅក្នុងការអនុវត្តវិជ្ជាជីវៈច្បាប់ប្រចាំថ្ងៃ។

នៅក្នុងឆ្នាំ ១៩៩៦ Dato' Nazri ត្រឡប់មកប្រទេសម៉ាឡេស៊ី ដែលនៅទីនោះ លោកបានចូលរួមបង្កើតសេវាកម្មគ្រប់គ្រងសាច់ប្រាក់ ជាមួយធនាគារក្នុងស្រុកមួយ ហើយលោកបានទទួលបទពិសោធន៍ នៅក្នុងវិស័យសេវាកម្មបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងហិរញ្ញវត្ថុជាច្រើន។

មុនចូលបម្រើការជាមួយ ស៊ីអាយអិមប៊ី គ្រុប Dato' Nazri គឺជាប្រធាននាយកយុទ្ធសាស្ត្រនៃធនាគារមេយប៊ែង គីម អេង (Maybank Kim Eng) និងជានាយកការិយាល័យប្រធាននាយកប្រតិបត្តិ នៃធនាគារមេយប៊ែង អ៊ីនវេសមិន ប៊ើហាដ (Maybank Investment Bank Bhd) ដែលជាអង្គភាពរួមបញ្ចូលគ្នាមួយ រវាងធនាគារមេយប៊ែង អ៊ីនវេសមិន ប៊ើហាដ (Maybank Investment Bank Bhd) និងក្រុមហ៊ុន គីម អេង (Kim Eng Ltd.) ហើយលោកបានចូលរួមយ៉ាងសកម្ម នៅក្នុងកម្មវិធីសមាហរណកម្មក្រោយការរួមបញ្ចូលគ្នា (Post Merger Integration) ការគ្រប់គ្រងការផ្លាស់ប្ដូរ (Transformation Management) និងការពង្រីកថ្នាក់តំបន់ នៅទូទាំង ១០ ប្រទេស។

មុនចូលកាន់តួនាទីជាមួយនឹងធនាគារមេយប៊ែង លោកក៏ជាអនុប្រធានការិយាល័យគ្រប់គ្រងការផ្លាស់ប្ដូរ និងយុទ្ធសាស្ត្រ (Group Strategy & Transformation Management Office) នៅ ខេ & អិន កេណាងកា ប៊ើហាដ (K & N Kenanga Bhd) (ដែលជាក្រុមធនាគារវិនិយោគមួយ) ជាអនុប្រធាននៃត្យូន ម៉ាន់នី អេសឌីអិន ប៊ើហាដ (Tune Money Sdn Bhd) ដែលជាសេវាកម្មហិរញ្ញវត្ថុតាមអនឡាញដែលផ្ដល់សេវាកម្មចម្បង («no-frills» online financial service) ដំបូងគេរបស់អាស៊ី និងជាស្ថាបនិកនៃអាយភើរីនទីស អេសឌីអិន ប៊ើហាដ (iPerintis Sdn Bhd) និងជាអ្នកបង្កើតសេវាកម្មបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងសេវាកម្មហិរញ្ញវត្ថុអាជីវកម្មតាមប្រព័ន្ធអ៊ីនធើណេតរបស់ភេត្រូណាស់ គ្រុប (PETRONAS Group) ដែលសេវាកម្មនេះជម្រុញតម្រូវការផ្នែកបច្ចេកវិទ្យារបស់ភេត្រូណាស់ គ្រុប យ៉ាងខ្លាំង។

RENZO CHRISTOPHER VIEGAS
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិឥណ្ឌា

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន ០៦ លើក ក្នុងចំណោមកិច្ចប្រជុំទាំង ០៧លើក ក្នុងឆ្នាំ២០១៨

លោក Renzo Christopher Viegas ជនជាតិឥណ្ឌាស្នាក់នៅអចិន្ត្រៃយ៍ ក្នុងប្រទេសម៉ាឡេស៊ី បានទទួលសញ្ញាបត្របរិញ្ញាបត្រពាណិជ្ជកម្ម ពីសាកលវិទ្យាល័យប៉ុំបៃ (University of Bombay)។ លោកក៏ជាសមាជិកសមាគមន៍និស្សិតនៃវិទ្យាស្ថាន Chartered Accountants នៃប្រទេសឥណ្ឌា និងទទួលបានការបណ្តុះបណ្តាលក្លាយជាគណនេយ្យករជំនាញមួយរូបផងដែរ។

បច្ចុប្បន្ន លោក Viegas គឺជាទីប្រឹក្សាឲ្យប្រធាននាយកប្រតិបត្តិរបស់ ស៊ីអាយអិមប៊ី គ្រុប (CIMB Group) ដោយលោកផ្តល់ដំបូន្មានពាក់ព័ន្ធនឹងយុទ្ធសាស្ត្រផ្សេងៗ និងការអនុវត្តគម្រោងអាជីវកម្មសំខាន់ៗផ្សេងទៀតរបស់ ស៊ីអាយអិមប៊ី គ្រុប ។

លោកមានបទពិសោធន៍ជាច្រើន នៅក្នុងវិស័យធនាគារ។ លោកចាប់ផ្តើមអាជីពការងារ ជាមួយធនាគារ ស៊ីធីប៉ែង (Citybank) ក្នុងឆ្នាំ១៩៨៥ ដែលនៅទីនោះលោកបានចាប់ផ្តើមកាន់តួនាទីថ្នាក់ខ្ពស់មួយចំនួន នៅតាមបណ្តាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជាបន្តបន្ទាប់ រួមទាំងតួនាទីទទួលខុសត្រូវថ្នាក់តំបន់។ ក្នុងឆ្នាំ២០០៨ លោក Viegas បានចូលបម្រើការងារឲ្យធនាគារម៉ាឡេស៊ីមួយ ដែលនៅទីនោះ លោកបានឡើងកាន់តំណែងជានាយកគ្រប់គ្រងរង មុនពេលលោកចូលបម្រើការងារឲ្យ ស៊ីអាយអិមប៊ី គ្រុប នៅក្នុងខែមេសា ឆ្នាំ២០១២ ក្នុងតំណែងជាអនុប្រធាននាយកប្រតិបត្តិ។ បន្ទាប់មក លោកត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធាននាយកប្រតិបត្តិថ្នាក់តំបន់ ទទួលបន្ទុកសេវាកម្មហិរញ្ញវត្ថុបុគ្គល រហូតដល់ពេលលោកផ្លាស់ទៅកាន់តួនាទីបច្ចុប្បន្នរបស់លោក ក្នុងខែកក្កដា ឆ្នាំ២០១៦។

លោក Viegas ក៏ធ្លាប់ជាអភិបាលរបស់ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ (CIMB Bank Berhad) ក្រុមហ៊ុនធានារ៉ាប់រងសាន់ឡាយហ្វ៍ម៉ាឡេស៊ី (Sun Life Malaysia Assurance Berhad) និងក្រុមហ៊ុនធានារ៉ាប់រង (Takaful) សាន់ឡាយហ្វ៍ម៉ាឡេស៊ី (Sun Life Malaysia Takaful Berhad)។ សព្វថ្ងៃនេះ លោកក៏ជាអភិបាលមួយរូបរបស់ក្រុមហ៊ុនអាស្ត្រូម៉ាឡេស៊ីហូលឌីងប៊ើហាដ (Astro Malaysia Holdings Berhad) និងធនាគារ ស៊ីអាយអិមប៊ី វៀតណាម ផងដែរ។

YONG JIUNN RUN
អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិសឹង្ហបុរី

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន ០៦ លើក ក្នុងចំណោមកិច្ចប្រជុំទាំង ០៧លើក ក្នុងឆ្នាំ២០១៨

លោក Yong Jiunn Run បានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ជំនាញសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ ពីសាកលវិទ្យាល័យជាតិសឹង្ហបុរី (National University of Singapore)។

លោក Yong Jiunn Run ចាប់ផ្តើមការងារជាមួយធនាគារ ស៊ីអាយអិមប៊ី សឹង្ហបុរី (CIMB Bank Singapore) ក្នុងឆ្នាំ២០១១ ក្នុងតំណែងជានាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ដែលក្នុងតំណែងនេះ លោកទទួលបន្ទុកបង្កើតយុទ្ធសាស្ត្រ និងដឹកនាំអាជីវកម្មសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី សឹង្ហបុរី ដែលរួមមានបណ្តាក្រុមហ៊ុនពាក់កណ្តាលសាជីវកម្ម (Mid-Corporate) និងសហគ្រាសធុនតូច និងមធ្យមដែលទើបបង្កើតឡើងថ្មីៗ។

លោក Yong Jiunn Run ទទួលបាននូវបទពិសោធន៍ ក្នុងអាជីវកម្មសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្មយ៉ាងច្រើនលើសលប់ ក្នុងរយៈពេល ២៨ឆ្នាំ កន្លងមកនេះ ដែលដំបូងឡើយលោកចាប់ផ្តើមអាជីពការងាររបស់លោក ក្នុងតួនាទីជាបុគ្គលិកផ្នែកសេវាកម្មអតិថិជន និងបន្ទាប់មកទទួលខុសលើការងារផ្នែកគ្រប់គ្រង និងតួនាទី ក្នុងកិច្ចការសំខាន់ៗមួយចំនួនទៀត នៅអំឡុងពេលដែលលោកបម្រើការងារឲ្យធនាគារ មេយប៊ែង (Maybank) ធនាគារប៊ីអិនភី ប៉ារីបាស (BNP Paribas) និងសាជីវកម្មធនាគារចិនក្រៅប្រទេស (Oversea-Chinese Banking Corporation)។

ប៊ុន យីន
ប្រធាននាយកប្រតិបត្តិ/អភិបាលមិនឯករាជ្យប្រតិបត្តិ

សញ្ជាតិខ្មែរ

- ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧ លើក ក្នុងឆ្នាំ២០១៨
- ជាសមាជិកគណៈកម្មាធិការ ហានិភ័យ

លោក ប៊ុន យីន បានទទួលសញ្ញាបត្រឧត្តមសិក្សាផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងធនាគារ ពីក្រសួងហិរញ្ញវត្ថុ កម្ពុជា នៅឆ្នាំ១៩៨៧។

លោក ប៊ុន យីន ត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីការកាន់តំណែងជាអគ្គនាយករងរបស់ធនាគារ ចាប់តាំងពីពេលបង្កើតធនាគារដំបូង នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក លោកត្រូវបានតែងតាំងជាអភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោកក៏ជាសមាជិកនៃគណៈកម្មាធិការហានិភ័យរបស់ធនាគារផងដែរ។

ក្នុងតំណែងជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យីន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

លោក ប៊ុន យីន បម្រើការនៅក្នុងវិស័យធនាគារអស់រយៈពេលជាង ៣៨ឆ្នាំ។ ជាមួយបទពិសោធន៍ធនាគារយ៉ាងច្រើនសន្ធឹកសន្ធាប់ និងទំនាក់ទំនងល្អជាមួយអតិថិជនទាំងក្នុងស្រុក និងអតិថិជនថ្នាក់តំបន់ បានធ្វើឲ្យលោកក្លាយជាបុគ្គលដ៏សំខាន់មួយរូប ក្នុងការដឹកនាំអាជីវកម្មរបស់ធនាគារ។ លោកក៏ត្រូវបានទទួលស្គាល់ថាជាបុគ្គលដ៏សំខាន់មួយរូប នៅក្នុងឧស្សាហកម្មធនាគារទាំងមូលផងដែរ។

DATIN ROSSAYA MOHD NASHIR
លេខាធិការក្រុមហ៊ុនរួម

សញ្ជាតិម៉ាឡេស៊ី

Datin Rossaya Mohd Nashir បច្ចុប្បន្នគឺជាលេខាធិការក្រុមហ៊ុនរបស់ ស៊ីអាយអិមប៊ី គ្រុប (CIMB Group)។ លោកស្រីចូលបម្រើការងារជាមួយធនាគារ នៅក្នុងឆ្នាំ២០០២ ដោយចូលធ្វើការក្នុងការិយាល័យសេវាកម្មនីតិកម្មក្រុមហ៊ុន។ លោកស្រីគឺជាបុគ្គលមួយរូប ដែលជួយបង្កើតនាយកដ្ឋានលេខាធិការក្រុមហ៊ុនឡើង នៅក្នុងឆ្នាំ២០០៤ និងត្រូវបានតែងតាំងជាលេខាធិការក្រុមហ៊ុនរបស់ ស៊ីអាយអិមប៊ី គ្រុប នៅក្នុងឆ្នាំ២០០៦។

ជាមួយតួនាទីជាលេខាធិការក្រុមហ៊ុន លោកស្រីទទួលខុសត្រូវក្នុងការផ្តល់ការប្រឹក្សា និងដំបូន្មានសមស្របពាក់ព័ន្ធនឹងតួនាទី និងកាតព្វកិច្ចផ្សេងៗរបស់ក្រុមប្រឹក្សាភិបាល ដើម្បីធានាថា ស៊ីអាយអិមប៊ី អនុវត្តអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ តំណែងរបស់លោកស្រីបានពង្រីកដើម្បីគ្របដណ្តប់ប្រតិបត្តិការតាមតំបន់របស់ស៊ីអាយអិមប៊ី គ្រុប ដោយលោកស្រីដើរតួនាទីជាអ្នកទំនាក់ទំនង រវាងក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ ទាំងនៅក្នុងប្រទេសម៉ាឡេស៊ី និងនៅក្នុងប្រតិបត្តិការថ្នាក់តំបន់របស់ ស៊ីអាយអិមប៊ី គ្រុប ដើម្បីធានាថាក្របខណ្ឌអភិបាលកិច្ចធនាគារ ត្រូវបានរៀបចំក្នុងលក្ខណៈមួយ ដែលគាំទ្រដល់ទស្សនវិស័យរបស់ ស៊ីអាយអិមប៊ី គ្រុប។ លើសពីអភិបាលកិច្ចបែបបុរាណ លោកស្រីក៏ដើរតួនាទីជា ប្រភពធនធាន និងជាបុគ្គលជំនិតមួយរូបឲ្យក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ផងដែរ។

លោកស្រីមានចំណេះដឹងផ្នែកវិស័យធនាគារយ៉ាងទូលំទូលាយ ជាមួយបទពិសោធន៍ក្នុងការងារលេខាធិការក្រុមហ៊ុនជាងពីរទសវត្សរ៍។ មុនចូលបម្រើការងារនៅក្នុង ស៊ីអាយអិមប៊ី គ្រុប លោកស្រីបម្រើការងារឲ្យក្រុមហ៊ុន ភើម៉ូដាឡាន ណេសិនណល បើហាដ (Permodalan National Berhad) ក្នុងតំណែងជាលេខាធិការក្រុមហ៊ុនរួមនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួននៃក្រុមហ៊ុននេះ។ លោកស្រីបានចាប់ផ្តើមអាជីពការងារដំបូង នៅក្រុមហ៊ុន ថាម អេនជីនៀរីង គ្រុប (Time Engineering Group)។

Datin Rossaya គឺជាសមាជិកមួយរូបនៃវេទិកាប្រឹក្សា អំពីនីតិវិធីក្រុមហ៊ុន (Corporate Practice Consulative Forum) របស់គណៈកម្មាការក្រុមហ៊ុននៃម៉ាឡេស៊ី (Companies Commission of Malaysia) ហើយក៏ជាអភិបាលមួយរូបនៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួន នៅក្នុង ស៊ីអាយអិមប៊ី គ្រុប។ លោកស្រីគឺជាជើងឯកនិរន្តភាព ស៊ីអាយអិមប៊ី (CIMB Sustainability Champion)។ លោកស្រីបានផ្តួចផ្តើមគម្រោងមួយចំនួន ដើម្បីជំរុញនិរន្តរភាពនៅក្នុងកន្លែងធ្វើការឲ្យ #teamcimb។ លោកស្រីចូលរួមយ៉ាងសកម្ម ក្នុងការជំរុញការចូលរួមរបស់ស្ត្រី ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយលោកស្រីបានចូលរួមសកម្មភាព ក្នុងកិច្ចផ្តួចផ្តើមតាមលក្ខណៈបណ្តាញផ្សេងៗ ដើម្បីលើកកម្ពស់បញ្ហានេះផងដែរ។

លី សោភា
លេខាធិការក្រុមហ៊ុនរួម

សញ្ជាតិខ្មែរ

លោកស្រី លី សោភា មានតួនាទីជាលេខាធិការក្រុមហ៊ុនរួមរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃចាប់ផ្តើមប្រតិបត្តិការដំបូងរបស់ធនាគារ នៅខែវិច្ឆិកា ឆ្នាំ២០១០ មកម្ល៉េះ។ លោកស្រី គឺជាលេខាធិការក្រុមហ៊ុនរួមមួយរូបនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រីក៏ជាលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រង និងជាអ្នកចូលរួមអចិន្ត្រៃយ៍ក្នុងគណៈកម្មាធិការផ្សេងៗទៀត របស់ធនាគារ ដែលក្នុងនោះរួមមានគណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជា។

មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី ធ្លាប់បម្រើការងារជាជំនួយការ នាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងនាយកផ្នែកនីតិកម្ម និងកិច្ចការក្រុមហ៊ុននៅក្នុងធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុនអស់រយៈពេល ០៦ ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុននៅកន្លែង ដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រី ក៏ទទួលបានបរិញ្ញាបត្រជំនាញ គណនេយ្យ ពីមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជាសាកលវិទ្យាល័យពុទ្ធិសាស្ត្រ) ផងដែរ។ នៅឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

គណៈកម្មាធិការ
គ្រប់គ្រង

ហេង ធីតា
នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

សញ្ជាតិខ្មែរ

លោកស្រី ហេង ធីតា ទទួលបន្ទុកគ្រប់គ្រងទូទៅ និងសកម្មភាពហិរញ្ញវត្ថុ លើផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គលរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ហើយភារកិច្ចរបស់លោកស្រីរួមមានផ្នែកអភិវឌ្ឍន៍ផលិតផល ផ្នែកលក់ និងចែកចាយ និងផ្នែកគ្រប់គ្រងឥណទាន ទៅលើអតិថិជនបុគ្គល។ លោកស្រីជាអ្នកបង្កើតយុទ្ធសាស្ត្រអាជីវកម្ម និងទទួលខុសត្រូវ ទៅលើផ្នែកចែកចាយផលិតផលតាមសាខា សេវាកម្មហិរញ្ញវត្ថុជាន់ខ្ពស់ (Preferred Banking) ឥណទានគេហដ្ឋាន ឥណទានរថយន្ត និងសេវាកម្មប័ណ្ណឥណទាន (Credit Cards)។

លោកស្រី ហេង ធីតា ចាប់ផ្តើមអាជីពការងារជាបុគ្គលិកផ្នែកលក់ នៅក្នុងក្រុមហ៊ុននាំចេញ នាំចូល ហើយបន្ទាប់មកបានធ្វើការ នៅក្នុងក្រុមហ៊ុនផ្សាយពាណិជ្ជកម្មអន្តរជាតិមួយ អស់រយៈពេល ៤ ឆ្នាំ ផ្នែកទំនាក់ទំនងអតិថិជន មុននឹងលោកស្រីចេញទៅបន្តការសិក្សា នៅប្រទេសជប៉ុន។ ក្រោយពេលវិលមកប្រទេសកម្ពុជាវិញ លោកស្រីបានចូលបម្រើការងារ ជាអ្នកផ្តល់ប្រឹក្សា ដល់ធនាគារពិភពលោក ក្នុងកម្មវិធីមេគង្គអភិវឌ្ឍន៍ឯកជន (Mekong Private Development Facility)។

មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី ធីតា ធ្លាប់បំពេញការងារនៅធនាគារធំមួយ ក្នុងប្រទេសកម្ពុជា អស់រយៈពេល ៨ឆ្នាំ ដែលក្នុងអំឡុងពេលនោះ លោកស្រីកាន់តួនាទីគ្រប់គ្រងមួយចំនួន ដូចជានាយកផ្នែកទីផ្សារ នាយកផ្នែកគាំទ្រសេវាកម្មហិរញ្ញវត្ថុបុគ្គល ហើយបន្ទាប់មកជានាយកផ្នែកគ្រប់គ្រងបណ្តាញសាខា។

លោកស្រី ហេង ធីតា ទទួលបានបរិញ្ញាបត្រពីសាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) នៅរាជធានីភ្នំពេញ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកទីផ្សារ និងអាជីវកម្ម នៅសាកលវិទ្យាល័យអន្តរជាតិនៃប្រទេសជប៉ុន។

ហុង ជៀប
នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

សញ្ជាតិខ្មែរ

ជាមួយនឹងបទពិសោធន៍ការងារជាច្រើនឆ្នាំ នៅក្នុងវិស័យធនាគារពាណិជ្ជ លើផ្នែកបម្រើសេវាកម្មអតិថិជន ព្រមទាំងផ្នែកគ្រប់គ្រងហានិភ័យ លោក ហុង ជៀប មានចំណេះដឹង លើវិស័យធនាគារ និងអតិថិជន ក្នុងការផ្តល់នូវយោបល់ដល់ផ្នែក ដែលពាក់ព័ន្ធ ក្នុងដំណើរការអាជីវកម្មរបស់ធនាគារ ព្រមទាំងការគ្រប់គ្រងហានិភ័យ។ លោក ហុង ជៀប ក៏ធ្លាប់បានបម្រើការងារជានាយកគ្រប់គ្រងហានិភ័យ របស់ធនាគារបរទេសមួយ នៅក្នុងប្រទេសឡាវផងដែរ។ មុនពេលក្លាយជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ លោក ហុង ជៀប ធ្លាប់កាន់តំណែងជា នាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលលោកត្រូវទទួលបន្ទុក ផ្នែកគ្រប់គ្រងហានិភ័យទូទៅ និងជាប្រធានគណៈកម្មការឥណទាន នៅក្នុងធនាគារ ដោយធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាព ដែលពាក់ព័ន្ធ ដើម្បីធានាការអនុវត្តដ៏ខ្ជាប់ខ្ជួននូវវប្បធម៌គ្រប់គ្រងហានិភ័យ នៅក្នុងធនាគារទាំងមូល។

ក្នុងមុខតំណែងជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម លោក ហុង ជៀប ទទួលបន្ទុកផ្នែកថែរក្សា និងបង្កើនគុណភាព ផ្នែកឥណទាន ប្រមូលប្រាក់បញ្ញើ ដើម្បីសម្រេចបានគោលដៅមូលធនរបស់ធនាគារ ពង្រីកប្រសិទ្ធភាពក្រុមការងារ និងស្មារតីក្រុម រួមទាំងបង្កើនចំណូលមិនមែនការប្រាក់របស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម។ ក្រៅពីនេះ លោក ហុង ជៀប បានពង្រឹងសហប្រតិបត្តិការ រវាងក្រុមការងារសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងក្រុមការងារដទៃទៀត នៅក្នុងធនាគារ ដើម្បីពង្រីកការលក់ តាមរយៈការណែនាំបន្ត និងការទាក់ទងអតិថិជនឲ្យប្រើផលិតផល និងសេវាកម្មផ្សេងៗទៀត ក្នុងគោលបំណងផ្តល់នូវបទពិសោធន៍បម្រើសេវាកម្មអតិថិជន ឲ្យកាន់តែល្អប្រសើរ។

លោក ហុង ជៀប ទទួលបានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ហើយបានបញ្ចប់កម្មវិធីភាពជាអ្នកដឹកនាំ CIMB-INSEAD ផងដែរ។

ហេង តូរ៉ង់
នាយករតនាគារ និងទីផ្សារ

សញ្ជាតិខ្មែរ

លោក ហេង តូរ៉ង់ ជាហេរញ្ញិកនៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ភារកិច្ចចម្បងរបស់លោក រួមមានការប្រមូលចាត់ចែងមូលនិធិ ការគ្រប់គ្រងតារាងតុល្យការ ការលក់រូបិយប័ណ្ណបរទេស ការលក់ផលិតផលវិនិយោគ ឬផលិតផលផ្សេងៗ ដែលផ្សារភ្ជាប់នឹងទីផ្សារ ព្រមទាំងផ្នែកទំនាក់ទំនងទូទៅ និងកម្រិតហានិភ័យរបស់ស្ថាប័នហិរញ្ញវត្ថុ។ ក្នុងការបំពេញមុខតំណែងលោកតែងមានទំនាក់ទំនងការងារជាប្រចាំ ជាមួយអតិថិជន ទាំងផ្នែកបុគ្គល និងក្រុមហ៊ុន។ លោកបានអភិវឌ្ឍជំនាញរបស់ខ្លួន លើផ្នែកផលិតផលទីផ្សារ ដូចជាការទិញ-លក់រូបិយប័ណ្ណបរទេស និស្សន្ទវត្ថុ ទីផ្សាររូបិយវត្ថុ និងអន្តរធនាគារ ព្រមទាំងសហការជាមួយអង្គភាពអាជីវកម្មនីមួយៗ ទាំងខាងក្នុង និងក្រៅតំបន់ ដើម្បីទ្រទ្រង់ឱកាសលក់ផ្សេងៗទៀត ដែលបង្កើនប្រាក់ចំណេញដល់ធនាគារនូវកម្រិតខ្ពស់បំផុត។ លោកបានចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងខែកញ្ញា ឆ្នាំ២០១០ ក្នុងមុខងារជាអ្នកគ្រប់គ្រងហានិភ័យ និងជាលេខាធិការរបស់គណៈកម្មាធិការហានិភ័យ រហូតដល់ពាក់កណ្តាលឆ្នាំ ២០១៣ មុនពេលលោកបានផ្លាស់ប្តូរទៅកាន់មុខតំណែងជានាយករតនាគារ។

មុនពេលចូលបម្រើការងារនៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោក ហេង តូរ៉ង់ ធ្លាប់ជាប្រធានផ្នែកគ្រប់គ្រងហានិភ័យរតនាគារ និងទីផ្សារ និងមានបទពិសោធន៍៦ឆ្នាំ លើផ្នែកគ្រប់គ្រងសាច់ប្រាក់ ក្នុងនាយកដ្ឋានរតនាគារ នៃធនាគារធំមួយនៅក្នុងប្រទេសកម្ពុជា។

លោក ហេង តូរ៉ង់ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបញ្ញាសាស្រ្ត នៃកម្ពុជា ក្នុងឆ្នាំ២០១១ និងបានបញ្ចប់វគ្គសិក្សា Accelerated Universal Bankers Program ពីសាកលវិទ្យាល័យបច្ចេកវិទ្យា ណាន់យ៉ាង (Nayang Technological University) ក្នុងប្រទេសសិង្ហបុរី នាឆ្នាំ២០១៤។ បច្ចុប្បន្ន លោកកំពុងបន្តការសិក្សាផ្នែកសញ្ញាបត្រគណនេយ្យ ជំនាញថ្នាក់គណនេយ្យករជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) នៅមជ្ឈមណ្ឌល ដែលទទួលបានអាជ្ញាប័ណ្ណពីចក្រភពអង់គ្លេសនៅក្នុងប្រទេសកម្ពុជា។

គី សាណា
នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងប្រតិបត្តិការធនាគារ

សញ្ជាតិខ្មែរ

លោកស្រី គី សាណា បានបម្រើការងារ ក្នុងវិស័យធនាគារ ជាង ១៧ ឆ្នាំ និងបានគ្រប់ដណ្តប់មុខងារជាច្រើនក្នុងវិស័យនេះ។ លោកស្រីបានចាប់ផ្តើមអាជីព ជាមួយនឹងធនាគារអន្តរជាតិជាច្រើន និងកាន់មុខតំណែងផ្សេងៗគ្នា គិតចាប់ពីផ្នែកសេវាកម្មជួរមុខ ដល់ផ្នែកការិយាល័យគាំទ្រកណ្តាល និងពីផ្នែកឥណទាន និងផ្នែកហិរញ្ញប្បទានពាណិជ្ជកម្ម ដល់គណៈគ្រប់គ្រងជាន់ខ្ពស់។ លោកស្រីបានចូលបម្រើការងារនៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ជាប្រធានសាខា ដែលជាសាខាដំបូងគេបង្អស់របស់ធនាគារ។ លោកស្រីទទួលបន្ទុកលើសេវាកម្មធនាគារជាន់ខ្ពស់ Preferred Banking និងសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មុនពេលត្រូវបានតែងតែជា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងប្រតិបត្តិការធនាគារ។ នៅក្នុងមុខតំណែងនេះ លោកស្រីទទួលខុសត្រូវ លើការគ្រប់គ្រងទំនាក់ទំនងសេវាកម្មធនាគារ ជាមួយអតិថិជនក្រុមហ៊ុនធំៗ និងសមិទ្ធិផលរបស់សេវាកម្មហិរញ្ញវត្ថុសាជីវកម្មទាំងមូល ក្នុងធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសកម្ពុជា។ លើសពីសេវាកម្មផ្តល់ឥណទានសាជីវកម្ម បែបប្រពៃណី លោកស្រីមានតួនាទី ក្នុងការផ្តល់ដំណោះស្រាយ និងគុណតម្លៃបន្ថែម ស្របនឹងតម្រូវការសេវាកម្មប្រតិបត្តិការធនាគារ រួមមានការគ្រប់គ្រងសាច់ប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាធនាគារតាមប្រព័ន្ធអ៊ីនធើណេត។

ក្នុងអំឡុងពេលនៃការបំពេញការងាររបស់ខ្លួន លោកស្រី ទទួលបានរង្វាន់មួយចំនួន រួមមាន៖

១. ពានរង្វាន់សាខាឆ្នើមប្រចាំឆ្នាំ ២០១១ ពីធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា
២. ពានរង្វាន់បុគ្គលិកឆ្នើមប្រចាំឆ្នាំ ២០១១ ពីធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា
៣. ពានរង្វាន់អឹមមើរ៉ល ឆ្នាំ ២០១៣ (Emerald Award 2013) សម្រាប់អ្នកគ្រប់គ្រងថ្នាក់កណ្តាល ពី ស៊ីអាយអិមប៊ី គ្រុប ជាដើម។

លោកស្រី គី សាណា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រ ផ្នែកគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រង និងចូលរួមវគ្គសិក្សា Accelerated Universal Bankers Program នៅសាកលវិទ្យាល័យបច្ចេកវិទ្យា ណាន់យ៉ាង (Nayang Technological University) ក្នុងប្រទេសសិង្ហបុរី។

អ៊ុំ ចិន្តាភក្តី
នាយិកាធនធានសាជីវកម្ម

សញ្ជាតិខ្មែរ

ក្នុងនាមជាស្ថាបនិកដំបូងគេមួយរូប និងជាអ្នកចាប់ផ្តើមរៀបចំចាត់ចែង ក្នុងការបង្កើតធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី អ៊ុំ ចិន្តាភក្តី ត្រូវបានតែងតាំងជាអ្នកទទួលបន្ទុកក្នុងការគ្រប់គ្រងដឹកនាំផ្តោតលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សដែលរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការគ្រប់គ្រងការអនុវត្តការងារ និងប្រាក់រង្វាន់លើកទឹកចិត្ត / ការចូលរួមសកម្មភាពសង្គមនានា ក្នុងន័យផ្សារភ្ជាប់ការប្រាស្រ័យទាក់ទងរវាងនិយោជិត និងនិយោជក / វប្បធម៌នៃការកសាង កិត្តិនាមស្ថាប័ន ការបណ្តុះបណ្តាលនិងការអភិវឌ្ឍ។

រហូតមកដល់បច្ចុប្បន្ន លោកស្រីនៅតែបន្តតួនាទីក្នុងការកសាង ពង្រឹង និងបង្កើនសមត្ថភាពនិយោជិត ក៏ដូចជាធនធានមនុស្ស តាមរយៈការផ្តល់នូវជំនាញល្អៗ និងចំណេះដឹងថ្មីៗ កម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍន៍នានា កម្មវិធីសិក្សាដ៏ទូលំទូលាយ ទាំងនៅក្នុងស្រុក និងនៅថ្នាក់តំបន់ ព្រមទាំងបង្កើតឲ្យមានការប្រកួតប្រជែងសមត្ថភាព ដើម្បីបង្កើនផលិតភាពរបស់ធនាគារទាំងមូល ហេតុនេះហើយ បានជាលោកស្រីតែងតែចាត់ទុកការទាញយក និងការរក្សាទុកនូវនិយោជិតសក្តានុពល ដែលមានទេពកោសល្យ ជាអាទិភាពចម្បង ព្រោះលក្ខខណ្ឌធនធានមនុស្សជាកត្តាសំខាន់ក្នុងការជួយពន្លឿនភាពរីកចម្រើន និងនិរន្តរភាពរបស់អាជីវកម្ម លក្ខខណ្ឌទាំងនេះសុទ្ធតែជាយុទ្ធសាស្ត្រសម្រាប់រយៈពេលខ្លី មធ្យម និង ទៅថ្ងៃអនាគតរបស់ធនាគារយើង ដើម្បីតាមឲ្យទាន់ការវិវឌ្ឍនៃយុគសម័យកាលឌីជីថល និងបច្ចេកវិទ្យាទំនើប។

ជាការពិតណាស់ លោកស្រីតែងតែបានធ្វើការសហការយ៉ាងជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំគ្រប់លំដាប់ ដើម្បីធានាឲ្យបានថា រាល់សមិទ្ធិផលទាំងឡាយដែលទទួលបាន របស់ធនាគារ ស៊ីអាយអិមប៊ី ស្របទៅតាមផែនការដូចដែលបានគ្រោងទុក ក្នុងការដាក់ចេញ ក្រោមការជួយគាំទ្រយ៉ាងមុតមាំ ដោយកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ថ្នាក់តំបន់។

មិនត្រឹមតែជាអ្នកគ្រប់គ្រងនាយកដ្ឋានធនធានមនុស្សប៉ុណ្ណោះទេ លោកស្រីក៏ត្រូវទទួលបន្ទុកជាអ្នកគ្រប់គ្រងនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងទ្រព្យសម្បត្តិផងដែរ ដោយរួមបញ្ចូលទាំងការគិតពីនីតិវិធី និងយុទ្ធសាស្ត្រនានា។

យ៉ាងណាមិញ លោកស្រីគឺជាបុគ្គលដ៏សំខាន់ម្នាក់ ដែលទទួលបន្ទុកគ្រប់គ្រងគម្រោងទ្រព្យសម្បត្តិចម្បងៗរបស់ធនាគារ ស៊ីអាយអិមប៊ី ដើម្បីធានាឲ្យបាន នូវរាល់គម្រោងទាំងនោះត្រូវបានចាត់ចែងដោយត្រឹមត្រូវ រីឯការចំណាយទៀតសោត ត្រូវតែប្រាកដថាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

គួររំលឹកទៅដល់ជីវប្រវត្តិរបស់លោកស្រីវិញ មុនពេលចាប់ផ្តើមចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី អ៊ុំ ចិន្តាភក្តី មានបទពិសោធន៍ជាង១៣ឆ្នាំ ក្នុងតំណែងជាអ្នកគ្រប់គ្រង ផ្នែកធនធានមនុស្ស ជាមួយបណ្តាស្ថាប័នជាច្រើនរួចមកហើយ។ លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីវិទ្យាស្ថានជាតិគ្រប់គ្រង។

ហេង វុទ្ធី
នាយកហិរញ្ញវត្ថុ

សញ្ជាតិខ្មែរ

លោក ហេង វុទ្ធី គឺជាបុគ្គលមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានចូលរួមដំបូង នៅពេលធនាគារបានបង្កើត ក្នុងឆ្នាំ២០១០។ ភារកិច្ចចម្បងរបស់លោក គឺរួមមានការគ្រប់គ្រងមុខងារហិរញ្ញវត្ថុ រៀបចំផែនការ ដឹកនាំ និងគ្រប់គ្រងបុគ្គលិក ក្នុងការអភិវឌ្ឍ អនុវត្ត និងរៀបចំគោលការណ៍ និងនីតិវិធី សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា គណនេយ្យ ពន្ធដារ និងរបាយការណ៍បទប្បញ្ញត្តិ ព្រមទាំងយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារទាំងមូល។

លោក វុទ្ធី ត្រួតពិនិត្យផងដែរ លើប្រព័ន្ធ និងរបាយការណ៍គណនេយ្យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការអាជីវកម្ម និងដើរតួនាទីជាអ្នកសម្របសម្រួល ជាមួយក្រុមហ៊ុនមេ នៅប្រទេសម៉ាឡេស៊ីផងដែរ។ មុនពេលចូលបម្រើការងារនៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកមានបទពិសោធន៍ ៨ឆ្នាំ ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់តួនាទីជា នាយករងហិរញ្ញវត្ថុ នៅធនាគារធំមួយក្នុងប្រទេសកម្ពុជា។

លោក វុទ្ធី បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយបានបញ្ចប់ការសិក្សាថ្នាក់គណនេយ្យករជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) ពីសាលាពាណិជ្ជកម្ម CamEd ដែលជាស្ថាប័នទទួលបានសិទ្ធិជាផ្លូវការ ពីចក្រភពអង់គ្លេស ក្នុងការបណ្តុះបណ្តាល ACCA នៅប្រទេសកម្ពុជា។

អ៊ុក ថានិន
នាយកគ្រប់គ្រងផលិតផល

សញ្ជាតិខ្មែរ

លោក អ៊ុក ថានិន បានចូលបម្រើការងារ នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១៧ ដែលមានតួនាទីត្រួតពិនិត្យ លើនាយកដ្ឋានគ្រប់គ្រងផលិតផល។ ទំនួលខុសត្រូវការងាររបស់លោក គឺរួមមានការរៀបចំ ការសម្របសម្រួល និងការអនុវត្តគម្រោងគោលការណ៍ និងសេចក្តីណែនាំ ដែលពាក់ព័ន្ធនឹងផលិតផលថ្មីៗ និងមានស្រាប់ ដើម្បីស្របតាមតម្រូវការទីផ្សារ។ ក្នុងឆ្នាំកន្លងមកនេះ លោកបានចាត់ចែងនាយកដ្ឋានគ្រប់គ្រងផលិតផល និងបាននាំយកផលិតផលថ្មីៗ ដោយជោគជ័យ ដូចជាឥណទានគេហដ្ឋាន ជាមួយនឹងការធានារ៉ាប់រងអាយុជីវិត ឥណទានបុគ្គល ផលិតផលប្រាក់បញ្ញើ និងឥណទានជាប្រាក់រៀល ដែលនាំឲ្យធនាគារ ស៊ីអាយអិមប៊ី កាន់តែមានភាពប្រកួតប្រជែងមួយកម្រិតទៀត នៅលើទីផ្សារ។ មិនតែប៉ុណ្ណោះ លោកក៏ដឹកនាំសម្របសម្រួល លើគម្រោងទូទាំងធនាគារជាច្រើនផងដែរ រួមមានគម្រោង FAST ធនាគារឌីជីថល សេវាធនាគារដោយខ្លួនឯង និងគម្រោងមួយចំនួនទៀត ជាមួយនឹងដៃគូខាងក្រៅរបស់ធនាគារ។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី លោកមានបទពិសោធន៍ ៩ឆ្នាំ នៅក្នុងវិស័យឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងផ្នែកផ្សេងៗគ្នា ដូចជាសេវាកម្មធានារ៉ាប់រងទូទៅ ការគ្រប់គ្រងឥណទាន និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម។

លោក អ៊ុក ថានិន ធ្លាប់ទទួលអាហារូបករណ៍ ពីរដ្ឋាភិបាលសិង្ហបុរី ដោយបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ពីសាកលវិទ្យាល័យជាតិ សិង្ហបុរី ក្នុងឆ្នាំ២០០៦។ ជាមួយគ្នានេះ លោកក៏ទទួលបានអាហារូបករណ៍ Fulbright ផងដែរ ដោយបានបញ្ចប់ថ្នាក់អនុបណ្ឌិត ពីសាកលវិទ្យាល័យ Vanderbilt នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១២ ហើយព្រមទាំងបានក្លាយជាសមាជិក Beta Gamma Sigma ដែលជាស្ថាប័នអន្តរជាតិ សម្រាប់ថ្នាក់ឧត្តមសិក្សាផ្នែកអាជីវកម្ម។

ហេង វិបុត្រ
នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ

សញ្ជាតិខ្មែរ

លោក ហេង វិបុត្រ បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃទី០១ ខែសីហា ២០១៨។ ក្នុងនាមជា នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ លោកទទួលបន្ទុកលើការដឹកនាំផ្នែកព័ត៌មានវិទ្យា សន្តិសុខព័ត៌មានវិទ្យា អភិបាលកិច្ចព័ត៌មានវិទ្យា និងប្រតិបត្តិការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យាឌីជីថល និងប្រតិបត្តិការស្នូលរបស់ធនាគារទាំងមូល។ មិនតែប៉ុណ្ណោះ លោកមានទំនួលខុសត្រូវ ក្នុងការរៀបចំយុទ្ធសាស្រ្ត ពិនិត្យមើលការអនុវត្តផែនការ ការកែលម្អដំណើរការអាជីវកម្ម និងអភិបាលកិច្ចប្រតិបត្តិការ ស្របតាមកំណើនអាជីវកម្ម ព្រមទាំងមុខងារការធានាលើការអនុលោមតាម ដើម្បីធានាបាននូវគុណភាពកិច្ចការប្រចាំថ្ងៃល្អប្រសើរ ដោយផ្អែកទៅលើគោលការណ៍ នីតិវិធី និងការអនុលោមតាមច្បាប់។

លោកវិបុត្រ មានបទពិសោធន៍ការងារជាង ១៦ឆ្នាំ នៅវិស័យធនាគារ ហើយលោកបានចាប់ផ្តើមអាជីពការងារជា វិស្វករសរសេរកម្មវិធីកុំព្យូទ័រ និងផ្តើមបង្កើតប្រព័ន្ធស្នូលរបស់ធនាគារ ក្នុងឆ្នាំ២០០៣។ មុនពេលចូលបម្រើការ នៅធនាគារ ស៊ីអាយអិមប៊ី លោកធ្លាប់បំពេញការងារជានាយកសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ជាមួយនឹងធនាគារក្នុងស្រុកដ៏ធំមួយ ក្នុងប្រទេសកម្ពុជា។

លោក ហេង វិបុត្រ ទទួលបានបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្រ្តកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

លី សោភា
នាយកនីតិកម្ម និងលេខាធិការក្រុមហ៊ុន

សញ្ជាតិខ្មែរ

លោកស្រី លី សោភា មានតួនាទីជានាយកនីតិកម្ម និងលេខាធិការក្រុមហ៊ុននៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃចាប់ផ្តើមប្រតិបត្តិការដំបូងរបស់ធនាគារ នៅខែវិច្ឆិកា ឆ្នាំ២០១០ មកម្ល៉េះ។ លោកស្រីទទួលបន្ទុកលើ និងចាត់ចែងតួនាទីលេខាធិការក្រុមហ៊ុន និងនីតិកម្ម។ លោកស្រី គឺជាលេខាធិការក្រុមហ៊ុន មួយរូបនៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រីក៏ជាលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រង និងជាអ្នកចូលរួមអចិន្ត្រៃយ៍ក្នុងគណៈកម្មាធិការផ្សេងៗទៀតរបស់ធនាគារ ដែលក្នុងនោះរួមមានគណៈកម្មាធិការហានិភ័យ។

មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី ធ្លាប់បម្រើការងារជាជំនួយការ នាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងនាយកផ្នែកនីតិកម្ម និងកិច្ចការក្រុមហ៊ុននៅក្នុងធនាគារធំមួយក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុនអស់រយៈពេល ០៦ ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុននៅកន្លែងដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានបរិញ្ញាបត្រជំនាញ គណនេយ្យ ពីមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជាសាកលវិទ្យាល័យពុទ្ធិសាស្ត្រ) ផងដែរ។ នៅឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញនីតិឯកជន ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

គៀន វឌ្ឍនា
នាយកគ្រប់គ្រងហានិភ័យ

សញ្ជាតិខ្មែរ

លោក គៀន វឌ្ឍនា គឺជានាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលមានតួនាទីត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យ និងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងផ្នែកអាជីវកម្មផ្សេងទៀត ព្រមទាំងក្រុមការងារហានិភ័យ របស់ ស៊ីអាយអិមប៊ី គ្រុប ដើម្បីបញ្ចូល និងបញ្ជ្រាបវប្បធម៌ គ្រប់គ្រងហានិភ័យ នៅក្នុងធនាគារ។

លោក គៀន វឌ្ឍនា គឺជាអ្នកចូលរួមដំបូងមួយរូប ក្នុងការបង្កើតក្រុមការងារគ្រប់គ្រងឥណទាន នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ដែលត្រួតពិនិត្យមើលឥណទាន គ្រប់ផ្នែកអាជីវកម្ម (សេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម)។ លោកមានចំណេះដឹង និងបទពិសោធន៍ច្រើន លើផ្នែកគ្រប់គ្រងឥណទាន។ លោកបានពង្រឹងជំនាញរបស់ខ្លួនបន្ថែម ជាមួយនឹងការយល់ដឹងអំពីអតិថិជន និងវិស័យធនាគារ តាមរយៈការធ្វើការជាមួយ ជាមួយក្រុមការងារគ្រប់គ្រងឥណទាន ក្នុងប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ដែលទទួលបន្ទុកត្រួតពិនិត្យសំណើសុំឥណទានទាំងអស់ ពីប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី។

លោក គៀន វឌ្ឍនា ត្រូវបានតែងតាំងជាប្រធានគណៈកម្មការឥណទាន ដោយផ្អែកលើបទពិសោធន៍ច្រើន ផ្នែកគ្រប់គ្រងឥណទាន ក្នុងរយៈ១២ឆ្នាំ ក្នុងវិស័យធនាគារ។ លោកផ្តល់នូវទិសដៅ និងការណែនាំ ដើម្បីរក្សា និងទាក់ទាញអតិថិជនល្អៗ ព្រមទាំងធានាឲ្យបាននូវគុណភាពឥណទាន ដែលធនាគារមាន។ ក្រៅពីនេះ លោកពិនិត្យមើលការគ្រប់គ្រងហានិភ័យប្រភេទផ្សេងទៀត ដែលរួមមានហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួលជាដើម។ លោកទទួលបានបរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងបរិញ្ញាបត្រផ្នែកគណិតវិទ្យា ហើយលោកក៏បានបញ្ចប់កម្មវិធីបណ្តុះបណ្តាលជំនាញវាយតម្លៃឥណទានរបស់ Omega ផងដែរ។

ឈុន ពុទ្ធកុម្ភៈវត្តី
នាយកប្រតិបត្តិតាម

ខៀវ ឡានីន
នាយកសវនកម្មផ្ទៃក្នុង

សញ្ជាតិខ្មែរ

លោកស្រី ឈុន ពុទ្ធកុម្ភៈវត្តី បានចូលបម្រើការងារនៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងមុខតំណែងជានាយកប្រតិបត្តិតាម នៅខែសីហា ឆ្នាំ២០១៧។ លោកស្រីទទួលបន្ទុកលើការងារគ្រប់គ្រងរួម លើមុខងារប្រតិបត្តិតាម និងរាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ ក្នុងមុខតំណែងជានាយកប្រតិបត្តិតាម លោកស្រីវត្តីត្រួតពិនិត្យ និងណែនាំការងារទាំងឡាយ ដែលទាក់ទងនឹងផ្នែកប្រតិបត្តិតាម នៅក្នុងធនាគារ និងជាអ្នកទំនាក់ទំនងចម្បងជាមួយធនាគារជាតិ នៃកម្ពុជា និងអជ្ញាធរដទៃទៀត។

លោកស្រី ឈុន ពុទ្ធកុម្ភៈវត្តី បានចាប់ផ្តើមអាជីពការងារជា សវនករ ក្នុងក្រុមហ៊ុនសវនកម្មអន្តរជាតិមួយ ហើយបន្ទាប់មកលោកស្រីបានចាប់យកតួនាទីការងារ ផ្នែកប្រតិបត្តិតាមក្នុងវិស័យហិរញ្ញវត្ថុ។ លោកស្រីវត្តី មានបទពិសោធន៍ការងារ៧ឆ្នាំ ក្នុងវិស័យធនាគារ ជាមួយនឹងជំនាញផ្នែកប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ មុនពេលចូលបម្រើការងារក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រីវត្តី ធ្លាប់បម្រើការងារជា នាយកគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងគ្រប់គ្រងផ្ទៃក្នុង នៅធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។

លោកស្រីវត្តី បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ បច្ចុប្បន្ន លោកស្រីកំពុងសិក្សាថ្នាក់គណនេយ្យករជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) ពីស្ថាប័នមួយនៅប្រទេសកម្ពុជា ដែលទទួលបានសិទ្ធិជាផ្លូវការ ពីចក្រភពអង់គ្លេស ក្នុងការបណ្តុះបណ្តាល ACCA។

សញ្ជាតិខ្មែរ

ក្នុងនាមជាអ្នកត្រួសត្រាយម្នាក់ ក្នុងគណៈកម្មាធិការគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅពេលបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០ លោក ខៀវ ឡានីន ទទួលខុសត្រូវលើការអភិវឌ្ឍ ពិនិត្យមើលផែនការសវនកម្ម យុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ ព្រមទាំងការគ្រប់គ្រងទូទៅក្នុងនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ធនាគារ។

លោក ឡានីន បានចូលបម្រើការងារ ក្នុងផ្នែកសវនកម្ម នៅតាមស្ថាប័នហិរញ្ញវត្ថុ អស់រយៈពេលជាង ១៦ឆ្នាំ ដែលលោកមានសមត្ថភាព ក្នុងការបំពេញតួនាទីបានយ៉ាងល្អ និងជាជំនួយទៅដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ក្នុងការបង្កើតការគ្រប់គ្រងចំណាយប្រកបដោយប្រសិទ្ធភាព ការវាយតម្លៃហានិភ័យ ការផ្តល់អនុសាសន៍ លើវិធានការកាត់បន្ថយហានិភ័យ និងការធានាដំណើរការអភិបាលកិច្ច ឲ្យបានល្អប្រសើរ។

លោក ខៀវ ឡានីន បានទទួលបរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យបៀលប្រាយ។

របាយការណ៍ហិរញ្ញវត្ថុ

៨២ របាយការណ៍ក្រុមប្រឹក្សាភិបាល
៨៣ របាយការណ៍សវនករឯករាជ្យ
៨៤ តារាងតុល្យការ
៨៥ របាយការណ៍លទ្ធផល
៨៦ របាយការណ៍បម្រែបម្រួលមូលធន
៨៧ របាយការណ៍លំហូរសាច់ប្រាក់
៨៨ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
១១៤ ឧបសម្ព័ន្ធ៖ កំណត់សម្គាល់ស្តីពីតម្រូវការតាមប្រកាសរបស់ធនាគារកណ្តាល

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា «ធនាគារ») សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

អំពីធនាគារ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ហើយធនាគារនេះគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ភាគហ៊ុនទាំងស្រុង ដោយ CIMB Bank Berhad ដែលជាធនាគារមានអាជ្ញាប័ណ្ណចុះបញ្ជីអាជីវកម្ម នៅប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន CIMB Group Holdings Berhad ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្មនៅប្រទេសម៉ាឡេស៊ី គឺជាក្រុមហ៊ុនមេធំបង្អស់។

សកម្មភាពអាជីវកម្មចម្បងៗ

សកម្មភាពអាជីវកម្មចម្បងៗរបស់ធនាគារ គឺការផ្ដល់សេវាកម្មផ្នែកធនាគារជាច្រើនប្រភេទ និងសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលប្រតិបត្តិការ និងភាគលាភ

លទ្ធផលហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី១០។

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មិនមានការប្រកាស ឬការបង់ភាគលាភទេ។

ដើមទុន

ក្នុងអំឡុងឆ្នាំ ធនាគារបានបង្កើនដើមទុនបន្ថែម ចាប់ពី ៦២.៥០០.០០០ ដុល្លារអាមេរិក ដល់ ៧៥.០០០.០០០ ដុល្លារអាមេរិក តាមការបន្ថែមសាច់ប្រាក់ពីក្រុមហ៊ុនមេចំនួន ៦.២០០.០០០ ដុល្លារអាមេរិក និងបង្វិលពីប្រាក់ចំណេញរក្សាទុកចំនួន ៦.៣០០.០០០ដុល្លារអាមេរិក។

ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រា សំវិធានធនយ៉ាងពេញលេញ សម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពី កាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនបុរេប្រទាន និងឥណទានអាក្រក់ ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនបុរេប្រទាន និងឥណទានអាក្រក់និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

ទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្ដាទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលបានមកវិញ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីរបស់ធនាគារ ត្រូវបានកាត់បន្ថយឲ្យស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្ដែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ និងកាលៈទេសៈណាមួយ ដែលបណ្ដាលឲ្យតម្លៃទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនត្រឹមត្រូវជាសារវន្តនោះឡើយ។

បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំ ដើម្បីការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមកក្រៅពីដំណើរការ អាជីវកម្មធនាគារធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃផុតកំណត់សងនោះទេ។

ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្ដាលឲ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានកំហុសឆ្គងជាសារវន្តនោះឡើយ។

ប្រតិបត្តិការដែលមានលក្ខណៈមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ ពុំមានរងនូវផលប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងខុសពីធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្នុងចន្លោះពេលរវាងដំណាច់ឆ្នាំហិរញ្ញវត្ថុមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងខុសប្រក្រតី ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងឆ្នាំ និងរហូតមកទល់នឹងកាលបិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

Dato' Wira Zainal Abidin Bin Mahamad Zain	ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលឯករាជ្យ មិនប្រតិបត្តិ)
បណ្ឌិត មី កល្យាណ	សមាជិក (អភិបាលឯករាជ្យ និងមិនប្រតិបត្តិ)
អ្នកស្រី Aisyah Lam Binti Abdullah	សមាជិក (អភិបាលឯករាជ្យ និងមិនប្រតិបត្តិ)
លោក ប៊ុន យីន	សមាជិក (អភិបាលមិនឯករាជ្យ និងប្រតិបត្តិ)
Dato' Shahrul Nazri Abdul Rahim	សមាជិក (អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ)
លោក Yong Jiunn Run	សមាជិក (អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ)
លោក Renzo Christopher Viegas	សមាជិក (អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ)

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឲ្យក្រុមប្រឹក្សាភិបាល ៖

១. ប្រើប្រាស់គោលការណ៍គណនេយ្យសមស្របដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះត្រូវអនុវត្តគោលការណ៍ទាំងនោះឲ្យបានស៊ីសង្វាក់គ្នា។

២. អនុវត្តតាមគោលការណ៍ណែនាំ ដែលចេញដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រកបដោយប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យក្នុងការសន្មតថា ធនាគារអាចនឹងបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមមានកំណត់សម្គាល់ ដែលភ្ជាប់មកជាមួយនឹងបានបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំង លទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ប៊ុន យីន

អភិបាលប្រតិបត្តិ / ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩

របាយការណ៍សវនករឯករាជ្យ

ជូនភាគទុនិកធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា «ធនាគារ») បង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា «ធនាគារកណ្តាល»)។

របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- តារាងតុល្យការ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្ម នៃកម្ពុជា (ហៅកាត់ថា «ស្តង់ដារសវនកម្ម»)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀត នៅក្នុងកថាខណ្ឌ «ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ» នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំបានទទួលមានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋាន សម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌ សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា «ក្រមសីលធម៌អន្តរជាតិ») និងអនុលោម ទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា «ក្រមសីលធម៌ វគសក»)។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវ ផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយ «ក្រមសីលធម៌អន្តរជាតិ» និង«ក្រមសីលធម៌ វគសក»។

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបាននាកាលបរិច្ឆេទរបាយការណ៍នេះរួមមាន របាយការណ៍របស់ប្រឹក្សាភិបាល និងឧបសម្ព័ន្ធដែលជាតម្រូវការរបស់ធនាគារកណ្តាល ប៉ុន្តែឧបសម្ព័ន្ធទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំ ផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្ត ដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត ដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

ការទទួលខុសត្រូវរបស់ថ្នាក់គ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

ថ្នាក់គ្រប់គ្រងទទួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ ចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលថ្នាក់គ្រប់គ្រងកំណត់ថាមានភាពចាំបាច់ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ថ្នាក់គ្រប់គ្រងទទួលខុសត្រូវ ក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗ ដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យ សម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែថ្នាក់គ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាង ដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្ម ដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្ម ដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្ត ដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្ម ដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាការងឿងឆ្ងល់ ប្រកបដោយវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យ ដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំ រួមមានការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការបដិសេធនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យ ដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលថ្នាក់គ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋាន លើភាពសមស្របនៃការប្រើប្រាស់ មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់ថ្នាក់គ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជា ដុំកំភួនទៅលើលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ក្នុងពេលអនាគត អាចបណ្តាលឲ្យធនាគារឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែងដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្ត ក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd.

គុយ លីម
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩

តារាងតុល្យការ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

		២០១៨		២០១៧	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៤	៧៨.៧១៨.២៣៦	៣១៦.២៨៩.៨៧២	១៧.៩០៤.៤០២	៧២.២៨០.០៧១
សមតុល្យនៅធនាគារកណ្តាល	៥	២១៩.៧៧១.៩១២	៨៨៣.០៤៣.៥៤២	១៩០.៧៧៧.១៨០	៧៧០.១៦៧.៤៧៦
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ	៦	៨.៤៤៩.៧១៥	៣៣.៩៥០.៩៥៥	៥៦.៣៧៧.៩៥៧	២២៧.៥៩៧.៨១២
ឥណទាន និងបុរេប្រទានអតិថិជន	៧	៥៣៤.៤៤៩.៥៧៦	២.១៤៧.៤១៨.៣៩៦	៣៩៨.៥៨៨.១៩៧	១.៦០៩.១០០.៥៥១
ទឹកប្រាក់ត្រូវទារពីក្រុមហ៊ុនមេផ្ទាល់	៨	៩១.២១៧	៣៦៦.៥១០	៥៧.៦៩៥	២៣២.៩១៥
ទ្រព្យសកម្មផ្សេងៗ	៩	៤.៤៥២.៩១៣	១៧.៨៩១.៨០៤	៣.៦២៧.២៣៧	១៤.៦៤៣.១៥៦
ទ្រព្យសម្បត្តិ និងបរិក្ខារ	១០	២.៧៨២.៩៥៧	១១.១៨១.៩២១	២.៩៦៨.៦៥១	១១.៩៨៤.៤៤៤
ទ្រព្យសកម្មអរូបី	១១	៦១៦.៩៧៦	២.៤៧៩.០១០	៤២០.៥៩១	១.៦៩៧.៩២៦
ពន្ធពន្យារទ្រព្យសកម្ម	១២	១.៨៨០.០០០	៧.៥៥៣.៨៤០	១.៣៥៤.៤៩៩	៥.៤៦៨.១១២
ទ្រព្យសកម្មសរុប		៨៥១.២១៣.៥០២	៣.៤២០.១៧៥.៨៥០	៦៧២.០៧៦.៤០៩	២.៧១៣.១៧២.៤៦៣
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ	១៣	២៨.៩១៣.៤៩៦	១១៦.១៧៤.៤២៧	១៨.៣៨៦.០៤៤	៧៤.២២៤.៤៦០
ប្រាក់បញ្ញើរបស់អតិថិជន	១៤	៦៨០.៨៦៥.៧៣៨	២.៧៣៥.៧១៨.៥៣៥	៥៤១.៧៤៨.៩៧៧	២.១៨៧.០៤០.៦២០
អនុបំណុល	១៥	៧.០០០.០០០	២៨.១២៦.០០០	៧.០០០.០០០	២៨.២៥៩.០០០
ប្រាក់កម្ចី	១៦	១០.១៥៩.២៨៣	៤០.៨១៩.៩៩៩	-	-
ទឹកប្រាក់ជំពាក់អ្នកផ្គត់ផ្គង់	១៧	៩២៧.៧១០	៣.៧២៧.៥៣៩	៨៥៦.១៨៧	៣.៤៥៦.៤២៧
បំណុលពន្ធលើប្រាក់ចំណូល		៣.១៩២.៧៦១	១២.៨២៨.៥១៤	១.៨២១.១៦៧	៧.៣៥២.០៥១
សំវិធានធនសម្រាប់កិច្ចសន្យាក្រៅ តារាងតុល្យការ		៨៨៩.៤៦៧	៣.៥៧៣.៨៧៨	-	-
បំណុលផ្សេងៗ	១៨	២៥.០៩១.៩៧៤	១០០.៨១៩.៥៥១	២៥.៥៥៦.១៣១	១០៣.១៧០.១០១
បំណុលសរុប		៧៥៧.០៤០.៤២៩	៣.០៤១.៧៨៨.៤៤៣	៥៩៥.៣៦៨.៥០៦	២.៤០៣.៥០២.៦៥៩
មូលធនភាគទុនិក					
ដើមទុន	១៩	៧៥.០០០.០០០	៣០១.៣៥០.០០០	៦២.៥០០.០០០	២៥២.៣១២.៥០០
ប្រាក់ចំណេញរក្សាទុក		១៩.១៧៣.០៧៣	៧៧.០៣៧.៤០៧	១៤.២០៧.៩០៣	៥៧.៣៥៧.៣០៤
មូលធនភាគទុនិកសរុប		៩៤.១៧៣.០៧៣	៣៧៨.៣៨៧.៤០៧	៧៦.៧០៧.៩០៣	៣០៩.៦៦៩.៨០៤
បំណុល និងមូលធនភាគទុនិក សរុប		៨៥១.២១៣.៥០២	៣.៤២០.១៧៥.៨៥០	៦៧២.០៧៦.៤០៩	២.៧១៣.១៧២.៤៦៣

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៨៨ ដល់ទំព័រទី ១១៣ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លទ្ធផល

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

		២០១៨		២០១៧	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ចំណូលការប្រាក់	២០	៣៦.២៨០.២៦៣	១៤៥.៧៧៤.០៩៧	២៧.៣៨៤.២២២	១១០.៥៥០.១០៤
ចំណាយការប្រាក់	២០	(១១.៨៨២.១០៥)	(៤៧.៧៤២.២៩៨)	(៩.៣៨៣.៤៥៣)	(៣៧.៨៨១.០០០)
ចំណូលការប្រាក់សុទ្ធ		២៤.៣៩៨.១៥៨	៩៨.០៣១.៧៩៩	១៨.០០០.៧៦៩	៧២.៦៦៩.១០៤
ចំណូលកម្រៃសេវា និងជើងសា	២១	៦.៣៧២.៨៧០	២៥.៦០៦.១៩២	៤.៥៤០.៩១១	១៨.៣៣១.៦៥៨
ចំណូល/(ចំណាយ) ប្រតិបត្តិការផ្សេងៗ		៩៩៧.៦៣៩	៤.០០៨.៥១៤	(២៥.៦៨២)	(១០៣.៦៧៨)
ចំណាយផ្នែកបុគ្គលិក	២២	(៧.៣៣៥.៥៩៧)	(២៩.៤៧៤.៤២៩)	(៥.៦២៧.០២៨)	(២២.៧១៦.៣១២)
ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី	២៣	(១.០៤៤.៧៥៥)	(៤.១៩៧.៨២៦)	(១.១៦៥.៣៩៨)	(៤.៧០៤.៧១២)
ចំណាយទូទៅ និងចំណាយរដ្ឋបាល	២៤	(៦.៤៩០.១៨៨)	(២៦.០៧៧.៥៧៥)	(៤.២៣៥.១១២)	(១៧.០៩៧.១៤៧)
ចំណេញមុនសំវិធានធន		១៦.៨៩៨.១២៧	៦៧.៨៩៦.៦៧៥	១១.៤៨៨.៤៦០	៤៦.៣៧៨.៩១៣
សំវិធានធនសម្រាប់ការថយចុះតម្លៃខាតឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន	២៥	(២.៤៧៦.៣១២)	(៩.៩៤៩.៨២២)	(១.៥៤៤.៩៩៨)	(៦.២៣៧.១៥៧)
ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល		១៤.៤២១.៨១៥	៥៧.៩៤៦.៨៥៣	៩.៩៤៣.៤៦២	៤០.១៤១.៧៥៦
ចំណាយពន្ធលើប្រាក់ចំណូល	២៦	(៣.១៥៦.៦៤៥)	(១២.៦៨៣.៤០០)	(២.១១៣.០៨២)	(៨.៥៣០.៥១២)
ចំណេញក្នុងឆ្នាំ		១១.២៦៥.១៧០	៤៥.២៦៣.៤៥៣	៧.៨៣០.៣៨០	៣១.៦១១.២៤៤
ចំណេញបែងចែកទៅ៖					
ម្ចាស់ភាគទុនិករបស់ធនាគារ		១១.២៦៥.១៧០	៤៥.២៦៣.៤៥៣	៧.៨៣០.៣៨០	៣១.៦១១.២៤៤

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៨៨ ដល់ទំព័រទី ១១៣ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

	បែងចែកទៅឲ្យភាគទុនិករបស់ក្រុមហ៊ុនមេ		
	ដើមទុន	រក្សាទុក	សរុប
	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ដុល្លារអាមេរិក
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧			
គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧	៥០.០០០.០០០	៦.៣៧៧.៥២៣	៥៦.៣៧៧.៥២៣
ដើមទុនបន្ថែម	១២.៥០០.០០០	-	១២.៥០០.០០០
ចំណេញក្នុងឆ្នាំ	-	៧.៨៣០.៣៨០	៧.៨៣០.៣៨០
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧	៦២.៥០០.០០០	១៤.២០៧.៩០៣	៧៦.៧០៧.៩០៣
សមមូលនឹងពាន់រៀល	២៥២.៣១២.៥០០	៥៧.៣៥៧.៣០៤	៣០៩.៦៦៩.៨០៤
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨			
គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨	៦២.៥០០.០០០	១៤.២០៧.៩០៣	៧៦.៧០៧.៩០៣
ដើមទុនបន្ថែម	៦.២០០.០០០	-	៦.២០០.០០០
បង្វិលប្រាក់ចំណេញរក្សាទុកទៅជាដើមទុន	៦.៣០០.០០០	(៦.៣០០.០០០)	-
ចំណេញក្នុងឆ្នាំ	-	១១.២៦៥.១៧០	១១.២៦៥.១៧០
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨	៧៥.០០០.០០០	១៩.១៧៣.០៧៣	៩៤.១៧៣.០៧៣
សមមូលនឹងពាន់រៀល	៣០១.៣៥០.០០០	៧៧.០៣៧.៤០៧	៣៧៨.៣៨៧.៤០៧

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៨៨ ដល់ទំព័រទី ១១៣ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

		២០១៨		២០១៧	
	កំណត់សម្គាល់	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីប្រតិបត្តិការ	២៧	(២៦.២៨៣.៤២៩)	(១០៥.៦០៦.៨១៧)	៥៦.៤៨៤.៨៣៤	២២៨.០២៩.២៧៤
ការប្រាក់បានទទួល		៣៥.៦៣៤.៩៩១	១៤៣.១៨១.៣៩៤	២៦.៥៧០.៨៦៩	១០៧.២៦៦.៥៩៨
ការប្រាក់បានបង់		(១១.១០៨.៨២៧)	(៤៤.៦៣៥.២៦៧)	(៨.៩៧៧.៣៧៥)	(៣៦.២៤១.៦៦៣)
ពន្ធលើប្រាក់ចំណូលបានបង់		(២.៣១០.៥៥២)	(៩.២៨៣.៧៩៨)	(២.៤៨១.៥៦៥)	(១០.០១៨.០៧៨)
សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីសកម្មភាព ប្រតិបត្តិការ		(៤.០៦៧.៨១៧)	(១៦.៣៤៤.៤៨៨)	៧១.៥៩៦.៧៦៣	២៨៩.០៣៦.១៣១
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ប្រាក់តម្កល់ធានាលើដើមទុនបន្ថែម		(១.២៥០.០០០)	(៥.០២២.៥០០)	(១.២៥០.០០០)	(៥.០៤៦.២៥០)
សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		៣៤.៨៣៨	១៣៩.៩៧៩	-	-
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ		(៨០៤.៩៧៤)	(៣.២៣៤.៣៨៦)	(១.៦៤០.៣៥០)	(៦.៦២២.០៩៣)
ការទិញទ្រព្យសកម្មអរូបី		(៤០២.៩៩២)	(១.៦១៧.៦១៥)	(៣០៨.៦៦៨)	(១.២៤៦.០៩៣)
សាច់ប្រាក់សុទ្ធបានប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		(២.៤២២.៧២៨)	(៩.៧៣៤.៥២២)	(៣.១៩៩.០១៨)	(១២.៩១៤.៤៣៦)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពីប្រាក់កម្ចី		១០.១៥៩.២៨៣	៤០.៨១៩.៩៩៩	-	-
ដើមទុនបង់បន្ថែម		៦.២០០.០០០	២៤.៩១១.៦០០	១២.៥០០.០០០	៥០.៤៦២.៥០២
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន		១៦.៣៥៩.២៨៣	៦៥.៧៣១.៥៩៩	១២.៥០០.០០០	៥០.៤៦២.៥០២
កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		៩.៨៦៨.៧៣៨	៣៩.៦៥២.៥៨៩	៨០.៨៩៧.៧៤៥	៣២៦.៥៨៤.១៩៧
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ		១៨៩.០៣៥.៩២៩	៧៦៣.១៣៨.០៤៥	១០៨.១៣៨.១៨៤	៤៣៦.៥៥៣.៨៤៨
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(៣.៥៩១.៦៨២)	-	-
សាច់ប្រាក់និងសាច់ប្រាក់សមមូលចុងឆ្នាំ	២៨	១៩៨.៩០៤.៦៦៧	៧៩៩.១៩៨.៩៥២	១៨៩.០៣៥.៩២៩	៧៦៣.១៣៨.០៤៥

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៨៨ ដល់ទំព័រទី ១១៣ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

១. ព័ត៌មានទូទៅ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ក្រោមអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្មលេខ ០០០១០៥២៤ ចេញដោយក្រសួងពាណិជ្ជកម្ម ហើយធនាគារបានចាប់ផ្តើមប្រតិបត្តិការនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។ ធនាគារត្រូវបានកាន់កាប់ទាំងស្រុងដោយ CIMB Bank Berhad ជាធនាគារដែលមានអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្ម នៅប្រទេសម៉ាឡេស៊ី។ ធនាគារ CIMB Group Holdings Berhad ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាធារណៈ នៅប្រទេសម៉ាឡេស៊ីជាក្រុមហ៊ុនមេធំបំផុត។

សកម្មភាពចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាកម្មផ្នែកធនាគារជាច្រើនប្រភេទ និងសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានទទួលអាជ្ញាប័ណ្ណផ្នែកធនាគារ ចេញដោយធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា «ធនាគារកណ្តាល») នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ២០AB កែងមហាវិថីព្រះនរោត្តម និងផ្លូវលេខ ១១៨ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតភាពគ្រប់ឆ្នាំទាំងអស់ ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ ចេញដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា «CAS»)។ក្នុងការអនុវត្តស្តង់ដារគណនេយ្យកម្ពុជា ធនាគារក៏បានប្រើប្រាស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ នៃកម្ពុជា (ហៅកាត់ថា «CFRS») គឺ CFRS7 ស្តីពី «ឧបករណ៍ហិរញ្ញវត្ថុ៖ ការលាតត្រដាងព័ត៌មាន»។

គោលការណ៍គណនេយ្យ ដែលបានប្រើប្រាស់អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅ នៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញ អំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាប អំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមទៅតាម CAS និងគោលការណ៍ណែនាំផ្សេងៗចេញដោយធនាគារជាតិ នៃកម្ពុជា តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាព គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងឆ្នាំ។ ទោះបីជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់ស្តែងចុងក្រោយអាចនឹងខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់បំផុត ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

២.២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា«CIFRS») ដែលផ្អែកទៅតាមស្តង់ដារទាំងអស់ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ («IASB») រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ ឆ្នាំគណនេយ្យ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬសម្រាប់ឆ្នាំគណនេយ្យបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ ០៥៨ សហវ-កជគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុម័តឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពន្យារពេលអនុវត្ត CIFRS រហូតដល់ឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬឆ្នាំបន្ទាប់ពីនេះ។

ស្តង់ដារគណនេយ្យ ដែលធនាគារប្រើប្រាស់នាពេលបច្ចុប្បន្នគឺ CAS មានភាពខុសប្លែកគ្នាជាច្រើនផ្នែក បើធៀបនឹង CIFRS។ ដូចនេះការអនុវត្ត CIFRS នឹងបណ្តាលឲ្យមានផលប៉ះពាល់ខ្លះៗ លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។ ធនាគារកំពុងត្រួតពិនិត្យ ពីផលប៉ះពាល់នៃការអនុវត្ត CIFRS។

២.៣ ការប្តូររូបិយប័ណ្ណ

ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់វែងដោយប្រើរូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា «រូបិយប័ណ្ណគោល»)។ ប្រាក់ដុល្លារអាមេរិកឆ្លុះបញ្ចាំងនូវធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈនានាដ៏មានសារសំខាន់របស់ធនាគារ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

ខ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាត ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

គ. បង្ហាញជាប្រាក់រៀល

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគផ្លូវការ ដែលចេញផ្សាយដោយធនាគារកណ្តាល គិតត្រឹមកាលបរិច្ឆេទរាយការណ៍ ដែល ១ដុល្លារអាមេរិកស្មើនឹង ៤.០១៨រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៣៧រៀល)។ តួលេខដែលបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបាន ប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងៗទៀតទេ។

២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសមតុល្យដែលមានកាលកំណត់ដើមបីខែ ឬតិចជាង គិតចាប់ពីថ្ងៃទទួលបានរាប់ទាំងសាច់ប្រាក់ក្នុងដៃ សមតុល្យមិនជាប់កម្រិត (non-restricted balance) នៅធនាគារកណ្តាល និងសមតុល្យ និងដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។

២.៥ ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជនទាំងអស់ត្រូវបានរាយការណ៍ ក្នុងតារាងតុល្យការតាមចំនួនទឹកប្រាក់ដើម ដែលមិន ទាន់ទូទាត់ ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនលើឥណទានបាត់បង់។

ឥណទាន និងបុរេប្រទាន ត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពជាក់លាក់ថានឹងអាចប្រមូលបានមកវិញ។ ឥណទាន និងបុរេប្រទានដែលប្រមូលបានមកវិញ បន្ទាប់ពីបានជម្រះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសំវិធានធនរួចហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

២.៦ សំវិធានធនឥណទានបាត់បង់

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទានបាត់បង់ និងសំវិធានធន ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្តាលលេខធ៧-០៩-០៧៤ប្រ.កចុះថ្ងៃទី២៥ខែកុម្ភៈឆ្នាំ២០០៩ ស្តីពី «ចំណាត់ថ្នាក់ទ្រព្យសកម្ម និងសំវិធានធន» សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ធនាគារកណ្តាលបានចេញប្រកាសលេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី «ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន» សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ឥណទាន និងបុរេប្រទានអតិថិជន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រា សំវិធានធនអប្បបរមាអាស្រ័យទៅតាម ចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្ម ដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមានព័ត៌មានផ្សេងទៀត ដែលចង្អុលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ។

សំវិធានធនឥណទាន និងបុរេប្រទាន ត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីឥណទាន និងបុរេប្រទានអតិថិជន។

សំវិធានធនប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារ ត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារ។

តារាងខាងក្រោមនេះបង្ហាញពីចំណាត់ថ្នាក់ឥណទាន និងសំវិធានធនអប្បបរមាតាមតម្រូវការ៖

ប្រកាសថ្មីលេខ ធ៧-០១៧-៣៤៤ ប្រ.ក និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ

ចំណាត់ថ្នាក់ហ្វាស៊ីលីធី	ចំនួនថ្ងៃផុតកំណត់	សំវិធានធន
រយៈពេលខ្លី		
សំវិធានធនទូទៅ៖		
ឥណទានធម្មតា	តិចជាង ១៥ ថ្ងៃ	១%
សំវិធានធនជាក់លាក់៖		
ឥណទានឃ្លាំមើល	១៥ ថ្ងៃ - ៣០ ថ្ងៃ	៣%
ឥណទានក្រោមស្តង់ដារ	៣១ ថ្ងៃ - ៦០ ថ្ងៃ	២០%
ឥណទានសង្ស័យ	៦១ ថ្ងៃ - ៩០ ថ្ងៃ	៥០%
ឥណទានបាត់បង់	៩១ ថ្ងៃ ឬលើស	១០០%
រយៈពេលវែង		
សំវិធានធនទូទៅ៖		
ឥណទានធម្មតា	តិចជាង ៣០ថ្ងៃ	១%
សំវិធានធនជាក់លាក់៖		
ឥណទានឃ្លាំមើល	៣០ ថ្ងៃ - ៨៩ ថ្ងៃ	៣%
ឥណទានក្រោមស្តង់ដារ	៩០ ថ្ងៃ - ១៧៩ ថ្ងៃ	២០%
ឥណទានសង្ស័យ	១៨០ ថ្ងៃ - ៣៥៩ ថ្ងៃ	៥០%
ឥណទានបាត់បង់	៣៦០ ថ្ងៃ ឬលើស	១០០%

ប្រកាសចាស់លេខ ធ៧-០៩-០៧៤ ប្រ.ក

ចំណាត់ថ្នាក់ហ្វាស៊ីលីធី	ចំនួនថ្ងៃផុតកំណត់	សំវិធានធន
រយៈពេលខ្លី		
សំវិធានធនទូទៅ៖		
ឥណទានធម្មតា	តិចជាង ៣០ថ្ងៃ	១%
សំវិធានធនជាក់លាក់៖		
ឥណទានឃ្លាំមើល	៣០ ថ្ងៃ - ៨៩ ថ្ងៃ	៣%
ឥណទានក្រោមស្តង់ដារ	៩០ ថ្ងៃ - ១៧៩ ថ្ងៃ	២០%
ឥណទានសង្ស័យ	១៨០ ថ្ងៃ - ៣៥៩ ថ្ងៃ	៥០%
ឥណទានបាត់បង់	៣៦០ ថ្ងៃ ឬលើស	១០០%

ការផ្លាស់ប្តូរសំវិធានធនក្នុងអំឡុងឆ្នាំ ដោយត្រូវបានអនុវត្ត ទៅតាមតម្រូវការនៃប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ដូច្នេះ ផលប៉ះពាល់ពីការផ្លាស់ប្តូរនេះ ត្រូវបានអនុវត្តទៅមុខ។

២.៧ កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការធម្មតានៃអាជីវកម្ម ធនាគារចុះកិច្ចសន្យា ដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗ រួមមានកិច្ចសន្យាឥណទាន លិខិតឥណទាន និងការធានាផ្សេងៗ។ គោលការណ៍គណនេយ្យ និងសំវិធានធនអប្បរមា បានអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាលលេខ ធ៧-០១៧-៣៤៤ ប្រ.ក និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ នៅក្នុងកំណត់សម្គាល់២.៦ ខាងលើ នៅពេលដែលកិច្ចសន្យាពាក់ព័ន្ធ និងឥណទានផ្សេងៗមានការថយចុះ។

សំវិធានធន សម្រាប់កិច្ចសន្យាក្រៅតារាងតុល្យការ បានបង្ហាញនៅក្នុងខ្ទង់គណនីបំណុលដាច់ដោយឡែកពីគ្នា។

២.៨ មូលនិធិសោធននិវត្តន៍

ធនាគារបានបង្កើតមូលនិធិសោធននិវត្តន៍ ដើម្បីជាប្រយោជន៍នៃបុគ្គលិកអចិន្ត្រៃយ៍ទាំងអស់។ ទាំងនិយោជិត និងនិយោជកបានរួមចំណែក ម្នាក់ ៥% នៃប្រាក់ខែរបស់និយោជិត។ សម្រាប់បុគ្គលិក ដែលបានធ្វើការរយៈពេលបីឆ្នាំ ឬតិចជាង នឹងទទួលបានត្រឹមតែវិភាគទានសរុបរបស់ពួកគេ នៅពេលលាលែងពីការងារ និងចូលនិវត្តន៍ប៉ុណ្ណោះ។ សម្រាប់បុគ្គលិក ដែលធ្វើការរយៈលើសពីបីឆ្នាំ នឹងត្រូវទទួលបានទាំងវិភាគទានរបស់ខ្លួន និងវិភាគទានរបស់ធនាគារ។ ធនាគារបានផ្តល់ការប្រាក់ សម្រាប់មូលនិធិទាំងវិភាគទានរបស់ធនាគារ និងបុគ្គលិក ហើយអត្រាការប្រាក់មានកាលកំណត់រយៈពេល១២ខែ។ ចំណាយវិភាគទាន (៥%ពីធនាគារ) ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានប្រចាំខែ។

២.៩ ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

វិសោធនកម្មលើច្បាប់ ស្តីពីការងារ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ និងប្រកាសរបស់ក្រសួងលេខ ៤៤៣ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ បានណែនាំឲ្យគ្រឹះស្ថានសហគ្រាសឯកជនទាំងអស់ ទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដោយត្រូវទូទាត់រៀងរាល់ប្រាំមួយខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ ចំពោះបុគ្គលិក ដែលមានកិច្ចសន្យាការងារអចិន្ត្រៃយ៍។ ប្រកាសនេះក៏បានណែនាំឲ្យទូទាត់ប្រាក់បំណាច់អតីតភាពការងាររំពុក សម្រាប់បុគ្គលិកដែលបានបម្រើការងារជូនក្រុមហ៊ុនមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅបន្តបម្រើការងារក្នុងក្រុមហ៊ុន។ ការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំពុក អាស្រ័យទៅតាមចំនួនឆ្នាំ ដែលបុគ្គលិកម្នាក់បានបម្រើការងារជូនក្រុមហ៊ុន ហើយមិនត្រូវលើសពី៦ខែ នៃប្រាក់បៀវត្សរ៍ជុលមធ្យមទេ។ ប្រាក់បំណាច់អតីតភាពការងាររំពុកនេះ ត្រូវបង់ឲ្យបុគ្គលិកចំនួន ៧,៥ ថ្ងៃ រៀងរាល់៦ខែម្តង ផ្គួបជាមួយនឹងប្រាក់បំណាច់អតីតភាពការងារថ្មី។

បំណុលប្រាក់បំណាច់អតីតភាពការងាររំពុក ត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រ projected unit credit ដើម្បីធ្វើការប៉ាន់ស្មានឲ្យបានកាន់តែល្អនូវតម្លៃចុងក្រោយ ដែលក្រុមហ៊ុនត្រូវបង់ឲ្យបុគ្គលិកជាថ្នូរនឹងការបម្រើការងារជូនក្រុមហ៊ុន ក្នុងពេលបច្ចុប្បន្ន និងក្នុងឆ្នាំកន្លងមក។ កាតព្វកិច្ចនេះកើតឡើង នៅ

ពេលដែលបុគ្គលិកបានបម្រើការងារជូនក្រុមហ៊ុន ហើយត្រូវបានរំពឹងថាក្រុមហ៊ុននឹងទូទាត់ប្រាក់បំណាច់នេះ ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។ តម្លៃបច្ចុប្បន្ននៃការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំពឹក ត្រូវបានកំណត់ដោយធ្វើអប្បហារចំណាយប៉ាន់ស្មាននាពេលអនាគត ដោយយោងទៅតាមអត្រាការប្រាក់លើទីផ្សារនាពេលបច្ចុប្បន្ន នៅក្នុងវិស័យនេះ។

២.១០ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ ដែលបណ្តាលមកពីការថយចុះតម្លៃ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់ផ្សេងៗ ក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មទាំងនោះ។

ចំណាយនាពេលបន្ទាប់មកទៀត ពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃចុះបញ្ជីនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដ ប្រជាថាផលប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងការថែទាំ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ទ្រព្យសកម្មកំពុងសាងសង់ មិនត្រូវបានធ្វើរំលស់ទេ។ ការធ្វើរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានរំលស់ថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនោះ តាមអត្រាប្រចាំឆ្នាំខាងក្រោម៖

	អត្រារំលស់
ការកែលម្អលើទ្រព្យជួល	២០% ឬតិចជាងតាមកាលកំណត់ជួល
បរិក្ខារការិយាល័យ	១០ - ២០%
បរិក្ខារកុំព្យូទ័រ	២០ - ៣៣%
យានយន្ត	២០%

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាមឲ្យស្មើនឹងចំនួន ដែលអាចប្រមូលមកវិញ។

ចំណេញ ឬខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រាជាបន្ទុក នៅក្នុងរបាយការណ៍លទ្ធផល។

២.១១ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើង ក្នុងការទិញកម្មវិធីនោះ និងយកវាមកប្រើប្រាស់។ ថ្លៃដើមនេះ ត្រូវបានធ្វើរំលស់ រយៈពេលបីឆ្នាំ ដោយប្រើវិធីសាស្រ្តរំលស់ថេរ លើកលែងតែអាជ្ញាប័ណ្ណប្រព័ន្ធធនាគារស្នូល ដែលមានអាយុកាលប្រើប្រាស់ រយៈពេល១០ឆ្នាំ។

ចំណាយលើការថែទាំកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយ នៅពេលដែលមានប្រតិបត្តិការនោះកើតឡើង។

២.១២ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណា ដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ ហើយវាត្រូវបាន ត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់តាត្រាមចំនួនលម្អៀងរវាងតម្លៃយោង ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់ទ្រព្យនោះ។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណា ដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលវាបានកើតឡើង។ ការកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រលប់មកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ទៅតាមចំនួនតម្លៃយោងរបស់ទ្រព្យសកម្ម ដែលមិនលើសពីតម្លៃយោងដែលត្រូវបានកំណត់រួច កាត់កងជាមួយនឹងរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

២.១៣ អនុបំណុល

អនុបំណុលត្រូវបានចាត់ទុកជាបំណុលហិរញ្ញវត្ថុ នៅពេលដែលធនាគារមានកាតព្វកិច្ចក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅអង្គភាពមួយផ្សេងទៀត ឬត្រូវផ្តោះប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាមួយអង្គភាពមួយផ្សេងទៀត ក្រោមលក្ខខណ្ឌដែលមិនសូវអំណោយផលចំពោះធនាគារ ហើយប្រសិនបើមិនដូច្នោះទេ វានឹងត្រូវបានកត់ត្រាជាមូលធន។ បំណុលបន្ទាប់បន្សំដែលត្រូវអនុម័តដោយធនាគារជាតិ នៃកម្ពុជា ត្រូវបានបញ្ចូលទៅក្នុងខ្ទង់ប្រភេទទីពីរ នៅក្នុងការគណនាមូលនិធិផ្ទាល់របស់ធនាគារ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា។

អនុបំណុលត្រូវបានរាយការណ៍តាមចំនួនប្រាក់ដើម ដែលនៅមិនទាន់ទូទាត់។

២.១៤ ចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានពីឥណទាន និងបុរេប្រទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ លើកលែងតែមានការសង្ស័យខ្លាំង ចំពោះការប្រមូលប្រាក់មកវិញ ដែលក្នុងករណីនេះការប្រាក់នឹងត្រូវបានព្យួរ រហូតដល់បានទទួលសាច់ប្រាក់ជាក់ស្តែង។ គោលការណ៍ក្នុងការព្យួរការប្រាក់ គឺអនុលោមស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ស្តីពីការព្យួរការប្រាក់លើឥណទានមិនដំណើរការ និងសំវិធានធនលើឥណទានបាត់បង់។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

២.១៥ ចំណូលកម្រៃ និងជើងសា

ចំណូលកម្រៃ និងជើងសា ត្រូវបានកត់ត្រាជាចំណូល នៅពេលដែលបានបំពេញសេវាកម្មជូនអតិថិជន។ ចំណូលកម្រៃ និងជើងសា រួមមានចំណូលបានមកពីសេវាកម្មផ្ទេរប្រាក់ចេញ-ចូល សេវា ATM និងសេវាផ្សេងៗទៀត។

កម្រៃលើការផ្តល់ឥណទាន ត្រូវបានគេកត់ត្រាជាចំណូល នៅពេលផ្តល់ឥណទានឲ្យអតិថិជន។

២.១៦ ភតិសន្យាប្រតិបត្តិ

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យ នៅមានចំណែកហានិភ័យ និងផលកម្មសិទ្ធជាសារវន្តត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃ ភតិសន្យានោះ។

២.១៧ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចដែលធនាគារបានបង្កើតឡើង នាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល និងនៅពេលដែលមានភាពប្រាកដថា នឹងមានតម្រូវការឲ្យមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានបានយ៉ាងគួរឲ្យជឿជាក់។

នៅពេលដែលមានកាតព្វកិច្ចប្រហាក់ប្រហែលគ្នាជាច្រើន កម្រិតនៃលំហូរចេញ ដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់កាតព្វកិច្ចទាំងមូល។

សំវិធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់កាតព្វកិច្ចដែលរំពឹងទុកដោយប្រើអត្រាអប្បហារមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃសមរម្យបច្ចុប្បន្ននៃតម្លៃពេលវេលាទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

២.១៨ ពន្ធលើប្រាក់ចំណូល

បន្ទុកពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធ ដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេស ដែលធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារត្រូវបានធ្វើសំវិធានធន ដោយប្រើវិធីសាស្រ្តបំណុល លើលម្អៀងបណ្តោះអាសន្ននៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់សម្រាប់គោលដៅពន្ធ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថាត្រូវអនុវត្តចំពោះលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាត្រូវបានកត់ត្រាត្រលប់មកវិញ អាស្រ័យទៅតាមច្បាប់សារពើពន្ធ ដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទរាយការណ៍។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានទូទាត់ ជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីទូទាត់បំណុលពន្ធក្នុងគ្រា ជាមួយនឹងពន្ធពន្យារទ្រព្យសកម្ម ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាក្រុមហ៊ុននឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីយកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយ ប្រសិនបើមិនមានភាពប្រាកដថានឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធត្រូវបានទទួលស្គាល់។

២.១៩ ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលចាត់ទុកថាជាភាគីពាក់ព័ន្ធ គឺជាភាគីដែលមានលទ្ធភាពគ្រប់គ្រង ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយទៀត ក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឲ្យនិយមន័យថា ជាភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងហោចណាស់ ១០% នៃដើមទុន ឬសិទ្ធិបោះឆ្នោតរួមទាំងបុគ្គលទាំងឡាយណា ដែលចូលរួមនៅក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល ដែលបានរាយការណ៍។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកលើបទពិសោធន៍នាពេលកន្លងមក និងកត្តាផ្សេងៗ ដូចជាការរំពឹងទុកអំពីហេតុការណ៍នាពេលអនាគត ដែលគេជឿថាមានភាពសមហេតុផល ទៅតាមកាលៈទេសៈផ្សេងៗ។

(ក) ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃហ្វាស៊ីលីធីហិរញ្ញវត្ថុ

